ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសុខាភិបាល

# សៀវភៅបណ្តុះបណ្តាលស្តីពីការផ្តល់ប្រឹក្សា
# និង ការធ្វើតេស្តឈាមរកមេរោគអេដស៍
# ដោយស្ម័គ្រចិត្ត និងរក្សាការសំងាត់

មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក នឹងកាមរោគ

កញ្ញា ២០០៤

បោះពុម្ពលើកទី១ ចំនួន ៥០០ ច្បាប់

ខែ ធ្នូ ២០០៤

# អារម្ភកថា

នៅខែធ្នូ ឆ្នាំ២០០២ មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជម្ងឺអេដស៍ សើស្បែក និង កាមរោគ（NCHADS）បានបញ្ចេញនូវឯកសារយុទ្ធសាស្ត្រផ្លូវការ ដែលគូសបញ្ជាក់ពីគោលនយោបាយយុទ្ធសាស្ត្រ និង គោលការណ៍ណែនាំរបស់ក្រសួងសុខាភិបាលសំរាប់ការផ្តល់ប្រឹក្សា និងធ្វើតេស្តឈាមរកមេរោគអេដស៍ដោយស្ម័គ្រចិត្ត និងរក្សាការសំងាត់នៅព្រះរាជាណា ចក្រកម្ពុជា។

ក្រសួងសុខាភិបាលនៃរាជរដ្ឋាភិបាលកម្ពុជា ចាត់ទុកការផ្តល់ប្រឹក្សា និងធ្វើតេស្តឈាមរកមេរោគអេដស៍ដោយស្ម័គ្រចិត្ត និងរក្សាការសំងាត់（VCCT）ថាជាអន្តរាគមន៍ដ៏សំខាន់ដើម្បីកាត់បន្ថយនូវការប្រព្រឹត្តប្រឈមមុខនឹងការឆ្លងមេរោគអេដស៍ ដូច្នេះហើយវាគឺជាផ្នែកមួយដ៏សំខាន់នៃយុទ្ធសាស្ត្របង្ការ និងថែទាំបន្តសំរាប់អ្នកផ្ទុកមេរោគអេដស៍។ មិនតែប៉ុណ្ណោះវាក៏ជាផ្នែកមួយដ៏សំខាន់នៅក្នុងសេវាព្យាបាលបន្ត ដែលកំពុងតែពង្រឹង នឹងពង្រីក។ ការផ្តល់ប្រឹក្សា និងធ្វើតេស្តឈាមរកមេរោគអេដស៍គឺជា ចំណុចចាប់ផ្តើម សំរាប់ ទៅកាន់សេវាផ្សេងៗទៀតដូចជា ការទទួលឱសថសំរាប់បង្ការនិង ព្យាបាលជំងឺឱកាសនិយមផ្សេងៗ ឱសថការពារជំងឺរបេង កម្មវិធីការពារការឆ្លងមេរោគអេដស៍ពីម្តាយទៅទារក（PMTCT）និងកម្មវិធីថែទាំអ្នកជំងឺអេដស៍តាមផ្ទះ និងការទទួលឱសថប្រឆាំងមេរោគអេដស៍（ឱសថពន្យាជីវិត）។

ដោយមានផែនការពង្រីក និងបង្កើនសេវាផ្តល់ប្រឹក្សា និងធ្វើតេស្តឈាមនៅក្នុងប្រទេសក្នុងឆ្នាំ ២០០៤ មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជម្ងឺអេដស៍ សើស្បែក និង កាមរោគ មានគោលបំណងពង្រឹងនូវគុណភាពនៃសេវា VCCT ដែលមានស្រាប់ ហើយរៀបចំមូលដ្ឋានគ្រឹះអោយកាន់តែរឹងមាំសំរាប់សេវាថ្មីៗដែលនឹងត្រូវបង្កើតឡើង។

សៀវភៅបណ្តុះបណ្តាលនេះបានចងក្រងឡើងដើម្បីប្រើប្រាស់ក្នុងការបណ្តុះបណ្តាលបុគ្គលិកដែលនឹងធ្វើការ ជាអ្នកផ្តល់ប្រឹក្សាតាមសេវា VCCT ។ សៀវភៅនេះក៏អាចប្រើប្រាស់សំរាប់វគ្គបំពាក់បំប៉នបន្ថែមចំពោះអ្នកផ្តល់ប្រឹក្សា ដែលធ្លាប់បានទទួលការបណ្តុះបណ្តាលរួចមកហើយដែរ ។

ខ្ញុំសូមថ្លែងអំណរគុណចំពោះក្រុមការងារបច្ចេកទេស VCCT ដែលបានធ្វើការជាប់ជាបន្តជាមួយនឹងមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជម្ងឺអេដស៍ សើស្បែក និង កាមរោគ ក្នុងការពង្រឹងសេវា VCCT នៅទូទាំងព្រះរាជាណាចក្រកម្ពុជា។

**ថ្ងៃទី ខែ ធ្នូ ឆ្នាំ ២០០៤**

**អគ្គនាយកបច្ចេកទេសសុខាភិបាល**

# សេចក្តីថ្លែងអំណរគុណ

ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់ក្រុមការងារបច្ចេកទេសសេវាផ្តល់ប្រឹក្សា និង ធ្វើតេស្តឈាមរកមេរោគអេដស៍ដោយស្ម័គ្រចិត្ត និងរក្សាការសំងាត់ និង ជាពិសេសដល់អង្គការសុខភាពគ្រួសារអន្តរជាតិ ដែលបានសហការណ៍យ៉ាងសកម្មក្នុងការរៀបចំបង្កើតសៀវភៅបណ្តុះបណ្តាលស្តី ពីការផ្តល់ប្រឹក្សា និង ធ្វើតេស្តឈាម និងដល់អង្គការក្រៅរដ្ឋាភិបាលដទៃទៀត ដូចជា អង្គការ CHEC, Policy Project, RHAC, WVI, US-CDC, URC, SCC ដែលបានផ្តល់នូវគំនិត និងអនុសាសន៏ដល់ការបង្កើតសៀវភៅបណ្តុះបណ្តាលនេះ និងជាពិសេសដល់:

| | |
|---|---|
| ១. លោកស្រី ប្រាធីន ធម្មរក្ស | អង្គការសុខភាពគ្រួសារអន្តរជាតិ |
| ២. លោក វេជ្ជបណ្ឌិត នង កាន្ទារ៉ា | ផ្នែកថែទាំជំងឺអេដស៍ |
| ៣. លោកវេជ្ជបណ្ឌិត ព្រហ្ម ផានិត | ផ្នែកថែទាំជំងឺអេដស៍ |
| ៤. លោកវេជ្ជបណ្ឌិត សុខ បញ្ញា | ផ្នែកថែទាំជំងឺអេដស៍ |
| ៥. លោក វេជ្ជបណ្ឌិត ជា ច័ន្ទកុសលមុនី | ផ្នែកថែទាំជំងឺអេដស៍ |

ដែលបានប្រឹងប្រែងអស់កំលាំងកាយចិត្ត និងពេលវេលាដ៏មានតំលៃក្នុងការរៀបចំតាក់តែងបង្កើតសៀវភៅបណ្តុះបណ្តាលការផ្តល់ប្រឹក្សា និងធ្វើតេស្តឈាមរកមេរោគអេដស៍ ដោយស្ម័គ្រចិត្ត និងរក្សាការសំងាត់ ។

ខ្ញុំសង្ឃឹមថាសៀវភៅបណ្តុះបណ្តាលនេះអាចជួយដល់ការបណ្តុះបណ្តាលអ្នកផ្តល់ប្រឹក្សាប្រកបដោយគុណភាពខ្ពស់ក្នុងការរួបចំណែកបង្ការការរីករាលដាលជំងឺអេដស៍ និងក្នុងការគាំទ្រដល់ការធ្វើតេស្តឈាមរកមេរោគអេដស៍ និងការថែទាំ និងព្យាបាលអ្នកផ្ទុកមេរោគអេដស៍ និងអ្នកជំងឺអេដស៍នៅក្នុងព្រះរាជាណាចក្រកម្ពុជាយើងនៅពេលបច្ចុប្បន្ន និងនៅពេលអនាគត ។

**ថ្ងៃទី ខែ ធ្នូ ឆ្នាំ ២០០៤**

**ប្រធានមជ្ឈមណ្ឌលជាតិប្រយុទ្ធនិង**

**ជំងឺអេដស៍ សើស្បែក និងកាមរោគ**

**វេជ្ជ. មាន ឈីវុន**

# មាតិកា

ទំព័រ

**សេចក្តីផ្តើម:** ១

១-សកម្មភាព ទី១: ការរីករាលដាលនៃការឆ្លងមេរោគអេដស៍/ជម្ងឺអេដស៍ នៅកម្ពុជា ៧

២-សកម្មភាព ទី២: ការផ្តល់ប្រឹក្សា និងធ្វើតេស្តឈាមរកមេរោគអេដស៍ ដោយស្ម័គ្រចិត្ត និងរក្សាការ
សំងាត់ជាផ្នែកមួយនៃយុទ្ធសាស្ត្របង្ការការឆ្លងមេរោគអេដស៍និងព្យាបាលជម្ងឺអេដស៍ ១៧

៣-សកម្មភាព ទី៣: ចំណេះដឹងស្តីពីមេរោគអេដស៍/ជម្ងឺអេដស៍
សំនួរពិភាក្សា ត្រូវ ឬ ខុស ស្តីពីមេរោគអេដស៍/ជម្ងឺអេដស៍ ២៩

៤-សកម្មភាព ទី៤: កំរិតប្រឈមមុខនឹងគ្រោះថ្នាក់ និង ការវាយតំលៃលើការប្រឈមមុខនឹងគ្រោះថ្នាក់
តើលក្ខណៈប្រឈមមុខនឹងគ្រោះថ្នាក់មានកំរិតណា? ៣៨

៥-សកម្មភាព ទី៥: ទស្សនៈ ការអោយតំលៃ និង ការដឹងខ្លួន
តើអ្នកគិតយ៉ាងណាចំពោះគាត់? ៤៨

៦-សកម្មភាព ទី៦: គោលការណ៍នៃការផ្តល់ប្រឹក្សា - ការរក្សាការសម្ងាត់ ៥៤
ស្រោមសំបុត្ររឿងសម្ងាត់

៧- សកម្មភាព ទី៧: គោលការណ៍នៃការផ្តល់ប្រឹក្សា - ការផ្តោតលើអតិថិជន
សូមអ្នក ជួយប្រាប់ខ្ញុំផង? ៥៩

៨- សកម្មភាព ទី៨: គោលការណ៍នៃការផ្តល់ប្រឹក្សាមិនបង្គាប់បញ្ជា :
ដើរដោយទុកចិត្ត ៦៦

៩-សកម្មភាព ទី៩: ជំនាញក្នុងការផ្តល់ប្រឹក្សា
វីដេអូស្តីពីការផ្តល់ប្រឹក្សា និង ផ្តល់យោបល់ត្រឡប់ ៧០

១០-សកម្មភាព ទី១០: គោលការណ៍ និង ជំនាញក្នុងការផ្ដល់ប្រឹក្សា
ប្រើប្រាស់គោលការណ៍ និង ជំនាញទាំងអស់រួមគ្នា
តើខ្ញុំគួរតែធ្វើតេស្តរកមេរោគអេដស៏ឫទេ?
តើខ្ញុំគួរធ្វើយ៉ាងណាចំពោះប្តីខ្ញុំ? ៩៨

១១-សកម្មភាព ទី១១: ការផ្ដល់ប្រឹក្សាដើម្បីបង្ការ ការវាយតំលៃការប្រឈមមុខនឹងគ្រោះថ្នាក់
និង ផែនការកាត់បន្ថយការប្រឈមមុខនឹង គ្រោះថ្នាក់ ១១០

១២-សកម្មភាព ទី១២: អារម្មណ៍របស់បុគ្គលដែលមកធ្វើតេស្តរកមេរោគអេដស៏
និងហេតុផលធ្វើតេស្តនិងមិនធ្វើតេស្ត ១២២

១៣-សកម្មភាព ទី១៣: គោលនយោបាយយុទ្ធសាស្ត្រ និងគោលការណ៍ណែនាំស្តីពីការផ្តល់
ប្រឹក្សា និងធ្វើតេស្តរកមេរោគអេដស៏ដោយស្ម័គ្រចិត្តនិងរក្សាការសំងាត់ ១២៧

១៤-សកម្មភាព ទី១៤ : ផលប៉ះពាល់នៃមេរោគអេដស៏ និងជម្ងឺអេដស៏លើបុគ្គល ១៣៣

ទី១៥-សកម្មភាព ទី១៥: ការផ្តល់ប្រឹក្សាមុនធ្វើតេស្ត ១៣៦

១៦-សកម្មភាព ទី១៦: ការផ្តល់ប្រឹក្សាក្រោយធ្វើតេស្ត ការផ្តល់លទ្ធផលតេស្តអវិជ្ជមាន(គ្មានផ្ទុក)
និងវិជ្ជមាន(មានផ្ទុក) ១៤៣

១៧-សកម្មភាព ទី១៧: ការថែទាំ ការគាំទ្រ និង ការបញ្ជូនបន្ត (ការថែទាំបន្ត)
ការរស់នៅដោយមានតំលៃ ១៥៥

១៨-សកម្មភាព ទី១៨: ការប្រាប់លទ្ធផលទៅអ្នកដទៃ និងការធ្វើការជាមួយប្តីប្រពន្ធដែលមាន
លទ្ធផលតេស្តឈាមខុសគ្នា ១៦០

១៩-សកម្មភាព ទី១៩: វគ្គបញ្ចប់ និងការវាយតំលៃលើវគ្គសិក្សា ១៦៤

# សេចក្តីផ្តើម

## សារតារ និង សេចក្តីផ្តើម

សៀវភៅបណ្តុះបណ្តាលនេះបានរៀបចំបង្កើតឡើងដោយផ្អែកលើឯកសារបណ្តុះបណ្តាលស្តីពីការផ្តល់ប្រឹក្សា និងធ្វើតេស្តឈាមរកមេរោគអេដស៍ដោយ ស្ម័គ្រចិត្ត និងរក្សាការសំងាត់របស់មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជម្ងឺអេដស៍ សើស្បែក និង កាមរោគ (NCHADS), ឯកសារគំរូ និង គោលការណ៍ណែនាំស្តីពីការផ្តល់ប្រឹក្សា និងធ្វើតេស្តឈាមរកមេរោគអេដស៍ដោយស្ម័គ្រចិត្ត និងរក្សាការសំងាត់ របស់អង្គការសុខភាពពិភពលោក (WHO) និង ទីភ្នាក់ងារសហប្រជាជាតិទទួលបន្ទុកជំងឺអេដស៍ (UNAIDS) ម៉្យដែលផ្តោតទៅលើអតិថិជន និង ការកាត់បន្ថយ គ្រោះថ្នាក់ របស់US-CDC, បច្ចេកទេស និងបទពិសោធន៍របស់អង្គការសុខភាពគ្រួសារអន្តរជាតិ (FHI) ជាមួយនិងរបៀប បណ្តុះបណ្តាល របស់ EC/AIHD AIDS Project and ACCESS នៅក្នុងប្រទេសថៃ ហើយនិងមេរៀននិងបទពិសោធន៍របស់អ្នក ផ្តល់ការប្រឹក្សា និងធ្វើតេស្តដោយស្ម័គ្រចិត្តនានានៅកម្ពុជា ដូចជាអង្គការទស្សនៈពិភពលោកកម្ពុជា (WV-Cambodia) អង្គការ រ៉ាក់ (RHAC) និងមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជម្ងឺអេដស៍ សើស្បែកនិងកាមរោគ។ ខ្លឹមសារ និងឧទាហរណ៍លើ ករណីសិក្សានានា ត្រូវបានរៀបរៀងឡើងអោយស្របនឹងបរិបទ និង ស្ថានភាពនៅព្រះរាជាណាចក្រកម្ពុជា។

កម្មវិធីបណ្តុះបណ្តាលនេះបានតាក់តែងឡើងសំរាប់បណ្តុះបណ្តាលជាដំបូងដល់អ្នកផ្តល់ប្រឹក្សានៅសេវាធ្វើតេស្តឈាមរកមេរោគអេដស៍ដោយស្ម័គ្រចិត្តនិងរក្សាការសំងាត់ ។ សេចក្តីព្រាងសៀវភៅនេះជាភាសាអង់គ្លេសបានធ្វើរួចក្នុងខែមិថុនា ឆ្នាំ២០០៣ ហើយបានចែក ជូនដល់ សមាជិកអនុគណកម្មការ VCCT ដើម្បីពិនិត្យនិងផ្តល់យោបល់ ។ ក្រុមរៀបរៀងកម្មវិធីបណ្តុះបណ្តាលយើងខ្ញុំសូមថ្លែងអំណរគុណចំពោះយោបល់ទាំងឡាយដែលបានទទួលពីអង្គការ CHEC, SSC, CARE, URC, POLICY Project លោក Jack Spencer US-CDC និងសហការីនានា លើសេចក្តីព្រាងសៀវភៅ បណ្តុះបណ្តាលនេះ ។ យើងខ្ញុំបានបញ្ចូលយោបល់ទាំងនោះទៅក្នុងសៀវភៅនេះ និងសៀវភៅ "គោលការណែនាំសំរាប់ អនុវត្តន៏ " តាមដែលអាចធ្វើបាន ។

សេចក្តីព្រាងឯកសារនេះបានបកប្រែជាភាសាខ្មែរក្នុងខែសីហា ឆ្នាំ២០០៣ ។ តាមសំណូមពរ របស់សមាជិកអនុកម្មការ VCCT យើងខ្ញុំបានសាកល្បងប្រើប្រាស់មេរៀនមួយចំនួនជាមួយក្រុមអ្នក ផ្តល់ប្រឹក្សា នៅខេត្តបាត់ដំបងចាប់ខែ តុលា ២០០៣ ដល់ខែមេសា ឆ្នាំ២០០៤ ។ លើសពីនេះទៅទៀតឯកសារនេះបានបញ្ចូលបញ្ហា និងចំណុចពាក់ព័ន្ធផ្សេងៗ ដែលក្រុមយើងខ្ញុំ បានលឺបានឃើញនៅពេលចុះតាមដានសេវា VCCT នៅតាមបណ្តាខេត្តនានា។ ការពិនិត្យ និង កែសំរួលមេរៀនទាំងអស់ជាចុងក្រោយបានបញ្ចប់នៅខែ កញ្ញា ឆ្នាំ២០០៤ បន្ទាប់ពីបានប្រើប្រាស់សាកល្បងនៅខែ កក្កដា និងខែកញ្ញា ឆ្នាំ ២០០៤ កន្លងមក។

យើងខ្ញុំទទួលស្គាល់ថានៅមានបញ្ហា/ចំណុចជាច្រើនដែលពាក់ព័ន្ធនឹងការកែលំអរគុណភាពនិង ការបង្កើននូវចំនួនសេវាផ្តល់ប្រឹក្សា និងធ្វើតេស្តឈាម រកមេរោគអេដស៍ដោយស្ម័គ្រចិត្ត និងរក្សាការសំងាត់ (VCCT) នៅកម្ពុជាក៏ដោយ ក៏សៀវភៅបណ្តុះបណ្តាលនេះ មានបំណងជួយ ជាផ្នែកមួយ នៃកិច្ចខិតខំប្រឹងប្រែងប្រកប ដោយកិច្ចសហការនិងការពុះពារគ្រប់បែបយ៉ាង ។

## គោលបំណងនៃការបណ្តុះបណ្តាល

គោលបំណងរបស់សៀវភៅបណ្តុះបណ្តាលនេះគឺដើម្បីផ្តល់ការបណ្តុះបណ្តាលដល់អ្នកផ្តល់ប្រឹក្សានៃសេវា VCCT នូវជំនាញសំខាន់ៗជាមូលដ្ឋាន ដែលចាំបាច់សំរាប់ប្រើប្រាស់ក្នុ ងសេវានេះ ។ មានមេរៀនជាច្រើនដែលអាចយកទៅបណ្តុះបណ្តាលដល់អ្នកផ្តល់ប្រឹក្សាអំពីជំងឺអេដស៍ដែលធ្វើការនៅសេវាសុខភាពផ្សេងៗទៀតនៅក្នុងសហគមន៍ ។

វាជាការចាំបាច់ណាស់ដែលអ្នកផ្តល់ប្រឹក្សាអំពីមេរោគអេដស៍ ជំងឺអេដស៍ត្រូវមានចំណេះដឹងច្បាស់លាស់ អំពីមេរោគអេដស៍និងជំងឺអេដស៍ និងជំនាញក្នុងការផ្តល់ប្រឹក្សាផងដែរ។ ដូច្នេះកម្មវិធីបណ្តុះបណ្តាលនេះបានបញ្ចូលបញ្ហានានាដែល ទាក់ទងនឹង HIV/AIDS ទៅក្នុងគ្រប់មេរៀន ។ ដូច្នេះការបណ្តុះបណ្តាលនេះផ្តល់នូវឳកាសជាច្រើនដល់សិក្ខាកាមអោយជជែកនិងពិភាក្សាអំពីជំនឿ និងការភ័ន្តច្រឡំដែលគេអាចមានពីមុនមក។ ក្នុងឋានៈជាអ្នកផ្តល់ប្រឹក្សា ការយល់ដឹងអំពីការអោយតំលៃនិង ទស្សនៈរបស់ខ្លួន ហើយ មិនតំរូវអោយគេធ្វើតាម ជារឿងសំខាន់ ។ សៀវភៅនេះសង្កត់ធ្ងន់ទៅលើការគោរពចំពោះអតិថិជនការរក្សាការសម្ងាត់ ការមិនវិនិច្ឆ័យ ហើយផ្តោតការយកចិត្តទុកដាក់លើអតិថិជនរួមទាំងការយល់ដឹងពីអារម្មណ៍ពាក់ព័ន្ធនានា នៅពេលត្រូវ ធ្វើតេស្តឈាមរកមេរោគអេដស៍ ហើយត្រូវប្រឈមមុខនឹងផលប៉ះពាល់នៃការរស់នៅដោយមានផ្ទុកមេរោគអេដស៍ /ជម្ងឺអេដស៍នោះ។

ដើម្បីអោយមានជំនាញក្នុងការផ្តល់ប្រឹក្សា មានការបង្ហាញ VIDEO ខ្លីៗស្តីអំពីការផ្តល់ប្រឹក្សាមុនពេលសិក្ខាកាមចូលរួម សកម្មភាពនានា និងល្បែងដើរតួ។ ការបណ្តុះបណ្តាលផ្តោតលើការស្តាប់ដោយយកចិត្តទុកដាក់ ការយល់ចិត្ត និងការផ្តល់ប្រឹក្សាបែបបង្ការ និងគាំទ្រ ។ គ្រប់ជំនាញចាំបាច់ ទស្សនៈសមរម្យ និង ចំណេះដឹងចាំបាច់ទាំងឡាយដែលបានដាក់បញ្ចូលក្នុង ការបណ្តុះបណ្តាលនេះ គឺដើម្បីរៀបចំខ្លួនសិក្ខាកាមអោយទទួលយកនូវចំណុចសំខាន់ៗ ដើម្បីផ្តល់ការផ្តល់ប្រឹក្សាមុន និង ក្រោយធ្វើតេស្តឈាមរកមេរោគអេដស៍ប្រកបដោយការយកចិត្តទុកដាក់និងប្រសិទ្ធិភាព។

នៅចុងបញ្ចប់នៃវគ្គបណ្តុះបណ្តាលរយៈពេលប្រាំថ្ងៃ សិក្ខាកាមម្នាក់ៗ ត្រូវមានឳកាសធ្វើការងារក្រោមការអភិបាលរបស់ អ្នកផ្តល់ប្រឹក្សា VCCT ដែលមានបទពិសោធន៍ច្រើន ក្នុងរយៈពេលយ៉ាងហោចណាស់ ៣-៥ ថ្ងៃ ដើម្បីអោយគេទទួលបាន បទពិសោធន៍ជាក់ស្តែងខ្លះៗ មុននឹងត្រឡប់ទៅសេវាផ្តល់ប្រឹក្សានិងធ្វើតេស្តឈាម ហើយបំពេញការងារនេះដោយខ្លួនគេផ្ទាល់។

ដោយហេតុថា ការរៀនសូត្រជាដំណើរការបន្តបន្ទាប់នោះ មិនគួរគិតថាវគ្គបណ្តុះបណ្តាលនេះជាចំណុចចុងបញ្ចប់ឡើយ ។ វគ្គបណ្តុះបណ្តាលនេះ ផ្តល់អោយនូវជំនាញជាមូលដ្ឋានស្តីពីការផ្តល់ប្រឹក្សាពីជំងឺអេដស៏ ។ អ្នកផ្តល់ប្រឹក្សាគួរមានឱកាស រៀន បន្ថែមទៀតតាមរយៈវិធីសាស្រ្តជាច្រើន ដូចជា វគ្គបណ្តុះបណ្តាលបំប៉ន ការពិភាក្សាពីករណីផ្សេងៗ និង ការចែករំលែកបទពិសោធន៏នៅក្នុងបណ្តាញអ្នកផ្តល់ប្រឹក្សា ។

## សកម្មភាពបណ្តុះបណ្តាល

គ្រូបង្ហាត់ ឬ អ្នកសំរបសំរួលវគ្គនេះ ត្រូវតែជាអ្នកផ្តល់ប្រឹក្សាអំពីមេរោគអេដស៏ និងជំងឺអេដស៏ប្រកបដោយបទពិសោធន៏ ។ ការធ្វើបែបនេះនឹងធានាបានថា គេមានលទ្ធភាពឆ្លើយនឹងសំណួរ ឬក៏សំរួលក្នុងស្ថានភាពលំបាកដែលអាចកើតមានឡើងអំឡុងពេលវគ្គបណ្តុះបណ្តាល ។
ចំនួនសិក្ខាកាមដែលចូលរួមក្នុងវគ្គសិក្សានិមួយៗមិនគួរលើសពី២០នាក់ឡើយ ។ យ៉ាងហោចណាស់គួរមានអ្នកសំរបសំរួល ពី២ ទៅ៣ នាក់សំរាប់វគ្គសិក្សារយៈពេល៥ថ្ងៃ ។

នៅពេលចាប់ផ្តើមវគ្គបណ្តុះបណ្តាល អ្នកសំរបសំរួលវគ្គគួរស្នើសុំអ្នកស្ម័គ្រចិត្តពីរនាក់សំរាប់រៀងរាល់ថ្ងៃបន្តបន្ទាប់ ។ ម្នាក់មានតួនាទីប្រមូលចំណាប់អារម្មណ៏ និងការសង្កេតទូទៅសំរាប់មួយថ្ងៃៗ ម្នាក់ទៀតរំលឹកមេរៀនឡើងវិញរាល់ៗព្រឹកថ្ងៃបន្ទាប់ ។ អ្នកផ្ទុកមេរោគអេដស៏ក៏អាចទទួលការបណ្តុះបណ្តាល និងក្លាយជាអ្នកផ្តល់ប្រឹក្សាដ៏ល្អបានដែរ ។ យើងគួរជ្រើសរើសនិងបណ្តុះបណ្តាលគាត់អោយក្លាយទៅជាអ្នកផ្តល់ប្រឹក្សាអំពីជំងឺអេដស៏ ។ នៅសកម្មភាពទី១៣ ស្តីអំពីផលប៉ះពាល់នៃមេរោគអេដស៏និងជំងឺអេដស៏លើបុគ្គល អ្នកសំរបសំរួលនឹងអញ្ជើញអ្នកផ្ទុកមេរោគអេដស៏ដែលហ៊ាននិយាយពីរឿងរ៉ាវរបស់គាត់មកចែក រំលែកបទពិសោធន៏ផ្ទាល់ជាមួយសិក្ខាកាមក្នុងវគ្គសិក្សា ។

# កម្មវិធីបណ្តុះបណ្តាលរយៈពេលបួនថ្ងៃ

## សកម្មភាពថ្ងៃទី ១៖

ពិធីបើកវគ្គបណ្តុះបណ្តាល

ការណែនាំពីគោលបំណងវគ្គសិក្សា និងការបង្ហាញខ្លួន

ការធ្វើតេស្តវាយតំលៃមុនវគ្គបណ្តុះបណ្តាល

បទបញ្ញត្តិជាក្រុម

**ពេលព្រឹក៖**

សកម្មភាព ទី១៖ ការរីករាលដាលនៃមេរោគអេដស៍/ជម្ងឺអេដស៍ នៅកម្ពុជា

សកម្មភាព ទី២៖ ការផ្តល់ប្រឹក្សា និងធ្វើតេស្តឈាមរកមេរោគអេដស៍ ដោយស្ម័គ្រចិត្តនិងរក្សាការសំងាត់ជាផ្នែកមួយនៃយុទ្ធសាស្ត្របង្ការមេរោគអេដស៍និងព្យាបាលជម្ងឺអេដស៍

**ពេលល្ងាច៖**

សកម្មភាព ទី៣៖ ចំណេះដឹងស្តីពីមេរោគអេដស៍/ជម្ងឺអេដស៍

ចំណោទសួរ ត្រូវ ឬ ខុស ស្តីពីមេរោគអេដស៍/ជម្ងឺអេដស៍

សកម្មភាព ទី៤៖ ករិតប្រឈមមុខនឹងគ្រោះថ្នាក់ និង ការវាយតំលៃលើការប្រឈមមុខនឹងគ្រោះថ្នាក់

តើលក្ខណៈប្រឈមមុខនឹង គ្រោះថ្នាក់មានករិតណា?

## សកម្មភាពថ្ងៃទី ២

**ពេលព្រឹក**

រំលឹកឡើងវិញនូវសកម្មភាពថ្ងៃទី១

សកម្មភាព ទី៥៖ ទស្សនៈ ការអោយតំលៃ និង ការដឹងខ្លួនឯង

តើអ្នកគិតយ៉ាងណាចំពោះគាត់?

សកម្មភាព ទី៦៖ គោលការណ៍នៃការផ្តល់ប្រឹក្សា - ការរក្សាការសម្ងាត់

ស្រោមសំបុត្ររឿងសម្ងាត់

សកម្មភាព ទី៧៖ គោលការណ៍នៃការផ្តល់ប្រឹក្សា - ការផ្តោតលើអតិថិជន

សូមអ្នកជួយប្រាប់ខ្ញុំផង?

**ពេលល្ងាច**

សកម្មភាព ទី៨:  គោលការណ៍នៃការផ្តល់ប្រឹក្សា  មិនបង្គាប់បញ្ជា :

ការដើរដោយទុកចិត្ត

សកម្មភាព ទី៩:  ជំនាញក្នុងការផ្តល់ប្រឹក្សា

វីដេអូស្តីពីការផ្តល់ប្រឹក្សា និង ផ្តល់យោបល់ត្រឡប់

**សកម្មភាពថ្ងៃទី ៣**

**ពេលព្រឹក**

រំលឹកឡើងវិញនូវសកម្មភាពថ្ងៃទី២

សកម្មភាព ទី១០:គោលការណ៍ និង ជំនាញក្នុងការផ្តល់ប្រឹក្សា

ប្រើប្រាស់គោលការណ៍ និង ជំនាញទាំងអស់រួមគ្នា

តើខ្ញុំគួរតែធ្វើតេស្តរកមេរោគអេដស៍ឬទេ?

តើខ្ញុំគួរធ្វើយ៉ាងណាចំពោះប្តីខ្ញុំ?

សកម្មភាព ទី១១: ការផ្តល់ប្រឹក្សាដើម្បីបង្ការ  ការវាយតំលៃការប្រឈមមុខនឹងគ្រោះថ្នាក់ និងផែនការកាត់បន្ថយ

ការប្រឈមមុខនឹង គ្រោះថ្នាក់

**ពេលល្ងាច**

សកម្មភាព ទី១២: អារម្មណ៍របស់បុគ្គលដែលមកធ្វើតេស្តឈាមរកមេរោគអេដស៍ និងហេតុផលធ្វើតេស្តនិងមិនធ្វើ

តេស្តឈាម

សកម្មភាព ទី១៣: គោលនយោបាយយុទ្ធសាស្ត្រ និងគោលការណ៍ណែនាំស្តីពីការផ្តល់ប្រឹក្សា និងធ្វើតេស្តឈាមរកមេ

រោគអេដស៍ដោយស្ម័គ្រចិត្តនិងរក្សាការសំងាត់

**សកម្មភាពថ្ងៃទី ៤**

**ពេលព្រឹក**

រំលឹកឡើងវិញនូវសកម្មភាពថ្ងៃទី៣

សកម្មភាព ទី១៤: ផលប៉ះពាល់នៃមេរោគអេដស៍ និងជម្ងឺអេដស៍លើបុគ្គល ការផ្តល់ប្រឹក្សាមុនធ្វើតេស្តឈាម

សកម្មភាពទី ១៥: ការផ្តល់ប្រឹក្សាមុនពេលធ្វើតេស្តឈាម

**ពេលល្ងាច**

សកម្មភាព ទី១៦: ការផ្តល់ប្រឹក្សាក្រោយពេលធ្វើតេស្តឈាម

ការផ្តល់លទ្ធផលតេស្តឈាម អវិជ្ជមាន ( គ្មានផ្ទុក)

**សកម្មភាពថ្ងៃទី ៥**

**ពេលព្រឹក**

រំលឹកឡើងវិញនូវសកម្មភាពថ្ងៃទី៤

សកម្មភាពទី ១៦: ការផ្តល់ប្រឹក្សាក្រោយពេលធ្វើតេស្តឈាម

ការផ្តល់លទ្ធផលតេស្តឈាមវិជ្ជមាន( មានផ្ទុក)

សកម្មភាពទី១៧: ការថែទាំ ការគាំទ្រ និង ការបញ្ជូនបន្ត ( ការថែទាំជាបន្ត)

ការរស់នៅដោយមានតំលៃ

សកម្មភាពទី១៨ : ការប្រាប់លទ្ធផលតេស្តឈាមទៅអ្នកដទៃ និងការធ្វើការជាមួយប្តីប្រពន្ធដែលមាន

លទ្ធផលតេស្តឈាមខុសគ្នា

**ពេលល្ងាច**

ការប្រើប្រាស់ទំរង់បែបបទចុះបញ្ជី និងគំរូរបាយការណ៍

ការធ្វើតេស្តឈាមវាយដំលៃក្រោយវគ្គបណ្តុះបណ្តាល និងការវាយតំលៃលើវគ្គបណ្តុះបណ្តាល

ពិធីបិទវគ្គ និងប្រគល់វិញ្ញាប័ណ្ណប័ត្រ

# សកម្មភាព ទី១

# ការរីករាលដាលនៃមេរោគអេដស៍/ជម្ងឺអេដស៍ នៅកម្ពុជា

# សកម្មភាព ទី១
# ការរីករាលដាលនៃមេរោគអេដស៍/ជម្ងឺអេដស៍ នៅកម្ពុជា

ជាការចាំបាច់ដែលសិក្ខាកាម មានការយល់ដឹងអំពីស្ថានភាពខ្លះៗទាក់ទងនឹងមេរោគអេដស៍/ជម្ងឺអេដស៍ នៅក្នុងប្រទេសកម្ពុជា ដើម្បីអោយគេយល់ដឹងពីទំនាក់ទំនងសេវា VCCT និងការបង្ការ ការព្យាបាល ជំងឺអេដស៍នៅកម្ពុជា។

## គោលបំណង:

ដើម្បីផ្តល់ដល់សិក្ខាកាមនូវការយល់ដឹង ស្តីពីស្ថានភាពមេរោគអេដស៍/ជម្ងឺអេដស៍ នៅកម្ពុជា។ អ្នកសំរបសំរួល ក៏អាចបង្ហាញ ឬ ពិភាក្សាផងដែរពីស្ថានភាពមេរោគអេដស៍/ជម្ងឺអេដស៍លើសកលលោក និងក្នុងតំបន់ មុននឹងនិយាយពីស្ថានភាពនៅកម្ពុជា។

## សំភារ:

**ផ្ទាំងបញ្ចាំង ១-១០**

ពតិមានលើ ផ្ទាំងបញ្ចាំងទាំងនេះគឺបានមកពី ការអង្កេតឈាមឆ្នាំ២០០២ និងការអង្កេតការប្រព្រឹត្តឆ្នាំ២០០១ របស់មជ្ឈមណ្ឌលជាតិប្រយុទ្ធ នឹងជំងឺអេដស៍ សើស្បែកនិងកាមរោគ។

ពេលណាបានទទួលពតិមានថ្មីៗ អ្នកសំរបសំរួលអាចប្រើប្រាស់លទ្ធផលនៃការអង្កេតឈាមរកអត្រាប្រេវ៉ាឡង់មេរោគអេដស៍ (HSS) និង ការអង្កេតការប្រព្រឹត្ត (BSS) ចុងក្រោយបង្អស់នៅកម្ពុជា នៅក្នុងមេរៀននេះ។

ស្លាយសំរាប់បញ្ចាំងគួរបង្ហាញនូវដំណើរការរាតត្បាតរបស់មេរោគអេដស៍ និងការថយចុះនូវអត្រាប្រេវ៉ាឡង់មេរោគអេដស៍ក្នុងចំណោមក្រុមប្រជាជនសំខាន់ៗក្នុងបណ្តាឆ្នាំកន្លងមកនេះ។ តាមរយៈពតិមាននៃការអង្កេត HSS និង ការតាមដានអង្កេត BSS គេគួរកត់សំគាល់ថា អត្រាប្រេវ៉ាឡង់នៃមេរោគអេដស៍ ក្នុងចំណោមស្ត្រីរកស៊ីផ្លូវភេទ នៅតែមានកំរិតខ្ពស់នៅឡើយ ហើយ បុរសជាច្រើន នៅតែទៅរកសេវាផ្លូវភេទ នៅឡើយដែរ។ នេះមានសារសំខាន់នៅក្នុងការក្នុងការផ្តល់ការប្រឹក្សាដើម្បីការពារ។

## ដំណើរការ:

ការបង្ហាញ និង ការពិភាក្សា

**Activity 1 Transparency 1**



**Activity 1 Transparency 2**



**Activity 1 Transparency 3**



**Activity 1 Transparency 4**



**Activity 1 Transparency 5**



## Activity 1 Transparency 6



**Activity 1 Transparency 7**



## Activity 1 Transparency 8

### Direct & Indirect FSWs Always Condom Use with Clients: 1997-01

### Sex with FSWs Past Year: All Male Groups: Cambodia 1997-01




* In 1999 always condom use specified "in last 3

# សកម្មភាព ទី២

# ការផ្តល់ប្រឹក្សា និងធ្វើតេស្តឈាម រកមេរោគអេដស៍ ដោយស្ម័គ្រចិត្ត និងរក្សា ការសំងាត់ ជាផ្នែកមួយនៃ យុទ្ធសាស្ត្រ បង្ការការចំលងមេរោគអេដស៍ និងព្យាបាល ជម្ងឺអេដស៍

# សកម្មភាព ទី២
# ការផ្តល់ប្រឹក្សា និងធ្វើតេស្តឈាមរកមេរោគអេដស៍ដោយស្ម័គ្រចិត្ត និងរក្សាការសំងាត់ (VCCT) ជាផ្នែកមួយនៃយុទ្ធសាស្រ្ត បង្ការមេរោគអេដស៍ និងព្យាបាលជម្ងឺអេដស៍

សេវាផ្តល់ប្រឹក្សា និងធ្វើតេស្តឈាមរកមេរោគអេដស៍ដោយស្ម័គ្រចិត្ត (VCCT) បានក្លាយទៅជាអន្តរាគមន៍មួយដែលសំខាន់ក្នុងកម្មវិធីបង្ការនិងព្យាបាលជម្ងឺអេដស៍នៅប្រទេសជឿនលឿន និងប្រទេសកំពុងអភិវឌ្ឍន៍នានា ។ សេវា VCCT បានវិវត្តន៍ទៅមុខដើម្បីឆ្លើយតបទៅនឹងសេចក្តីត្រូវការរបស់ប្រជាជន និងការផ្លាស់ប្តូរនូវសមត្ថភាពរបស់សេវាសុខាភិបាល ក្នុងការព្យាបាលនិងគាំទ្រអ្នកផ្ទុកមេរោគអេដស៍ ។

ការផ្តល់ប្រឹក្សា និងធ្វើតេស្តឈាមរកមេរោគអេដស៍ដោយស្ម័គ្រចិត្ត (VCCT) គឺមិនមែនគ្រាន់តែជាការបូមឈាម និងធ្វើតេស្តដើម្បីកំណត់ថាតើបុគ្គលម្នាក់មានផ្ទុកមេរោគអេដស៍ឬក៏អត់ប៉ុណ្ណោះទេ។ វាគឺជាចំណុចចាប់ផ្តើម ដំបូងដ៏សំខាន់ដើម្បីទៅកាន់សេវាផ្សេងៗទៀតរួមមានការផ្តល់ប្រឹក្សាដើម្បីបង្ការ និងព្យាបាលជំងឺឱកាសនិយមដែលកើតលើអ្នកផ្ទុកមេរោគអេដស៍ ការបង្ការ និង ការព្យាបាលជំងឺរបេង ការគាំទ្រផ្លូវចិត្ត និង ការបង្ការការចំលងមេរោគ អេដស៍ពីម្តាយទៅកូន។ ការផ្តល់ប្រឹក្សា និងធ្វើតេស្តឈាមរកមេរោគអេដស៍ដោយស្ម័គ្រចិត្ត ដែលមានគុណភាពខ្ពស់អាចសំរបសំរួល និងជំរុញទឹកចិត្តអ្នកមានផ្ទុក មេរោគអេដស៍អោយបានទទួលប្រើប្រាស់នូវការថែទាំដ៏សមស្របនានា។ ការផ្តល់ប្រឹក្សា និងធ្វើតេស្តឈាមរកមេរោគអេដស៍ដោយស្ម័គ្រចិត្តនិងរក្សាការសំងាត់ ក៏ជាអន្តរាគមន៍សំរាប់ផ្លាស់ប្តូរការប្រព្រឹត្តដ៏មានប្រសិទ្ធិភាព ហើយជាយុទ្ធសាស្រ្ត បង្ការដ៏មានប្រសិទ្ធិភាពផងដែរ។ សេវាផ្តល់ប្រឹក្សានិងធ្វើតេស្តឈាមរកមេរោគអេដស៍ដោយស្ម័គ្រចិត្ត មិនគួរជាសេវាដាច់ដោយឡែកនោះឡើយ ប៉ុន្តែវាគួរផ្សាភ្ជាប់រឺដាក់បញ្ចូលទៅក្នុងសេវា សុខាភិបាលផ្សេងៗ។

## តើការផ្តល់ប្រឹក្សាអំពីមេរោគអេដស៍ ខុសគ្នានឹងការផ្តល់ប្រឹក្សាផ្សេងទៀតដូចម្តេចខ្លះ?

ការផ្តល់ប្រឹក្សាពីមេរោគអេដស៍ ទាមទារនូវជំនាញផ្តល់ប្រឹក្សាជាមូលដ្ឋានមួយចំនួន ដូចការផ្តល់ប្រឹក្សាផ្សេងទៀតដែរ ប៉ុន្តែលក្ខណៈនៃមេរោគអេដស៍ និង ជម្ងឺអេដស៍ ធ្វើអោយការផ្តល់ប្រឹក្សាផ្នែកនេះ មានលក្ខណៈពិសេស។ ការផ្តល់ប្រឹក្សាទាក់ទងនឹងមេរោគអេដស៍/ជម្ងឺអេដស៍ រួមមាន ការផ្តល់ប្រឹក្សាដើម្បីបង្ការ និង ការផ្តល់ប្រឹក្សាសំរាប់ការថែទាំព្យាបាល និង ការគាំទ្រផ្លូវចិត្ត។ ទោះបីជាអ្នកផ្តល់ប្រឹក្សាប្រកបដោយបទពិសោធន៍ច្រើនក៏ដោយ ក៏នៅតែមានកង្វល់ពី លទ្ធភាពរបស់គេ ក្នុងការផ្តល់ប្រឹក្សាពីមេរោគអេដស៍ដែរ។ អ្នកផ្តល់ប្រឹក្សា VCCT តែងតែមានកង្វល់ ពីលទ្ធភាពរបស់គេក្នុងការផ្តល់លទ្ធផល តេស្តឈាមទៅអោយអតិថិជន ជាពិសេសការផ្តល់លទ្ធផលតេស្តឈាមវិជ្ជមាន ទៅអោយអតិថិជន ឬក៏អំពីលទ្ធភាពរបស់គេ ក្នុងការឆ្លើយ

តបទៅលើ ប្រតិកម្មរបស់អតិថិជនដែលមានលទ្ធផលតេស្តឈាមវិជ្ជមាននោះ។ ការផ្តល់ប្រឹក្សាអំពីមេរោគអេដស៍ /ជំងឺអេដស៍ ប្រកបដោយប្រសិទ្ធិភាព តំរូវអោយមានចំណេះដឹងអំពីមេរោគអេដស៍/ជំងឺអេដស៍ ហើយនិងជំនាញក្នុងការផ្តល់ប្រឹក្សា ។

**គោលបំណងៈ**

ដើម្បីអោយសិក្ខាកាមយល់ពីដំណើរការ គោលគំនិត តួនាទី និងចំណងទាក់ទងនៃសេវា VCCT ដែលជាផ្នែកមួយនៃសេវាបង្ការ មេរោគអេដស៍/ និង ព្យាបាលជម្ងឺអេដស៍ គឺដើម្បីកាត់បន្ថយនូវការ ប្រឈមមុខ នឹងការឆ្លងមេរោគអេដស៍ ហើយជួយអ្នកផ្ទុកមេរោគអេដស៍ អោយបានទទួលនូវពតិមានចាំបាច់នានាស្តីពីការថែទាំ និងការព្យាបាល និងបញ្ជូនទៅកាន់សេវាពាក់ព័ន្ធផ្សេងៗទៀត។

**សំភារៈ**

ផ្ទាំងបញ្ចាំងលេខ ១-៩

**ដំណើរការៈ**

មុននឹងបង្ហាញ និងពិភាក្សា អ្នកសំរបសំរួលគួរសួរសំណួរចំនួន ២-៣ ទៅសិក្ខាកាមស្តីពីគំនិតរបស់គេពី VCCT ដែលគេបានលឺ ឬដឹង ។

ឧទាហរណ៍ៈ

ហេតុអ្វីការធ្វើតេស្តឈាមរកមេរោគអេដស៍ចាំបាច់អោយមានការផ្តល់ប្រឹក្សា?

តើការផ្តល់ប្រឹក្សា និងធ្វើតេស្តឈាមរកមេរោគរកអេដស៍ដោយស្ម័គ្រចិត្តគឺជាអ្វី ?

តើសេវា VCCT មានគោលបំណងអ្វី?

ហេតុអ្វីបានជា VCCT មានសារៈសំខាន់?

ទុកពេលអោយសិក្ខាកាមឆ្លើយ និង ពិភាក្សាពីសំណួរ ទាក់ទងនឹងបរិបទនៅកម្ពុជា។

បន្ទាប់មក បន្តចូលទៅផ្នែកបង្ហាញ និង ពិភាក្សា ដោយប្រើផ្ទាំងបញ្ចាំងលេខ ១-៩។

ផ្ទាំងបញ្ចាំងលេខ ១ សំរាប់សកម្មភាព ទី២

## ហេតុដូចម្តេចបានជាការធ្វើតេស្តឈាមរកមេរោគអេដស៍ត្រូវការ ការផ្តល់ប្រឹក្សា?

- ពីព្រោះមេរោគអេដស៍អាចនាំអោយកើតជំងឺធ្ងន់ធ្ងរបាន ការភ័យខ្លាច - អតិថិជនត្រូវរៀបចំខ្លួន
- ការដឹងអំពីលទ្ធផលវិជ្ជមានអាចនាំអោយមានផលវិបាក- អតិថិជនត្រូវដឹងអំពីផលប៉ះពាល់និងការគាំទ្រនានា
- ការសំរេចចិត្តធ្វើតេស្តឈាមគឺធ្វើឡើងដោយស្ម័គ្រចិត្ត- ត្រូវបញ្ជាក់ ការយល់ដឹងនិងព្រមព្រៀង
- ការទទួលដឹងលទ្ធផលតេស្តឈាមវិជ្ជមានជាការលំបាកមួយ- អតិថិជនត្រូវការ ការគាំទ្រនិងពិតមាន

**អ្នកជំងឺអេដស៍ត្រូវការការព្យាបាលផ្លូវកាយ ការគាំទ្រផ្លូវចិត្ត និង ការគាំទ្រពីសង្គម**

# តើការផ្តល់ប្រឹក្សានិងធ្វើតេស្តឈាមរកមេរោគអេដស៍គឺជាអ្វី?

- ការផ្តល់ប្រឹក្សាអំពីអេដស៍គឺជា:
  - ការសន្ទនាដោយសម្ងាត់រវាងអតិថិជន និង អ្នកផ្តល់ប្រឹក្សា មានបំណងបង្កើនលទ្ធភាពរបស់អតិថិជនអោយ ទប់ទល់ជាមួយនឹងភាពតានតឹង ផ្នែកផ្លូវចិត្ត ហើយអាចសំរេចចិត្តដោយខ្លួនឯង ដើម្បីដោះស្រាយបញ្ហា ដែលទាក់ទងនឹងមេរោគអេដស៍/ជម្ងឺអេដស៍ ។
- ការផ្តល់ប្រឹក្សានិងធ្វើតេស្តឈាមរកមេរោគអេដស៍ដោយស្ម័គ្រចិត្ត និងរក្សាការសំងាត់
  - ការរួមបញ្ចូលសកម្មភាពទាំងពីរ-គឺការផ្តល់ប្រឹក្សានិង ធ្វើតេស្តឈាមនៅក្នុងសេវាតែមួយដែលបង្កើនផលប្រយោជន៏របស់សកម្មភាពទាំងពីរ

ផ្ទាំងបញ្ចាំងបង្ហាញលេខ ៣ សំរាប់សកម្មភាព ទី ២

## តើការផ្តល់ប្រឹក្សាស្តីពីអេដស៍ ខុសគ្នានឹង ការផ្តល់ប្រឹក្សាផ្សេងទៀត យ៉ាងណាខ្លះ?

- ការផ្តល់ប្រឹក្សាស្តីពីអេដស៍ តំរូវអោយមានការពិភាក្សាយ៉ាងជាក់លាក់ស្តីពីការប្រព្រឹត្តផ្លូវភេទ
- ការផ្តល់ប្រឹក្សាស្តីពីអេដស៍ តំរូវអោយមានការពិភាក្សាអំពី ការឈឺ និង ការស្លាប់
- អ្នកផ្តល់ប្រឹក្សា ត្រូវធ្វើការជាមួយអតិថិជនដែលមានជំនឿ និងការប្រព្រឹត្តខុសប្លែកពីខ្លួនឯង ។ គាត់អាចមានទស្សនៈយល់ឃើញ និងការអោយតំលៃដែលមានលក្ខណៈខុសគ្នាពីទស្សនៈយល់ឃើញការអោយតំលៃរបស់អ្នកផ្តល់ប្រឹក្សា ដូចនេះ អ្នកផ្តល់ប្រឹក្សាត្រូវ យល់អំពីទស្សនៈរបស់ខ្លួន ហើយទុកវាដោយឡែក និងមិនត្រូវអោយវាមកជ្រៀតជ្រែក ដែលនាំអោយការផ្តល់ ប្រឹក្សាពុំមានប្រសិទ្ធិភាព ។

- ការផ្តល់ប្រឹក្សាស្តីពីអេដស៍ តំរូវអោយអ្នកផ្តល់ប្រឹក្សា ពិចារណាទៅលើ ផលប៉ះពាល់ និង តម្រូវការរបស់បុគ្គល ដៃគូ និង សមាជិកគ្រួសាររបស់គាត់ ផងដែរ ។

ផ្ទាំងបញ្ចាំងបង្ហាញលេខ ៤ សំរាប់សកម្មភាពទី ២

## ហេតុអ្វីបានជា ការផ្តល់ប្រឹក្សា និងធ្វើតេស្តឈាមរកមេរោគអេដស៍ ដោយស្ម័គ្រចិត្តនិងរក្សាការសំងាត់ (VCCT) មានសារៈសំខាន់?

- នៅកម្ពុជាភាគច្រើននៃអ្នកផ្ទុកមេរោគអេដស៍ មិនទាន់ដឹងថាខ្លួនគេបានឆ្លងមេរោគអេដស៍នៅឡើយ ។
- ការដឹងពីស្ថានភាពឈាម (serostatus) របស់បុគ្គលម្នាក់ៗ អាចនាំអោយ គេផ្លាស់ប្តូរ ការប្រព្រឹត្តរបស់គេ - ដើម្បីការពារ និងថែទាំខ្លួនគេ ដៃគូនិងកូនរបស់គេ ។
- ការដឹងពីស្ថានភាពឈាម អាចជួយបុគ្គលម្នាក់ៗ ក្នុងការរៀបចំផែនការ ជីវិត និង ធ្វើការសំរេចចិត្តដ៏សំខាន់ផ្សេងៗ ។
- ផ្តល់ឱកាសសំរាប់ការផ្តល់ប្រឹក្សាដើម្បីបង្ការ និង ការបញ្ជូនបន្តទៅសេវាថែទាំ ព្យាបាល និង គាំទ្រនានា ។

**ផ្ទាំងបញ្ចាំងបង្ហាញលេខ ៥ សំរាប់សកម្មភាពទី ២**

## ការផ្តល់ប្រឹក្សា និងធ្វើតេស្តឈាមរកមេរោគអេដស៍ដោយស្ម័គ្រចិត្តនិងរក្សាការសំងាត់ គឺជាចំណុចចាប់ផ្តើម សំរាប់ការបង្ការ និងការថែទាំ




ប្រភព: UNAIDS "របាយការណ៍ស្តីពីការរាតត្បាតរបស់មេរោគអេដស៍/ជម្ងឺអេដស៍លើសកលលោក - ខែកក្កដា ២០០២" (www.unaids.org/barcelona/ ទទួលបាននៅថ្ងៃទី៨ កក្កដា ២០០២)

**តួនាទីចំបងៗ សំរាប់ VCCT:**

- ជួយអតិថិជន ក្នុងការទប់ទល់ និងធ្វើការសំរេចចិត្តរបស់ខ្លួន ដែលពាក់ព័ន្ធនឹងមេរោគអេដស៍/ជម្ងឺអេដស៍
- ជួយអតិថិជនដែលមករកសេវា VCCT អោយចាប់ផ្តើម និង បន្តការប្រព្រឹត្តដើម្បីការការពារខ្លួន
- ដើរតួជាចំណុចចាប់ផ្តើមទៅកាន់សេវាបង្ការ និង ការថែទាំ ព្យាបាល និងការគាំទ្រផ្សេងៗទៀត ។

ផ្ទាំងបញ្ចាំងលេខ ៦ សំរាប់សកម្មភាពទី ២

# ការអប់រំទូទៅស្តីពីមេរោគអេដស៍/ជម្ងឺអេដស៍ នៅតាមសហគមន៍

## ការយល់ដឹងពីគុណប្រយោជន៍របស់សេវាផ្តល់ប្រឹក្សា

## និងធ្វើតេស្តឈាមរកមេរោគអេដស៍ដោយស្ម័គ្រចិត្តនិងរក្សាការសំងាត់ VCCT

**ការសំរេចចិត្តមកកាន់សេវា VCCT**

↓

**ការផ្តល់ប្រឹក្សាមុនធ្វើតេស្តឈាមៈ**

ការរក្សាការសំងាត់ ហេតុផលដែលមករកសេវា ធ្វើតេស្តឈាម

ចំណេះដឹងស្តីពីមេរោគអេដស៍ ការចំលងមេរោគអេដស៍

ការវាយតំលៃលើការប្រឈមមុខគ្រោះថ្នាក់

អត្ថន័យនៃ HIV-, HIV+ និង រយៈពេលចំហរ

ផែនការនៅពេលដែលដឹងលទ្ធផលតេស្តឈាម

ការយល់ដឹងនិងព្រមព្រៀង

↓

**ការសំរេចចិត្តធ្វើតេស្តឈាម**

→ **មិនធ្វើ**

→ **ធ្វើ**

↓

**ការផ្តល់ប្រឹក្សាក្រោយធ្វើតេស្តឈាម**

**លទ្ធផលតេស្តអវិជ្ជមាន (HIV-):**

ប្រាប់លទ្ធផលតេស្តឈាម

រយៈពេលចំហរ

ណែនាំសំរាប់ធ្វើតេស្តឈាមជាថ្មី

ផែនការកាត់បន្ថយការប្រឈមមុខគ្រោះថ្នាក់ដើម្បី

អោយស្ថិតនៅមិនឆ្លងមេរោគ អវិជ្ជមាន

**លទ្ធផលតេស្តឈាមវិជ្ជមាន (HIV+):**

ផែនការនៅពេលដែលដឹងលទ្ធផលតេស្តឈាម

ការគាំទ្រផ្លូវចិត្ត

ពន្យល់អំពីដំណាក់កាលនៃជំងឺអេដស៍

ការរួមភេទមានសុវត្ថិភាព ការរក្សាសុខភាព

ការពិនិត្យសុខភាព

ការការពារនិងព្យាបាលជំងឺឱកាសនិយម

ការប្រើឱសថប្រឆាំងមេរោគអេដស៍ សេវាគាំទ្រផ្សេងៗ

↓

**ការផ្តល់ប្រឹក្សាបន្ត** និងការគាំទ្រផ្លូវចិត្ត ការរៀបចំផែនការនាពេលអនាគតនិងការថែទាំកុមារ និង អ្នករស់នៅក្នុងបន្ទុក

ផ្ទាំងបញ្ចាំងលេខ ៧ សំរាប់សកម្មភាព ទី២

# សមាសភាគនៃការផ្តល់ប្រឹក្សា និងធ្វើតេស្តឈាមរកមេរោគអេដស៍ ដោយស្ម័គ្រចិត្តនិងរក្សាការសំងាត់(VCCT)

- ធានារក្សាការសំងាត់ដល់អតិថិជន
- ការប៉ាន់ប្រមាណពីចំណេះដឹងអំពីអេដស៍របស់អតិថិជន
- ការផ្តល់ពតិមានពិតត្រឹមត្រូវ
- ធ្វើការវាយតំលៃលើការប្រឈមនឹងការឆ្លងរបស់អតិថិជន
- ការរៀបចំផែនការកាត់បន្ថយឱកាសនៃការឆ្លងរបស់អតិថិជន
- ការបង្ហាញពីការប្រើស្រោមអនាម័យអោយបានត្រឹមត្រូវ និងផ្តល់ឱកាស អោយអតិថិជនបង្ហាញ
- ពន្យល់ពីការធ្វើតេស្តឈាម និងការសំរេចចិត្តដោយខ្លួនឯង
- ពិភាក្សាពី អត្ថន័យនៃលទ្ធផលបេស់តេស្តឈាមរកមេរោគអេដស៍
- ប៉ាន់ប្រមាណពីលទ្ធភាពទប់ទល់នឹងលទ្ធផលរបស់អតិថិជន
- ការប្រាប់ពីលទ្ធផលតេស្តឈាម
- ការផ្តល់ការគាំទ្រផ្លូវចិត្ត និងអារម្មណ៏ និង ការបញ្ជូនបន្តអោយបានសមស្រប

ផ្ទាំងបញ្ចាំង ៨ សំរាប់សកម្មភាពទី ២

# VCCT ជួយជំរុញការផ្លាស់ប្តូរការប្រព្រឹត្ត

## ការស្រាវជ្រាវនៅប្រទេស Uganda

ក្នុងអតិថិជនចំនួន ២៩០៥ នាក់ ដែលចូលរួមក្នុងការស្រាវជ្រាវ ក្រោយពីការធ្វើតេស្តឈាមរយៈពេលប្រាំមួយខែមក

- ការប្រើស្រោមអនាម័យ
    - មុនការធ្វើតេស្តឈាម ១០% បានប្រើប្រាស់ស្រោមអនាម័យទៀងទាត់
    - ៦ ខែបន្ទាប់ពីធ្វើតេស្តឈាម  ការប្រើប្រាសស្រោមអនាម័យទៀងទាត់ មាន ៨៩% ជាមួយនឹង ដៃគូរួមភេទជាប់លាប់ ហើយ១០០% ជាមួយដៃគូរួមភេទមិនជាប់លាប់
    - បុរសគ្មានផ្ទុកមេរោគអេដស៍ ជាមួយនឹងដៃគូរួមភេទមិនជាប់លាប់ បានបង្កើនការប្រើស្រោម អនាម័យទៀងទាត់ ពី៣៤% ទៅ៩៣% ហើយនិងជាមួយដៃគូរួមភេទជាប់លាប់ ពី១៦% ទៅ៣៨%
    - ស្ត្រីមានផ្ទុកមេរោគអេដស៍ បានបង្កើនការប្រើប្រាស់ស្រោមអនាម័យជាមួយដៃគូរួមភេទមិនជាប់លាប់ ពី ១៤% ទៅ ៩៤%  ហើយនិងជាមួយដៃគូរួមភេទជាប់លាប់ ពី ១៥% ទៅ ៣៤% ។

## ការស្រាវជ្រាវក្នុងប្រទេសចំនួនបី (Kenya, Tanzania និង Trinidad)

ការប្រៀបធៀបប្រសិទ្ធិភាពនៃ VCCT ជាមួយនឹងប្រសិទ្ធិភាពនៃការផ្តល់ពតិមាន និងការអប់រំសុខភាព ទៅលើការកាត់បន្ថយការប្រឈមមុខគ្រោះថ្នាក់ - គឺការរួមភេទជាមួយដៃគូមិនជាប់លាប់ ដោយគ្មានការការពារ

- បុរស: មានការថយចុះនូវការប្រឈមគ្រោះថ្នាក់ ៣៥% ក្រោយ ការផ្តល់ប្រឹក្សា និងធ្វើតេស្តឈាម ធៀបនឹងការថយចុះនូវការប្រឈម គ្រោះថ្នាក់ តែ ១៣% ក្នុង ការផ្តល់ពតិមាន និង ការអប់រំសុខភាព
- ស្ត្រី: មានការថយចុះនូវការប្រឈមគ្រោះថ្នាក់ ៣៩% ក្រោយការផ្តល់ប្រឹក្សា និងធ្វើតេស្តឈាម  ធៀបនឹងការថយចុះនូវការប្រឈម គ្រោះថ្នាក់ តែ ១៧%ក្នុង ការផ្តល់ពតិមាន និង ការអប់រំសុខភាព ។

**ផ្ទាំងបញ្ចាំង លេខ៩ សំរាប់សកម្មភាព ទី២**

# ការផ្តល់ប្រឹក្សា និងធ្វើតេស្តឈាម
# រកមេរោគអេដស៍ ដោយស្ម័គ្រចិត្តនិងរក្សាការសំងាត់
# （VCCT）គឺជាចំណុចចាប់ផ្តើម
# និងមិនមែនបញ្ចប់ត្រឹមនេះឡើយ

# សកម្មភាព ទី៣

# ចំណោទសួរដើម្បីពិភាក្សានិងពិនិត្យឡើងវិញពី

# ចំណេះដឹងស្តីពីមេរោគអេដស៍ និងជម្ងឺអេដស៍

# សកម្មភាព ទី៣
## ចំណោទសួរដើម្បីពិភាក្សាពិនិត្យឡើងវិញ ពីចំណេះដឹងស្តីពីមេរោគអេដស៍និងជម្ងឺអេដស៍

ចាប់តាំងពីមានការរាតត្បាតនៃមេរោគអេដស៍/ជម្ងឺអេដស៍មក មានពាក្យចចាមអារ៉ាម និងការយល់ច្រឡំជាច្រើន។ ការមានចំណេះដឹងពិតត្រឹមត្រូវ ស្តីពីមេរោគអេដស៍/ជម្ងឺអេដស៍ រួមទាំងពតិមានថ្មីៗស្តីពីការ ព្យាបាល និង ការថែទាំមានសារៈសំខាន់ខ្លាំង ណាស់ សំរាប់ការផ្តល់ប្រឹក្សាពីមេរោគអេដស៍/ ជម្ងឺអេដស៍។ ក្នុងកំឡុងពេលពីរ-បីឆ្នាំកន្លងមកនេះ នៅប្រទេសកម្ពុជាមានការ បោះពុម្ភសៀវភៅ និងឯកសារជាច្រើន។ អ្នកសំរបសំរួលគួរមានឯកសារទាំងនោះសំរាប់ផ្តល់អោយសិក្ខាកាម ។

**គោលបំណង:**

ដើម្បីពិភាក្សានិងពិនិត្យឡើងវិញពីចំណេះដឹងស្តីពីមេរោគអេដស៍/ជម្ងឺអេដស៍ដែលសិក្ខាកាមត្រូវដឹង ដើម្បីមានលទ្ធភាពផ្តល់ការប្រឹក្សាប្រកបដោយគុណភាព។

**វិធីសាស្ត្រ:**

ការសួរ និងការឆ្លើយសំណួរដើម្បីអោយសិក្ខាកាមទាំងអស់ មានឱកាសបានពិនិត្យមើលឡើងវិញពីចំណេះដឹងរបស់គេស្តីពីមេរោគអេដស៍/ជម្ងឺអេដស៍ ក៏ដូចជាការ រៀនសូត្រនិងទទួលពតិមានថ្មីៗ ផងដែរ។

**សំភារ:**

១- ក្រដាសសំណួរ និង ក្រដាសចំលើយសំរាប់គ្រប់សិក្ខាកាមទាំងអស់
២- សន្លឹកក្រដាសសំណួរបត់ ពី ១ ដល់ ១៦ ហើយនិង ក្រដាសសមួយចំនួន ប្រសិនបើមានសិក្ខាកាម លើសពី១៦ នាក់។

**ដំណើរការ:**

១- ចែកក្រដាសសំណួរអោយសិក្ខាមទាំងអស់

២- ផ្តល់ពេលវេលាអោយសិក្ខាកាម ចំនួន ១០នាទី ដើម្បីឆ្លើយបំពេញសំណួរ
៣- អោយសិក្ខាកាម ចាប់យកសន្លឹកក្រដាសសំណួរម្តងមួយៗ។ ប្រសិនបើមានសិក្ខាកាមលើសពី ១៦នាក់ អ្នកខ្លះនឹងទទួលបានក្រដាស គ្មានសំណួរ។

៤- ចាប់ផ្តើមពីសំណួរទី ១ រហូតដល់សំណួរទី ១៦។ អោយសិក្ខាកាមម្នាក់ៗឆ្លើយនឹងសំណួរដែលគេចាប់បាន ហើយផ្តល់នូវការពន្យល់បានច្បាស់ពីចំលើយរបស់គេ។ អ្នកសំរបសំរួលលើកទឹកចិត្តអោយមានការពិភាក្សាច្រើន រួចផ្តល់ចំលើយត្រឹមត្រូវ។ ក្នុងករណីដែលចំលើយរបស់សិក្ខាកាម មិនត្រឹមត្រូវសូមផ្តល់ពតិមានបន្ថែមតាមតម្រូវការ។ ផ្តល់ឱកាសសំរាប់ការសួរសំណួរ និង ការសួរបញ្ជាក់នានា។

៥- ផ្តល់ក្រដាសចំលើយ ដល់សិក្ខាកាមទាំងអស់

៦- គូសបញ្ជាក់ថា ពតិមានពិតត្រឹមត្រូវស្តីពីមេរោគអេដស៍/ជម្ងឺអេដស៍ពិតជាមានសារៈសំខាន់ណាស់ សំរាប់ការងាររបស់អ្នកផ្តល់ប្រឹក្សា។ អ្នកធ្វើការងារនេះ ត្រូវស្វែងរកពតិមានបន្ថែមជាប់ជាប្រចាំ។ នៅពេលមិនច្បាស់ គេមិនគួរផ្តល់ពតិមាន ដែលស្រពេចស្រពិលឡើយ។ អ្នកផ្តល់ប្រឹក្សាត្រូវបែងចែកការពិតអោយដាច់ពី ទស្សនៈ របស់គាត់ចំពោះរឿងរ៉ាវ រឺបញ្ហាអ្វីមួយ។

(<u>សំគាល់</u>: សំណួរ និងចំលើយទាំង១៦នេះជាបញ្ជីដ៏ខ្លីមួយ។ នៅពេលដែលចំណេះដឹងរបស់សហគមន៍ និង អ្នកធ្វើការផ្តល់ប្រឹក្សាកើនឡើងនោះ បញ្ជីអាចវែងជាងនេះ ហើយត្រូវរៀបចំអោយបានសមស្របទៅនឹងបរិបទ និងស្ថានភាពជាក់ស្តែង)។

**សកម្មភាព ទី៣ ឯកសារចែកលេខ ១**

## ចំណោទសួរដើម្បីពិភាក្សានិងពិនិត្យឡើងវិញ ពីចំណេះដឹងស្តីពីមេរោគអេដស៍ និងជម្ងឺអេដស៍

### ត្រូវ រឺ ខុស

សូមគូសសញ្ញា √ សំរាប់ *ត្រូវ* ឬ គូសសញ្ញា X សំរាប់ *ខុស* នៅពីមុខសំណួរនិមួយៗ។

១- ស្រ្តីមានផ្ទៃពោះមានផ្ទុកមេរោគអេដស៍ មានឱកាសច្រើនជាង៥០% ក្នុងការចំលងមេរោគអេដស៍ ទៅកូនរបស់នាង។

២- ការធ្វើតេស្តឈាមរកអង្គបដិបក្ខមេរោគអេដស៍ គួរតែត្រូវបានធ្វើឡើងរយៈពេលបីខែ បន្ទាប់ពីការ ប្រព្រឹត្តប្រឈមមុខគ្រោះថ្នាក់ចុងក្រោយបង្អស់ ដើម្បីទទួលបាននូវលទ្ធផលតេស្តឈាម ពិតត្រឹមត្រូវ។

៣- អ្នកណាក៏ដោយ ដែលមានផ្ទុកមេរោគអេដស៍ គួរតែទទួលបាននូវឱសថប្រឆាំងមេរោគអេដស៍ (ARV) អោយ បានឆាប់បំផុត។

៤- បុគ្គលមានផ្ទុកមេរោគអេដស៍ ដែលប្រពន្ធ័ការពារខ្លួនចុះខ្សោយហើយនោះ គួរតែប្រើឱសថតាមបញ្ជាគ្រូពេទ្យ សំរាប់រយៈពេលណាមួយនោះដើម្បីបង្ការរោគឱកាសនិយមមួយចំនួន។

៥- ជំងឺឱកាសនិយមជាច្រើន អាចកើតឡើងក្នុងចំណោមអ្នកមានផ្ទុកមេរោគអេដស៍/ជម្ងឺអេដស៍ ដូចជាជម្ងឺរបេង ជម្ងឺរលាកសួត ជម្ងឺរលាកស្រោមខួរ និង ជំងឺផ្សិតក្នុងមាត់ អាចព្យាបាលអោយជាបាន។

៦- នៅក្នុងប្រទេសខ្លះ គេអាចព្យាបាលអ្នកជម្ងឺអេដស៍ អោយអោយជាសះស្បើយបាន

៧- សារធាតុសរីរាង្គរាវចេញពីខ្លួនអ្នកផ្ទុកមេរោគអេដស៍/ជម្ងឺអេដស៍ មានផ្ទុកមេរោគអេដស៍ ប៉ុន្តែសារធាតុសរីរាង្គរាវដែលមានវីរុសគ្រប់គ្រាន់សំរាប់ចំលងទៅអ្នកផ្សេងបាន មានដូចជា ឈាម ទឹកកាម និង ទឹករំអិលប្រដាប់ភេទស្រ្តី។

៨- មនុស្សដែលឆ្លងមេរោគអេដស៍ អាចរស់នៅបានរយៈពេលច្រើនជាង ៥ ឆ្នាំ។

៩- ជាទូទៅអ្នកផ្ទុកមេរោគអេដស៍ ដែលមាន CD4 តិចជាង ២០០ Celles/$mm^3$ មានឱកាសច្រើននឹងកើតជំងឺឱកាសនិយម។

១០- បីបុគ្គលដែលមានការប្រព្រឹត្តប្រឈមមុខគ្រោះថ្នាក់ខ្លះៗ ដែលបានស្រក់ទម្ងន់ជាងប្រាំគីឡូក្រាមក្នុងមួយខែ ហើយមានរលាកកន្ទួលៗនៅលើស្បែក។ គេអាចសន្និត់បានថាបុគ្គលនោះបានឆ្លងមេរោគអេដស៍ហើយ។

១១- គេអាចធ្វើរោគវិនិច្ឆ័យមើលឃើញមេរោគអេដស៍ក្នុងខ្លួនទារកទើបនឹងកើត តាមរយៈការធ្វើតេស្តរកអង្គបដិបក្ខ។ បើលទ្ធផលតេស្តឈាមចេញមកវិជ្ជមាននោះ គេអាចសន្និដ្ឋានបានថា ទារកនោះ បានឆ្លងមេរោគអេដស៍ ពីម្តាយ ។

១២- ឱសថប្រឆាំងមេរោគអេដស៍(ARV) មិនល្អឡើយសំរាប់ស្ត្រីមានផ្ទៃពោះ ដែលមានផ្ទុកមេរោគអេដស៍

១៣-**សំណាង** ពេលខ្លះ ចាក់ថ្នាំញៀនដោយប្រើម្ជុលរួមជាមួយមិត្តភ័ក្ត្ររបស់គាត់ ។ បើគាត់មិនឃើញ ឈាមជាប់ នៅលើម្ជុលរឺស៊ីរ៉ាំងចាក់រួមគ្នាទេនោះ ពួកគេទាំងអស់គ្នា ពិតជាមានសុវត្ថិភាពហើយ ។

១៤-**សុខា** ជានិច្ចកាល ពិនិត្យពិច្ច័យហ្មត់ចត់លើដងខ្លួន រួមទាំងផ្នែកខាងក្រោមនៃពោះ និង ប្រដាប់ភេទរបស់ស្រី ដែលគាត់រួមរ័ក្សជាមួយ ។ ធ្វើបែបនេះគាត់ដឹងថាដៃគូរួមរក្ស័របស់គាត់ គ្មានជម្ងឺអេដស៍ ។

១៥- គេនិយាយថា មានស្រោមអនាម័យខ្លះ ត្រូវបានផលិតឡើងដោយមានមេរោគអេដស៍ ជាប់មកជាមួយវា ។

១៦-មានឱសថសំរាប់បន្ថយការចំលងមេរោគអេដស៍ពីម្តាយទៅកូន ។

**ចំលើយ:**

១. **ខុស:** ទារក អាចឆ្លងមេរោគអេដស៍ពីម្តាយរបស់គេ តាមរបៀបបីយ៉ាង ដូចខាងក្រោម:

ក. ការចំលងមេរោគអេដស៍តាមរយៈឈាមនៅក្នុងសុកដែលបញ្ជូនពីម្តាយទៅកូន នៅពេលដែលទារកមិនទាន់កើត

ខ. ពីឈាមរបស់ម្តាយ ក្នុងអំឡុងពេលឈឺពោះសំរាល និង ពេលសំរាលកូន។

គ. ពីទឹកដោះម្តាយ

បើម្តាយមានផ្ទុកមេរោគអេដស៍ ទារកមានឱកាសឆ្លងមេរោគអេដស៍ ប្រមាណជា ២៥-៣០% បើពុំមានអន្តរាគមន៍អ្វីទាំងអស់។

២. **ត្រូវ:** ការធ្វើតេស្តរកមេរោគអេដស៍ មិនមែនរកវីរុស(អេចអាយវី)ផ្ទាល់តែម្តងទេ។ ការធ្វើតេស្តឈាមគឺជាការរកអង្គបដិបក្ខចំពោះវីរុសនោះ។ អង្គបដិបក្ខ គឺជាសារធាតុដែលខ្លួនរបស់អ្នកបង្កើតឡើងដើម្បី ព្យាយាមការពារខ្លួនអ្នកទប់ទល់នឹងមេរោគអេដស៍។

វាទាមទារនូវពេលវេលាខ្លះ សំរាប់អោយខ្លួនរបស់យើងបង្កើតបាននូវអង្គបដិបក្ខគ្រប់គ្រាន់ ដែលអាចអោយការធ្វើតេស្តឈាមរកមេរោគអេដស៍រកឃើញបាន។ ឧទាហរណ៍ បើបុរសម្នាក់បានឆ្លងមេរោគអេដស៍កាលពីសប្តាហ៍ មុន ហើយ គាត់ធ្វើតេស្តឈាមនៅថ្ងៃនេះ នោះលទ្ធផលតេស្ត ឈាមអាចនឹងអវិជ្ជមានពីព្រោះខ្លួន របស់គាត់មិនទាន់មានពេល វេលា គ្រប់គ្រាន់ដើម្បីបង្កើតបាននូវអង្គបដិបក្ខអោយបានច្រើននៅឡើយ (នេះហៅថារយៈពេលចំហរ)។ ក៏ប៉ុន្តែមេរោគអេដស៍ គឺប្រាកដជាមាននៅក្នុងខ្លួនគាត់។ បើគាត់ធ្វើតេស្តឈាមម្តងទៀតរយៈពេលបីខែក្រោយមកទៀត នោះលទ្ធផលតេស្តឈាម នឹងវិជ្ជមាន ព្រោះថាខ្លួនគាត់មានអង្គបដិ បក្ខច្រើននៅពេលនោះ ហើយអង្គបដិបក្ខទាំងនោះ នឹងលេចចេញអោយឃើញនៅក្នុងលទ្ធផលតេស្តឈាមរកមេរោគអេដស៍។

៣. **ខុស:** មនុស្សដែលមានផ្ទុកមេរោគអេដស៍ អាចរស់នៅដោយមានសុខភាពល្អ បានរយៈពេលយូរប្រសិនបើគេដឹងពី របៀបថែទាំខ្លួនរបស់គេ។ ឱសថប្រឆាំងមេរោគអេដស៍(ARV) អាចបង្កើតអោយមានផលលំបាកមួយចំនួន នៅពេលចាប់ផ្តើមប្រើវាហើយ អ្នកជំងឺត្រូវតែប្រើវាអស់មួយជីវិត។ មានលក្ខណៈវិនិច្ឆ័យជាច្រើនដែលត្រូវ ពិចារណាមុនពេលវេជ្ជបណ្ឌិតផ្តល់វេជ្ជបញ្ជាអោយប្រើឱសថARV ។ វេជ្ជបណ្ឌិតអាចចេញវេជ្ជបញ្ជា

អោយប្រើឱសថ ARV ដល់អ្នកផ្ទុកមេរោគអេដស៍ ដែលមានប្រព័ន្ធការពារខ្លួនចុះខ្សោយទ្រុឌទ្រោមខ្លាំង។ ការនេះអាចធ្វើរោគ វិនិច្ឆ័យឃើញតាមរយៈការធ្វើតេស្តរាប់ CD4 របស់គាត់។ នៅប្រទេសកម្ពុជាគោលការណ៍ណែនាំរបស់ថ្នាក់ជាតិបានចែងថា ឱសថប្រឆាំងនឹងមេរោគអេដស៍គួរផ្តល់អោយអ្នកដែលមានCD4តិចជាង ២00 Cells/$m^3$ ។

៤. **ត្រូវ:** គេអាចបង្ការជំងឺឱកាសនិយមខ្លះ ដោយប្រើឱសថអង់ទីប៊ីយូទិចមួយចំនួន។ ឧទាហរណ៍ cotrimoxazole (បាក់ទ្រីម) អាចបង្ការជម្ងឺរលាកសួត (PCP)លើអ្នកផ្ទុកមេរោគអេដស៍ដែលមាន CD4 តិចជាង ២00 Cells/$m^3$។ ឱសថត្រូវតែផ្តល់អោយដោយវេជ្ជបណ្ឌិតមានជំនាញ ហើយគេត្រូវតាមដានអ្នកជម្ងឺជាបន្តបន្ទាប់ តាំងពីពេលចាប់ផ្តើមប្រើឱសថទាំងនោះ ។

៥. **ត្រូវ:** នៅពេលមានលេចចេញរោគសញ្ញា អ្នកជំងឺគួរតែស្វែងរកការព្យាបាលពីវេជ្ជបណ្ឌិតមានជំនាញ - គឺអោយបានកាន់តែឆាប់ កាន់តែល្អ។

៦. **ខុស:** មិនទាន់មានឱសថព្យាបាលជម្ងឺអេដស៍អោយជាដាច់នៅឡើយទេ។ ជម្ងឺនានាដែលពាក់ព័ន្ធនឹងមេរោគអេដស៍ អាចព្យាបាលបាន។ ឱសថដែលគេស្គាល់ថាជា ឱសថពន្យាជីវិត (ARV) អាចជួយអោយខ្លួនប្រាណមនុស្សយើងប្រឆាំងទល់នឹងមេរោគអេដស៍បាន ប៉ុន្តែមិនអាចកំចាត់មេរោគអេដស៍នោះនៅក្នុងខ្លួនបានទាំងស្រុងឡើយ។ វាអាចជួយអ្នកជម្ងឺអេដស៍អោយរស់នៅបានយូរ។ មានតែវេជ្ជបណ្ឌិត ដែលមានជំនាញត្រឹមត្រូវប៉ុណ្ណោះដែលអាចចេញវេជ្ជ បញ្ជា អោយប្រើឱសថទាំងនេះបាន។ ឱសថនេះមានតំលៃថ្លៃ។

៧. **ត្រូវ:** មេរោគអេដស៍គឺជាវីរុស ដែលរស់នៅក្នុងសារធាតុរាវក្នុងខ្លួនមនុស្ស ដូចជា ឈាម ទឹកកាមទឹករំអិលរបស់ប្រដាប់ភេទស្ត្រី និង ទឹកដោះម្តាយ។ នៅក្នុងសារធាតុរាវទាំងនេះ មានវីរុស ជាច្រើន ដូច្នេះបុគ្គលម្នាក់អាចចំលងវាទៅបុគ្គលម្នាក់ទៀត តាមរយៈការប្តូរសារធាតុរាវ ទាំងនេះ។ នៅក្នុងសារធាតុរាវ ផ្សេងដូចជា ទឹកមាត់ ទឹកនោម និង ទឹកភ្នែក ក៏មានវីរុសនេះដែរតែមានបរិមាណតិចតួចហើយមិនគ្រប់គ្រាន់អោយចំលងមេរោគអេដស៍បានទេ។

៨. **មិនប្រាកដទេ:** អ្នកផ្ទុកមេរោគអេដស៍ អាចរស់នៅបានដល់ ១០-១៥ ឆ្នាំ ដោយមិនប្រើឱសថអ្វីទាំងអស់បើគេចេះ ពីរបៀបថែទាំខ្លួនរបស់គេ ហើយរស់នៅក្នុងបរិស្ថានស្អាតល្អ។ នៅកម្ពុជាមនុស្សភាគច្រើនបានដឹងពីស្ថានភាពផ្ទុកមេរោគអេដស៍របស់ខ្លួនក្រោយពេលបានឆ្លងមេរោគអេដស៍រួចជាយូរមកហើយ។ ការស្វែងរកការ

ព្យាបាល ចំពោះជម្ងឺទាំងអស់បានឆាប់រហ័សក្រោយពីកើតជំងឺនោះមកអាចជួយអ្នកផ្ទុកមេរោគអេដស៍/ជម្ងឺអេដស៍អោយរស់នៅបានយូរ ។

៩. **ត្រូវ:** ជាធម្មតា អ្នកផ្ទុកមេរោគអេដស៍ដែលមាន CD4 តិចជាង ២០០ Cells/m$^3$ មានឱកាសងាយនឹងកើតជំងឺ ឱកាសនិយមបានច្រើន ។ ក៏ប៉ុន្តែមានអ្នកផ្ទុកមេរោគអេដស៍/ជំងឺអេដស៍ខ្លះ នៅតែមានសុខភាពល្អ ទោះបីជា CD4 របស់គេ មានតិចជាង ១០០ Cells/m$^3$ ក៏ដោយ ។

១០. **ខុស:** យើងមិនអាចសន្និដ្ឋានថា អ្នកណាម្នាក់មានផ្ទុកមេរោគអេដស៍ឡើយ បើគេមិនទាន់បានធ្វើតេស្តឈាមឃើញថាវិជ្ជមាន ( ផ្ទុកមេរោគអេដស៍) ទេនោះ ។

១១. **ខុស:** ទោះបីគេប៉ាន់ប្រមាណថា បើគ្មានអន្តរាគមន៍អ្វីសោះ ប្រមាណជា ៣០% នៃកុមារ កើតពីម្តាយដែលមានផ្ទុកមេរោគអេដស៍ នឹងអាចឆ្លងមេរោគអេដស៍ក៏ដោយ ក៏គ្រប់កុមារទាំងអស់ ដែលបានកើតពីម្តាយមានផ្ទុកមេរោគអេដស៍នោះ នឹងមានអង្គបដិបក្ខមេរោគអេដស៍ដែលទទួលពីម្តាយមក ហើយពេលដែល ធ្វើតេស្តឈាមទៅនឹង ឃើញលទ្ធផលវិជ្ជមាន តាមរយៈការធ្វើតេស្តឈាមដោយវិធី ELISA ឬ ការធ្វើតេស្តរហ័ស ។ បើទារកនោះពិតជា អវិជ្ជមានមែន នោះអង្គបដិបក្ខដែលទទួលពីម្តាយ នឹងចាប់ផ្តើមបាត់ទៅវិញ នៅពេលដែលកុមារមានអាយុពី ៩ ទៅ ១៥ ខែ ។ ដូច្នេះហើយទើបគេណែនាំអោយធ្វើតេស្តឈាមរកមើលអង្គបដិបក្ខមេរោគអេដស៍នៅពេលកុមារ មានអាយុលើសពី ១៨ខែ ។ តេស្តឈាមដែល រកឃើញសមាសភាគរបស់មេរោគអេដស៍ (ដូចជា PCR ឬក៏ការបណ្តុះមេរោគ) អាចរកឃើញមេរោគអេដស៍ នៅក្នុងខ្លួនកុមារបានប៉ុន្តែបច្ចេកទេសទាំងនេះមានតំលៃថ្លៃ ហើយលំបាកធ្វើ ។

១២. **ខុស:** ស្ត្រីមានផ្ទៃពោះ អាចទទួលឱសថប្រឆាំងមេរោគអេដស៍(ARV) ពីវេជ្ជបណ្ឌិតដែលមានជំនាញ ។ ក៏ប៉ុន្តែឱសថប្រឆាំងមេរោគអេដស៍( ឱសថពន្យាជីវិត) អាចមានផលពិបាក ដែលចាំបាច់ត្រូវតែតាមដានបន្ត ។

១៣. **ខុស:** ទោះជាអ្នកមើលមិនឃើញមានឈាមក៏ដោយ ក៏អាចមានឈាមបន្តិចបន្តួច ដែលអ្នកមិនអាចមើលឃើញដែរ ឬក៏មានឈាមខ្លះនៅសល់ក្នុងស៊ីរ៉ាំង ។ ឈាមជាប់នៅលើម្ជុល ឬនៅក្នុងស៊ីរ៉ាំងអាចមានមេរោគអេដស៍ ឬមេរោគផ្សេងទៀត ។ ជានិច្ចកាល ការប្រើប្រាស់ស៊ីរ៉ាំងរួមគ្នា គឺជារឿងមួយគ្រោះថ្នាក់ ។

១៤. **ខុស:** មនុស្សដែលមើលទៅឃើញថាមានសុខភាពល្អ ហើយគ្មានសញ្ញា ឬ រោគសញ្ញាជម្ងឺអ្វី សោះក៏អាចមានផ្ទុកមេរោគអេដស៍ដែរ។ មេរោគអេដស៍មិនអាចអោយគេមើលឃើញលើប្រដាប់ភេទឡើយ។ វិធីតែមួយគត់ដើម្បីអោយដឹងថាអ្នកណាម្នាក់ផ្ទុកមេរោគអេដស៍ឬក៏អត់នោះគឺការធ្វើតេស្តឈាម។

១៥. **ខុស:** នេះជាពាក្យចចាមអារាម វាមិនពិតទេ។ ស្រោមអនាម័យ មានអនាម័យស្អាតល្អ ហើយមានសុវត្ថិភាព។

១៦. **ត្រូវ:** មានឱសថប្រឆាំងមេរោគអេដស៍ **(ARV)** ដែលអាចបន្ថយការចំលងមេរោគអេដស៍ ពីម្តាយទៅកូនបាន។ ប្រសិនបើវេជ្ជបណ្ឌិតដឹងថា ម្តាយមានផ្ទុកមេរោគអេដស៍ហើយនោះ គាត់អាចផ្តល់ឱសថ **ARV** ដល់ម្តាយ ក្នុងអំឡុងពេលឈឺពោះសំរាលកូន ហើយបន្ទាប់មកផ្តល់ឱសថដដែលនោះទៅទារក។ អន្តរាគមន៍នេះមានប្រសិទ្ធិភាព ក្នុងការកាត់បន្ថយការ ចំលងមេរោគអេដស៍ពីម្តាយទៅកូន។

# សកម្មភាព ទី៤

# កំរិតប្រឈមមុខនឹងគ្រោះថ្នាក់ និងការវាយតំលៃលើការប្រឈមមុខនឹងគ្រោះថ្នាក់ តើលក្ខណៈប្រឈមមុខនឹងគ្រោះថ្នាក់មានកំរិតណា?

# សកម្មភាព ទី៤

## តើលក្ខណៈប្រឈមមុខនឹងគ្រោះថ្នាក់ មានកំរិតណា?

នៅប្រទេសកម្ពុជា ការឆ្លងមេរោគអេដស៍ភាគច្រើន កើតឡើងតាមរយៈការរួមភេទ។ ការយល់ ដឹងបាន ល្អស្តីពីកំរិត ប្រឈមមុខនឹងគ្រោះថ្នាក់នៃការប្រព្រឹត្តផ្លូវភេទ នឹងជួយអោយអ្នកផ្តល់ប្រឹក្សាវាយតំលៃលើកំរិតគ្រោះថ្នាក់ឆ្លងមេរោគអេដស៍ដែលអតិថិជនប្រឈមមុខជាមួយ ហើយជួយអោយគេកំណត់ពីរបៀបផ្តល់ប្រឹក្សា។ មនុស្សជាច្រើន នៅសួរសំណួរ ស្តីពីរបៀប ចំលង មេរោគអេដស៍និងការប្រឈមមុខគ្រោះថ្នាក់នឹងការចំលងមេរោគអេដស៍តាមរយៈសកម្មភាពធម្មតាប្រចាំថ្ងៃ និងទំនាក់ទំនងនឹងការរស់នៅជាមួយអ្នកផ្ទុកមេរោគអេដស៍/ជម្ងឺអេដស៍។

**<u>គោលបំណង:</u>**

១- ដើម្បីបង្កើនការយល់ដឹងស្តីពីកំរិតប្រឈមមុខនឹងគ្រោះថ្នាក់

២- ដើម្បីបង្កើនការយល់ដឹងរបស់អ្នកផ្តល់ប្រឹក្សាស្តីពីការវាយតំលៃការប្រឈមមុខនឹងគ្រោះថ្នាក់ ជាពិសេសក្នុងចំណោមអ្នកដែលចង់ធ្វើតេស្តរឺក៏អ្នកដែលព្រួយបារម្ភ។

**<u>វិធីសាស្ត្រ:</u>**

១- ការពិភាក្សាតាមក្រុមតូចៗ និង ការផ្លាស់ប្តូរគំនិតគ្នា

២- ការពិភាក្សាតាមក្រុមត្រូវអនុវត្តតាមរយៈការផ្លាស់ប្តូរពត៌មាន និងយោបល់គ្នា ដើម្បីវាយតំលៃពីការប្រឈមមុខនឹងគ្រោះថ្នាក់ និង ធ្វើអោយមានការយល់ដឹងដូចគ្នា។

**<u>សំភារៈ</u>**

១- សន្លឹកប័ណ្ណប្រឈមមុខគ្រោះថ្នាក់ចំនួន ២៥ (មាននៅអង្គការ FHI)។ ក្រុមនិមួយៗនឹងមានប័ណ្ណមួយឈុត ២៥សន្លឹក។

២- ផ្ទាំងបញ្ចាំងលេខ ១-៥

**<u>ដំណើរការ:</u>**

១- ចែកសិក្ខាកាមជា ២-៤ក្រុម អាស្រ័យទៅលើចំនួនសិក្ខាកាមទាំងអស់។ ក្រុមនិមួយៗមានគ្នា ៤-៦នាក់។

២- ចែកប័ណ្ណមួយឈុតអោយក្រុមមួយៗ។

៣- អ្នកសំរបសំរួលសរសេរនៅលើក្ដារខៀន ឬ ផ្ទាំងក្រដាសធំៈ *ការប្រឈមគ្រោះថ្នាក់ខ្ពស់ ការប្រឈមគ្រោះថ្នាក់មធ្យម, ការប្រឈមគ្រោះថ្នាក់ទាប* និង *គ្មានការប្រឈមគ្រោះថ្នាក់*។

៤- អោយសមាជិកក្រុមនិមួយៗពិភាក្សាគ្នាពីកំរិតនៃការប្រឈមគ្រោះថ្នាក់មាននៅក្នុងប័ណ្ណនិមួយៗ ហើយដាក់រាយវាតាមលំដាប់នៃការប្រឈមមុខគ្រោះថ្នាក់ ដូចដែលគេគិត។ អនុញ្ញាតពេល ៧-១០នាទី សំរាប់ក្រុមនិមួយដើម្បីបញ្ចប់កិច្ចការនេះ។

៥- អ្នកសំរបសំរួល ប្រើប័ណ្ណមួយឈុត។ ចាប់យកប័ណ្ណម្ដងមួយៗ ហើយសួរអោយសិក្ខាកាមឆ្លើយ។ ក្រុមនិមួយៗ ឬសិក្ខាកាម ម្នាក់ៗអាចមានចំលើយខុសៗគ្នា។ ប្រការនេះ នឹងផ្ដល់នូវឱកាសអោយមានការពិភាក្សា ក្នុងចំណោមសមាជិកក្រុម។ អ្នកសំរបសំរួល អាចបញ្ជាក់ឡើងវិញពីសភាពការណ៍ រឺក៏ផ្ដល់ពត៌មានបន្ថែម។ ការប្រឈមមុខនឹងគ្រោះថ្នាក់ នៃទង្វើខ្លះនៅក្នុង ប័ណ្ណ អាចអាស្រ័យទៅលើបុគ្គលដែលប្រព្រឹត្តទង្វើនោះ។ ឧទាហរណ៍ ការរួមរ័ក្សដោយគ្មាន ប្រើស្រោមអនាម័យ អាចមិន មែនជាការប្រឈមគ្រោះថ្នាក់ឡើយ ប្រសិនបើជាការរួមរ័ក្សរវាងប្ដីនិងប្រពន្ធដែលមិនធ្លាប់ដែលរួមរ័ក្សជាមួយអ្នក ដ៏ទៃសោះ ប៉ុន្ដែវានឹងធ្វើអោយមានការប្រឈមមុខនឹង គ្រោះ ថ្នាក់កំរិត ខ្ពស់បើទង្វើបែបនេះកើតឡើងរវាងបុរស ជាមួយ នឹងស្ដ្រីរកស៊ីផ្លូវភេទ។ អ្នកសំរបសំរួលដាក់ប័ណ្ណនិមួយៗតាមកំរិតការប្រឈមមុខនឹងគ្រោះថ្នាក់អោយគ្រប់គ្នាអាចមើលឃើញ។

៦- បើមិនមានសំណួរថែមទៀតទេ អ្នកសំរបសំរួល ត្រូវពិនិត្យមើលឡើងវិញលើចំណេះដឹងស្ដីពីមេរោគអេដស៍/ជម្ងឺអេដស៍ ដោយប្រើផ្ទាំងបញ្ចាំងលេខ ១-៥។

៧- អ្នកសំរបសំរួលត្រូវពន្យល់ពី របៀបផ្ដល់ពត៌មានស្ដីពីមេរោគអេដស៍/ជម្ងឺអេដស៍ និងកត្តាផ្សេងៗដែលអ្នកផ្ដល់ប្រឹក្សាត្រូវចងចាំ (ប្រើផ្ទាំងបញ្ចាំង លេខ៥)។

- អ្នកផ្ដល់ប្រឹក្សា និងបុគ្គលិកធ្វើការក្នុងកម្មវិធីអេដស៍ ត្រូវតែមានពត៌មានពិតត្រឹមត្រូវ ព្រោះគេត្រូវផ្ដល់ពត៌មានទាំងឡាយនោះទៅអ្នកដ៏ទៃ។
- អ្នកដែលផ្ដល់ពត៌មានស្ដីពីមេរោគអេដស៍/ជម្ងឺអេដស៍ ត្រូវពន្យល់អោយច្បាស់ទៅដល់អ្នកដែលសួរសំនួរ។ មិនត្រូវនិយាយថាបុគ្គលម្នាក់ ទំនងជាឆ្លងមេរោគអេដស៍ ឬក៏អត់នោះឡើយ។
- នៅពេលឆ្លើយសំណួរស្ដីពីមេរោគអេដស៍/ជម្ងឺអេដស៍ អ្នកធ្វើការងារនេះ ត្រូវប៉ាន់ប្រមាណពីមូល ហេតុដែលអតិថិជនសួរសំណួរ។ ថាតើការសួរសំណួរនោះ គឺជាការសួរពត៌មាន ជាទស្សនរបស់បុគ្គល ឬក៏ មកពីគេព្រួយបារម្ភ?
- ការផ្ដល់ចំលើយ ឬពត៌មានមិនច្បាស់លាស់ អាចនឹងមានផលប៉ះពាល់ទៅលើអតិថិជន ទាក់ទងទៅ នឹងការបង្ការ និងការទទួលយក និងរបៀបដែលគេត្រូវរស់នៅជាអ្នកផ្ទុកមេរោគអេដស៍/ជម្ងឺអេដស៍។

១
ទារកដែលបៅដោះម្តាយដែលមានផ្ទុកមេរោគអេដស៍

២
មុតម្ជុលចាក់ថ្នាំ ឬឧបករណ៍មុតស្រួចដោយចៃដន្យ

៣
មូសខាំ

៤
ការប្រើមាត់ ឬអណ្តាតក្នុងការរួមភេទ

៥
ការប៉ះពាល់ដំបៅ ឈាម ទឹករងៃរបស់អ្នកផ្ទុកមេរោគអេដស៍ ឬអ្នកជម្ងឺអេដស៍

៦
ការរស់នៅឬធ្វើការជាមួយអ្នកផ្ទុកមេរោគអេដស៍ឬជំងឺអេដស៍

៧
ការប្រើកន្ត្រៃកាត់ក្រចក ឬ ឡាមកោរជាមួយគ្នា

**ប័ណ្ណប្រឈមមុខគ្រោះថ្នាក់**

**សំភារៈ:**

ប័ណ្ណប្រឈមមុខគ្រោះថ្នាក់ទាំង ២៥

បណ្ណ័ប្រឈមមុខគ្រោះថ្នាក់ ៤កំរិត: ប្រឈមគ្រោះថ្នាក់ ប្រឈមគ្រោះថ្នាក់មធ្យម ប្រឈមគ្រោះថ្នាក់ទាប គ្មានការប្រឈមគ្រោះថ្នាក់

រូបភាពមនុស្ស/ក្រុមតំរៀបប័ណ្ណ

៨
ការបញ្ចូលឈាមដែលមានមេរោគអេដស៍

៩
ការបឺត ឬជញ្ជក់មាត់

១០
ការត្រូវតែប្រើអណ្តាត ឬ មាត់សំរាប់រួមភេទ

១១
ការរួមភេទដោយប្រើស្រោមអនាម័យ

១២
ការរួមភេទតាមគូថដោយមិនប្រើស្រោមអនាម័យ

១៣
ការរួមភេទនៅពេលមានរដូវ

១៤
ការប្រើម្ជុលចាក់ថ្នាំញៀនរួមគ្នា

១៥
ការបបោសអង្អែល

១៦
ការរួមភេទដោយដៃ

១៧
ការរួមភេទនៅពេលមានដំបៅនៅលើប្រដាប់ភេទឬកើតជម្ងឺកាមរោគ

១៨
ការថែទាំអ្នកផ្ទុកមេរោគអេដស៍ ឬអ្នកជម្ងឺអេដស៍

១៩
ការរួមភេទតាមទ្វារមាសដោយមិនប្រើស្រោមអនាម័យ

២០
ការក្អកកណ្តាស់

២១
ការប្រើប្រាស់បង្គន់រួមគ្នា

២២
ការប្រាស្រ័យទាក់ទងជាមួយអ្នកផ្ទុកមេរោគអេដស៍

២៣
ការញុំាបាយរួមគ្នា

២៤
ការប្រើម្ជុលសាក់សេទកោសខ្យល់ច្រាសដុសធ្មេញរួមគ្នា

២៥
ការប្រើដៃរួមភេទដោយខ្លួនឯង

## ឧទាហរណ៍នៃលទ្ធផលការងារ

ចេញពីទង្វើសកម្មភាពទាំង ២៥ តាមរយៈការពិភាក្សាតាមក្រុមនិមួយៗ នោះ ឧទាហរណ៍នៃលទ្ធផលដែលក្រុមរៀបតាមលំដាប់កំរិតនៃការប្រឈមមុខនឹងគ្រោះថ្នាក់ ដែលទំនងជាទៅរួចនោះ គឺអាចដូចខាងក្រោមនេះ:

### *ការប្រឈមគ្រោះថ្នាក់ខ្ពស់*

៨
ការបញ្ចូលឈាមដែលមានមេរោគអេដស៍

១៤
ការប្រើម្ជុលចាក់ថ្នាំញៀនរួមគ្នា

១៧
ការរួមភេទនៅពេលមានដំបៅនៅលើប្រដាប់ភេទ ឬ កើតជម្ងឺកាមរោគ

១២
ការរួមភេទតាមគូថដោយមិនប្រើស្រោមអនាម័យ

១៣
ការរួមភេទនៅពេលមានរដូវ

១៩
ការរួមភេទតាមទ្វារមាសដោយមិនប្រើស្រោមអនាម័យ

### *ការប្រឈមគ្រោះថ្នាក់មធ្យម*

១
ទារកដែលបៅដោះម្តាយដែលមានផ្ទុកមេរោគអេដស៍

៤
ការប្រើមាត់ ឬ អណ្តាតក្នុងការរួម...

៥
ការប៉ះពាល់ដំបៅ ឈាម ទឹករងៃរបស់អ្នកផ្ទុកមេរោគអេដស៍ ឬអ្នកជម្ងឺអេដស៍

### *ការប្រឈមគ្រោះថ្នាក់ទាប*

២
មុតម្ជុលចាក់ថ្នាំ ឬ ឧបករណ៍មុតស្រួចដោយចៃដន្យ

១១
ការរួមភេទដោយប្រើស្រោមអនាម័យ

១០
ការត្រូវគេប្រើអណ្តាត ឬ មាត់សំរាប់រួមភេទ

១៨
ការថែទាំអ្នកផ្ទុកមេរោគអេដស៍ ឬ អ្នកជម្ងឺអេដស៍

២៥
ការប្រើដៃរួមភេទដោយខ្លួនឯង

២៤
ការប្រើម្ជុលសាក់សេនកោសខ្យល់ច្រាសដុសធ្មេញរួមគ្នា

### *គ្មានការប្រឈមគ្រោះថ្នាក់*

៩
ការបឺត ឬជញ្ជក់មាត់

៣
មូសខាំ

៧
ការប្រើកន្ត្រៃកាត់ក្រចក ឬឡាមកោររួមគ្នា

៦
ការរស់នៅឬធ្វើការជាមួយអ្នកផ្ទុកមេរោគអេដស៍

១៥
ការបបោសអង្អែល

១៦
ការរួមភេទដោយដៃ

២០
ការក្អកកណ្តាស់

២១
ការប្រើប្រាស់បង្គន់រួមគ្នា

២២
ការប្រាស្រ័យទាក់ទងជាមួយអ្នកផ្ទុកមេរោគអេដស៍

២៣
ការញុំាបាយរួមគ្នា

**ផ្ទាំងបញ្ចាំងលេខ ១ (សកម្មភាពទី៤)**

**កំរិតប្រឈមមុខនឹងគ្រោះថ្នាក់**

- **ការប្រឈមមុខខ្ពស់** — ជាការប្រឈមមុខគ្រោះថ្នាក់ដែលអាចចំលងរឺ ទទួលមេរោគអេដស៍ បាន ហើយមានមនុស្ស ជាច្រើន ត្រូវបានឆ្លង ដោយសារតែការប្រព្រឹត្តនេះ
- **ការប្រឈមមុខមធ្យម** — មានឱកាសនឹងចំលង រឺទទួលមេរោគអេដស៍ ខ្លះៗ ប៉ុន្តែ តិចជាងការប្រព្រឹត្តដែលមាន "ការប្រឈមមុខខ្ពស់"
- **ការប្រឈមមុខទាប** — ជាទ្រឹស្តី មានការប្រឈមមុខគ្រោះថ្នាក់ខ្លះៗដែរ។ ប៉ុន្តែ ក្នុងស្ថានភាពជាក់ស្តែង មានឱកាសតិចតួចណាស់ ដែលមនុស្សនឹងឆ្លងមេរោគអេដស៍ តាមរយៈ សកម្មភាពទាំងនេះ រឺក៏ មានមនុស្សតិចតួច ណាស់ ដែលដឹងថាបានឆ្លងមេរោគអេដស៍ពី សកម្មភាព នេះ។
- **គ្មានការប្រឈមមុខ** — គ្មានការប្រឈមមុខនឹងការឆ្លងមេរោគអេដស៍ តាមរយៈសកម្មភាពទាំងនេះ ឡើយ។

**ផ្ទាំងបញ្ហាំងលេខ២** ( សកម្មភាពទី៤)

## មានកត្តាបី ដើម្បីអោយបុគ្គលម្នាក់ឆ្លងមេរោគអេដស៍

### ប្រភព

-មេរោគអេដស៍រស់នៅក្នុងឈាមមនុស្ស ដោយភ្ជាប់ខ្លួនវានឹងគ្រាប់ឈាមស ។

-មេរោគអេដស៍ ឋិតនៅក្នុងសារធាតុរាវ ដូចជាឈាម ទឹកកាម ទឹករំអិល តាមទ្វារមាស និង ទឹកដោះម្តាយ

### បរិមាណ និង គុណភាព

-ត្រូវមានបរិមាណមេរោគអេដស៍ គ្រប់គ្រាន់ នៅក្នុងសារធាតុរាវ

-មេរោគអេដស៍ ត្រូវតែមានគុណភាពខ្ពស់

-មេរោគអេដស៍ មិនអាចរស់នៅក្រៅខ្លួនមនុស្សបាន

-សភាពក្នុងខ្លួនមនុស្សនិងបរិដ្ឋានខ្លះៗធ្វើអោយមេរោគអេដស៍លំបាករស់នៅ ដូចជា អាស៊ីដក្នុងទឹកមាត់ ក្រពះ អាកាសធាតុ កំដៅនិងភាពស្ងួត

### ផ្លូវចំលង

មេរោគអេដស៍ ចំលងពីអ្នកផ្ទុកមេរោគនេះទៅមនុស្សម្នាក់ទៀត ដោយចូលទៅក្នុងប្រព័ន្ធឈាម ។

<u>ផ្ទាំងបញ្ចាំងលេខ៣</u> (សកម្មភាពទី៤)

## មេរោគអេដស៍ អាចឆ្លងពីមនុស្សដែលផ្ទុកមេរោគអេដស៍ ទៅអ្នកដទៃទៀត តាមរយៈ

ពីម្ដាយទៅទារក

-នៅពេលទារកនៅក្នុងស្បូនម្ដាយ

-ក្នុងពេលឈឺពោះសំរាល និង ពេលសំរាល

-អំឡុងពេលបំបៅដោះម្ដាយ

ការប្រើម្ជុលចាក់ និង ស៊ីរ៉ាំងរួមគ្នា និងការបញ្ចូលឈាម

ការរួមភេទតាមទ្វារមាស និងរន្ធគូថ ដោយមិនប្រើស្រោមអនាម័យ

**ផ្ទាំងបញ្ចាំងលេខ៤( សកម្មភាពទី៤)**

**ការរួមភេទ**

**តាមមាត់**

- មានការប្រឈមមុខគ្រោះថ្នាក់ខ្លះៗក្នុងករណីរួមភេទតាមមាត់ ជាមួយបុរសមានផ្ទុកមេរោគអេដស៍ នៅពេលដែលៈ

  -បុរសបាញ់បញ្ចេញទឹកកាមចូលទៅក្នុងមាត់ ហើយ មានការរលាក រឺដំបៅ ក្នុងមាត់របស់ដៃគូគាត់ ។

  -បុរសមានជំងឺកាមរោគ ហើយដៃគូគាត់ មានជំងឺក្នុងបំពង់ក ។

- ប្រសិនបើបុគ្គលម្នាក់មាន***ជម្ងឺកាមរោគនៅលើប្រដាប់ភេទ  ជំងឺកាមរោគនោះ*** អាចនឹងឆ្លងចូលទៅលើមាត់របស់ដៃគូ តាមរយៈការរួមភេទតាមមាត់ ។

**<u>ផ្ទាំងបញ្ចាំងលេខ៩</u> សកម្មភាព៤**

# ការផ្តល់ពតិមាន និង ការឆ្លើយសំណួរស្តីពីមេរោគអេដស៍ និងជម្ងឺអេដស៍



## សកម្មភាព ទី៥

## ទស្សនៈ ការអោយតំលៃ និង ការដឹងខ្លួន

## តើអ្នកគិតយ៉ាងណាចំពោះគាត់?

# សកម្មភាព ទី៥

## តើអ្នកគិតដូចម្តេចចំពោះគេ?

ចំណុចមួយដ៏សំខាន់ស្តីពីការផ្តល់ប្រឹក្សា គឺលទ្ធភាពរបស់អ្នកផ្តល់ប្រឹក្សាក្នុងការទទួលយកនិងការយល់ដឹងពីស្ថានភាពរបស់អតិថិជន។ បញ្ហានេះ រួមបញ្ចូលទាំង ទស្សនៈយល់ឃើញ គំនិត និង ជំនឿស្តីពីការប្រព្រឹត្ត និង របៀបដែលបុគ្គលម្នាក់ គួរដឹកនាំជីវិត របស់គេ។ បើអ្នកផ្តល់ប្រឹក្សា ប្រើប្រាស់ជំនឿ រឺទស្សនៈរបស់គាត់ ដើម្បីវិនិច្ឆ័យលើការប្រព្រឹត្ត របស់អតិថិជននោះ វានឹងបង្កើត ឡើងនូវគំលាតក្នុងទំនាក់ទំនងផ្តល់ប្រឹក្សា។ អតិថិជន អាចមានអារម្មណ៍ ហាក់ដូចជាខ្លួន គាត់កំពុងត្រូវបាន គេស្តីបន្ទោសអោយហើយការផ្តល់ប្រឹក្សានោះ នឹងមិនមានប្រយោជន៍ដល់អតិថិជនឡើយ។

**<u>ចំណុចសំខាន់ៗស្តីពីសកម្មភាពនេះ</u>**

មនុស្សគ្រប់ៗរូប សុទ្ធតែខុសៗគ្នា។ មនុស្សផ្សេងគ្នា មានទស្សនៈយល់ឃើញរឺគំនិតខុសៗគ្នា ចំពោះ រឿងអ្វីមួយរឺ អំពីការ ប្រព្រឹត្តណាមួយ។ សភាពនេះគឺដោយសារការអប់រំ បទពិសោធន៍ ផ្នត់គំនិត និង ការអោយតំលៃ របស់យើងម្នាក់ៗ ទៅលើអ្វីៗ ឬ ការប្រព្រឹត្តផ្សេងៗ។ ជំនឿរឺការអោយតំលៃដែលយើងមាន ធ្វើអោយយើងគិត ខុសៗពីគ្នា ស្តីពីមនុស្ស ឬ ការប្រព្រឹត្តផ្សេងៗ។ ជាធម្មតា អ្វីដែលយើងដឹងអំពីអ្នកដ៏ទៃ គឺគ្រាន់តែជាចំណែកមួយនៃរឿងរ៉ាវរបស់គាត់ទាំងមូល ។

ជួនកាល យើងប្រើគំនិតរបស់យើងក្នុងការវិនិច្ឆ័យ ថាទង្វើណាមួយល្អ រឺអាក្រក់ ។ នៅពេលដែល យើងប្រើ ការវិនិច្ឆ័យរបស់យើងក្នុងអំឡុងពេលនៃការផ្តល់ប្រឹក្សា យើងកំពុងតែគិតជំនួសអតិថិជនហើយ (អតិថិជនមិនបានគិតដោយខ្លួនគេផ្ទាល់)។ បើធ្វើយ៉ាងដូច្នេះ គឺសេវាដែលយើងកំពុងផ្តល់អោយនោះ មិនមែនជាការផ្តល់ប្រឹក្សាឡើយ ប៉ុន្តែជាការប្រៀនប្រដៅ ឬ ការបញ្ជាហើយ។

សកម្មភាពនេះគឺផ្តោតទៅលើទស្សនៈយល់ឃើញ គំនិត និង ជំនឿ។ នៅពេលបញ្ចប់គឺគ្មានការសន្និដ្ឋានថាអ្វីត្រូវ អ្វីខុសនោះឡើយ ដូច្នេះ វាមិនមែនងាយស្រួលនឹងធ្វើអោយសិក្ខាកាមគ្រប់រូបទទួលយកនូវការប្រព្រឹត្តរបស់អតិថិជនគេបានទាំងអស់។ ប៉ុន្តែ សកម្មភាពនេះ នឹងជួយ អោយសិក្ខាកាមដឹងថា យើងតែងតែវិនិច្ឆ័យទៅលើមនុស្ស ឬទង្វើរបស់គេ ដោយមិនដឹងខ្លួន។ អ្នកផ្តល់ប្រឹក្សា ត្រូវតែដឹងពី អារម្មណ៍ និងទស្សនៈយល់ឃើញរបស់ខ្លួន នៅខណៈនោះ (ពេលកំពុងនិយាយជាមួយអតិថិជន) ហើយមិនត្រូវអោយវាជ្រៀត ជ្រែកជាមួយនឹងការផ្តល់ប្រឹក្សា។ សិក្ខាកាមគួរមានទស្សនៈទូលំទូលាយ ហើយចង់យល់ដឹងពី អ្នកដ៏ទៃ និង បញ្ហារបស់គេ។

**គោលបំណង:**

១- ដើម្បីបង្កើនការយល់ដឹងរបស់សិក្ខាកាមអំពីទស្សនៈរបស់គេ ចំពោះការប្រព្រឹត្តផ្សេងៗរបស់មនុស្សនៅ ក្នុងសង្គម ។

២- ដើម្បីជួយសិក្ខាកាមអោយយល់ថា ទស្សនៈ និងភាពលំអៀង អាចជះផលប៉ះពាល់ទៅលើការងាររបស់គេ

៣- ដើម្បីជួយសិក្ខាកាមអោយយល់ថា ការវិនិច្ឆ័យ អាចរាំងស្ទះដល់ការផ្តល់ប្រឹក្សា ហើយជះឥទ្ធិពលទៅលើទំនាក់ទំនងល្អជាមួយនឹងអតិថិជន រួមទាំងការយល់ដឹងពីអារម្មណ៍របស់អតិថិជន និងបញ្ហា របស់គេ ។

**<u>វិធីសាស្ត្រ:</u>**

១- អ្នកសំរបសំរួលផ្តល់តារាងស្តីពីការប្រព្រឹត្ត ទៅអោយសិក្ខាកាមម្នាក់ៗ ជាមួយគ្នានឹងក្រដាស់ពណ៌ខុសៗគ្នា រាងមូល សំរាប់បុរស និង ស្ត្រី ។

២- ដោយមិនបាច់សរសេរឈ្មោះរបស់គេ សិក្ខាកាមរៀបដាក់ចំណុចមូលពណ៌របស់ខ្លួន នៅតាមចន្លោះនានាទៅតាមអ្វីដែល គេគិត ។

**<u>សំភារៈ</u>**

១- តារាងស្តីពីការប្រព្រឹត្ត សំរាប់សិក្ខាកាម

២- ក្រដាស់មូលពណ៌ សំរាប់បិទ ( បើគ្មានប្រើប៊ិចពណ៌សំរាប់គូសខ្វែង)

៣- ផ្ទាំងក្រដាស់ធំស្តីពីការប្រព្រឹត្ត សំរាប់ដាក់លើជញ្ជាំង

**<u>ការណែនាំដល់អ្នកសំរបសំរួល</u>**

- អ្នកសំរបសំរួលពន្យល់ពីកំរិតទទួលយកដែលអាចទទួលយកបាន ឬ ក៏មិនបានដោយចង្អុលបង្ហាញអោយឃើញពីទស្សនៈយល់ឃើញ ទៅតាមនោះគឺ: 0 អាចទទួលយកបាន ហើយកំរិតមិនអាចទទួលយកបានប្រែប្រួល ពី -១ =មិនអាចទទួលយកបានទាបបំផុត, -៣ មិនអាចទទួលយកបានមធ្យមនិង -៥ = មិនអាចទទួលយកបានខ្ពស់បំផុត ។
- អ្នកសំរបសំរួល ជំរុញដល់ការពិភាក្សា ដោយប្រើផ្ទាំងក្រដាសធំស្តីពីការប្រព្រឹត្ត ដោយចង្អុលបង្ហាញអោយឃើញពីកំរិតទទួលយកបាន ឬ មិនទទួលយកបាន ណាមួយដែលអាចទទួលយកបាន ណាមួយដែលមិនអាចទទួលយកបាន ឬ អាចទទួលយកបានតិចបំផុត ឬក៏ ការប្រព្រឹត្តតែមួយ តែសិក្ខាកាមផ្សេងគ្នា កំណត់កំរិតទទួលយកបាន ផ្សេងគ្នា ។
- ចេញពីសំណួរ ចំលើយ និង ការពិភាក្សារបស់សិក្ខាកាម អ្នកសំរបសំរួលត្រូវចង្អុលបង្ហាញថា ប្រសិនបើយើងមានទស្សនៈ យល់ឃើញថា *ចូលចិត្ត* ឬ *មិនចូលចិត្ត* ចំពោះការប្រព្រឹត្តមួយណានោះ ទស្សនៈយល់ឃើញ និងអារម្មណ៍របស់យើងអាចមាន ឬមិនមាន ឥទ្ធិពលទៅលើរបៀបដែលយើងនិយាយ និងធ្វើការជាមួយអតិថិជន ។

**ដំណើរការៈ**

១- ពន្យល់ពីសកម្មភាពនេះ ដោយណែនាំសិក្ខាកាមអោយបញ្ចេញនូវទស្សនៈយល់ឃើញរបស់គេដោយស្មោះត្រង់ស្តីពីការប្រព្រឹត្តិនីមួយៗនៅលើ ផ្ទាំងក្រដាស។ អ្នកសំរបសំរួល ចែកក្រដាសមូលពណ៌ ពណ៌មួយសំរាប់បុរសហើយពណ៌មួយទៀតសំរាប់ស្ត្រី។ អោយ គេដាក់(បិទ)ក្រដាសមូលមួយ នៅក្នុងរង្វង់ "*បុរស*" ឬ "*ស្ត្រី* " ប៉ុន្តែមិនបាច់អោយគេសរសេរឈ្មោះគេទេ។

២- អោយសិក្ខាកាមដាក់ក្រដាសមូលពណ៌របស់គេ អោយលឿនតាមអាចធ្វើបាន ទៅក្នុងចន្លោះដែលគេជ្រើសរើស ហើយប្រគល់ក្រដាសនោះ មកអោយអ្នកសំរបសំរួលវិញ។

៣- បន្ទាប់ពីប្រមូលក្រដាសស្តីពីការប្រព្រឹត្តទាំងអស់មកវិញហើយ អ្នកសំរបសំរួលចែកក្រដាសនោះទៅអោយសិក្ខាកាមម្នាក់ៗវិញ ដោយចាប់ហុចទៅអោយគេដោយចៃដន្យ ដោយមិនប្រាប់គេថា ក្រដាសនោះ ជារបស់អ្នកណាឡើយ។

៤- សិក្ខាកាមម្នាក់ៗបិទក្រដាសមូលពណ៌ អោយស៊ីទៅនឹងអ្វីដែលគេបានទទួលទៅលើផ្ទាំងក្រដាសធំតាមកំរិតការទទួល រឺមិនទទួល។

៥- ក្រោយពេលសិក្ខាកាមម្នាក់ៗបានបិទហើយ ហៅសិក្ខាកាមទាំងអស់មកពិនិត្យមើលទំនោរជារួមនៃទស្សនៈយល់ឃើញដែល បានតំរៀបដាក់នៅលើផ្ទាំងក្រដាសធំ។

ពិភាក្សាជាមួយសិក្ខាកាមអំពីការបិទលើផ្ទាំងក្រដាសថាតើវាឆ្លុះបញ្ចាំងអំពីទស្សនៈ និង ជំនឿអ្វីខ្លះ ហើយមកពីហេតុអ្វី?

៦- លើកយកការប្រព្រឹត្ត២ រឺ៣ មកពិភាក្សា ផ្លាស់ប្តូរគំនិត និង សួរអំពីហេតុផលរបស់សិក្ខាកាម សំរាប់ការអាចទទួលយកបាន ឬ មិនអាចទទួលយកបាន នូវការប្រព្រឹត្តនិមួយៗនោះ។

៧- សួរសិក្ខាកាមៈ

ក- ថាតើការប្រព្រឹត្តដែលរើសយកមកនេះ គឺជាការប្រព្រឹត្តដែលអាចកើតមានឡើងជារឿយៗដែរឬទេ?

ខ- តើអ្នកផ្តល់ប្រឹក្សានឹងជួបជាមួយអ្នកដែលមានការប្រព្រឹត្តបែបនេះរឺទេ?

គ- បើអ្នកជួបជាមួយអតិថិជនដែលប្រព្រឹត្តបែបនេះ តើអ្នកនឹងមានអារម្មណ៍ដូចម្តេច?

ឃ- ប្រសិនបើបុគ្គលនោះ នៅតែបន្តការប្រព្រឹត្តបែបនេះ តើអ្នក នឹងមានអារម្មណ៍យ៉ាងណា?

៨- សង្ខេបសកម្មភាពស្តីពីការវិនិច្ឆ័យលើការប្រព្រឹត្ត និង ពីផលប៉ះពាល់ដែលអាចកើតឡើង។

**សកម្មភាព ទី៥ ឯកសារចែកលេខ១**

## តើអ្នកគិតដូចម្តេចចំពោះគេ?

☐ ប្រុស ☐ ស្រី

| ល រ | ***ការប្រព្រឹត្ត/តរិយាបថផ្លូវភេទ*** | ទទួលបាន 0 | មិនទទួលបាន -១ | មិនទទួលបាន -៣ | មិនទទួលបាន –៥ |
|---|---|---|---|---|---|
| ១ | **លោក វាសនា** នៅលីវ ។ ជាញឹកញយ គាត់ទៅផ្ទះបន ហើយ រួមរ័ក្សជាមួយស្រីរកស៊ីផ្លូវភេទ ។ | | | | |
| ២ | **ស្រីលក្ខណ៍** ជាស្រីឡង់សេស្រាបៀរ ។ នាងរួមរ័ក្ស ជាមួយ អតិថិជន ដើម្បីរកប្រាក់អោយបានច្រើន ។ | | | | |
| ៣ | លោក **វិចិត្រ** មានមិត្តស្រីជាច្រើន ។ គាត់រួមរ័ក្សជាមួយពួកគេ គ្រប់ៗគ្នា ។ | | | | |
| ៤ | លោក **ចំណាន** មានប្រពន្ធពីរនាក់ ។ គាត់មិនបានប្រាប់ប្រពន្ធ ដើមរបស់គាត់ ពីប្រពន្ធទីពីរគាត់ឡើយ ។ | | | | |
| ៥ | **កានីកា** រៀបការជាមួយវេជ្ជបណ្ឌិតម្នាក់ ។ នាងក៏ដេកដោយលួច លាក់ជាមួយមិត្តប្រុសរបស់នាង ដែលជាគ្រូបង្រៀន ដែរ ។ | | | | |
| ៦ | **និស្ស័យ** ជាបុរសរួមរ័ក្សជាមួយប្រុសដូចគ្នា ។ គាត់រស់នៅជា មួយបុរស ដែលគាត់រួមរ័ក្សជាមួយ ។ | | | | |
| ៧ | **កល្យាណ** ជានិស្សិត នៅសាលាគរុកោសល្យ ។ នាង រួមរ័ក្ស ដោយលួចលាក់ជាមួយបុរសអ្នកមានម្នាក់ ដែលរៀបការហើយ ។ នាងមិនស្រលាញ់បុរសនោះទេ ។ | | | | |
| ៨ | **ថាត** រៀបការហើយ ។ គាត់ដើរលេងផឹកស្រាបៀរ ជាមួយមិត្ត ភក្ត្រ ។ គាត់ដេកជាមួយស្រីឡង់សេស្រាបៀរ នៅពេលគាត់ស្រវឹង | | | | |
| ៩ | **ផានី** ជាស្ត្រីម្នាក់ដែលរួមរ័ក្សជាមួយអ្នកមានភេទដូចគ្នា ។ នាង រស់នៅជាមួយនឹងស្រី ដែលនាងរួមរ័ក្សជាមួយ ។ | | | | |
| ១០ | **ស្រទុំ** មានមិត្តប្រុសពីរនាក់ ។ នាងរួមរ័ក្ស ជាមួយមិត្ត ប្រុសទាំងពីរនាក់នោះ ។ | | | | |

| | | | | | |
|---|---|---|---|---|---|
| ១១ | **សក្កា** មានទំនាក់ទំនងជាមួយនឹងប្រពន្ធរបស់គេ ។ គាត់ក៏ធ្លាប់រួមរ័ក្សជាមួយនាងនោះដែរ ។ | | | | |
| ១២ | **ប្រានីត** ជានិស្សិត នៅពេលថ្ងៃ ។ នាង ធ្វើជាស្រី រកស៊ីផ្លូវភេទ លួចលាក់ ។ | | | | |
| ១៣ | **លោកស៊ីថា** នៅលីវ ។ គាត់មានផ្ទុកមេរោគអេដស៍ ។ | | | | |
| ១៤ | **ចិន្តា** ជាស្ត្រីរកស៊ីផ្លូវភេទ ។ នាងមានផ្ទុកមេរោគអេដស៍ ។ | | | | |
| ១៥ | លោក**សុខ** រៀបការហើយ ។ គាត់មានផ្ទុកមេរោគអេដស៍ ។ គាត់មិនបានប្រាប់ប្រពន្ធគាត់ពីស្ថានភាពផ្ទុកមេរោគអេដស៍ឡើយ, ប៉ុន្តែ ជានិច្ចកាល គាត់ប្រើស្រោម នៅពេលរួមរក្សជាមួយប្រពន្ធគាត់ ។ | | | | |
| ១៦ | **នាងរឿន** មានផ្ទុកមេរោគអេដស៍ ។ នាងត្រូវបានគេចាប់រំលោភ ។ នាងស្រលាញ់មិត្តប្រុសរបស់នាង ហើយចង់រៀបការជាមួយគាត់ ។ ប៉ុន្តែ នាងមិនចង់ប្រាប់គាត់ពីរឿងសម្ងាត់របស់ នាងឡើយ ។ | | | | |

# សកម្មភាព ទី៦

## គោលការណ៍នៃការផ្តល់ប្រឹក្សា

## ”ការរក្សាការសម្ងាត់ ”

## ”ស្រោមសំបុត្រសម្ងាត់”

# សកម្មភាព ទី៦
## ការរក្សាការសម្ងាត់

ការរក្សាការសម្ងាត់ គឺជាសីលធម៌វិជ្ជាជីវៈ ឬ ផ្នែកមួយនៃច្បាប់សំរាប់វិជ្ជាជីវៈជាច្រើន។ ទាំងនេះ រួមមានវិជ្ជាជីវៈផ្នែកវេជ្ជសាស្ត្រ ឬ វិជ្ជាជីវៈដែលផ្តល់ជំនួយផ្សេងទៀត ដូចជា អ្នកផ្តល់ប្រឹក្សា ជាដើម។ ពត៌មានស្តីពីអតិថិជន មិនអាចផ្តល់ ឬធ្វើអោយលេចលឺដល់អ្នកផ្សេងទៀត ទោះជាដោយអចេតនាក្តី រឺ ដោយចេតនាក្តី ដោយគ្មានការអនុញ្ញាតជាក់លាក់ពីអតិថិជន។

នៅក្នុងសង្គមខ្លះៗ ការទទួលយកនិងការយល់ដឹង ស្តីពីអ្នកដែលបានឆ្លងមេរោគអេដស៍នៅមានកំរិត។ មនុស្ស ជាច្រើន នៅតែបារម្ភ មានទស្សនៈបន្ទោសគេ ហើយភ័យខ្លាចជ្រុលពីការចំលងមេរោគអេដស៍។ ស្ថានភាពនេះ បានបង្កអោយមាន ផលវិបាកទៅលើជីវិតរស់នៅរបស់អ្នកផ្ទុកមេរោគអេដស៍។ ដូច្នេះ ការផ្តល់ប្រឹក្សាមុន និងក្រោយការធ្វើតេស្តឈាម និងការរក្សាការសម្ងាត់ចំពោះ លទ្ធផលតេស្ត មានសារៈសំខាន់ណាស់ សំរាប់អ្នកដែលបានធ្វើតេស្តឈាម។ ប្រសិនបើសេវា VCCT មិនបាន រក្សាការសម្ងាត់ របស់អតិថិជនទេនោះ វានឹងធ្វើអោយខូចឈ្មោះមណ្ឌល VCCT ជាមិន ខាន។

**<u>គោលបំណង:</u>**

១- ធ្វើត្រាប់នូវស្ថានភាព និងអារម្មណ៍ នៅពេលដែលអ្នកណាម្នាក់ ត្រូវនិយាយពីរឿងសម្ងាត់របស់ខ្លួនគេទៅអ្នក ដទៃ។
២- ដើម្បីអោយសិក្ខាកាមបានយល់ពីសារៈសំខាន់ និងភាពចាំបាច់ ដែលអ្នកផ្តល់ប្រឹក្សាត្រូវរក្សាការសម្ងាត់។

**<u>សំភារ:</u>**

១- ក្រដាសតូចៗ សំរាប់សិក្ខាកាមម្នាក់ៗ ដើម្បីអោយគេសរសេរពីការសម្ងាត់របស់គេ។
២- ស្រោមសំបុត្រសំរាប់សិក្ខាកាមម្នាក់ៗ។
៣- ប្រអប់សំរាប់ដាក់ស្រោមសំបុត្រទាំងអស់។
៤- ផ្ទាំងបញ្ចាំងបង្ហាញលេខ ១

**<u>ការណែនាំដល់អ្នកសំរបសំរួល:</u>**

- ព្យាយាមលើកទឹកចិត្តអោយសិក្ខាកាមសរសេរពីការសម្ងាត់មែនទែនរបស់គេ។
- អ្នកសំរបសំរួល គួរធ្វើហាក់ដូចជាអ្នកមិនគោរពសិទ្ធិរបស់បុគ្គលៗ ហើយមិនទទួលស្គាល់ពីការរក្សាការសម្ងាត់។
- លំហាត់នេះអាចបណ្តាលអោយមានភាពតានតឹងនិងប្រកែកគ្នា។ អ្នកសំរបសំរួល គួរតែព្យាយាមសំគាល់ពីអារម្មណ៍ និងការរំជួលចិត្តនានារបស់សិក្ខាកាម ហើយលើកវាឡើង នៅពេលបន្ទាប់មកទៀត ជាឧទាហរណ៍នៃអារម្មណ៍របស់អតិថិជន ដែលការសម្ងាត់របស់គាត់ ស្ទើរតែត្រូវបានបញ្ចេញអោយគេដឹង ឬក៏ត្រូវបានបញ្ចេញអោយគេដឹងរួចហើយ។

- ពេលចប់លំហាត់ អ្នកសំរបសំរួលគួរពន្យល់ប្រាប់ និងសុំទោសចំពោះសិក្ខាកាម ដែលត្រូវធ្វើតាមមេរៀន។

**ដំណើរការ:**

១- អ្នកសំរបសំរួលនិយាយពីសកម្មភាព "តើអ្នកគិតយ៉ាងដូចម្តេចចំពោះគេ?"សួរសិក្ខាកាមពីការប្រព្រឹត្តមួយចំនួន ដែលមិនអាចទទួលយកបាន។

២- ចង្អុលប្រាប់សិក្ខាកាមថា ការប្រព្រឹត្តភាគច្រើននៅក្នុងលំហាត់មុន គឺជាការប្រព្រឹត្តខាងផ្លូវភេទ ដែលជារឿងផ្ទាល់ខ្លួន។ ការប្រព្រឹត្តទាំងនេះ ភាគច្រើនជាការសម្ងាត់របស់បុគ្គល។ ក្រៅពីការប្រព្រឹត្តខាងផ្លូវភេទនេះមានរឿងជាច្រើននៅក្នុងជីវិតដែលយើងបានធ្វើ ហើយដែលអ្នកដទៃទៀតមិនដឹង ឬ មានតែមនុស្សតិច តួចដែល ដឹងពីរឿងនោះ។ ដោយសារហេតុផលនានា មានរឿងជាច្រើនដែលយើងមិនចង់អោយអ្នកដទៃទៀតដឹង។ ពីព្រោះបើអ្នកដ៏ទៃទៀតដឹងពីវា ពួកគេអាចមិនយល់ស្រប គេអាចមិនចូលចិត្តយើង ឬក៏វាអាចជះឥទ្ធិពលលើជីវិតរបស់យើង ឬជីវិតរបស់អ្នកដែលជិតស្និតនឹងយើង។

៣- សូមអោយសិក្ខាកាមម្នាក់ៗ សរសេរពីការសម្ងាត់ដែលគេលាក់បំផុតមួយ នៅលើក្រដាស។

៤- ដោយមិនបាច់ដាក់ឈ្មោះរបស់គេ នៅលើក្រដាសនោះ សិក្ខាកាមដាក់ក្រដាសការសម្ងាត់របស់គេក្នុងស្រោមសំបុត្របិទអោយជិត ហើយហុចមកអោយអ្នកសំរបសំរួល។

៥- អ្នកសំរបសំរួល ដាក់ស្រោមសំបុត្រសម្ងាត់ទាំងអស់ ចូលទៅក្នុងប្រអប់មួយ។

៦- អ្នកសំរបសំរួល សួរថាតើ ការសម្ងាត់នោះ ពិតជារឿងសម្ងាត់មែនឬ ហើយតើវាសំខាន់យ៉ាងណាចំពោះសិក្ខាកាម។

៧- ដោយមិនសុំការអនុញ្ញាត អ្នកសំរបសំរួល ធ្វើដូចជាចង់បើកស្រោមសំបុត្រ ហើយ អានមួយម្តងៗ ហើយសង្កេតមើលប្រតិកម្មរបស់សិក្ខាកាម។ ប្រសិនបើសិក្ខាកាម ប្រឆាំងនឹងការបើកស្រោមសំបុត្រនោះ អ្នកសំរបសំរួលអះអាងតបវិញថា មិនមានឈ្មោះនៅលើស្រោមសំបុត្រឡើយ ដូច្នេះ គេមិនដឹងថា តើស្រោមមួយណាជារបស់ អ្នកណាឡើយ។

៨- សួរសិក្ខាកាមទាំងអស់ ថាតើគេយល់ព្រមអោយបើកស្រោមសំបុត្រទាំងអស់ ឬក៏អត់។ ប្រសិនបើមានការស្ទាក់ស្ទើរ ឬ ការជំទាស់ ត្រូវសួរពីមូលហេតុ អារម្មណ៏ និងពិភាក្សាពីអ្វីដែលអាចកើតឡើងនៅពេលដែលការសម្ងាត់ របស់បុគ្គលត្រូវបំបែកអោយគេដឹង?

៩- អ្នកសំរបសំរួលអាចជំរុញការពិភាក្សាបន្ថែមទៀត ដោយសួរសិក្ខាកាមថាតើ គេធ្លាប់បានប្រាប់ការសម្ងាត់របស់គេទៅអ្នក ដទៃទៀតដែរឬក៏អត់? ហេតុអ្វីបានជាយើងប្រាប់រឿងសម្ងាត់របស់យើង ទៅមនុស្សរូបនោះ?

តើយើងនឹងមានអារម្មណ៏យ៉ាងណា បើអ្នកនោះ និយាយប្រាប់រឿងសម្ងាត់របស់យើង ទៅអ្នកដទៃទៀត?

តើមានករណីដែលអ្នកណាម្នាក់ មិនដែលនិយាយប្រាប់ការសម្ងាត់របស់ខ្លួន ទៅអ្នកដទៃទៀតសោះ មកពីហេតុអ្វី?

១០-	អ្នកសំរបសំរួលអាចបញ្ចប់មេរៀននេះ ដោយប្រើផ្ទាំងបញ្ចាំងលេខ១ ដែលពន្យល់ថា អតិថិជន ក៏ថ្លឹងថ្លែងមើលថា តើគាត់ គួរប្រាប់អ្នកផ្តល់ប្រឹក្សា ពីរឿងផ្ទាល់ខ្លួនរបស់គាត់ ឬក៏អត់? អតិថិជន ក៏ថ្លឹងថ្លែងមើលផងដែរ ថាតើអ្នកផ្តល់ប្រឹក្សា នឹងបញ្ចេញប្រតិកម្មតបវិញយ៉ាងណា ចំពោះរឿងរបស់គេនោះ? តើអ្នកផ្តល់ប្រឹក្សា នឹងនិយាយរឿងនោះប្រាប់ដល់ អ្នកផ្សេងទៀត ដែរឬក៏អត់?

ដូច្នេះនៅពេលចាប់ផ្តើមការផ្តល់ប្រឹក្សា អ្នកផ្តល់ប្រឹក្សាគួរតែប្រាប់អតិថិជនថា អ្វីដែលបានពិភាក្សាគ្នា និងលទ្ធផលតេស្តឈាម នឹងត្រូវរក្សាជាការសម្ងាត់។

១១-	កុំភ្លេចហែកចោលស្រោមសំបុត្រសម្ងាត់ទាំងអស់ នៅចុងបញ្ចប់នៃមេរៀននេះ។

ផ្ទាំងបញ្ចាំងលេខ ១ (សកម្មភាពទី៦)



# សកម្មភាព ទី៧

# គោលការណ៍នៃការផ្ដល់ប្រឹក្សា

ការផ្ដោតទៅលើអតិថិជន

ការបង្ហាប់ និងការផ្ដល់ពត៌មាន

*“ សូមអ្នក ជួយប្រាប់ខ្ញុំផង? ”*

## សកម្មភាព ទី៧

## *"សូមអ្នក ជួយប្រាប់ខ្ញុំផង?"*

អ្នកផ្តល់ប្រឹក្សា មិនមែនជាអ្នកធ្វើការសំរេចចិត្តលើបញ្ហាដែលអតិថិជនកំពុងតែជួបប្រទះនោះឡើយ។ ប្រសិនបើ អ្នកផ្តល់ប្រឹក្សាចាប់ ផ្តើមនិយាយប្រាប់អតិថិជនថា គាត់គួរធ្វើនេះ ធ្វើនោះ បានន័យថាអ្នកផ្តល់ប្រឹក្សាកំពុងតែគិត និងសំរេចចិត្ត ជំនួសអតិថិជន។ គោលបំណងសំខាន់នៃដំណើរការផ្តល់ប្រឹក្សា គឺដើម្បីជួយអោយអតិថិជនយល់ពីបញ្ហារបស់គេ ពិភាក្សាជាមួយអតិថិជន ដើម្បី ពិនិត្យរកជំរើសនានាដែលគាត់អាចធ្វើបាន គុណប្រយោជន៍ និងគុណវិបត្តិនៃជំរើសនិមួយៗ ដើម្បីបង្កើន លទ្ធភាពរបស់អតិថិជន ក្នុងការជ្រើសរើសយកជំរើសល្អបំផុតដោយខ្លួនគេផ្ទាល់។ បែបនេះហៅថា ការផ្តល់ប្រឹក្សាដែល **"ផ្តោតលើអតិថិជន"**។

ដើម្បីដំណើរការការផ្តល់ប្រឹក្សាពីមេរោគអេដស៍អោយមានប្រសិទ្ធិភាព វាជាការមួយសំខាន់ដែលអ្នកផ្តល់ប្រឹក្សាត្រូវយល់ច្បាស់អំពី **ភាពខុសគ្នារវាងការបង្គាប់ និង ការផ្តល់ពតិមាន**។

ទោះបីជាអ្នកផ្តល់ប្រឹក្សាប្រកបដោយបទពិសោធន៍ក៏ដោយ ក៏នៅតែចង់បង្គាប់ដែរ ជាពិសេសនៅពេលដែលអតិថិជនមានទុក្ខព្រួយខ្លាំង។ នៅក្នុងករណីនៃការផ្តល់ប្រឹក្សាពីមេរោគអេដស៍ ការបង្គាប់ មិនមានប្រយោជន៍ទេ ពីព្រោះការប្រព្រឹត្តពាក់ព័ន្ធនានាមានការលំបាកនឹងផ្លាស់ប្តូរ ហើយអតិថិជន និងអ្នកផ្តល់ប្រឹក្សា មានការអោយតំលៃខុសៗគ្នាលើការ ប្រព្រឹត្តទាំងនេះ។ ប្រសិនបើអតិថិជនគិតថា អ្នកផ្តល់ប្រឹក្សាកំពុងតែវិនិច្ឆ័យលើការប្រព្រឹត្តរបស់ គេនោះ គេអាចស្ទាក់ស្ទើរ នឹងប្រាប់រឿងរ៉ាវបន្ថែមទៀត ហើយអ្នកផ្តល់ប្រឹក្សានឹងមិនមាន ឱកាសជួយអតិថិជនបានឡើយ។

### <u>គោលបំណង:</u>

១- ដើម្បីជួយសិក្ខាកាមអោយយល់ថាតួនាទីនៃការផ្តល់ប្រឹក្សា គឺមិនមែនធ្វើការសំរេចចិត្តជួសអោយអតិថិជន ទេ។ ជាពិសេសការសំរេចចិត្ត លើបញ្ហាសំខាន់ៗ ទោះបីជានៅពេលត្រូវបានស្នើសុំ រឺមានការទទូចពីអតិថិ ជនក៏ដោយ។

២- ដើម្បីបង្ហាញអោយឃើញថា ការផ្តល់ប្រឹក្សា គឺជាដំណើរការដែលជួយអតិថិជន អោយរកនូវជំរើសនានាសំរាប់បញ្ហាគេ ហើយអោយគេអាចធ្វើការសំរេចចិត្តដោយខ្លួនគេផ្ទាល់។

### <u>វិធីសាស្ត្រ:</u>

ប្រើករណីសិក្សា សំរាប់ការពិភាក្សា និងការផ្លាស់ប្តូរគំនិតគ្នា។

## សំភារៈ

ករណីសិក្សា

## ដំណើរការៈ

១- ចែកករណីសិក្សាអោយសិក្ខាកាមម្នាក់ៗ។

២- អោយសិក្ខាកាមសរសេរបំពេញកន្លែងចន្លោះទទេ ហើយអោយផ្តល់ហេតុផលលើចំលើយរបស់គេ។

៣. នឹងមានចំលើយបីៈ

ក. គាំទ្រអតិថិជន អោយយក/មានកូន

ខ. មិនគាំទ្រអតិថិជន អោយយក/មានកូន។

គ. គ្មានចំលើយ អាស្រ័យលើការសំរេចចិត្តរបស់អតិថិជន

៤. អោយសិក្ខាកាម ដែលមានចំលើយប្រហាក់ប្រហែលគ្នា មកចូលក្រុមជាមួយគ្នា និងពិភាក្សាគ្នាពីចំលើយរបស់គេ ហើយសង្ខេបពីទស្សនៈយល់ឃើញរបស់ក្រុមដើម្បីចែករំលែកជាមួយនឹងថ្នាក់ទាំងមូល។ ក្រុមនិមួយៗ អាចប្រើ ផ្ទាំងបញ្ចាំង ឬក្រដាសធំ ដើម្បីបង្ហាញពីលទ្ធផលពិភាក្សារបស់ខ្លួន។

៥. អោយក្រុមនិមួយៗបង្ហាញពីចំលើយនិងហេតុផលរបស់គេ ចំពោះក្រុមធំ (ថ្នាក់ទាំងមូល)។

៦. ចំណុចដែលអ្នកសំរបសំរួល គួរពិភាក្សាបន្ថែមទៀត បន្ទាប់ពីក្រុមនិមួយៗ បង្ហាញចំលើយរបស់គេរួច គឺៈ

ក. តើអ្នកនឹងគិតយ៉ាងណា បើអតិថិជន មិនធ្វើតាមអ្វីដែលអ្នកបានណែនាំអោយគេធ្វើនោះ?

ខ.តើអ្នកនឹងទទួលខុសត្រូវដូចម្តេចលើអ្វីដែលអាចកើតឡើងពីលទ្ធផលនៃការណែនាំដែល អ្នកអោយទៅស្ត្រីនោះ?

គ. ចំលើយដែលបានផ្តល់អោយនិមួយៗ គឺផ្អែកទៅលើផលប្រយោជន៍របស់អ្នកណា?

៧. បញ្ចប់មេរៀនដោយបញ្ជាក់ថា តួនាទីរបស់អ្នកផ្តល់ប្រឹក្សា គឺដើម្បីជួយអតិថិជនអោយគិត ហើយអាចធ្វើការសំរេចចិត្ត ដោយខ្លួនគេផ្ទាល់។ ត្រូវប្រុងប្រយ័ត្ន នៅពេលផ្តល់ពតិមាន កុំអោយក្លាយទៅជា ការបង្គាប់។ កុំបញ្ចុះបញ្ចូលអតិថិជនអោយធ្វើអ្វី ដែលអ្នកផ្តល់ប្រឹក្សាចង់បាន។

## ចំណុចសំខាន់ៗៈ

គោលការណ៍សំខាន់នៃការផ្តល់ប្រឹក្សា គឺមិនមែនជាការតំរង់ទិស/ការណែនាំ ការប្រាប់អោយអតិថិជនធ្វើអ្វីមួយ ឬ ធ្វើការសំរេចចិត្តអោយអតិថិជនឡើយ ព្រោះវាអាចមានផលវិបាកជាប់ពាក់ពន្ធ័ជាច្រើននៃការសំរេចចិត្តអោយបែបនេះ។ វាអាចសម

ស្រប ឬ មិនសមស្របសំរាប់អតិថិជន។ តើអ្នកផ្តល់ប្រឹក្សានឹងទទួលខុសត្រូវយ៉ាងណាខ្លះចំពោះផលវិបាកទាំងនោះ បើអតិថិជននិយាយថា “ខ្ញុំធ្វើបែបនេះ ដោយសារតែអ្នកប្រាប់ខ្ញុំអោយធ្វើ ”។

តាមរយៈសកម្មភាពមេរៀននេះ សិក្ខាកាមនឹងយល់ថា ជាទូទៅ មនុស្សយើងចូលចិត្តផ្តល់ការបង្គាប់ ដល់អ្នកដទៃស្តីពី អ្វីដែលគេគួរធ្វើ។ ការធ្វើបែបនេះ មិនបានជួយដល់ម្ចាស់បញ្ហា អោយគេអាចដោះស្រាយបញ្ហា ដោយខ្លួនគេផ្ទាល់ឡើយ។ ដើម្បីជួយអោយ អតិថិជន គិតបានប្រសើរឡើង អ្នកផ្តល់ប្រឹក្សា ត្រូវលើកទឹកចិត្តអោយអតិថិជនគិត និងពិនិត្យមើលអោយបានច្រើនគ្រប់ជ្រុងជ្រោយ ជួយគេអោយមើលឃើញថា អាចមានជំរើសជាច្រើន។ ការផ្តល់ប្រឹក្សាល្អ ជួយបង្កើន សមត្ថភាពអតិថិជនអោយយល់ពីបញ្ហារបស់គេ ចេះគិត និងធ្វើការសំរេចចិត្ត ហើយរៀបចំខ្លួនគេដើម្បីប្រឈមមុខ និងទប់ទល់ជាមួយអ្វីដែលនឹងអាចកើតមានឡើង។

ឧទាហរណ៍ សំណួរ និង ពត៌មាន ដែលនឹងជួយអតិថិជនអោយគិតពីបញ្ហា និង ជំរើសនានា គឺៈ

១- លទ្ធភាពនៃការចំលងមេរោគអេដស៍ពីម្តាយទៅកូន (ផ្តល់ពត៌មាន)។

២- កម្មវិធីបង្ការការចំលងមេរោគអេដស៍ពីម្តាយទៅកូន មាននៅតាមមន្ទីរពេទ្យមួយចំនួន។

៣- ផែនការសំរាប់អនាគត? អោយអតិថិជនគិត។

៤- ក្រុមគ្រួសារ សាច់ញាតិ អ្នកដែលអាចជួយ រីគាំទ្រ? អោយអតិថិជនគិត។

៥- អ្វីអាចនឹងកើតឡើង ប្រសិនបើអតិថិជនមានកូន? អោយអតិថិជនគិត។

៦- ពត៌មាន ឬសំណួរដែលពាក់ពន្ធ័ផ្សេងទៀត។

**សកម្មភាពទី ៧ ឯកសារចែកលេខ ១**

***"សូមអ្នក ជួយប្រាប់ខ្ញុំផង?"***

ខ្ញុំឈ្មោះស្រីមុំ ជាស្រីរកស៊ីផ្លូវភេទ។ ខ្ញុំរកចំណូលបានប្រមាណជា ៣០ដុល្លា ក្នុងមួយខែ។ ខ្ញុំមានសង្សារម្នាក់។ គាត់ពេលខ្លះ ធ្វើការជាកម្មករសំណង់ គាត់រកប្រាក់បានតិចតួច។ យើងទាំងពីរនាក់រស់នៅជាមួយគ្នាពីរឆ្នាំមកហើយ។ ខ្ញុំពិតជាស្រលាញ់ គាត់ ហើយចង់រួមរស់ជាគ្រួសារជាមួយគាត់។ យើងនៅត្រឡោកបែក ជិតក្រុងភ្នំពេញ។

ថ្ងៃនេះខ្ញុំមកសេវាផ្តល់ប្រឹក្សា និងធ្វើតេស្តឈាមរកមេរោគអេដស៍ដោយស្ម័គ្រចិត្តនិងរក្សាការសំងាត់(VCCT)។ ខ្ញុំបានទទួលការផ្តល់ប្រឹក្សានិងធ្វើតេស្តឈាមរកមើលមេរោគអេដស៍។ លទ្ធផលតេស្តឈាមចេញមកវិជ្ជមាន។ ខ្ញុំមានផ្ទុកមេរោគអេដស៍។ ខ្ញុំមិន ដឹងថាតើសង្សាររបស់ខ្ញុំមានមេរោគអេដស៍ ឬក៏អត់ទេ? ខ្ញុំចង់មានកូន។ ខ្ញុំគិតថាបើសិនខ្ញុំមានកូននោះវានឹងធ្វើ អោយខ្ញុំសប្បាយចិត្តណាស់។ វានឹងជួយអោយទំនាក់ទំនងជាមួយសង្សាររបស់ខ្ញុំកាន់តែរឹងមាំឡើង។ នេះនឹងបង្ហាញដល់ គាត់ថា ខ្ញុំពិតជាស្រលាញ់ហើយប្តូរផ្តាច់ចំពោះគាត់។ ខ្ញុំចង់សួរអ្នកថាៈ

**<u>តើខ្ញុំគួរតែមានកូន ដែរឬទេ?</u>**

**ចំលើយៈ** ______________________________________________

**ហេតុផលៈ** ______________________________________________

______________________________________________________
______________________________________________________
______________________________________________________
______________________________________________________
______________________________________________________
______________________________________________________
______________________________________________________

សកម្មភាព ទី៧ ផ្ទាំងបញ្ចាំងលេខ ១

## ឧទាហរណ៍នៃលទ្ធផលចេញពីសកម្មភាព “សូមអ្នកជួយប្រាប់ខ្ញុំផង?”

មានហេតុផលបីប្រភេទ គឺៈ

ក.
គាំទ្រដល់អតិថិជន
អោយមានកូន

ហេតុផលៈ

- ប្រសិនបើអតិថិជនបានត្រៀមលក្ខណៈនឹងមានកូន នោះនាងគួរតែមាន
- គិតថា បើអតិថិជនមានកូន នាងនឹងសប្បាយចិត្តជាងមុន ហើយទំនាក់ទំនងជាមួយសង្សារនាង អាចនឹងកាន់តែរឹងមាំឡើង ។

ខ.
មិនគាំទ្រអោយ
អតិថិជន មានកូន

ហេតុផលៈ

- ប្តីក៏អាចមានផ្ទុកមេរោគអេដស៍ដែរ ហើយបើសិនជានាងមានកូន នោះកូននាងក៏អាចឆ្លងដែរ ។
- ប្រសិនបើឪពុកម្តាយរបស់កូននោះស្លាប់ទៅ តើបានអ្នកណានឹងមើលថែរក្សាកូននោះ?
- ប្តីរបស់នាង មិនមានការងារជាប់លាប់ ហើយមិនអាចរកចំណូលបានទៀងទាត់ជាប្រចាំឡើយ ។

គ.
ទុកអោយអតិថិជន
សំរេចចិត្ត

ហេតុផលៈ

- អតិថិជន ត្រូវសំរេចចិត្តពីរឿងនេះដោយខ្លួនឯងផ្ទាល់ ។
- លើកទឹកចិត្ត និងជំរុញអោយអតិថិជន គិតពីទិដ្ឋភាពនានាជាច្រើននៃការមានកូន នៅពេលខ្លួនមានផ្ទុកមេរោគអេដស៍ ហើយគិតពិចារណាលំអិតអំពីការមាន និង មិនមានកូន ។

# ការផ្តល់ប្រឹក្សា

ការផ្តល់ប្រឹក្សាគឺការជួយដល់អតិថិជនអោយៈ

- យល់ពីបញ្ហារបស់គេ
- មើលឃើញថាមានមធ្យោបាយផ្សេងៗដើម្បីទប់ទល់នឹងបញ្ហានោះ
- សំរេចចិត្តរើសយកមធ្យោបាយណាមួយ ដើម្បីទប់ទល់នឹងបញ្ហា ដោយខ្លួនគេផ្ទាល់

# សកម្មភាព ទី៨

# គោលការណ៍នៃការផ្តល់ប្រឹក្សា

ការមិនបង្គាប់

***“ ការដើរដោយទុកចិត្ត”***

# សកម្មភាព ទី៨

## ការមិនបង្គាប់

## *ការដើរដោយទុកចិត្ត*

ជាគោលការណ៍ យើងអាចដឹងថា តួនាទីរបស់អ្នកផ្តល់ប្រឹក្សា គឺមិនត្រូវបញ្ចុះបញ្ចូល ឬណែនាំអតិថិជន ក៏ប៉ុន្តែក្នុងបំណងល្អ អ្នកផ្តល់ប្រឹក្សា អាចផ្តល់ឱវាទ ឬការណែនាំដោយភ្លេចខ្លួន សំរាប់អោយអតិថិជនធ្វើតាម។ អ្នកផ្តល់ប្រឹក្សា គួរធ្វើការជាមួយនឹងអតិថិជន រហូតទាល់តែគេយល់ពីស្ថានភាពរបស់គេផ្ទាល់ ហើយអាចរើសយកជំរើសល្អបំផុតសំរាប់ខ្លួនគេផ្ទាល់។

### <u>គោលបំណង:</u>

ដើម្បីជួយសិក្ខាកាមយល់ពីសារៈសំខាន់នៃការមិនបង្គាប់ ឬ ការមិនសំរេចចិត្តជំនួសអតិថិជន ។

### <u>វិធីសាស្ត្រ:</u>

រើសសិក្ខាកាមប្រាំមួយនាក់ ហើយចែកជាបីគូ។ អោយគូនិមួយៗចេញក្រៅបន្ទប់។ ម្នាក់ក្នុងចំណោមគូនិមួយៗនឹងត្រូវគេចងបិទភ្នែក។ រៀបចំចាត់ចែងនៅក្នុងបន្ទប់ ដោយមិនអោយអ្នកនៅក្រៅបន្ទប់ដឹងពីអ្វីដែលបានរៀបចំចាត់ចែងទុកឡើយ។ សិក្ខាកាមផ្សេងទៀតនៅក្នុងបន្ទប់ នឹងសង្កេតលើសកម្មភាពនេះ។

### <u>សំភារៈ</u>

១- កន្សែងសំរាប់ចងបិទភ្នែកមនុស្សបីនាក់

២- ក្រដាសនៅលើកៅអីចំនួនបី

ក្នុងក្រដាសទីមួយ សរសេរថា: *បាយ និងត្រី*

ក្នុងក្រដាសទីពីរ សរសេរថា: *ទឹក និង ទឹកក្រូច*

ក្នុងក្រដាសទីបី សរសេរថា: *ស្រាបៀរ និង ស្រា*

៣. ដាក់កៅអីចំនួនបី អោយឋិតនៅផ្សេងឆ្ងាយដាច់ពីគ្នា។

## ដំណើរការៈ

១- អោយគូរនិមួយៗនៅក្រៅបន្ទប់ ប្រើកន្សែងដើម្បីចងបិទភ្នែកដៃគូម្នាក់។

២- កិច្ចការរបស់គូរនិមួយៗ គឺកាន់ដៃអ្នកចងបិទភ្នែក ហើយប្រាប់ណែនាំគេអោយដើរចូលក្នុងបន្ទប់ រួចជ្រើសរើសទៅអង្គុយលើកៅអីណាមួយ។ អ្នកសំរបសំរួលផ្តល់ការណែនាំដល់គូនិមួយៗ ម្តងមួយគូៗ។

៣- កិច្ចការរបស់អ្នកសង្កេតការណ៍ គឺសង្កេតពីរបៀបដែលបុគ្គលទាំងពីរនាក់ក្នុងគូនិមួយៗ ធ្វើការជាមួយគ្នា? ប្រភេទចំណើរអាហារខុសៗគ្នាដែលបានផ្តល់អោយគូនិមួយៗ គឺតំណាងអោយជំរើសដែលត្រូវរើសយក។

៤- បន្ទាប់ពីផ្តល់ពត៌មានទាំងអស់រួចហើយ អ្នកសំរបសំរួល ហៅគូនិមួយៗ ចូលមកក្នុងបន្ទប់ មួយគូម្តងៗ។

អ្នកសំរបសំរួល និងអ្នកដទៃទៀត ត្រូវសង្កេតលើចំណុច ដូចខាងក្រោមៈ

- តើបុគ្គលដែលមើលឃើញនាំដៃគូដែលបិទភ្នែកទៅអង្គុយលើកៅអីណា? តើការដើរប្រព្រឹត្តទៅមានលក្ខណៈបែបណា?
- តើអ្នកដែលបិទភ្នែក មានឥរិយាបថ យ៉ាងម៉េចខ្លះ? តើគាត់ គ្រាន់តែធ្វើតាមអ្នកដែលអាចមើលឃើញ តើមាន ការរឹងទទឹងមិនចង់ធ្វើតាមដែរឬទេ នៅពេលដើរ តើអ្នកត្រូវបិទភ្នែកដើរដោយមានទំនុកចិត្ត ឬក៏ដោយស្ទាក់ស្ទើរ? តើអ្នកដែលត្រូវបិទភ្នែក ដឹងពីកន្លែងដែលគេកំពុងតែទៅដែរឬទេ?
- តើមានការពិភាក្សាគ្នារវាងដៃគូក្នុងគូនិមួយៗដែរឬទេ?

៥- បន្ទាប់ពីបញ្ចប់ការដើររួច អ្នកសំរបសំរួល សួរគូនិមួយៗពីលំហាត់នេះ។

*សំរាប់អ្នកដឹកនាំ:* អ្វីទៅជាហេតុផលនៃការជួយ ឬការនាំដៃគូទៅកាន់កៅអីដែលបានជ្រើសរើស? តើគេបានពិភាក្សាពីរឿងនេះជាមួយនឹងដៃគូដែលមើលមិនឃើញ ដែរឬទេ? ហេតុអ្វីបានជាពិភាក្សា ឬ ហេតុអ្វីបានជាមិនពិភាក្សា? ?

*សំរាប់អ្នកត្រូវបិទភ្នែក:* តើគាត់ដឹងថាមានកៅអីទាំងអស់ប៉ុន្មានដែរទេ? តើកៅអីណាមួយដែលខ្លួនចង់? តើគាត់មានអារម្មណ៍យ៉ាងម៉េចចំពោះអ្នកដឹកនាំ និងពីរបៀបដែលគេដឹកនាំគាត់? តើគាត់បាននិយាយទៅកាន់អ្នកដឹកនាំដែរឬទេនៅពេលកំពុងត្រូវបានគេដឹកនាំនោះ?

៦- អ្នកសំរបសំរួលសួរអ្នកសង្កេតផ្សេងទៀត ពីអ្វីដែលគេមើលឃើញក្នុងលំហាត់នេះប្រៀបធៀបនឹងការផ្តល់ប្រឹក្សា។

**ចំណុចសំខាន់ៗ:**

១-  លំហាត់ស្ដីពី *ការដើរដោយទុកចិត្ត* មានលក្ខណៈស្រដៀងគ្នាទៅនឹងទំនាក់ទំនងរវាងអ្នកផ្ដល់ប្រឹក្សានិងអតិថិជន។ អ្នកត្រូវគេបិទភ្នែក គឺដូចជាអ្នកណាម្នាក់ដែលថិតនៅក្នុងស្ថានភាពលំបាកមួយ ហើយមិនអាចមើលឃើញអ្វីៗ (បញ្ហា) បានច្បាស់លាស់។

២- អ្នកដឹកនាំ ឬ អ្នកផ្ដល់ប្រឹក្សា ប្រហែលជាបានដឹកនាំដៃគូដែលបិទភ្នែក ទៅកាន់កៅអី ដែលគាត់គិតថាល្អបំផុត សំរាប់អតិថិជនឬក៏ការធ្វើការសំរេចចិត្តអោយអតិថិជន។ ហើយជាញឹកញយ អ្នកផ្ដល់ប្រឹក្សាមិនបានសួរពីគំនិតយោបល់ ឬ អារម្មណ៍ របស់អតិថិជន។

៣.  បញ្ហាដែលអាចកើតឡើងនោះគឺថា អតិថិជនអាចមិនយល់ស្របជាមួយការសំរេចចិត្ត វឺមិនបានគិតថានោះគឺជាអ្វីដែលគាត់ចង់បានបំផុត វឺអ្វីដែលសមស្របបំផុតសំរាប់គាត់។ ដូច្នេះហើយអតិថិជនគួរតែជាអ្នកដែលធ្វើការសំរេច ចិត្ត។

សរុបសេចក្ដីមក អ្នកផ្ដល់ប្រឹក្សាមិនគួរផ្ដល់ការណែនាំដល់អតិថិជនឡើយ ក៏ប៉ុន្តែ ត្រូវគាំទ្រ ឬបង្កើនលទ្ធភាពរបស់អតិថិជន ក្នុងការគិតនិងប្រឈមទប់ទល់ជាមួយនឹងបញ្ហារបស់គេ ដោយខ្លួនគេផ្ទាល់។

# សកម្មភាព ទី៩
# ជំនាញក្នុងការផ្តល់ប្រឹក្សា

## សកម្មភាព ទី៩

## ការបង្កើតជំនាញក្នុងការផ្តល់ប្រឹក្សា

ក្រៅពីគោលការណ៍សំខាន់ៗស្តីពីការផ្តល់ប្រឹក្សា ដែលយើងបានពិភាក្សានៅមេរៀនខាងដើម មានជំនាញមួយចំនួនទៀតដែលសិក្ខាកាមត្រូវបង្កើត ដើម្បីអោយក្លាយទៅជាអ្នកផ្តល់ប្រឹក្សាដ៏ល្អ។ ក្នុងអំឡុងពេលធ្វើការផ្តល់ប្រឹក្សាជាមួយអតិថិជនអ្នកផ្តល់ប្រឹក្សាត្រូវបញ្ចូលគ្នានូវគោលការណ៍និងជំនាញនានា ។

អ្នកផ្តល់ប្រឹក្សាល្អ ទាមទារអោយមានទាំងជំនាញផ្សេងៗ និងការទទួលយក ការគោរព និងជំនឿថា អតិថិជនអាចធ្វើការសំរេចចិត្តបានល្អសំរាប់ខ្លួនគេផ្ទាល់ និង មានចិត្តចង់ជួយអ្នកដ៏ទៃយ៉ាងពិតប្រាកដ។

ចំណុចគន្លឹះសំខាន់ៗ ដែលចាំបាច់សំរាប់ដំណើរការការផ្តល់ប្រឹក្សា មានបញ្ចូលក្នុងឈុតខ្សែវីដេអូ គឺ:

- ការមិនវិនិច្ឆ័យ
- ការរក្សាការសម្ងាត់
- ផ្តោតលើអតិថិជន
- ការយល់ចិត្ត ឬការផ្តល់ការយកចិត្តទុកដាក់ចំពោះអារម្មណ៍ និង ការរំជួលចិត្តរបស់អតិថិជន
- ការប្រាស្រ័យទាក់ទងល្អ រួមមាន ការស្តាប់ដោយយកចិត្តទុកដាក់ ការសួរបញ្ជាក់ និង ការធ្វើសង្ខេប
- ធ្វើការបញ្ជូនបន្តបានសមស្រប

**<u>គោលបំណង:</u>**

១- ដើម្បីជួយសិក្ខាកាមអោយមើលឃើញ និងយល់ពីចំណុចគន្លឹះជាមូលដ្ឋាននៃការផ្តល់ប្រឹក្សា

២- ដើម្បីបង្ហាញថា ជំនាញផ្តល់ប្រឹក្សាល្អ អាចនឹងកើតឡើងបាន ប្រសិនបើមានបំណងប្រាថ្នា

**<u>សំភារៈ</u>**

១- ទូរទស្សន៍ និង ក្បាលវីដេអូរ

២- ឈុតខ្សែវីដេអូ បង្ហាញ និងប្រៀបធៀបឆាកផ្តល់ប្រឹក្សាចំនួន ៦ ដែលនៅខ្វះខាត និង ឆាកចំនួន ៦ ដែលធ្វើបានល្អ។

៣- ចែកឯកសារអោយសិក្ខាកាម ដើម្បីសរសេរចូលពីការសង្កេតរបស់គេទៅលើឆាកនិមួយៗពីខ្សែវីដេអូ (៦ ឆាក ដែលនៅខ្វះខាត មិនទាន់ល្អគ្រប់គ្រាន់)

## ដំណើរការះ

១- ចែកឯកសារលេខ ១ អោយសិក្ខាកាម ដើម្បីអោយគេកត់ត្រាការសង្កេតរបស់គេ

២- ពន្យល់ដល់សិក្ខាកាមថា ឆាកនៃខ្សែវីដេអូដែលពួកគេនឹងមើលនោះ បង្ហាញអោយឃើញនូវប្រភេទនៃការសន្ទនាដែលបង្កើតលទ្ធផលផ្សេងៗគ្នាក្នុងអំឡុងពេលដំណើរការផ្តល់ប្រឹក្សា។ បង្ហាញឆាកខ្សែវីដេអូមួយម្តងៗ។ បន្ទាប់ពីមើលចប់ ឆាកនិមួយៗ ឈប់បន្តិច ហើយអោយសិក្ខាកាម សរសេរការសង្កេតឃើញ របស់គេ។

៣- នៅពេលមើលចប់ទាំង៦ឆាក ហើយសិក្ខាកាមបានសរសេរគំនិតយោបល់របស់គេរួចនោះ បញ្ចាំងឆាកវីដេអូទាំងអស់ឡើងវិញ ហើយពិភាក្សាលើគំនិតយោបល់ពីសិក្ខាកាមមួយឆាកម្តងៗ។

៤- បន្ទាប់ពីបញ្ចប់ការពិភាក្សាទៅលើការផ្តល់ប្រឹក្សាដែលមិនទាន់ល្អរួចមក បញ្ចាំងឆាកខ្សែវីដេអូដែលបង្ហាញពីការផ្តល់ប្រឹក្សាល្អ ហើយអោយសិក្ខាកាមប្រៀបធៀបគ្នាមើល ថាតើវាដូចគ្នា ឬក៏ខុសគ្នាពីឆាកបញ្ចាំងលើកមុនយ៉ាងដូចម្តេច?

៥- អ្នកសំរបសំរួល សង្ខេបពីចំណុចគន្លឹះ និង ជំនាញផ្តល់ប្រឹក្សាជាមូលដ្ឋាននានា ដកស្រង់ចេញពីខ្សែវីដេអូ និង ពីរបៀបដែលវាមានផលដល់ដំណើរការផ្តល់ប្រឹក្សាដូចម្តេច។ អ្នកសំរបសំរួលក៏អាចផ្តល់អោយនូវឧទាហរណ៍ ខ្លះផ្សេងទៀតពីបទពិសោធន៍ជាក់ស្តែង។

## គន្លឹះសំខាន់ៗនៃការផ្តល់ប្រឹក្សា

### ១-ការមិនវិនិច្ឆ័យ

នៅពេលដែលអ្នកផ្តល់ប្រឹក្សាធ្វើការវិនិច្ឆ័យស្តីពីទង្វើ ឬឥរិយាបថរបស់អតិថិជនផ្អែកលើជំនឿ គំនិត ឬអាកប្បកិរិយារបស់គាត់ផ្ទាល់នោះ អតិថិជន អាចមានអារម្មណ៍ថា អ្នកផ្តល់ប្រឹក្សា អាចមិនយល់ពីបញ្ហារបស់គាត់ ហើយគេអាចមិនច្បាស់ថាតើអ្នកផ្តល់ប្រឹក្សា មានបំណងចង់ស្តាប់ ឬជួយគេ ឬក៏អត់ទេ? អតិថិជន អាចមានអារម្មណ៍ ហាក់ដូចជាខ្លួនត្រូវបានគេស្តីបន្ទោស ឬក៏មិនទុកចិត្តអ្នកផ្តល់ប្រឹក្សា ហើយមិនចង់និយាយច្រើនឡើយ។ អ្នកផ្តល់ប្រឹក្សាត្រូវតែដឹងពីអារម្មណ៍ និង អាកប្បកិរិយា របស់ខ្លួន ហើយនៅពេលនោះដែរគឺត្រូវមានបំណងចង់ស្តាប់ និងយល់ពីទង្វើ និងឥរិយាបថ/ការប្រព្រឹត្តរបស់អ្នកដទៃ និង ការសំរេចចិត្តរបស់គេ។

## ២-ការរក្សាការសម្ងាត់

ដោយសារតែមានមនុស្សខ្លះនៅក្នុងសង្គមយើង ដែលមិនទាន់យល់ ឬទទួលអ្នកផ្ទុកមេរោគអេដស៍ និងអ្នកជម្ងឺអេដស៍ គឺនៅតែមានការមាក់ងាយនិងការរើសអើងដែលជះឥទ្ធិពលទៅលើជីវិតរស់នៅរបស់អ្នកផ្ទុកមេរោគអេដស៍អ្នកជម្ងឺអេដស៍។ ដូច្នេះការរក្សាការសម្ងាត់ស្តីពីមេរោគរាគអេដស៍គឺជាការសំខាន់ណាស់សំរាប់អតិថិជន។

ការសំរេចចិត្តសំរាប់អ្នកដែលមក VCCT ដើម្បីទទួលការផ្តល់ប្រឹក្សា និងធ្វើតេស្តឈាមរកមើលមេរោគអេដស៍គឺផ្អែក លើការទុកចិត្តថា អ្នកផ្តល់ប្រឹក្សាផ្នែក VCCT ជាអ្នកគួរអោយជឿទុកចិត្តបាន និងមានការយោគយល់ ហើយថា ពួកគេអាចនិយាយពី រឿងរ៉ាវឯកជនផ្ទាល់ខ្លួន និង បញ្ហាបុគ្គលផ្ទាល់ជាមួយនឹងអ្នកផ្តល់ប្រឹក្សាបាន។

## ៣-ការផ្តោតលើអតិថិជន

អតិថិជន គឺជាមនុស្សសំខាន់បំផុតនៅក្នុងដំណើរការផ្តល់ប្រឹក្សា។ ការផ្តល់ប្រឹក្សា គឺជាដំណើរការជួយអតិថិជនអោយយល់ពីបញ្ហារបស់គេ អោយមើលឃើញថាមានវិធី/មធ្យោបាយនានាដើម្បីប្រឈមទប់ទល់ជាមួយនឹងបញ្ហានោះ បង្កើតទំនុកចិត្ត និងលទ្ធភាពដើម្បីជ្រើសរើស ឬសំរេចចិត្តលើជំរើសល្អបំផុត ហើយជួយរៀបចំអតិថិជនអោយត្រៀមលក្ខណៈប្រុងប្រៀបនឹងអ្វីៗដែលអាចកើតមានឡើង។ ដូច្នេះគោលបំណងនៃការផ្តល់ប្រឹក្សា គឺមិនមែនជាការប្រាប់ ការផ្តល់ការណែនាំ ការបង្រៀន ឬធ្វើការសំរេចចិត្តជំនួសអោយអតិថិជនឡើយ។

## ៤-ការយល់ចិត្ត ឬ ការយកចិត្តទុកដាក់ចំពោះអារម្មណ៍របស់អតិថិជន

អតិថិជនភាគច្រើន មករកអ្នកផ្តល់ប្រឹក្សា នៅពេលដែលគេមានសំណួរ/ចំងល់ បញ្ហា ឬក៏ការតប់ប្រមល់ផ្លូវចិត្ត។ តួនាទីរបស់អ្នកផ្តល់ប្រឹក្សា គឺធ្វើអោយអតិថិជន មានអារម្មណ៍ធូរស្រាល ធ្វើអោយគាត់អាចបញ្ចេញនូវអារម្មណ៍របស់គេ និយាយរៀបរាប់ពីបញ្ហារបស់គេផ្ទាល់ និងបន្ថយភាពតានតឹងនានា ។ បើសិនជាអ្នកផ្តល់ប្រឹក្សាអាចបង្ហាញអោយឃើញថា គាត់យល់ពីអារម្មណ៍ និងស្ថានភាពរបស់អតិថិជន ទាំងតាមរយៈទឹកមុខ កាយវិការ និងពាក្យសំដី នោះអតិថិជន នឹងចែករំលែកនូវទុក្ខព្រួយ និងបញ្ហា របស់ខ្លួនគាត់ ហើយការផ្តល់ប្រឹក្សាអាចឈានទៅមុខ ដើម្បីដោះស្រាយបញ្ហានានា។

## ៥-ជំនាញការប្រាស្រ័យទាក់ទង

មានជំនាញចំបងៗមួយចំនួន ដែលទាក់ទងនឹងការប្រាស្រ័យទាក់ទងល្អ។ ទាំងនេះរួមមាន ការស្តាប់ដោយយកចិត្តទុកដាក់ ការសួរបញ្ជាក់ឡើងវិញ និងការធ្វើសង្ខេប។

ការស្តាប់ដោយយកចិត្តទុកដាក់ គឺជាជំនាញដ៏សំខាន់បំផុតមួយ។ អ្នកផ្តល់ប្រឹក្សាល្អ ត្រូវតែស្តាប់លឺ មិនត្រឹមតែពាក្យដែលគេបាននិយាយនោះឡើយ គឺត្រូវក្តាប់អោយបាននូវអត្ថន័យនិងអារម្មណ៍ផង។ ការយល់ដឹងអោយបានស៊ីជំរៅនៃបញ្ហា និងថាតើអតិថិជនមានអារម្មណ៍យ៉ាងម៉េចពីស្ថានភាពរបស់គេនោះ គឺមានសារៈសំខាន់ខ្លាំងណាស់។

ប្រសិនបើក្នុងអំឡុងពេលពិភាក្សាគ្នា រឿងរ៉ាវដែលអតិថិជននិយាយ នៅមិនទាន់ច្បាស់លាស់ ឬក៏អ្នកផ្តល់ប្រឹក្សា មិនសូវយល់ទេនោះ អ្នកផ្តល់ប្រឹក្សាត្រូវសួរបញ្ជាក់ពីរឿងរ៉ាវ ឬដំណើររឿងឡើងវិញ។ នៅពេលខ្លះ អតិថិជនអាចនិយាយពី រឿងរ៉ាវជាច្រើន ឬក៏មានបញ្ហាជាច្រើន អ្នកផ្តល់ប្រឹក្សាត្រូវពិនិត្យរកមើលថាតើមានបញ្ហាអ្វីខ្លះ បញ្ហាណាមួយដែលជាបញ្ហាចំបង ដែលត្រូវដោះស្រាយមុនគេ។ ហើយនៅចុងបញ្ចប់នៃការសន្ទនា អ្នកផ្តល់ប្រឹក្សាគួរ ធ្វើការសង្ខេបឡើងវិញពីអ្វីៗដែលបានពិភាក្សាគ្នា។

## ៦-ការបញ្ជូនបន្តដោយសមស្រប

បច្ចុប្បន្ននេះ មានសេវាសុខាភិបាលជាច្រើនទាក់ទងនឹងជំងឺអេដស៍ និងជម្ងឺកាមរោគទាំងនៅភ្នំពេញ និងនៅតាមបណ្តាខេត្ត អ្នកផ្តល់ប្រឹក្សាត្រូវស្វែងយល់អោយដឹងពតិមានច្បាស់លាស់ពីសេវាទាំងនោះ ដើម្បីបញ្ជូនអតិថិជនដែលមកធ្វើតេស្តឈាមរកមេរោគអេដស៍ទៅកាន់សេវាសមស្របនានា។ ការបញ្ជូនដ៏សមស្របនឹងមានប្រយោជន៍ ជួយដោះស្រាយបញ្ហាសំរាប់ អតិថិជនទាំងផ្នែកសុខភាព សង្គមនិងសេដ្ឋកិច្ច ។

# នាដកថាវីដេអូ

## ចំណុចគន្លឹះនៃការផ្តល់ប្រឹក្សា ដែលមានឥទ្ធិពលដល់ដំណើរការផ្តល់ប្រឹក្សា

## ឆាកទី ១

---

### <u>ការវិនិច្ឆ័យ</u>

អតិថិជន គឺជាស្រីរកស៊ីផ្លូវភេទ។ នាងធ្វើការជាស្រីរកស៊ីផ្លូវភេទ រយៈពេលពីរឆ្នាំមកហើយ។ នាងបានជួបទាក់ទងជាមួយបុគ្គលិកចុះអប់រំរបស់អង្គការក្រៅរដ្ឋាភិបាល ដែលបានប្រាប់នាងអំពីមេរោគអេដស៍ និងជម្ងឺអេដស៍។ នាងទៅសេវា VCCT ដើម្បីសាកសួរពីការធ្វើតេស្តឈាមរកមេរោគអេដស៍។

<u>អ្នកផ្តល់ប្រឹក្សា</u>: ជំរាបសួរ អញ្ជើញចូល។ តើនាងចង់ធ្វើតេស្តឈាមរកមេរោគអេដស៍ឬទេ?

<u>អតិថិជន</u>: ចាស៎ ខ្ញុំចង់ធ្វើតេស្តឈាមរកមើលមេរោគអេដស៍។

<u>អ្នកផ្តល់ប្រឹក្សា</u>: ហេតុអ្វីបានជាអ្នកចង់ធ្វើតេស្តឈាមរកមេរោគអេដស៍?
តើនាងធ្លាប់មានការប្រព្រឹត្តប្រឈមមុខនឹងការឆ្លងមេរោគអេដស៍ដែរឬទេ?
ឬ
តើដៃគូនាងធ្លាប់មានការប្រព្រឹត្តប្រឈមមុខនឹងការឆ្លងមេរោគអេដស៍ដែរឬទេ?

<u>អតិថិជន</u>: ខ្ញុំទទួលភ្ញៀវពេលយប់ ហើយខ្ញុំបានលឺពីមេរោគអេដស៍/ជម្ងឺអេដស៍ ដូច្នេះខ្ញុំចង់ធ្វើតេស្តឈាមរកមេរោគអេដស៍។

<u>អ្នកផ្តល់ប្រឹក្សា</u>: នាងជាអ្នករកស៊ីផ្លូវភេទ។ តើនាងរកស៊ីលក់ភេទយូរប៉ុណ្ណាហើយ? តើនាងដឹងថាវាមិនមែនជាមុខរបរល្អដែរទេ?

<u>អតិថិជន</u>: ខ្ញុំដឹងថាវាមិនមែនជាមុខរបរល្អទេ ប៉ុន្តែ ខ្ញុំបានធ្វើបែបនេះហួសហើយ តើខ្ញុំអាចធ្វើយ៉ាងម៉េចទៅ?

<u>អ្នកផ្តល់ប្រឹក្សា</u>: តើនាងប្រើស្រោមអនាម័យជាមួយគ្រប់ភ្ញៀវដែរឬទេ?

អតិថិជនៈ ខ្ញុំប្រើស្រោមអនាម័យជាមួយភ្ញៀវភាគច្រើន ប៉ុន្តែមានពេលខ្លះ នៅពេលភ្ញៀវណាអោយលុយខ្ញុំច្រើន ដោយមិនបាច់ប្រើស្រោមអនាម័យ ខ្ញុំក៏ព្រមដែរ។ ពេលខ្លះភ្ញៀវស្រវឹងខ្លាំងហើយមិនចង់ប្រើស្រោម ខ្ញុំក៏មិនដឹងថាធ្វើយ៉ាងម៉េចដែរ។

អ្នកផ្តល់ប្រឹក្សាៈ តើនាងដឹងទេ ការមិនប្រើស្រោមអនាម័យ គឺជាគ្រោះថ្នាក់ណាស់សំរាប់រូបនាង និងភ្ញៀវផងដែរ?

អតិថិជនៈ ចាស៎ ខ្ញុំដឹងថា វាប្រថុយគ្រោះថ្នាក់ដែរ !!!!!

## ការមិនវិនិច្ឆ័យ

អ្នកផ្តល់ប្រឹក្សាៈ ជំរាបសួរ អញ្ជើញចូល។ តើនាងចង់ធ្វើតេស្តឈាមរកមេរោគអេដស៍ដែរឬទេ?

អតិថិជនៈ ចាស៎ ខ្ញុំចង់ធ្វើតេស្តឈាមរកមើលមេរោគអេដស៍

អ្នកផ្តល់ប្រឹក្សាៈ តើនាងដឹងថាមេរោគអេដស៍ឆ្លងយ៉ាងម៉េច ដែររឺទេ?

អតិថិជនៈ ចាស៎ បុគ្គលិកអប់រំអង្គការក្រៅរដ្ឋាភិបាលបានប្រាប់ខ្ញុំថា មេរោគអេដស៍អាចឆ្លងតាមរយៈការរួមភេទដោយមិនប្រើស្រោមអនាម័យ ការប្រើម្ជុលរួមគ្នា និងការចំលងពីម្តាយទៅកូន។

អ្នកផ្តល់ប្រឹក្សាៈ តើនាងដឹងថាដើម្បីទទួលបានលទ្ធផលតេស្តឈាមពិតត្រឹមត្រូវ ការធ្វើតេស្តឈាមនោះត្រូវតែធ្វើរយៈពេលបីខែ បន្ទាប់ពី បានស្ថិតក្នុងស្ថានភាពប្រឈមមុខនឹងការឆ្លងមេរោគអេដស៍រួចមក?

អតិថិជនៈ អញ្ចឹងមែនឬ? ខ្ញុំគិតថាខ្ញុំស្ថិតក្នុងស្ថានភាពប្រឈមមុខ នឹងការឆ្លងមេរោគអេដស៍យូរហើយ។ ខ្ញុំធ្វើជាស្រីរកស៊ីផ្លូវភេទ

អ្នកផ្តល់ប្រឹក្សាៈ តើនាងស្ថិតក្នុងស្ថានភាពប្រឈមមុខ នឹងការឆ្លងមេរោគអេដស៍ជាងបីខែកន្លងមកនេះមែនដែរទេ?

អតិថិជនៈ ចាស៎ ខ្ញុំធ្វើជាស្រីរកស៊ីផ្លូវភេទ ពីរឆ្នាំហើយ។

អ្នកផ្តល់ប្រឹក្សាៈ តើនាងមានប្រើស្រោមអនាម័យជាមួយភ្ញៀវគ្រប់ពេលដែរឬទេ?

អតិថិជនៈ ខ្ញុំប្រើជាមួយភ្ញៀវភាគច្រើន ប៉ុន្តែពេលខ្លះនៅពេលមានភ្ញៀវណាអោយប្រាក់ច្រើន ដោយមិនបាច់ប្រើស្រោម

ខ្ញុំក៏យល់ព្រមដែរ។ ពេលខ្លះភ្ញៀវស្រវឹងខ្លាំងហើយមិនព្រមប្រើស្រោមអនាម័យ ខ្ញុំក៏មិនដឹងថាធ្វើយ៉ាងម៉េច។

អ្នកផ្តល់ប្រឹក្សា: តើនាងមានអារម្មណ៍យ៉ាងម៉េចដែរឥឡូវនេះ?

អតិថិជន: ខ្ញុំបារម្ភថាតើខ្ញុំអាចមានមេរោគអេដស៍ ខ្ញុំព្រួយចិត្ត។

អ្នកផ្តល់ប្រឹក្សា: តើនាងនឹងធ្វើអ្វី បើសិនជានាងមានមេរោគអេដស៍?

អតិថិជន: ខ្ញុំប្រហែលជាត្រូវបន្តរបរជាស្រីរកស៊ីផ្លូវភេទនេះតទៅទៀត។

## ការវិនិច្ឆ័យ

នៅក្នុងកំឡុងពេលផ្តល់ប្រឹក្សា ការវិនិច្ឆ័យ មានន័យថាអ្នកផ្តល់ប្រឹក្សាប្រើជំនឿ ឬគំនិតរបស់ខ្លួនផ្ទាល់ ដើម្បីអោយតំលៃទៅលើទង្វើរបស់អតិថិជន ដោយមិនពិចារណាពីមូលហេតុ ឬស្ថានភាព និងរឿងរ៉ាវរបស់អតិថិជន។ ការធ្វើបែបនេះអាចធ្វើអោយអតិថិជនមានអារម្មណ៍មិនល្អ យល់ច្រឡំ ហើយអាចធ្វើអោយអតិថិជនរារាំង ក្នុងការ បញ្ចេញបង្ហាញពេញលេញពីរឿងរ៉ាវរបស់ខ្លួន ដែលអាចជាឧបសគ្គដល់ការផ្តល់ប្រឹក្សាល្អ។

# ឆាកទី ២

## ការមិនរក្សាការសម្ងាត់

នៅសេវា VCCT ដែលជាផ្នែកមួយនៃមន្ទីរពេទ្យបង្អែកនៅក្នុងស្រុកប្រតិបត្តមួយ អតិថិជនដែលមកកាន់សេវា VCCT នេះ គឺជាស្ត្រីម្នាក់ដែលប្តីរបស់នាងបានចូលសំរាកនៅមន្ទីរពេទ្យបង្អែកដើម្បីព្យាបាលជំងឺរបេងសួត។ អតិថិជននេះដឹងថា ប្តីរបស់នាងបានព្យាបាលជំងឺរបេងសួត ប៉ុន្តែនាងមិនដឹងថាគាត់បានធ្វើតេស្តរកមេរោគអេដស៍ និងរកឃើញថាមានផ្ទុកមេរោគអេដស៍ឡើយ។ ប៉ុន្តែនាងបានស្គាល់អ្នកផ្សេងទៀតនៅក្នុងឃុំរបស់នាង ដែលមានផ្ទុកមេរោគអេដស៍ ហើយដោយសារតែប្តីរបស់ នាងបានធ្លាក់ខ្លួនឈឺរ៉ាំរ៉ៃ នាងសង្ស័យពីខ្លួនរបស់នាង។ ប្តីរបស់នាង ឈ្មោះ ហេង។ ស្ត្រីជាប្រពន្ធ ឬ ជាអតិថិជនឈ្មោះ នី។ អ្នកផ្តល់ប្រឹក្សាបានស្គាល់ប្តីប្រពន្ធនេះមួយរយៈមកហើយ។

<u>អ្នកផ្តល់ប្រឹក្សា</u>: ជំរាបសួរ ! បងនី បងបានទៅមើលប្តីបងដែររឺទេ?

<u>អតិថិជន</u>: ចាស់ ! ខ្ញុំបានទៅ។ ខ្ញុំគិតថាគាត់បានគ្រាន់បើថ្ងៃនេះ។ គាត់ក្អកតិចជាងពីមុន។

<u>អ្នកផ្តល់ប្រឹក្សា</u>: ហ្នឹងហើយ គាត់គួរតែបានគ្រាន់បើ ពីព្រោះគ្រូពេទ្យបានផ្តល់ថ្នាំអោយគាត់លេប ។ តើបងបានរួមរស់ជាមួយគាត់យូរប៉ុណ្ណាមកហើយ?

<u>អតិថិជន</u>: ប្រហែលជា ៣-៤ ឆ្នាំហើយ។

<u>អ្នកផ្តល់ប្រឹក្សា</u>: តើគាត់បានចេញដើរលេងខ្លះដែររឺអត់? ខ្ញុំចង់មានន័យថា ទៅលេងស្រីផ្សេងទៀត

<u>អតិថិជន</u>: បន្ទាប់ពីយើងបានរៀបការហើយ គាត់មិនបានដើរលេងច្រើនឡើយ ប៉ុន្តែ ពីមុននោះ ខ្ញុំមិនដឹងទេ ប្រហែលជាគាត់ធ្វើដូចប្រុសៗខ្មែរផ្សេងទៀត ដែរ។

<u>អ្នកផ្តល់ប្រឹក្សា</u>: តើបងចង់ធ្វើតេស្តឈាមរកមេរោគអេដស៍ដែរឬទេ?

<u>អតិថិជន</u>: ខ្ញុំកំពុងតែគិតពីរឿងនេះ។ តើបងគិតថា ខ្ញុំគួរតែធ្វើតេស្តឈាមរកមេរោគអេដស៍ដែរទេ?

<u>អ្នកផ្តល់ប្រឹក្សា</u>: ខ្ញុំគិតថា បងគួរតែធ្វើតេស្តឈាមរកមេរោគអេដស៍។ ខ្ញុំមានគោលបំណងល្អដល់បង។ តើបងដឹងពីការធ្វើតេស្តឈាម របស់បងហេងដែររឺទេ?

អតិថិជនៈ ខ្ញុំមិនដឹងពីលទ្ធផលតេស្តឈាមរបស់គាត់ទេ។ តើលទ្ធផលចេញមកយ៉ាងម៉េច?

អ្នកផ្តល់ប្រឹក្សាៈ អឺ! គាត់មានផ្ទុកមេរោគអេដស៍។ គាត់បានធ្វើតេស្តឈាមកាលពីពីរអាទិត្យមុននេះ។ ដោយសារបងជាប្រពន្ធគាត់, បងគួរតែដឹងថា គាត់មានផ្ទុកមេរោគអេដស៍។ បងក៏គួរតែធ្វើតេស្តឈាមដែរ។ បើបងមិន ទាន់មានផ្ទុកមេរោគ អេដស៍នៅឡើយទេ នោះនៅមានពេល និងវិធីសំរាប់ការពារខ្លួនបង។

អតិថិជនៈ (នៅស្ងៀម ដោយតក់ស្លុតខ្លាំង អតិថិជនមិនរំពឹងថានឹងលឺរឿងនេះឡើយ)

## ការរក្សាការសម្ងាត់

អ្នកផ្តល់ប្រឹក្សាៈ ជំរាបសួរ បងនី បងបានទៅមើលប្តីបងហេងដែរឬទេ?

អតិថិជនៈ ចាស់! ខ្ញុំបានទៅ។ ខ្ញុំគិតថាគាត់បានគ្រាន់បើថ្ងៃនេះ។ គាត់ក្អកតិចជាងពីមុន។

អ្នកផ្តល់ប្រឹក្សាៈ ហ្នឹងហើយ ខ្ញុំក៏គិតដូច្នេះដែរ។ ខ្ញុំគិតថាគាត់គ្រាន់បើជាងពេល គាត់ទើបមកដល់។ គាត់បានលេបឱសថតាមការណែនាំរបស់គ្រូពេទ្យ។

អតិថិជនៈ បើសិនគ្រូពេទ្យប្រាប់គាត់ពីរឿងអ្វីមួយ គាត់នឹងធ្វើតាម។ ប៉ុន្តែជាមួយខ្ញុំ ពេលខ្លះគាត់មិនស្តាប់ខ្ញុំទេ។ គាត់មិនចូលចិត្តលេបឱសថឡើយ។

អ្នកផ្តល់ប្រឹក្សាៈ មន្ទីរពេទ្យនៅឆ្ងាយពីផ្ទះបងបន្តិច តើបងមកទីនេះ គ្រាន់តែមកមើលប្តីបង ឬក៏បងចង់ធ្វើអ្វីផ្សេងទៀតដែរ?

អតិថិជនៈ មានប្រជាជនជាច្រើននៅស្រុកនេះ មានជម្ងឺអេដស៍។ ប្រពន្ធរបស់អ្នកដែលមានជំងឺរ៉ាំរ៉ៃច្រើនមានជម្ងឺអេដស៍ដែរ។ ខ្ញុំព្រួយចិត្ត និងសង្ស័យពីខ្លួនខ្ញុំ។ ខ្ញុំមានកូនតែមួយ ខ្ញុំចង់បានកូនទៀត។ ខ្ញុំចង់ដឹងថាតើខ្ញុំមានមេរោគអេដស៍ដែរឬអត់? ខ្ញុំគិតថានឹងធ្វើតេស្តរកមេរោគអេដស៍។

អ្នកផ្តល់ប្រឹក្សាៈ តើបងដឹងថាមេរោគអេដស៍ឆ្លង តាមរបៀបណាដែរទេ?

អតិថិជនៈ ចាស់ ! ខ្ញុំដឹង គឺតាមរយៈការដេកជាមួយគ្នា ការប្រើម្ជុលរួមគ្នា និងឆ្លងពីម្តាយទៅកូន។

អ្នកផ្តល់ប្រឹក្សាៈ តើបងនឹងធ្វើអ្វីទៅ បើសិនជាតេស្តឈាមទៅមានផ្ទុកមេរោគអេដស៍នោះ?

<u>អតិថិជន:</u> ប្រសិនបើខ្ញុំមានផ្ទុកមានរោគអេដស៍ នោះ ខ្ញុំនឹងមិនអោយមានផ្ទៃពោះទៀតទេ។

**ការរក្សាការសម្ងាត់**

ការរក្សាការសម្ងាត់ គឺជាសីលធម៌វិជ្ជាជីវៈសំខាន់បំផុតសំរាប់បុគ្គលិកសុខាភិបាល។ ដោយសារមេរោគអេដស៍/ជម្ងឺអេដស៍ វាជាប់ទាក់ទងនឹងទស្សនៈ និងការទទួលយករបស់មនុស្ស នៅក្នុងកាលៈទេសៈណាក៏ដោយ ក៏អ្នកផ្តល់ប្រឹក្សា មិនអាចប្រាប់អ្នកផ្សេងទៀត ពីលទ្ធផលតេស្តឈាមរបស់អ្នកណាម្នាក់បានឡើយ បើគ្មានការអនុញ្ញាតពីម្ចាស់ខ្លួនគេនោះ។ករណីលើកលែង គឺអាចមានតែសំរាប់ការពិគ្រោះពិភាក្សាពីការព្យាបាលអ្នកជំងឺក្នុងចំណោមបុគ្គលិកសុខាភិបាល ឬសំរាប់បញ្ជូនបន្ត។ ប៉ុន្តែ អ្នកជម្ងឺត្រូវ តែផ្តល់ការអនុញ្ញាតជាមុនសិន។

# ឧបករណ៍ ៣:

---

## មិនផ្តោតលើអតិថិជន

នៅសេវា VCCT មានអតិថិជនបុរសម្នាក់ បានមកពិភាក្សាអំពីការធ្វើតេស្តឈាមរកមេរោគអេដស៍។ ប្រពន្ធមុនរបស់គាត់បានស្លាប់ដោយសារជម្ងឺអេដស៍ គាត់មានសង្សារថ្មី។ មិត្តស្រីថ្មីរបស់ គាត់មិនបានដឹងពីប្រពន្ធមុនរបស់គាត់ឡើយ។ បុរសនោះមិនទាន់ច្បាស់ថា ខ្លួនគាត់ចង់ធ្វើតេស្តឈាមឬក៏អត់ទេ។

អ្នកផ្តល់ប្រឹក្សា: ជំរាបសួរលោក សុទ្ធី ! តើលោករង់ចាំយូរទេ?

អតិថិជន: មួយសន្ទុះហើយ

អ្នកផ្តល់ប្រឹក្សា: មានមនុស្សច្រើនថ្ងៃនេះ ដូច្នេះខ្ញុំត្រូវការពេលបន្តិច ដើម្បីជួបនិយាយជាមួយគេ។ លោកមកថ្ងៃនេះចង់ធ្វើតេស្តឈាមរកមើលមេរោគអេដស៍ ដែរឬទេ?

អតិថិជន: អឺ! ខ្ញុំបានគិតពីរឿងនេះ។ ខ្ញុំបានគិតថា ខ្ញុំចង់ធ្វើតេស្តឈាម ប៉ុន្តែឥឡូវពេលមកដល់ទីនេះខ្ញុំនៅស្ទាក់ស្ទើរនៅឡើយ។

អ្នកផ្តល់ប្រឹក្សា: ហេតុអ្វីបានជាលោកនៅស្ទាក់ស្ទើរ?

អតិថិជន: ប្រពន្ធមុនរបស់ខ្ញុំ បានស្លាប់ដោយសារអេដស៍ ពីរឆ្នាំកន្លងមកហើយ។ ឥឡូវនេះ ខ្ញុំមានសង្សារថ្មីម្នាក់ទៀត។ ពេលអនាគត ខ្ញុំចង់រៀបការជាមួយនាង។ ប៉ុន្តែ នាងមិនដឹងពីប្រពន្ធមុនរបស់ខ្ញុំឡើយ។ ខ្ញុំមិន ហ៊ានប្រាប់នាងពីរឿងនេះទេ។ ខ្ញុំខ្លាចថា នាងនឹងចាកចោលខ្ញុំ។

អ្នកផ្តល់ប្រឹក្សា: លោកអាចមិនឆ្លង ក៏ថាបានដែរ។ មានករណីខ្លះវាដូចអញ្ចឹង។

អតិថិជន: ក៏ប៉ុន្តែ ខ្ញុំក៏អាចមានឱកាសឆ្លងដែរ។ បើសិនខ្ញុំមិនបានធ្វើតេស្តឈាមទេ ហើយខ្ញុំមានផ្ទុកមេរោគអេដស៍ខ្ញុំអាច ចំលងរោគទៅមិត្តស្រីរបស់ខ្ញុំ។ តើលោកគ្រូគិតថាខ្ញុំគួរតែធ្វើតេស្តឈាមដែរឬទេ?

អ្នកផ្តល់ប្រឹក្សា: ស្តាប់មើលទៅ ខ្ញុំគិតថាលោកគួរតែធ្វើតេស្តឈាមដើម្បីអោយលោកដឹងថាមានមេរោគអេដស៍ដែររឺអត់ ដើម្បីអាចការពារមិត្តស្រីរបស់លោក។ លោកនឹងអស់សង្ស័យដែរ។ តើលោកគិតយ៉ាងម៉េចដែរ?

អតិថិជនៈ (នៅស្ងៀម)

**ផ្តោតលើអតិថិជន**

គោលការណ៍សំខាន់បំផុតនៃការផ្តល់ប្រឹក្សា គឺអតិថិជនត្រូវធ្វើការសំរេចចិត្ត ឬជ្រើសរើសនូវជំរើសដោយខ្លួនគាត់ផ្ទាល់។ អ្នកផ្តល់ប្រឹក្សា ត្រូវតែគោរពសិទ្ធិ និងសមត្ថភាពរបស់អតិថិជន។ តួនាទីរបស់អ្នកផ្តល់ប្រឹក្សា គឺធ្វើអោយបង្កើនឡើងនូវលទ្ធភាពរបស់អតិថិជនក្នុងការប្រើប្រាស់សមត្ថភាពរបស់គាត់តាមរយៈការលើកទឹកចិត្ត និងការផ្តល់ព័តិមាន។

## ផ្តោតលើអតិថិជន

អ្នកផ្តល់ប្រឹក្សាៈ ជំរាបសួរ លោក សុទ្ធី។ តើលោករង់ចាំយូរទេ?

អតិថិជនៈ មួយសន្ទុះហើយ

អ្នកផ្តល់ប្រឹក្សាៈ មានមនុស្សច្រើនថ្ងៃនេះ ដូច្នេះខ្ញុំត្រូវការពេលបន្តិច ដើម្បីជួបនិយាយជាមួយគេ។
លោកមកថ្ងៃនេះ តើចង់ធ្វើតេស្តឈាមរកមើលមេរោគអេដស៍ ដែរឬទេ?

អតិថិជនៈ អឺ ! ខ្ញុំបានគិតពីរឿងនេះ។ ប៉ុន្តែខ្ញុំមិនទាន់ប្រាកដក្នុងខ្លួន។ ចិត្តមួយចង់ធ្វើតេស្ត ក៏ប៉ុន្តែខ្ញុំនៅខ្លាចដែរ

អ្នកផ្តល់ប្រឹក្សាៈ តើលោកអាចប្រាប់ខ្ញុំបានទេ ហេតុអ្វីបានជាលោកគិតពីរឿងធ្វើតេស្តឈាមរកមេរោគអេដស៍?

អតិថិជនៈ ព្រោះថា ប្រពន្ធមុនរបស់ខ្ញុំ បានស្លាប់ដោយសារអេដស៍ ពីរឆ្នាំហើយ។ ឥឡូវខ្ញុំមានសង្សារថ្មីម្នាក់។ នាងមិនដឹងពីប្រពន្ធមុនរបស់ខ្ញុំឡើយ។ ខ្ញុំខ្លាចមិនហ៊ានប្រាប់នាងទេ។

អ្នកផ្តល់ប្រឹក្សាៈ តើលោកដឹងទេថាមានអ្នកខ្លះបានរួមភេទជាមួយអ្នកផ្ទុកមេរោគអេដស៍ ប៉ុន្តែគេមិនបានឆ្លងមេរោគអេដស៍ទេ?

អតិថិជនៈ មានអញ្ចឹងដែរ? អាចមានដែរ?

អ្នកផ្តល់ប្រឹក្សាៈ មានករណីខ្លះ គឺយ៉ាងដូច្នេះ។

អតិថិជនៈ ក៏ប៉ុន្តែ យើងមិនអាចដឹងឡើយ លុះត្រាតែយើងធ្វើតេស្ត ឈាមមើល មែនទេ?

អ្នកផ្តល់ប្រឹក្សាៈ ត្រូវហើយ

អតិថិជនៈ បើខ្ញុំធ្វើតេស្តឈាម ខ្ញុំនឹងដឹងភ្លាម។ បើខ្ញុំមិនមានផ្ទុកមេរោគអេដស៍ ខ្ញុំនឹងមានអារម្មណ៍ល្អ ហើយដឹងថាខ្ញុំនឹងមិនចំលងទៅសង្សាររបស់ខ្ញុំទេ. ប៉ុន្តែបើខ្ញុំមានមេរោគអេដស៍វិញ ខ្ញុំមិនដឹងថាខ្ញុំអាចទទួលបានឬក៏អត់?

អ្នកផ្តល់ប្រឹក្សាៈ បើសិនលោកមានផ្ទុកមេរោគអេដស៍ លោកនឹងលំបាកទទួលរឿងនេះ។

អតិថិជនៈ ពិតហើយលោកគ្រូ វាពិបាកណាស់ គ្រាន់តែគិតក៏ពិបាកណាស់ទៅហើយ។ ខ្ញុំមិនដែលបានគិតថាខ្ញុំនឹងមានផ្ទុកមេរោគអេដស៍ទេ។ ខ្ញុំជាមនុស្សល្អ។ ខ្ញុំមិនចង់បន្ទោសប្រពន្ធមុនរបស់ខ្ញុំ ដែលបានស្លាប់ហើយ។ ប៉ុន្តែវាពិបាកសំរាប់ខ្ញុំ បើខ្ញុំដឹងថា ខ្ញុំមានមេរោគអេដស៍។

អ្នកផ្តល់ប្រឹក្សាៈ ចុះឥឡូវនេះ តើលោកចង់ធ្វើអ្វីទៅ?

អតិថិជនៈ លោកគ្រូ បើខ្ញុំមិនធ្វើតេស្ត តើខ្ញុំអាចប្រើស្រោមអនាម័យបានរឺទេ? តើស្រោមអនាម័យប្រាកដជាមាន ប្រសិទ្ធភាពក្នុងការការពារមែនរឺអត់?

អ្នកផ្តល់ប្រឹក្សាៈ ស្រោមអនាម័យប្រាកដជាអាចបង្ការមេរោគអេដស៍បាន។ តើមិត្តស្រីរបស់លោកនឹងថាយ៉ាងម៉េចដែរ បើលោកប្រើស្រោមអនាម័យ?

អតិថិជនៈ ខ្ញុំនឹងប្រាប់នាងថា ស្រោមនឹងបង្ការកុំអោយនាងមានផ្ទៃពោះ។ នាងដឹងថា ខ្ញុំមិនចង់មានកូនទេ ឥឡូវនេះ។

អ្នកផ្តល់ប្រឹក្សាៈ ដូច្នេះ លោកមិនទាន់ចង់ធ្វើតេស្តឈាមនៅឡើយទេ ព្រោះលោកមិនដឹងថានឹងទទួលបានឬក៏អត់ បើលោកមាន មេរោគអេដស៍នោះ ប៉ុន្តែលោកចង់ការពារមិត្តស្រីរបស់លោក។

អតិថិជនៈ បាទ ហ្នឹងហើយ។

# ឆាកទី ទី៤:

---

## <u>ការមិនយកចិត្តទុកដាក់ចំពោះអារម្មណ៍</u>

អតិថិជន ម៉ុម ជាស្ត្រីមេម៉ាយ ដែលប្តីរបស់គាត់បានស្លាប់ដោយសារជំងឺអេដស៍ ជិតពីរឆ្នាំកន្លងមកហើយ។ គ្រួសារគាត់បានចំណាយ ប្រាក់កាសជាច្រើននៅពេលប្តីគាត់ឈឺ។ គ្រួសារគាត់បានលក់គោ និងដីធ្លីមួយចំនួន។ ម៉ុម មានកូនបីនាក់។ កូនច្បងមានការងារធ្វើ រីឯកូនប្អូនៗពីរនាក់ទៀតនៅរៀននៅឡើយ។ សុខភាពរបស់ម៉ុម មិនសូវល្អណាស់ណាទេ ។ ក្នុងពេលថ្មីៗនេះគាត់ក្អកច្រើន។ គាត់ពិបាកចិត្តពីខ្លួនគាត់ និងអនាគតរបស់កូនៗ ។ ម៉ុម ទៅសេវា VCCT នៅទីរួមខេត្ត។ នាងបានសំរេចចិត្តធ្វើតេស្តរកមេរោគអេដស៍ ។ សេវាធ្វើតេស្តឈាមនោះប្រើតេស្តរហ័ស។ ម៉ុម បានមកទទួលការផ្តល់ប្រឹក្សានិងធ្វើតេស្តឈាមនៅពេលព្រឹកនោះ។ ល្ងាចថ្ងៃដដែលនោះ នាងមកទទួលយកលទ្ធផលតេស្តឈាម។

<u>អ្នកផ្តល់ប្រឹក្សា</u>: ជំរាបសួរ ម៉ុម តើអ្នកមកទទួលលទ្ធផលតេស្តឈាមមែនទេ?

<u>អតិថិជន</u>: ចាស៎

<u>អ្នកផ្តល់ប្រឹក្សា</u>: ខ្ញុំសូមរំលឹកឡើងវិញម្តងទៀតពីអ្វីដែលយើងបានពិភាក្សាគ្នាពីព្រឹកមិញនេះ

<u>អតិថិជន</u>: ចាស៎! បាន

<u>អ្នកផ្តល់ប្រឹក្សា</u>: លទ្ធផលតេស្តឈាមអវិជ្ជមាន មានន័យថាមិនបានរកឃើញមេរោគអេដស៍នៅក្នុងឈាមរបស់អ្នក។ លទ្ធផលតេស្តវិជ្ជមាន មានន័យថាបានរកឃើញមេរោគអេដស៍នៅក្នុងឈាមរបស់អ្នក។ ទោះបីជាអ្នកខ្លះធ្វើតេស្តទៅឃើញថាវិជ្ជមានក៏ដោយ ក៏គេអាចរស់នៅបានយូរដែរ បើគេដឹងពីរបៀបថែរក្សាសុខភាព របស់គេ។ តើអ្នកយល់ពីចំណុចទាំងនេះដែរទេ?

<u>អតិថិជន</u>: ចាស៎! ខ្ញុំយល់ចំណុចទាំងនេះ។

<u>អ្នកផ្តល់ប្រឹក្សា</u>: តើអ្នកនឹងធ្វើយ៉ាងម៉េចបើអ្នកមានមេរោគអេដស៍?

<u>អតិថិជន</u>: បើខ្ញុំមានមេរោគអេដស៍ ខ្ញុំនឹងទៅរកគ្រូពេទ្យដើម្បីព្យាបាល (សំលេងនិងអកប្បកិរិយាបញ្ចេញនូវភាពទុក្ខព្រួយ)។ ខ្ញុំខ្លាចថាខ្ញុំនឹងមានមេរោគអេដស៍។

<u>អ្នកផ្តល់ប្រឹក្សា</u>: ព្រឹកមិញអ្នកនិយាយថា អ្នកនឹងអាចទទួលបាន ទោះបីជាលទ្ធផលតេស្តរបស់អ្នកចេញមកយ៉ាងណាក៏ដោយ។

អតិថិជន: ចាស់

អ្នកផ្តល់ប្រឹក្សា: ក្នុងស្រោមសំបុត្រនេះមានលទ្ធផលតេស្តឈាមរបស់អ្នកបើអ្នកមើលមិនយល់ខ្ញុំនឹងពន្យល់អោយ ( អ្នកផ្តល់ប្រឹក្សាហុចស្រោមសំបុត្រអោយ)

អតិថិជន: ចាស់! សុំមើលហើយប្រាប់អោយខ្ញុំផង

អ្នកផ្តល់ប្រឹក្សា: លទ្ធផលតេស្តឈាមរបស់អ្នក គឺវិជ្ជមាន។ អ្នកមានមេរោគអេដស៍ហើយ។

អតិថិជន: (នៅស្ងៀម)......

អ្នកផ្តល់ប្រឹក្សា: តើអ្នកមានអារម្មណ៍ យ៉ាងម៉េចដែរ?

អតិថិជន: ខ្ញុំភ័យណាស់ ខ្ញុំមិនដឹងថាត្រូវធ្វើយ៉ាងម៉េចទេ។ ពេលដែលប្តីខ្ញុំឈឺ ខ្ញុំបានមើលថែទាំគាត់។ តើអ្នកណានឹងមើលថែទាំខ្ញុំ នៅពេលខ្ញុំឈឺ តើអ្នកណានឹងមើលថែទាំកូនរបស់ខ្ញុំបើសិនខ្ញុំស្លាប់ទៅ។ (យំខ្សឹកខ្សួល..)

អ្នកផ្តល់ប្រឹក្សា: អ្នកមិនគួរព្រួយបារម្ភច្រើនពេកទេ។ អ្នកមិនទាន់ធ្លាក់ខ្លួនឈឺនៅឡើយ។ មានមនុស្សជាច្រើនមានមេរោគអេដស៍នៅស្រុកយើង ។

អតិថិជន: (នៅស្ងៀម មើលមកអ្នកផ្តល់ប្រឹក្សា)

## ការយកចិត្តទុកដាក់ចំពោះអារម្មណ៍

អ្នកផ្តល់ប្រឹក្សា: ជំរាបសួរ ! ម៉ុម តើអ្នកមកទទួលលទ្ធផលតេស្តឈាមមែនទេ?

អតិថិជន: ចាស់

អ្នកផ្តល់ប្រឹក្សា: ខ្ញុំសូមរំលឹកឡើងវិញម្តងទៀតពីអ្វីដែលយើងបានពិភាក្សាគ្នាពីព្រឹកមិញនេះ

អតិថិជន: ចាស់ បាន

អ្នកផ្តល់ប្រឹក្សា: លទ្ធផលតេស្តឈាមអវិជ្ជមាន មានន័យថាមិនបានរកឃើញមេរោគអេដស៍នៅក្នុងឈាមរបស់អ្នក។ លទ្ធផលតេស្តឈាមវិជ្ជមាន មានន័យថាបានរកឃើញមេរោគអេដស៍នៅក្នុងឈាមរបស់អ្នក។ ទោះបីជាអ្នកខ្លះធ្វើ

តេស្តឈាម ទៅឃើញថាវិជ្ជមានក៏ដោយ ក៏គេអាចរស់នៅបានយូរដែរ បើគេដឹងពីរបៀបថែរក្សាសុខភាពរបស់គេ។ តើអ្នកយល់ពីចំណុចទាំងនេះដែរទេ?

<u>អតិថិជន:</u> ចាស៎ ខ្ញុំយល់ចំណុចទាំងនេះ។

<u>អ្នកផ្តល់ប្រឹក្សា:</u> តើអ្នកនឹងធ្វើយ៉ាងម៉េចបើអ្នកមានមេរោគអេដស៍?

<u>អតិថិជន:</u> (មើលទៅកន្លែងផ្សេង) ខ្ញុំមិនទាន់ដឹងទេថាតើនឹងធ្វើយ៉ាងម៉េច?

<u>អ្នកផ្តល់ប្រឹក្សា:</u> ព្រឹកមិញអ្នកក៏និយាយអញ្ចឹងដែរហើយ អ្នកក៏និយាយទៀតថាអ្នកនៅតែចង់ដឹង លទ្ធផលតេស្តពីព្រោះបើមិនទាន់បានដឹង អ្នកនៅតែសង្ស័យនិងបារម្ភណ៍។

<u>អតិថិជន:</u> ចាស! ខ្ញុំចង់ដឹងទោះបីជាលទ្ធយ៉ាងណាក៏ដោយ

<u>អ្នកផ្តល់ប្រឹក្សា:</u> ក្នុងស្រោមសំបុត្រនេះមានលទ្ធផលតេស្តរបស់អ្នក តើអ្នកចង់បើកមើលលទ្ធផលនៅទីនេះទេ?

<u>អតិថិជន:</u> ចាស៎! សុំមើលហើយប្រាប់អោយខ្ញុំផង

<u>អ្នកផ្តល់ប្រឹក្សា:</u> លទ្ធផលតេស្តឈាមរបស់អ្នក គឺវិជ្ជមាន។ អ្នកមានមេរោគអេដស៍។

<u>អតិថិជន:</u> (នៅស្ងៀម).....

<u>អ្នកផ្តល់ប្រឹក្សា:</u> តើឥឡូវនេះ អ្នកមានអារម្មណ៍យ៉ាងម៉េចដែរ?

<u>អតិថិជន:</u> ខ្ញុំភ័យណាស់ ខ្ញុំមិនដឹងថាត្រូវធ្វើយ៉ាងម៉េចទេ។ ពេលដែលប្តីខ្ញុំឈឺ ខ្ញុំបានមើលថែទាំគាត់។ តើអ្នកណានឹងមើលថែទាំខ្ញុំ នៅពេលខ្ញុំឈឺ តើអ្នកណានឹងមើលថែទាំកូនរបស់ខ្ញុំបើសិនខ្ញុំស្លាប់ទៅ។ (យំខ្សឹកខ្សួល..)

<u>អ្នកផ្តល់ប្រឹក្សា:</u> ខ្ញុំយល់ ថានេះគឺជាការលំបាកណាស់សំរាប់អ្នក។ តើអ្នកព្រួយបារម្ភពីអ្វីខ្លាំងជាងគេ?

<u>អតិថិជន:</u> ខ្ញុំព្រួយបារម្ភពីកូនៗខ្ញុំ។ ពួកវានៅក្មេងៗនៅឡើយ ហើយមិនទាន់ចេះមើលថែទាំខ្លួនឯងបាននៅឡើយទេ។

អ្នកផ្តល់ប្រឹក្សា: តើសុខភាពរបស់អ្នកយ៉ាងម៉េចដែរឥឡូវនេះ?

អតិថិជន: ខ្ញុំក្អកខ្លះៗ ខ្ញុំមិនដឹងថាតើខ្ញុំមានជំងឺរបេង ឬក៏ជម្ងឺផ្សេងទៀត ដែរឬអត់ទេ?

អ្នកផ្តល់ប្រឹក្សា: ការបង្ការជំងឺផ្សេងៗ នឹងជួយអ្នកអោយរស់នៅបានយូរជាមួយកូនរបស់អ្នក។ នៅមន្ទីរពេទ្យ បង្អែកនេះ មានគ្រូពេទ្យដែលអាចពិនិត្យមើលសុខភាពអោយអ្នកផ្ទុកមេរោគអេដស៍ហើយនឹងផ្តល់ការណែនាំ និងអោយថ្នាំដើម្បី បង្ការនិងព្យាបាលជម្ងឺផ្សេងៗ ដែលកើតលើអ្នកជំងឺអេដស៍។

**ការយកចិត្តទុកដាក់ចំពោះអារម្មណ៍**

អារម្មណ៍និងការរំជួលចិត្តជាកត្តាសំខាន់ណាស់ក្នុងការកំណត់ពីការសប្បាយរីករាយ ឬ ការសៅហ្មងសំរាប់មនុស្សយើង។ សំរាប់អ្នកផ្ទុកមេរោគអេដស៍ ពួកគេត្រូវជួបប្រទះការលំបាកទាំងផ្នែកសុខភាព និងផ្លូវចិត្តផងដែរ។ ស្ត្រីមេម៉ាយជាច្រើន ត្រូវបានទទួលខុសត្រូវមើលថែទាំកូន បន្ទាប់ពីប្តី របស់គេស្លាប់ចោលទៅ។ ស្ត្រីមួយចំនួនត្រូវជួបប្រទះនឹងការរើសអើងនៅក្នុងសហគមន៍របស់គេ។ អ្នកផ្តល់ប្រឹក្សា គួរតែយកចិត្តទុកដាក់ចំពោះអារម្មណ៍ និងការព្រួយបារម្ភណ៍ កង្វល់ របស់អតិថិជន។

# ឆាកទី ទី៥

---

## កង្វះខាតក្នុងការប្រាស្រ័យទាក់ទង

អតិថិជនជាបុរសម្នាក់ឈ្មោះ សាមិត្ត។ សាមិត្ត ជាអ្នកបើកបររថយន្តដឹកជញ្ជូនផ្លូវឆ្ងាយ។ គាត់ធ្វើដំណើរទៅខេត្តមួយចំនួនដើម្បីដឹកទំនិញអោយក្រុមហ៊ុនជាច្រើន។ គាត់បានធ្វើតេស្តឈាមរកមេរោគបីដងហើយ។ ពេលដែលគាត់ធ្វើតេស្តឈាមចុងក្រោយ រកឃើញ ថាគាត់មានផ្ទុកមេរោគអេដស៍។ ឥឡូវនេះគាត់នៅមានសុខភាពល្អ។ គាត់មានការលំបាកនឹងទទួលលទ្ធផលតេស្តឈាមនេះណាស់។ គាត់ទៅសេវា VCCT មួយទៀតដែលគាត់មិនដែលធ្លាប់ទៅពីមុនមក។ ថ្ងៃនោះគឺជាថ្ងៃចន្ទ័ហើយ សេវា VCCT នោះមានមនុស្ស ច្រើន។ អ្នកផ្តល់ប្រឹក្សាត្រូវទទួលអតិថិជនជាច្រើន។

<u>អ្នកផ្តល់ប្រឹក្សា</u>: ជំរាបសួរ តើថ្ងៃនេះលោកសុខសប្បាយជាទេ?

<u>អតិថិជន</u>: តើខ្ញុំអាចជួបនិយាយជាមួយអ្នកបានទេ សុំទោសចំពោះការរំខាន។

<u>អ្នកផ្តល់ប្រឹក្សា</u>: តើលោកមកទីនេះជាលើកទីមួយឬទេ?

<u>អតិថិជន</u>: បាទ

<u>អ្នកផ្តល់ប្រឹក្សា</u>: តើចាំយូរទេ?

<u>អតិថិជន</u>: យូរបន្តិចដែរ ប៉ុន្តែមិនអីទេ។ ខ្ញុំគិតយ៉ាងយូរ មុននឹងមកទីនេះ។ លទ្ធផលតេស្តរបស់ខ្ញុំ ធ្វើអោយខ្ញុំច្របូកច្របល់ខ្លាំងណាស់។ មនុស្សម្នាក់អាចនឹងឆ្កួតឡប់បានដោយសារតែរឿងនេះ។ វាដូចជាទិញឆ្នោតហើយត្រូវ យ៉ាងដូច្នោះដែរ។ លេខមួយតែម្តង? ការងារខ្ញុំរវល់ខ្លាំងណាស់ ខ្ញុំត្រូវធ្វើដំណើរទៅខេត្តជាច្រើន។ ខ្ញុំគិតថានឹងឈប់ធ្វើការហើយ។ ប្រហែលជាខ្ញុំគួរតែធ្វើអោយខ្លួនបានសប្បាយ ទៅទីណាកន្លែងណាឆ្ងាយដែលខ្ញុំអាចទៅបាន។ មានន័យអីទៅនៅក្នុងជីវិត? ហេតុអីបានជាយើងចាំបាច់ ត្រូវធ្វើការងារខ្លាំងពេក? តើលុយអាចធ្វើអីកើត? តើអ្នកយល់ស្របនឹងខ្ញុំទេ?

<u>អ្នកផ្តល់ប្រឹក្សា</u>: លោកចង់មានន័យថា លទ្ធផលធ្វើតេស្តឈាមដែលលោកបានធ្វើហើយនោះ គឺវាអវិជ្ជមាន អញ្ចឹងហើយបានជាលោកមានអារម្មណ៍ធូរស្រាលជាងមុន។

<u>អតិថិជន</u>: ទេ! ខ្ញុំមិនចង់និយាយពីរឿងនឹងទេ។ ខ្ញុំមិនចង់ជឿទេ។ វាដូចជាការយល់សប្តិ។ ខ្ញុំចង់កុហកខ្លួនឯង។

អ្នកផ្តល់ប្រឹក្សា: លោកមិនចង់ប្រាប់អ្នកណាទេ។ លោកធ្វើដំណើរច្រើន ដូច្នេះហើយ លោកចង់ធ្វើដំណើរអោយបានសប្បាយរីករាយក្នុងចិត្ត។

អតិថិជន: ទេ ! ខ្ញុំមិនមានលុយច្រើនទេ

អ្នកផ្តល់ប្រឹក្សា: ដូច្នេះ លោកមានបញ្ហាសេដ្ឋកិច្ច។

អតិថិជន: មិនមែនទេ ខ្ញុំមានលុយខ្លះដែរ ប៉ុន្តែខ្ញុំមិនមែនជាអ្នកមានទេ។

## ការប្រាស្រ័យទាក់ទងល្អ

អ្នកផ្តល់ប្រឹក្សា: ជំរាបសួរ តើថ្ងៃនេះលោកសុខសប្បាយជាទេ?

អតិថិជន: តើខ្ញុំអាចជួបនិយាយជាមួយអ្នកបានទេ សុំទោសចំពោះការរំខាន។

អ្នកផ្តល់ប្រឹក្សា: តើលោកមកទីនេះជាលើកទីមួយឬទេ?

អតិថិជន: បាទ

អ្នកផ្តល់ប្រឹក្សា: តើចាំយូរទេ?

អតិថិជន: យូរបន្តិចដែរ ប៉ុន្តែមិនអីទេ។ ខ្ញុំគិតយ៉ាងយូរ មុននឹងមកទីនេះ។ លទ្ធផលតេស្តរបស់ខ្ញុំ ធ្វើអោយខ្ញុំច្របូកច្របល់ខ្លាំងណាស់។ មនុស្សម្នាក់អាចនឹងឆ្កួតឡប់បានដោយសារតែរឿងនេះ។ វាដូចជាទិញឆ្នោតហើយត្រូវ យ៉ាងដូច្នោះដែរ។ លេខមួយតែម្តង? ការងារខ្ញុំរវល់ខ្លាំងណាស់ ខ្ញុំត្រូវធ្វើដំណើរទៅខេត្តជាច្រើន។ ខ្ញុំគិតថានឹងឈប់ធ្វើការហើយ។ ប្រហែលជាខ្ញុំគួរតែធ្វើអោយខ្លួនបានសប្បាយ ទៅទីណាកន្លែងណាឆ្ងាយដែលខ្ញុំអាចទៅបាន។ មានន័យអីទៅនៅក្នុងជីវិត? ហេតុអីបានជាយើងចាំបាច់ ត្រូវធ្វើការងារខ្លាំងពេក? តើលុយអាចធ្វើអីកើត? តើអ្នកយល់ស្របនឹងខ្ញុំទេ?

អ្នកផ្តល់ប្រឹក្សា: ស្តាប់ មើលទៅលោកមានការព្រួយបារម្ភណ៍ពីលទ្ធផលតេស្តឈាមរបស់លោក?

អតិថិជន: បាទ ! ខ្ញុំដូចជាច្របូកច្របល់បន្តិច ហើយមិនចង់ជឿទេ។

អ្នកផ្តល់ប្រឹក្សាៈ អញ្ចឹង! ដូច្នេះលោកធ្លាប់បានធ្វើតេស្តឈាមរកមេរោគអេដស៍ ពីមុនមកហើយ

អតិថិជនៈ បាទ បីដងហើយ

អ្នកផ្តល់ប្រឹក្សាៈ តើលោកមានអារម្មណ៍យ៉ាងម៉េចដែរឥឡូវនេះ?

អតិថិជនៈ ខ្ញុំកំពុងគិតចង់ធ្វើតេស្តឈាមម្តងទៀត ដើម្បីអោយបានដឹងច្បាស់។

**ការប្រាស្រ័យទាក់ទងល្អ**

ជំនាញប្រាស្រ័យទាក់ទង ដូចជា ការស្តាប់ដោយយកចិត្តទុកដាក់ គឺសំខាន់ណាស់សំរាប់អ្នកផ្តល់ប្រឹក្សា ដើម្បីអោយ យល់ពី ស្ថានភាព និងបញ្ហារបស់អតិថិជន។ អ្នកដែលស្តាប់បានល្អ លឺមិនត្រឹមតែ ពាក្យពេជន៍ដែលបាននិយាយ ចេញមកប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងអត្ថន័យ និងចំណុចសំខាន់ៗរបស់អ្នកនិយាយទៀតផង គឺទាំងខ្លឹមសារ ទាំងអារម្មណ៍។ នៅពេលកំពុងប្រាស្រ័យទាក់ទង ឬ ស្តាប់ អ្នកផ្តល់ប្រឹក្សា ត្រូវសង្កេតលើឫកពារនិយាយស្តី ឬក៏លើភាសាកាយវិការរបស់ អតិថិជនផងដែរ ដើម្បីយល់បានច្បាស់ពីអារម្មណ៍របស់គេ។

# ឆាកទី ៦

## មិនបញ្ជូនបន្ត

អតិថិជនម្នាក់អាយុ៣៦ឆ្នាំ មកសេវា VCCT ដែលថិតនៅក្បែរគ្លីនិកកាមរោគមួយ។ គាត់មានផ្ទៃពោះប្រាំខែហើយ។ ប្ដីរបស់គាត់ឧហ្សាហ៍ឈឺញឹកញាប់ ។អតិថិជននេះ ឈ្មោះ សុផាមានមន្ទិលសង្ស័យពីខ្លួនគាត់។ គាត់បានមកធ្វើតេស្ដឈាម រកមេរោគអេដស៍ហើយដឹងថាគាត់មានផ្ទុកមេរោគអេដស៍។

<u>អ្នកផ្ដល់ប្រឹក្សា</u>: តើអ្នកមានអារម្មណ៍យ៉ាងម៉េចដែរ បន្ទាប់ពីដឹងថាមានផ្ទុកមេរោគអេដស៍?

<u>អតិថិជន</u>: ខ្ញុំគិតថាវាជាកម្មរបស់ខ្ញុំ។ ប្រហែលជាខ្ញុំបានធ្វើអំពើមិនល្អពីជាតិមុន។

<u>អ្នកផ្ដល់ប្រឹក្សា</u>: តើអ្នកគិតចង់ធ្វើអ្វីខ្លះ ឥឡូវនេះ?

<u>អតិថិជន</u>: ខ្ញុំមិនដឹងថាធ្វើអ្វីទេ មានបញ្ហាច្រើនណាស់។ ប្ដីរបស់ខ្ញុំក៏ឈឺជារឿយៗទៀត។ ជីវភាពរស់នៅរបស់ យើងមិនសូវល្អទេ។ ដូចលោកគ្រូបាននិយាយមុនពេលធ្វើតេស្ដហើយថាមេរោគអេដស៍ អាចឆ្លងពីម្ដាយទៅកូនបាន។ ខ្ញុំមិនចង់អោយកូនរបស់ខ្ញុំឆ្លងមេរោគអេដស៍ពីខ្ញុំឡើយ ក៏ប៉ុន្តែ ឥឡូវនេះ ប្រហែលជាហួសពេលនឹងយកកូនចេញហើយ។

<u>អ្នកផ្ដល់ប្រឹក្សា</u>: ព្រោះអ្នកមានផ្ទៃពោះ ច្រើនខែហើយ បើអ្នកយកកូនចេញនៅពេលនេះគឺមិនមានសុវត្ថិភាពឡើយ។ ក៏ប៉ុន្តែមិនមែនគ្រប់ទារក ទាំងអស់ សុទ្ធតែឆ្លងមេរោគអេដស៍ពីម្ដាយនោះឡើយ។

<u>អតិថិជន</u>: ខ្ញុំបានលឺថាមានឱសថម្យ៉ាងសំរាប់ម្ដាយដែលមានមេរោគអេដស៍ ដើម្បីការពារកុំអោយឆ្លងទៅកូន។ តើខ្ញុំអាច ទទួលសេវានេះនៅកន្លែងណា?

<u>អ្នកផ្ដល់ប្រឹក្សា</u>: អ្នកកំពុងនិយាយពីកម្មវិធីកាត់បន្ថយការឆ្លងមេរោគអេដស៍ពីម្ដាយទៅកូន។ នៅកន្លែងនេះយើងអត់មានទេ មន្ទីរពេទ្យផ្សេងប្រហែលជាមាន ប៉ុន្តែខ្ញុំមិនដឹងច្បាស់ទេ ។ ប្រហែលអ្នកឯងត្រូវទៅមន្ទីរពេទ្យផ្សេងឬទៅភ្នំពេញ។

<u>អតិថិជន</u>: ខ្ញុំក្រ មិនមានលុយច្រើនទេ។ ប្ដីរបស់ខ្ញុំក៏តែងតែឈឺទៀត។ ខ្ញុំមិនអាចធ្វើដំណើរទៅណាបានទេ ។

អ្នកផ្ដល់ប្រឹក្សា: មើលទៅអ្នកមានការលំបាកលំបិនណាស់។ កាលពីពេលដែលប្ដីរបស់អ្នកនៅមានសុខភាពល្អនៅឡើយ នោះជីវភាពរស់នៅរបស់អ្នកគ្រាន់បើជាងនេះមែនទេ?

អតិថិជន: ចាស់ ! គាត់ធ្វើជាទាហាន។

**ការបញ្ជូនបន្ត**

អ្នកផ្ទុកមេរោគអេដស៍តែងមានបញ្ហាជាច្រើន ហើយការផ្ដល់តែសេវាផ្ដល់ប្រឹក្សាមួយមុខដើម្បីគាំទ្រផ្លូវចិត្តគឺមិនអាចគ្រប់គ្រាន់ទេ ដោយសារមានបញ្ហាទាក់ទងនឹងសុខភាពផ្សេងៗទៀត ដែលត្រូវតែគិតគូរដោះស្រាយ។ ដូច្នេះអ្នកផ្ដល់ប្រឹក្សា ត្រូវដឹងពី សេវាពាក់ព័ន្ធសមស្របនានា ដែលអាចរកបាននៅក្នុងតំបន់ ស្រុក ឬខេត្ត ដើម្បីអាចធ្វើការបញ្ជូនបន្តបានសមស្រប និង ជួយកាត់បន្ថយបញ្ហារបស់អតិថិជន។ អ្នកផ្ដល់ប្រឹក្សាមុននឹងធ្វើការបញ្ជូនត្រូវតែសុំការអនុញ្ញាតពីអតិថិជនជាមុនសិន ថាបុគ្គលិកពាក់ព័ន្ធនោះនឹងដឹងពីការផ្ទុកមេរោគអេដស៍របស់គាត់។

**ការបញ្ជូនបន្ត**

អ្នកផ្ដល់ប្រឹក្សា: តើអ្នកមានអារម្មណ៍យ៉ាងម៉េចដែរ បន្ទាប់ពីដឹងថាមានផ្ទុកមេរោគអេដស៍?

អតិថិជន: ខ្ញុំគិតថាវាជាកម្មរបស់ខ្ញុំ។ ប្រហែលជាខ្ញុំបានធ្វើអំពើមិនល្អពីជាតិមុន។

អ្នកផ្ដល់ប្រឹក្សា: តើអ្នកគិតចង់ធ្វើអ្វីខ្លះ ឥឡូវនេះ?

អតិថិជន: ខ្ញុំមិនដឹងថាធ្វើអ្វីទេ មានបញ្ហាច្រើនណាស់។ ប្ដីរបស់ខ្ញុំក៏ឈឺជារឿយៗទៀត។ ជីវភាពរស់នៅរបស់ យើងមិនសូវល្អទេ។ ដូចលោកគ្រូបាននិយាយមុនពេលធ្វើតេស្ដហើយថាមេរោគអេដស៍ អាចឆ្លងពីម្ដាយទៅកូនបាន។ ខ្ញុំមិនចង់អោយកូនរបស់ខ្ញុំឆ្លងមេរោគអេដស៍ពីខ្ញុំឡើយ ក៏ប៉ុន្តែ ឥឡូវនេះ ប្រហែលជាហួសពេលនឹងយកកូនចេញហើយ។

អ្នកផ្ដល់ប្រឹក្សា: យើងអាចធ្វើអ្វីបានខ្លះដែរបន្ទាប់ពីដឹងថាអ្នកមានផ្ទុកមេរោគអេដស៍។ នៅឯមន្ទីរពេទ្យបង្អែក បាត់ដំបងមានសេវាមួយហៅថា “ការបង្ការការចំលងមេរោគអេដស៍ពីម្ដាយទៅកូន”។ ដើម្បីកាត់បន្ថយនូវឱកាសនៃការចំលងមេរោគអេដស៍ពីម្ដាយទៅកូន គេផ្ដល់ឱសថអោយម្ដាយលេបមុនពេលសំរាលកូន

ហើយក៏អោយឱសថទៅ ទារកដែលទើបនឹងកើតផងដែរ។ គេអាចធ្វើបែបនេះ ប្រសិនបើស្រ្តីមានផ្ទៃពោះ យល់ព្រមសំរាលកូននៅឯ មន្ទីរពេទ្យនោះ។

អតិថិជនៈ តើការធ្វើយ៉ាងនេះ នឹងជួយបង្ការកូនរបស់ខ្ញុំមិនអោយឆ្លងមេរោគអេដស៍ ដែរទេ?

អ្នកផ្តល់ប្រឹក្សាៈ តាមធម្មតា បើមិនប្រើឱសថប្រឆាំងនឹងមេរោគអេដស៍ទេនោះ ប្រមាណជា៣០%នៃទារកដែលកើតពីម្តាយមានផ្ទុកមេរោគអេដស៍ នឹងមានផ្ទុកមេរោគអេដស៍។ កម្មវិធីបង្ការការចំលងមេរោគអេដស៍ ពីម្តាយទៅកូនអាចកាត់បន្ថយ ឱកាសឆ្លងមេរោគអេដស៍មកត្រឹមតែប្រម៉ាណជា ១០%ប៉ុណ្ណោះ។ បើអ្នកចង់ជួបពិភាក្សាជាមួយបុគ្គលិកសុខាភិបាលខ្ញុំនឹងជួយធ្វើសំបុត្របញ្ជូនអោយ ។ ប៉ុន្តែបើធ្វើបែបនេះ បុគ្គលិកពាក់ព័ន្ធគេនឹងដឹងថាអ្នកមានផ្ទុកមេរោគអេដស៍។ តើអ្នកអាចអោយបុគ្គលិកដែលជាឆ្មបនិងគិលានុបដ្ឋាក-យិកាដឹងថា អ្នកមានផ្ទុកមេរោគអេដស៍ដែររឺទេ?

អតិថិជនៈ តើគេនឹងរក្សាការសម្ងាត់អោយខ្ញុំដែរទេ ឬក៏ គេនឹងប្រាប់អ្នកផ្សេងទៀតថាខ្ញុំមានមេរោគអេដស៍ ?

អ្នកផ្តល់ប្រឹក្សាៈ គេនឹងរក្សាការសម្ងាត់អោយអ្នក។ គេនឹងមិនប្រាប់អ្នកដែលមិនត្រូវការចាំបាច់ដឹងពីរឿងនេះឡើយ។

អតិថិជនៈ អរគុណច្រើន ! សូមសរសេរប័ណ្ណបញ្ជូនអោយខ្ញុំផង។

អ្នកផ្តល់ប្រឹក្សាៈ អ្នកបាននិយាយថា ប្តីរបស់អ្នកតែងតែឈឺជារឿយៗ។ នៅក្នុងឃុំរបស់អ្នក មានសេវាថែទាំសុខភាពតាមផ្ទះសំរាប់អ្នកដែលឈឺរ៉ាំរ៉ៃ។ តើមានគេមកមើលប្តីរបស់អ្នកដែរទេ?

អតិថិជនៈ ទេ! មិនមានអ្នកណាមកទេ។ យើងមិនបានប្រាប់អ្នកណាថា គាត់ឈឺទេ។ តើគេនឹងថាគាត់កើតអេដស៍ ទេ បើអ្នកទាំងនោះមកជួបគាត់?

អ្នកផ្តល់ប្រឹក្សាៈ សេវាថែទាំតាមផ្ទះជួយអ្នកមានជម្ងឺរ៉ាំរ៉ៃទូទៅ គឺមិនត្រឹមតែអ្នកមានជំងឺអេដស៍នោះទេ។ ពួកគេក៏ផ្តល់អង្ករខ្លះៗផងដែរ ការឧបត្ថម្ភនេះ អាចនឹងជួយសំរាលបន្ទុកដល់អ្នកខ្លះៗដែរ។ អ្នកអាចទៅរកជួបពួកគេទៅតាម អាស័យដ្ឋាននេះ ឬក៏ ខ្ញុំអាចផ្តល់ពតិមានដល់គេពីប្តីរបស់អ្នក បើអ្នកចង់។

## សកម្មភាព ទី៩ ឯកសារលេខ១

| គំនិតយោបល់/ការសង្កេតពីការផ្តល់ប្រឹក្សាសំរាប់ឆាកដែលនៅខ្វះខាតទាំង ៦ | |
|---|---|
| **ឆាកទី ១**<br>តើចំណុចណាខ្លះដែលអ្នកផ្តល់ប្រឹក្សាត្រូវកែលំអរ? | **ឆាកទី ២**<br>តើចំណុចណាខ្លះដែលអ្នកផ្តល់ប្រឹក្សាត្រូវកែលំអរ? |
| | |
| | |
| | |
| | |
| | |
| | |
| | |
| **ឆាកទី ៣**<br>តើចំណុចណាខ្លះដែលអ្នកផ្តល់ប្រឹក្សាត្រូវកែលំអរ? | **ឆាកទី ៤**<br>តើចំណុចណាខ្លះដែលអ្នកផ្តល់ប្រឹក្សាត្រូវកែលំអរ? |
| | |
| | |
| | |
| | |
| | |
| | |
| | |
| **ឆាកទី ៥**<br>តើចំណុចណាខ្លះដែលអ្នកផ្តល់ប្រឹក្សាត្រូវកែលំអរ? | **ឆាកទី ៦**<br>តើចំណុចណាខ្លះដែលអ្នកផ្តល់ប្រឹក្សាត្រូវកែលំអរ? |
| | |
| | |
| | |
| | |
| | |
| | |
| | |
| | |
| | |

**សកម្មភាព ទី៩ ឯកសារលេខ ១**

| គំនិតយោបល់/ការសង្កេតពីការផ្ដល់ប្រឹក្សាឆាកដែលល្អទាំង ៦ | |
|---|---|
| **ឆាកទី ១**<br>តើចំណុចណាខ្លះដែលអ្នកផ្ដល់ប្រឹក្សាធ្វើបានល្អ? | **ឆាកទី ២**<br>តើចំណុចណាខ្លះដែលអ្នកផ្ដល់ប្រឹក្សាធ្វើបានល្អ? |
| | |
| | |
| | |
| | |
| | |
| | |
| | |
| **ឆាកទី ៣**<br>តើចំណុចណាខ្លះដែលអ្នកផ្ដល់ប្រឹក្សាធ្វើបានល្អ? | **ឆាកទី ៤**<br>តើចំណុចណាខ្លះដែលអ្នកផ្ដល់ប្រឹក្សាធ្វើបានល្អ? |
| | |
| | |
| | |
| | |
| | |
| | |
| | |
| **ឆាកទី ៥**<br>តើចំណុចណាខ្លះដែលអ្នកផ្ដល់ប្រឹក្សាធ្វើបានល្អ? | **ឆាកទី ៦**<br>តើចំណុចណាខ្លះដែលអ្នកផ្ដល់ប្រឹក្សាធ្វើបានល្អ? |
| | |
| | |
| | |
| | |
| | |
| | |
| | |
| | |
| | |

សកម្មភាព ទី៩ ផ្ទាំងបញ្ចាំង លេខ១

# “ការផ្តល់ប្រឹក្សាគឺជាអ្វី?”

## ការផ្តល់ប្រឹក្សា គឺជាៈ

ការសន្ទនាទៅវិញទៅមកជាលក្ខណៈ ឯកជន និងរក្សា
ការសំងាត់ ដើម្បីជួយអតិថិជនអោយយល់ពីបញ្ហារបស់គាត់
និង អោយគាត់អាចទប់ទល់នឹងបញ្ហានោះ ដោយខ្លួនឯងបាន ។

## សកម្មភាព ទី៧  ផ្ទាំងបញ្ជាំងលេខ ២

ទំនាក់ទំនងល្អ
ទំនុកចិត្ត
ភាពកក់ក្តៅ
ងាយស្រួលនិយាយជាមួយ

ការទទួលយក ហើយ
យល់ពីការសំរេចចិត្ត
និង ទង្វើរបស់គាត់

ជឿជាក់លើសមត្ថភាព
របស់អតិថិជនក្នុងការ
សំរេចចិត្ត

យកចិត្តទុកដាក់
ចំពោះបញ្ហា និង
អារម្មណ៍

## កត្តាដែលជួយអោយ
## មានការផ្តល់ប្រឹក្សាល្អ

រិះរកមធ្យោបាយ
ជាមួយគ្នាដើម្បី
ទប់ទល់នឹងបញ្ហា



ការលើកទឹកចិត្ត

ផ្តល់ជំនួយ  ផ្តល់ពត៌មានដែល
មានប្រយោជន៍
បញ្ជូនទៅសេវាផ្សេងទៀត

ការរក្សាការសម្ងាត់

សុភាពរាបសារ
គួរអោយជឿទុកចិត្ត

ជំរុញអោយមានការផ្លាស់
ប្តូរនិងមានការដោះ
ស្រាយ បញ្ហា

# សកម្មភាព ទី១០

## គោលការណ៍ និងជំនាញផ្ដល់ការប្រឹក្សា

## ការប្រើប្រាស់នូវគោលការណ៍ និងជំនាញទាំងអស់រួមគ្នា

## តើខ្ញុំគួរធ្វើយ៉ាងណាចំពោះប្ដីខ្ញុំ?

## តើខ្ញុំគួរធ្វើតេស្ដឈាមរកមេរោគអេដស៍ដែរទេ?

# សកម្មភាព ទី១០
# តើខ្ញុំគួរធ្វើយ៉ាងណាចំពោះប្ដីខ្ញុំ?
# តើខ្ញុំគួរធ្វើតេស្តឈាមរកមេរោគអេដស៍ដែរទេ?

## ការដើរតួ

នៅក្នុងសកម្មភាពនេះ សិក្ខាកាមនឹងប្រើប្រាស់គោលការណ៍ និងជំនាញជាមូលដ្ឋាននានាដែលបានពិភាក្សា កន្លងមកហើយ យកមកអនុវត្តក្នុងការដើរតួ។

**គោលបំណង:**

១- ដើម្បីអោយសិក្ខាកាមអនុវត្តរួមគ្នានូវគោលការណ៍ និងជំនាញផ្សេងៗក្នុងភាពជាក់ស្តែង។

២- ដើម្បីអនុវត្តជំនាញការស្តាប់ដោយយកចិត្តទុកដាក់ ការយល់អារម្មណ៍ ជំនាញសួរសំណួរ និងសង្ខេប។

៣- ដើម្បីផ្លាស់ប្តូរបទពិសោធន៏គ្នា តាមរយៈការដើរតួ។

**សំភារៈ**

ករណីសិក្សា ១: តើខ្ញុំគួរធ្វើយ៉ាងណាចំពោះប្ដីខ្ញុំ?

ករណីសិក្សា ២: តើខ្ញុំគួរធ្វើតេស្តឈាមរកមេរោគអេដស៍ដែរទេ?

**ដំណើរការ:**

១- ប្រាប់សិក្ខាកាមថា នៅក្នុងល្បែងដើរតួនេះ អ្នកផ្តល់ប្រឹក្សានឹងត្រូវប្រើជំនាញជាច្រើន ដូចជា ការស្តាប់ ការសួរសំណួរ, ការបញ្ជាក់ និង ការសង្ខេប នៅក្នុងដំណើរនេះ។ បើអ្នកណាមានសំណួរគេអាចសួរបាន។

២- រៀបចំបែងចែកសិក្ខាកាមជា ២-៣ក្រុម ដែលមានគ្នា៤-៥នាក់ក្នុងមួយក្រុមៗ (គួរតែមានអ្នកសំរបសំរួលម្នាក់នៅប្រចាំ តាមក្រុមនិមួយៗ)។ នៅក្នុងក្រុមនិមួយៗ ម្នាក់ដើរតួជាអ្នកផ្តល់ប្រឹក្សា ម្នាក់ជាអតិថិជន ហើយអ្នកផ្សេង

ទៀត ជាអ្នកសង្កេតការណ៍ ហើយផ្តល់យោបល់នៅពេលដើរតួរួច ។ អ្នកសង្កេតការណ៍ គួរតែអង្គុយកុំអោយឆ្ងាយពេក ដើម្បី អោយ អាចស្តាប់លឺការសន្ទនា ប៉ុន្តែកុំអង្គុយជិតដៃគូល្បែងដើតួរពេកដែរ ។

៣- ចែកករណីសិក្សាទៅអោយ “អតិថិជន” ក្នុងល្បែងដើរតួ។ អោយ “អតិថិជន” ចេញក្រៅបន្ទប់ ហើយចូលមកវិញធ្វើជា “អតិថិជន”។ ផ្តល់ពេលអោយអតិថិជន ចំនួន ៥នាទី ដើម្បីត្រៀមខ្លួនរបស់គេ។ ក្រុមខ្លះអាចទទួលករណីសិក្សាលេខ១ ហើយក្រុមខ្លះទៀតទទួលករណីសិក្សាលេខ២ ។

៤- អ្នកសំរបសំរួលប្រាប់អ្នកសង្កេតការណ៍ថាពេលកំពុងសង្កេត អ្នកសង្កេតការណ៍គួរតែគិតពិចារណាលើល្បែងដើរតួ ហើយ គិតរកវិធីសួរសំណួរ ការបញ្ជាក់ ឬសង្ខេបផ្សេងទៀត បើអាចធ្វើបាន។

៥- ចាប់ផ្តើមដើរតួក្នុងការផ្តល់ប្រឹក្សា។ លើកទឹកចិត្តអោយដៃគូទាំងពីរអនុវត្តបន្តរហូតដល់ចប់ ។ បើវាលំបាកពេក អ្នកសំរបសំរួល គួរផ្តល់នូវការបង្ហើប ឬ ចង្អុលប្រាប់ខ្លះៗ ដើម្បីអោយគេអាចបន្តបាន។

៦- ន្ទាប់ពីធ្វើចប់ហើយពិភាក្សាពីល្បែងដើរតួនេះរួមគ្នាៈ តើអ្នកផ្តល់ប្រឹក្សាគិតដូចម្តេចអំពីការផ្តល់ប្រឹក្សារបស់ខ្លួន? ហើយចំពោះអតិថិជន តើគិតដូចម្តែចអំពីការផ្តល់ប្រឹក្សានោះ? តើអ្នកសង្កេតការណ៍ គិតយ៉ាងម៉េចពីការសំដែងរបស់អ្នក ដើរតួជាអ្នកផ្តល់ប្រឹក្សា និងជាអតិថិជន។ តើមានវិធីផ្សេងទៀតអ្វីខ្លះក្នុងការសួរសំណួរការសួរបញ្ជាក់ឡើងវិញ និង ការសង្ខេប... ។ល ។

៧- អ្នកសំរបសំរួលសង្កេតនិងផ្តល់យោបល់ :
តើអ្នកផ្តល់ប្រឹក្សា យល់ពីបញ្ហាដែរឬទេ?
តើការសង្ខេប ធ្វើបានត្រឹមត្រូវតាមដំណើររឿងដែរឬទេ?
តើសំណួរដែលសួរនោះ មានប្រយោជន៍សំរាប់ការពិភាក្សា ដែរឬទេ?

៨- បូកសរុបអំពីពីជំនាញនិមួយៗ និងដំណើរការនៃការផ្តល់ប្រឹក្សា ដោយប្រើផ្ទាំងបញ្ចាំងនិងឯកសារចែក។ ផ្តល់ការលើកទឹកចិត្តដល់សិក្ខាកាម ដោយគូសបញ្ជាក់ថា ជំនាញផ្តល់ប្រឹក្សា អាចកើនឡើងបាន តាមរយៈការអនុវត្តជាក់ស្តែង និងបទពិសោធន៍។

# សកម្មភាព ទី១០

## ករណីសិក្សា ទី១:

## “តើខ្ញុំគួរធ្វើយ៉ាងណាចំពោះប្តីខ្ញុំ?”

នាងនារី មានអាយុ ៤៥ឆ្នាំ។ គាត់ជាអ្នកស្រែនៅខេត្តបាត់ដំបង។ គាត់មានកូន 4 នាក់។ ប្តីគាត់ឈ្មោះ ញឹម បាន ធ្លាក់ខ្លួនឈឺអស់រយៈពេល ៤ខែហើយ។ អ្នកជិតខាងគេនិយាយថា គាត់កើតជំងឺអេដស៍។ នារី បានសំគាល់ ឃើញថា ចាប់តាំងពីប្តីរបស់គាត់ឈឺមក អ្នកជិតខាងមិនសូវមកលេងគាត់ញឹកញាប់ ដូចកាលពីមុនទេ។ នារីបាន សួរទៅប្តីគាត់ថា តើគាត់កើតអេដស៍មែនឬក៏អត់? ប្តីគាត់និយាយថាមិនមែនទេ ហើយប្រាប់នាងវិញ ថាជំងឺគាត់ អាចព្យាបាលជាបាន។ គ្រួសារគាត់បានចំណាយប្រាក់អស់ ជាច្រើនដើម្បីទិញឱសថផ្សេងៗ។ ពួកគាត់បានលក់គោ មួយនឹមទៅហើយ ប៉ុន្តែជម្ងឺរបស់ញឹមកាន់តែធ្ងន់ធ្ងរទៅៗ។ នារី មានការ ពិបាកចិត្តយ៉ាងខ្លាំង។ គាត់បានលឺគេ និយាយថា ជួនកាលមានអ្នកខ្លះបានទុកសាច់ញាតិរបស់គេចោលនៅវត្តក្បែនកេះ ដើម្បីអោយ ព្រះសង្ឃមើល ថែទាំ។ ថ្ងៃនេះ នារី មកទីរួមខេត្តបាត់ដំបងហើយជួប នឹងបុគ្គលិកផ្តល់ប្រឹក្សា។ នារី ប្រាប់បុគ្គលិកផ្តល់ប្រឹក្សា នោះថា គាត់ចង់នាំប្តីរបស់គាត់ទៅនៅវត្ត ហើយបានសាកសួរយោបល់បុគ្គលិក ផ្តល់ប្រឹក្សានោះ ថាតើគាត់ គួរធ្វើយ៉ាងណា?

# សកម្មភាពទី ១០

## ករណីសិក្សា ទី២:

## តើខ្ញុំគួរធ្វើតេស្តឈាមរកមេរោគអេដស៍ដែរទេ?

អតិថិជន ជាបុរសម្នាក់ ឈ្មោះ សុខុម គាត់ជាប៉ូលីសនៅភ្នំពេញ។ គាត់មានអាយុ ៤៣ឆ្នាំ រៀបការហើយ។ មួយឆ្នាំកន្លងមកនេះ គាត់មានទំនាក់ទំនងជាមួយស្ត្រីម្នាក់។ ថ្មីៗនេះ គាត់បានដឹងថា ស្ត្រីនេះ ក៏មានសង្សារផ្សេងទៀតដែរ។ សុខុម មិនដឹងថាតើសង្សាររបស់គាត់មានមេរោគអេដស៍ដែរឬក៏អត់ទេ ហើយថាគាត់បានឆ្លងមេរោគអេដស៍ពីនាងឬក៏អត់ឡើយ។ គាត់មិនបានប្រើស្រោមអនាម័យ នៅពេលរួមភេទ ជាមួយនាងឡើយ។ សុខុម បានមកសេវា **VCCT** ហើយសួរអ្នកផ្តល់ប្រឹក្សាថា "តើខ្ញុំគួរធ្វើតេស្តឈាមរកមេរោគអេដស៍ដែរឬទេ?"

**ផ្ទាំងបញ្ចាំងលេខ ១សំរាប់សកម្មភាព១០**

**ក. អ្នកផ្តល់ប្រឹក្សា បង្ហាញអោយឃើញ នូវភាសាកាយវិការត្រឹមត្រូវ**
(ចំងាយអង្គុយ សំលៀកបំពាក់ របៀបរបបអង្គុយ)

**ខ.សង្កេតបានល្អ លើអារម្មណ៍ របស់អតិថិជន**
(ទាំងពាក្យសំដី និង ឫកពា)

## ការស្តាប់ដ៏ល្អ

**គ.ការឆ្លើយតបបានសមរម្យ**

- ផ្តល់ពេលវេលាអោយអតិថិជន បញ្ចេញអារម្មណ៍
- បង្ហាញការយកចិត្តទុកដាក់ ដូចជាងក់ក្បាល
- សួរសំណួរនៅពេលចាំបាច់

**ឃ.សង្ខេបបានច្បាស់ ត្រឹមត្រូវ អំពីការលំបាក របស់អតិថិជន**

## ការស្តាប់ និង ការសង្ខេប

អតិថិជនខ្លះ ដែលមានបញ្ហាច្រើន អាចនិយាយច្រើន ហើយអាចនិយាយសារចុះសារឡើងដដែលៗ។ អ្នកផ្តល់ប្រឹក្សា ត្រូវសួរបញ្ជាក់អំពីបញ្ហា។ ការថាឡើងវិញនូវប្រយោគរបស់អតិថិជន នឹងធ្វើអោយអតិថិជន ឈប់ ហើយគិត បើការថាឡើងវិញរបស់អ្នកមិនត្រឹមត្រូវទេនោះ អតិថិជននឹងប្រាប់មកវិញ ។

ផ្ទាំងបញ្ចាំងលេខ ២ សំរាប់សកម្មភាព ទី១០

ផ្តល់ឱកាសអោយ
អតិថិជនបានបញ្ចេញនូវ
អារម្មណ៍ និង
ការរំជួលចិត្ត

## ការសួរសំណួរ

ដើម្បីបំភ្លឺអោយឃើញ
ច្បាស់នូវបញ្ហា និង
តាមដានដំណើររឿង

ផ្តល់ឱកាសអោយអតិថិជន
បានគិត ពិនិត្យមើល
ឡើងវិញ និង វិភាគ

**ផ្ទាំងបញ្ចាំងលេខ៣ សំរាប់សកម្មភាពទី ១០**

## សង្ខេប

- ដើម្បីអោយឈានទៅដល់ការយល់ដឹងដូចគ្នាជាមួយ នឹងអតិថិជន
- ប្រើឃ្លាខ្លី ប៉ុន្តែមានន័យ
- មិនបង្វែរសាច់រឿងរបស់អតិថិជន
- សង្ខេបពីបញ្ហា អារម្មណ៍ និងផែនការ

ផ្ទាំងបញ្ចាំងលេខ ៤សំរាប់សកម្មភាព ទី១០

# ការប្រើប្រាស់ជំនាញផ្សេងៗក្នុងការផ្តល់ប្រឹក្សា

| | | |
|---|---|---|
| ១ | **បង្ហាញអោយឃើញនូវការទទួល អតិថិជន និង ការលំបាក(បញ្ហា)របស់គេ** | • ស្តាប់ដោយយកចិត្តទុកដាក់<br>• បើកទូលាយចិត្តគំនិត/ទស្សនៈ មិនវិនិច្ឆ័យលើទង្វើ ឬ ឥរិយាបថ ការប្រព្រឹត្តដែលអតិថិជននិយាយ |
| ២ | **ពិភាក្សាពីរឿងរ៉ាវ/បញ្ហា ដែលមានសារៈសំខាន់ ចំពោះតម្រូវការ និងមានផល ប្រយោជន៍ដល់ អតិថិជន** | • ស្តាប់ដោយយកចិត្តទុកដាក់<br>• សង្ខេបពីរឿងរ៉ាវ/បញ្ហា និងអារម្មណ៍ បានសមស្រប<br>• ទុកគំនិតនិងតម្រូវការរបស់អ្នកផ្តល់ប្រឹក្សា ដោយឡែក កុំគិតជំនួសអតិថិជន |
| ៣ | **ជួយអតិថិជនអោយបញ្ចេញនូវបញ្ហា និង អារម្មណ៍របស់គាត់** | • ស្តាប់ដោយយកចិត្តទុកដាក់<br>• សួរសំណួរដែលពាក់ព័ន្ធដោយសមស្រប<br>• ឆ្លុះបញ្ចាំងពីអារម្មណ៍របស់អតិថិជន |
| ៤ | **ជួយអតិថិជនអោយរកមធ្យោបាយដោះស្រាយបញ្ហារបស់ខ្លួនដើម្បីទប់ទល់ជាមួយនឹងបញ្ហារបស់គាត់។** | • សួរសំណួរដែលជួយអតិថិជនអោយគិតរិះរកនូវ ជំរើសនានា<br>• ផ្តល់ពត៌មានដែលមានប្រយោជន៍។ |
| ៥ | **ផ្តល់ការលើកទឹកចិត្ត និងការគាំទ្រផ្លូវចិត្ត។** | • ស្តាប់ដោយយកចិត្តទុកដាក់<br>• ឆ្លុះបញ្ចាំងពីអារម្មណ៍របស់អតិថិជន<br>• បង្ហាញអោយឃើញនូវការយកចិត្តទុកដាក់<br>• បង្ហាញអោយឃើញពីភាពជឿជាក់ លើអតិថិជន |
| ៦ | **រក្សាការសម្ងាត់របស់គាត់** | • ប្រាប់អតិថិជនថាការរក្សាការសម្ងាត់ គឺជាគោលការណ៍របស់សេវា/អង្គការ។ |

**ផ្ទាំងបញ្ចាំងលេខ ៥ សំរាប់សកម្មភាពទី១០**

## ដំណើរការផ្តល់ប្រឹក្សា

**ទំនាក់ទំនងស្និទ្ធស្នាលល្អ**

**ពិនិត្យរកមើលបញ្ហា**

**បញ្ហា**

**វិភាគបញ្ហា**

មូលហេតុរបស់បញ្ហា

តម្រូវការរបស់អតិថិជន និង មធ្យោបាយដោះស្រាយបញ្ហា

**ការដោះស្រាយបញ្ហា**

**ជំរើសរបស់អតិថិជន**

- ជំរើសមានតែមួយ
- គិតពិចារណាលើជំរើសដែលមានពីរ
- ជំរើសដែលមានច្រើន

**ការបញ្ជូនបន្ត**

- ពត៌មានអំពីសេវានានា
- គំនិត ការយល់ឃើញ របស់អតិថិជន
- ការរក្សាការសម្ងាត់

<u>**ការពិចារណាអំពីជំរើសនានា**</u>

- ពិនិត្យមើលគុណសម្បត្តិ និងគុណវិបត្តិនៃជំរើសនីមួយៗ
- ពិនិត្យមើលផលប៉ះពាល់ដែលអាចកើតឡើង
- គិតអំពីអ្វីដែលអាចកើតឡើងបាន
- ថ្លឹងថ្លែង វាយតំលៃ និងជ្រើសរើសយកជំរើសណាមួយ
- ធ្វើផែនការ និងការរៀបចំ

**ផ្តល់ការលើកទឹកចិត្ត**

**តាមដានបន្ត**

**ឧទាហរណ៍នៃការសន្ទនា ដែលអនុវត្តតាមការផ្តល់ប្រឹក្សា ដកចេញពីករណីសិក្សាលេខ 2**

**បញ្ហា:** អតិថិជនព្រួយថា គាត់អាចឆ្លងមេរោគអេដស៍

**មូលហេតុនៃបញ្ហា:** ព្រោះអតិថិជន បានរួមរ័ក្សដោយមិនមានសុវត្ថិភាព ហើយដៃគូរបស់គាត់ក៏ប្រឈមមុខនឹងការឆ្លងមេរោគអេដស៍ដែរ ។.

**តំរូវការរបស់អតិថិជន:** សង្ស័យថាតើគាត់មានមេរោគអេដស៍ដែរឬអត់? ចង់ដឹងថាតើគាត់មានមេរោគអេដស៍ ឬអត់

**ការដោះស្រាយបញ្ហា:** អតិថិជនកំពុងគិតពីការធ្វើតេស្តឈាមរកមេរោគអេដស៍ ប៉ុន្តែគាត់មិនទាន់ប្រាកដនៅឡើយ ថាតើគាត់ អាចទទួលយកលទ្ធផលតេស្តឈាមបានឬអត់ ប្រសិនបើលទ្ធផលតេស្តឈាមនេះចេញមកវិជ្ជមាន ។

**ជំរើស:** គិតពិចារណារវាងជំរើសពីរ គឺរវាងការធ្វើតេស្តឈាម និងការមិនធ្វើតេស្តឈាម ។

**ការពិចារណាលើជំរើស:** ១- ពិនិត្យមើលពីគុណសម្បត្តិ និងគុណវិបត្តិនៃជំរើសទាំងពីរ ។

អ្វីទៅជាគុណសម្បត្តិ និងគុណវិបត្តិនៃការធ្វើតេស្ត? អតិថិជន បានវិភាគពីគុណសម្បត្តិនៃការធ្វើតេស្ត ដែលគាត់អាចនឹងដឹងភ្លាមថា តើគាត់មានមេរោគអេដស៍ឬអត់ ។ រួចគាត់គិតនឹងប្រើស្រោមអនាម័យជាមួយអ្នកណាដែលគាត់រួមរ័ក្សជាមួយ ។ គុណវិបត្តិនោះគឺបើលទ្ធផលតេស្ត ចេញមកវិជ្ជមាននោះ គាត់នឹងមិនអាចទទួលយកវា បានឡើយ ព្រោះថាគាត់ចេះតែគិតថា គាត់នឹងធ្លាក់ខ្លួនឈឺ ហើយស្លាប់ ។ គាត់ភ័យខ្លាចថា វានឹងតានតឹងផ្នែកអារម្មណ៍ សំរាប់រូបគាត់ពេក ។

១-២ អ្វីខ្លះទៅជាគុណសម្បត្តិ និងគុណវិបត្តិនៃការមិនធ្វើតេស្ត? អតិថិជន បានវិភាគថា បើគាត់មិនធ្វើតេស្ត គាត់មិនចាំបាច់ត្រូវដឹង និងទទួលយកលទ្ធផលតេស្ត ( ថាតើគាត់ឆ្លងមេរោគអេដស៍ ឬអត់) ។ ដូច្នេះ វានឹងជួយគាត់អោយមានអារម្មណ៍ល្អ មួយរយ:ហើយមិនចាំបាច់មានការតានតឹងអារម្មណ៍ឡើយ ។ ក៏ប៉ុន្តែបើមិនធ្វើតេស្តគាត់នៅតែគិតពីរឿងនេះ និងមានមន្ទិលសង្ស័យ នៅក្នុងចិត្តគាត់ ។

២- ពិនិត្យមើលពីផលប៉ះពាល់នានាដែលអាចកើតឡើង

២-១ បើគាត់ជ្រើសរើសយកការធ្វើតេស្តឈាម ហើយលទ្ធផលតេស្តឈាមនោះ ចេញមកវិជ្ជមាន ។ ប្រសិនបើគាត់ មិនអាចទទួលយកបានទេនោះ គឺនឹងមានផលប៉ះពាល់ផ្លូវ ចិត្តយ៉ាងច្រើន ហើយ គាត់មិនដឹងថាផលប៉ះពាល់នោះ វាមានរយៈពេលយូរប៉ុណ្ណាឡើយ ។

២-២ នៅពេលអនាគត ជាការចាំបាច់ណាស់ដែលគាត់ត្រូវប្រើស្រោមអនាម័យគ្រប់ពេលដែលរួមភេទ ប្រសិនបើគាត់មិនមានមេរោគអេដស៍ទេនោះ ការធ្វើបែបនេះនឹងបង្ការគាត់មិនអោយឆ្លងមេរោគអេដស៍ ហើយប្រសិនបើគាត់បានឆ្លងមេរោគហើយនោះ វានឹងជួយការពារដៃគូរួមភេទរបស់គាត់ពីការឆ្លងមេរោគអេដស៍ដែរ ។

៣- គិតអំពីអ្វីដែលអាចកើតឡើងបាន

បន្ទាប់ពីពិចារណាពីចំណុចទាំងនេះហើយ អ្វីដែលអាចកើតឡើងគឺថាអតិថិជនប្រហែលអាចសំរេចចិត្តថាមិនធ្វើតេស្តឈាមទេ ។

៤- ថ្លឹងថ្លែង វាយតំលៃ និងជ្រើសរើសយកជំរើសណាមួយ

អតិថិជន សំរេចចិត្តថាមិនធ្វើតេស្តទេនៅពេលនេះ ។

៥- ធ្វើផែនការ និង ការរៀបចំ

អ្នកផ្តល់ប្រឹក្សា ជួយអតិថិជនអោយឈានទៅដល់ការសំរេចចិត្ត បើមិនធ្វើតេស្តឈាមនៅពេលនេះ គាត់នឹងមិនទាន់ដឹងថាគាត់មានមេរោគអេដស៍ ឬអត់ ។ ព្យាយាមបន្ថយការព្រួយបារម្ភ ទទួលយកនូវអារម្មណ៍ និងការគិតរបស់ ខ្លួន ។ ធ្វើអោយខ្លួនគាត់ស៊ាំនឹងស្រោមអនាម័យ រៀនប្រើវា អោយបានត្រឹមត្រូវ ។

**ផ្តល់ការលើកទឹកចិត្ត:** អ្នកផ្តល់ប្រឹក្សា សង្កេត ពីចំណុចខ្លាំង និងសមត្ថភាពរបស់អតិថិជន ដើម្បីជួយអោយអតិថិជនមានការជឿជាក់លើខ្លួនឯង ហើយគិតថាគាត់មានសមត្ថភាពនឹងដោះស្រាយបញ្ហារបស់ខ្លួនគាត់បាន ។

**តាមដានបន្ត:** ផ្តល់ឱកាសដល់អតិថិជន អោយមកទទួលការផ្តល់ប្រឹក្សា នៅពេលណាដែលគាត់ត្រូវការ ។

*********************************

# សកម្មភាព ទី១១

# ការផ្តល់ប្រឹក្សាបង្ការ

# ការវាយតំលៃលើការប្រឈមមុខ និង

# ផែនការកាត់បន្ថយការប្រឈមមុខនឹងការឆ្លងមេរោគអេដស៍

# សកម្មភាព ទី១១

## ការផ្តល់ប្រឹក្សាបង្ការ ការវាយតំលៃលើការប្រឈមមុខ និង ផែនការកាត់បន្ថយការប្រឈមមុខ នឹងការឆ្លងមេរោគអេដស៍

ការផ្តល់ប្រឹក្សា និងធ្វើតេស្តរកមើលមេរោគអេដស៍ដោយស្ម័គ្រចិត្ត(VCCT) មានលក្ខណៈជាសេវាបង្ការ ក្នុងគោល បំណង ជំរុញការផ្លាស់ប្តូរការប្រព្រឹត្ត ដើម្បីបង្ការការឆ្លងនិងចំលងមេរោគអេដស៍ទៅអ្នកផ្សេងទៀត។ សេវានេះផ្តល់នូវ គុណប្រយោជន៍ សំរាប់អ្នកដែលធ្វើតេស្តទៅឃើញអវិជ្ជមាន ឬ វិជ្ជមានក៏ដោយ។ ការបង្ការទីមួយ មានន័យថា អតិថិជនដែលទទួលលទ្ធផល តេស្តឈាមអវិជ្ជមាន ត្រូវបានលើកទឹកចិត្តអោយកែប្រែការប្រព្រឹត្តរួមភេទដ៏ប្រថុយគ្រោះថ្នាក់របស់គេ ដើម្បីរក្សាភាព អវិជ្ជមានគ្មានផ្ទុកមេរោគអេដស៍របស់គេ ហើយនិងកាត់បន្ថយការប្រឈមមុខនឹងការឆ្លងមេរោគអេដស៍របស់គេ នាពេល អនាគត។ ការបង្ការទីពីរមានន័យថា ដើម្បីជួយអោយអតិថិជនដែលដឹងថាខ្លួនគេមានផ្ទុកមេរោគអេដស៍ហើយកាត់បន្ថយ ការប្រ ព្រឹត្តផ្លូវភេទដែលប្រឈមមុខនឹងការឆ្លងមេរោគអេដស៍បន្ថែមទៀត លើសពីនេះទៀតគឺជួយអោយគាត់រៀនពីរបៀប ការពារការចំលង មេរោគអេដស៍ទៅដៃគូរួមភេទរបស់គេ។

ការផ្តល់ប្រឹក្សាពីមេរោគអេដស៍ ទាមទារអោយមានការនិយាយជាក់លាក់ច្រើនពីការរួមភេទ។ ជាពិសេសនៅប្រទេសកម្ពុជា ផ្លូវចំបងនៃការចំលងមេរោគអេដស៍គឺតាមរយៈផ្លូវភេទ។ ក្នុងការពិភាក្សាជាមួយអតិថិជន អ្នកផ្តល់ប្រឹក្សាត្រូវនិយាយពីការ ប្រព្រឹត្តផ្លូវភេទរបស់គាត់ និងការប្រឈមមុខនឹងគ្រោះថ្នាក់ការឆ្លងមេរោគអេដស៍ពីការប្រព្រឹត្តបែបនោះ។ ដូច្នេះ អ្នកផ្តល់ប្រឹក្សា ត្រូវតែមានសមត្ថភាពក្នុងការនិយាយអំពីផ្លូវភេទ ហើយមានចំណេះដឹងស្តីពីការរួមភេទ ការប្រព្រឹត្តផ្លូវភេទ និង ការឆ្លងមេរោគ នានាតាមរយៈការរួមភេទ។

គោលការណ៍សំខាន់ស្តីពីការផ្លាស់ប្តូរការប្រព្រឹត្ត គឺការកំណត់រកអោយឃើញនូវឧបសគ្គ/ការរារាំង និង ហេតុជំរុញទឹកចិត្ត /ផល ប្រយោជន៍ សំរាប់ការផ្លាស់ប្តូរការប្រព្រឹត្តនោះ។ អ្នកផ្តល់ប្រឹក្សាត្រូវធ្វើការជាមួយនឹងអតិថិជន ដើម្បីកំណត់រកអោយឃើញពី ចំណុចទាំងនេះ។

ការវាយតំលៃការប្រឈមមុខនឹងការឆ្លងមេរោគអេដស៍ និងការរកមធ្យោបាយដើម្បីកាត់បន្ថយការប្រឈមមុខ អាចធ្វើនៅ ពេលផ្តល់ប្រឹក្សាមុនធ្វើតេស្ត ចំណែកឯផែនការកាត់បន្ថយការប្រឈមមុខជាក់លាក់សំរាប់ទាំងអតិថិជននិមួយៗ និងដៃគូរួម ភេទរបស់គេ អាចពិភាក្សាអោយបានច្រើននៅពេលផ្តល់ប្រឹក្សាក្រោយពេលធ្វើតេស្ត។ ការបង្ហាញពីការប្រើស្រោម អនាម័យ អាចធ្វើឡើង នៅពេលណាដែលសមស្រប។

**គោលបំណង:**

១- ដើម្បីរៀន និងអនុវត្តជាក់ស្តែងនូវការវាយតំលៃលើការប្រឈមមុខជាមួយនឹងអតិថិជន។

២- ដើម្បីរៀនពីរបៀបធ្វើការជាមួយនឹងអតិថិជនក្នុងការបង្កើនសមត្ថភាពការពារខ្លួនគេ និងដើម្បីអោយមានជំរើសច្រើនសំរាប់ការបង្ការ។

៣- ដើម្បីរៀនពីរបៀបធ្វើការជាមួយនឹងអតិថិជនក្នុងការជ្រើសរើសផែនការកាត់បន្ថយការប្រឈមមុខដែលសមស្របសំរាប់បុគ្គល ម្នាក់ៗ ។

៤- ដើម្បីរៀនពីការផ្តល់ប្រឹក្សាដើម្បីបង្ការ និងរបៀបលើកទឹកចិត្តអោយមានការផ្លាស់ប្តូរទស្សនៈ និងការប្រព្រឹត្ត ។

**វិធីសាស្ត្រ:**

ល្បែងដើរតួ ដោយចែកជាបីក្រុមគឺ មាន អ្នកផ្តល់ប្រឹក្សាម្នាក់ អតិថិជនម្នាក់ និងក្រុមអ្នកសង្កេតការណ៍។

**សំភារៈ:**

ឯកសារករណីសិក្សាចំនួន 3

**ដំណើរការ:**

1. ចាប់ផ្តើមដោយពន្យល់ណែនាំពីគោលបំណង និងចំណុចសំខាន់ៗ ក្នុងការផ្លាស់ប្តូរការប្រព្រឹត្ត និងការផ្តល់ប្រឹក្សាដើម្បីបង្ការ។ ប្រើផ្ទាំងបញ្ចាំងលេខ ១-៤។
2. ប្រាប់សិក្ខាកាមថា សកម្មភាពនេះ ទាមទារអោយមានការរួមបញ្ចូលគ្នានូវការវាយតំលៃលើការប្រឈមមុខនឹងការឆ្លងមេរោគអេដស៍ និងជំនាញផ្តល់ប្រឹក្សាផ្សេងៗរួមមាន ការស្តាប់ ការសួរសំណួរ ការសង្ខេប និងការឆ្លុះបញ្ចាំងអារម្មណ៍ ដើម្បីជួយអោយអតិថិជនដឹងពីការប្រឈមមុខរបស់ខ្លួន និងរៀបចំផែនការសំរាប់ពេលអនាគត។ អ្នកផ្តល់ប្រឹក្សាត្រូវដឹង និងអាចនិយាយពីការប្រឈមមុខ ទាក់ទងនឹងការប្រព្រឹត្តផ្សេងៗរបស់អតិថិជន។
3. ចែកសិក្ខាកាមជាបីក្រុមគឺ មាន អ្នកផ្តល់ប្រឹក្សាម្នាក់ អតិថិជនម្នាក់ និងអ្នកនៅសល់ជាអ្នកសង្កេតការណ៍
4. អ្នកសំរបសំរួល អោយទាំងអតិថិជន និងអ្នកផ្តល់ប្រឹក្សា ត្រៀមរៀបចំតួនាទីរបស់គេជាអតិថិជន និងអ្នកផ្តល់ប្រឹក្សា។
5. បន្ទាប់ពីល្បែងដើរតួ អ្នកសំរបសំរួលសួរក្រុមនិមួយៗអំពី :

   សួរអ្នកផ្តល់ប្រឹក្សា:

   - អ្វីទៅជាបញ្ហារបស់អតិថិជន?
   - តើអ្នកមានអារម្មណ៍យ៉ាងណាចំពោះអតិថិជននៅពេលផ្តល់ប្រឹក្សានោះ?

- សូមអោយលើកឧទាហរណ៍នូវការសង្កេបឡើងវិញដែលគាត់បានធ្វើ

សួរអតិថិជនៈ

- តើអ្នកបានរកឃើញជំរើសច្រើនជាងមុនរឺទេ បន្ទាប់ពីបានជជែកពិភាក្សាជាមួយអ្នកផ្តល់ប្រឹក្សានោះ?
- តើអ្នកពេញចិត្តនឹងការផ្តល់ប្រឹក្សាដែរឬទេ? ចំពោះផ្នែកណា?

អ្នកសង្កេតការណ៍ៈ

- តើអ្វីខ្លះជាបញ្ហាចំបងៗ របស់អតិថិជន?
- តើអតិថិជន បានឆ្លុះបញ្ចាំងពីអារម្មណ៍របស់ខ្លួនគេយ៉ាងម៉េចខ្លះ?
- តើអ្នកផ្តល់ប្រឹក្សា បានធ្វើអ្វីខ្លះ?
- ក្នុងអំឡុងពេលនៃការផ្តល់ប្រឹក្សា តើអតិថិជនមានអារម្មណ៍យ៉ាងម៉េចដែរ?

**ការវាយតំលៃលើការប្រឈមមុខ និង ផែនការកាត់បន្ថយការប្រឈមមុខនឹងការឆ្លងមេរោគអេដស៍**

1. អ្នកផ្តល់ប្រឹក្សា និងអតិថិជន ធ្វើការវាយតំលៃរួមគ្នាលើការប្រឈមមុខ។ អ្នកផ្តល់ប្រឹក្សាអាចផ្តល់ពតិមាន ក៏ប៉ុន្តែគួរចៀសវាងការបង្គាប់បញ្ជា ដោយសួរសំណួរៈ
   - តើអ្វីទៅ ដែលអ្នកគិតថាជាការប្រព្រឹត្តប្រឈមមុខសំរាប់រូបអ្នក?
   - តើអ្នកអាចធ្វើអ្វីបានខ្លះដើម្បីកាត់បន្ថយការប្រឈមមុខទាំងនេះ?
2. ពិនិត្យរកមើលពីជំរើសនានា សំរាប់កាត់បន្ថយការប្រឈមមុខ
   - ពតិមានស្តីពីប្តី/ប្រពន្ធ ឬដៃគូរួមភេទ
   - មធ្យោបាយ ឬបទពិសោធន៍សំរាប់កាត់បន្ថយនូវការប្រឈមមុខដែលអតិថិជនធ្លាប់បានប្រព្រឹត្តកន្លងមក។
   - ជំនាញខាងផ្នែកចរចារ
   - ការប្រាស្រ័យទាក់ទងជាមួយនឹងដៃគូ
3. អ្នកផ្តល់ប្រឹក្សានិយាយតិច តែស្តាប់អោយបានច្រើន
4. ជួយអតិថិជនអោយជ្រើសរើសនូវវិធីដែលសមស្របសំរាប់គាត់។ បើការប្រើស្រោមអនាម័យ គឺជាផ្នែកមួយនៃផែនការកាត់បន្ថយការប្រឈមមុខ សូមសួរអតិថិជនថា តើគាត់ដឹងអ្វីខ្លះអំពីស្រោមអនាម័យ ហើយសុំអោយអតិថិជនពាក់ស្រោមអនាម័យលើលឹង្គសិប្បនិមិត្ត មុននឹងអ្នកផ្តល់ប្រឹក្សាបង្ហាញពីរបៀបពាក់ ស្រោមអនាម័យ។
5. អ្នកផ្តល់ប្រឹក្សាពិនិត្យរកមើលគុណប្រយោជន៍ផ្សេងៗមកលើកទឹកចិត្តអោយអតិថិជនផ្លាស់ប្តូរការប្រព្រឹត្ត

# សកម្មភាព ទី ១១. ការផ្តល់ប្រឹក្សាដើម្បីបង្ការ

## ករណីសិក្សាទី ១:

**ចិត្រា** ជាអតិថិជនបុរសនៅលីវ មានអាយុ ២៥ឆ្នាំ។ គាត់បានធ្វើការជាមួយក្រុមហ៊ុនមួយអស់រយៈពេលជិតពីរឆ្នាំហើយ។ ចិត្រាធ្លាប់មានសង្សារម្នាក់។ នាងបានព្រមរួមរ័ក្សជាមួយគាត់ ហើយជានិច្ចកាលទទូចចង់រៀបការជាមួយគាត់ ប៉ុន្តែ ចិត្រាមិនទាន់មានអារម្មណ៍ថាបានត្រៀមខ្លួនសំរាប់រៀបការនៅឡើយ។ ជារឿយៗ គេប្រកែកគ្នាពីរឿងនេះ ហើយចុងបញ្ចប់ ក៏បែកគ្នាទៅ។ ចិត្រា មិនចង់មានសង្សារថ្មីឡើយ ដោយគិតថាវានឹងឈានទៅដល់រឿងដដែលដូចគ្នានេះ។ ដូច្នេះនៅពេលចង់រួមរ័ក្សគាត់ទៅជាមួយស្រីឡង់សេស្រាបៀរ ដែលគាត់គិតថាមិនមានជំងឺ។ ពេលខ្លះ ស្រីឡង់សេស្រាបៀរបានសុំអោយគាត់ប្រើស្រោមអនាម័យហើយពេលខ្លះទៀត មិនបានប្រើស្រោមទេ។

ថ្ងៃមួយ ចិត្រា បានលឺថា មិត្តរបស់គាត់ម្នាក់បានស្លាប់ដោយសារជំងឺអេដស៍។ គាត់ភ័យខ្លាចថា គាត់អាចនឹងឆ្លងមេរោគអេដស៍ដែរ។ គាត់បានមកសេវា VCCT ដើម្បីធ្វើតេស្តឈាមរកមេរោគអេដស៍។ លទ្ធផលតេស្តឈាមចេញមកអវិជ្ជមាន។ ចិត្រាបានធូរក្នុងចិត្ត ហើយចង់ការពារខ្លួនកុំអោយឆ្លងមេរោគអេដស៍។ គាត់បន្តជួបពិភាក្សាជាមួយអ្នកផ្តល់ប្រឹក្សា ។

**<u>បញ្ហា:</u>**

អតិថិជនចង់ការពារកុំអោយឆ្លងមេរោគអេដស៍ ប៉ុន្តែមិនចង់ឈប់លេងស្រីទេ។ អតិថិជនមិនចូលចិត្តប្រើស្រោមអនាម័យព្រោះគាត់មានអារម្មណ៍ថា វាមិនដូចពីធម្មជាតិ។

# សកម្មភាពទី១១.  ការផ្តល់ប្រឹក្សាដើម្បីបង្ការ

## ករណីសិក្សាទី ២:

សុផាណា ជាអតិថិជនស្រី មានអាយុ ២២ឆ្នាំ។ នាងមកពីខេត្តកំពង់ចាម។ សុផាណា បានធ្វើការជាស្រីឡង់សេស្រាបៀរនៅភ្នំពេញរយៈពេលមួយឆ្នាំហើយ។ ប្រាក់ចំណូលរបស់នាងពីការលក់ស្រាបៀរបានតែ ៤0ដុល្លាក្នុងមួយខែ។ ទោះបីជានាងមានសង្សារម្នាក់ ឈ្មោះ វុទ្ធី អាយុ 26ឆ្នាំ ក៏ដោយ ក៏សុផាណា តែងតែទៅជាមួយភ្ញៀវ ដើម្បីនាងអាចរកប្រាក់បានច្រើន ថែមទៀតដែរ។ ភ្ញៀវភាគច្រើនរបស់សុផាណា គឺ បុរសអ្នកមាន១មកពីភ្នំពេញ ហើយពួកគេមើលពីខាងក្រៅទៅ ដូចជា ស្អាត គ្មានជំងឺ។ ពេលខ្លះ សុផាណា បានសុំអោយភ្ញៀវប្រើស្រោមអនាម័យ ប៉ុន្តែពេលខ្លះទៀត ពួកគេមិនអាចរកស្រោមបាន ទេ។

ពេលរួមរ័ក្សជាមួយ វុទ្ធី សុផាណា មិនប្រើស្រោមឡើយ ព្រោះ វុទ្ធី មិនចូលចិត្តវា។ នាងក៏ចង់បង្ហាញអោយវុទ្ធីឃើញដែរថានាងមានភក្តី ភាព និងស្មោះត្រង់ ប្រគល់ខ្លួនអោយវុទ្ធី ហើយស្រឡាញ់គាត់។

ថ្ងៃមួយ សុផាណា នឹកខ្លាចពីខ្លួននាង ដោយលឺថាមានស្ត្រីឡង់សេស្រាបៀរខ្លះធ្លាក់ខ្លួនឈឺដោយសារអេដស៍ ព្រោះថាពេលខ្លះនាងប្រើស្រោម ហើយពេលខ្លះទៀតមិនបានប្រើ។ នាងមិនដឹងថា តើ វុទ្ធី ធ្លាប់មានសង្សារផ្សេងពីមុនមកដែរឬទេ? នាងបានបបួល វុទ្ធី ទៅធ្វើតេស្តឈាមរកមេរោគអេដស៍ ប៉ុន្តែ វុទ្ធី បានបដិសេធ ដោយនិយាយថា គាត់មិនមានការប្រឈមមុខអ្វីទេ ដូច្នេះ មិនចាំបាច់ធ្វើតេស្តឈាមទេ។

សុផាណា បានមកសេវា VCCT មួយ នៅភ្នំពេញ។ នៅពេលទទួលលទ្ធផលតេស្តឈាមអ្នកផ្តល់ប្រឹក្សាបានប្រាប់នាងថា នាងគ្មានផ្ទុក មេរោគអេដស៍ទេ។ នាងអរណាស់ ហើយចង់បានការណែនាំខ្លះ១ពីអ្នកផ្តល់ប្រឹក្សាដើម្បីកុំអោយឆ្លងមេរោគអេដស៍។

## <u>បញ្ហា:</u>

អតិថិជនចង់ការពារខ្លួននាងពីការឆ្លងមេរោគអេដស៍ ក៏ប៉ុន្តែ មានការលំបាកនឹងពិភាក្សា ឬចរចារជាមួយភ្ញៀវ និងសង្សាររបស់នាងអំពីការប្រើស្រោមអនាម័យ។

# សកម្មភាព ទី១១. ការផ្តល់ប្រឹក្សាដើម្បីបង្ការ

## ករណីសិក្សាលេខ ៣៖

អតិថិជនស្រី ឈ្មោះ ស៊ីណា អាយុ ២៥ឆ្នាំ។ ថ្មីៗនេះ នាងបានដឹងថា ប្តីនាងមានផ្ទុកមេរោគអេដស៍។ សុខភាពប្តីនាង នៅល្អនៅឡើយទេ ហើយគាត់ចង់រួមរ័ក្សជាមួយស៊ីណា។ ស៊ីណា បានមកសេវា VCCT ដើម្បីធ្វើតេស្តឈាមរកមេរោគអេដស៍។ នៅពេលទទួល លទ្ធផលតេស្តឈាមអ្នកផ្តល់ប្រឹក្សាបានប្រាប់ នាងថា នាងមិនមានផ្ទុកមេរោគអេដស៍ទេ។ ស៊ីណា សប្បាយចិត្តណាស់ប៉ុន្តែមិន ដឹងថាត្រូវធ្វើយ៉ាងណាជាមួយប្តីនាង។ ពីឥឡូវនេះតទៅនាងមាន អារម្មណ៍ស្ទាក់ស្ទើរនឹងរួមរ័ក្សជាមួយប្តីនាងដោយខ្លាចឆ្លង មេរោគអេដស៍។ ប៉ុន្តែ បើនាងបដិសេធដាច់ណាត់តែម្តងពេកនោះ ប្តីនាងអាចនឹងខឹងនាង។

**<u>បញ្ហា៖</u>**

អតិថិជន បានសួរថា តើនាងគួរតែបន្តរួមរ័ក្សជាមួយនឹងប្តីនាងតទៅទៀត ឬយ៉ាងណា? បើនាងបន្តរួមរ័ក្សជាមួយគាត់ទៀត តើនាង គួរធ្វើអ្វីខ្លះ? តើត្រូវធ្វើយ៉ាងម៉េចដើម្បីបន្ថយនូវការប្រឈមមុខ? នាងបានលឺពីស្រោមអនាម័យ ប៉ុន្តែមិន ដែលធ្លាប់ឃើញនិងប្រើវាពីមុនមកទេ។ តើនាងគួរធ្វើយ៉ាងណា?

ផ្ទាំងបញ្ចាំងលេខ១ សំរាប់សកម្មភាពទី១១

ដើម្បីអោយអតិថិជនអាចវាយតំលៃលើ
ការប្រឈមមុខរបស់ខ្លួន

## ការផ្តល់ប្រឹក្សា
## ដើម្បីបង្ការ

ដើម្បីជួយអតិថិជនអោយរិះរកមធ្យោបាយ ជាក់
ស្តែង ដើម្បីបង្ការខ្លួន និង ដៃគូគេពីការឆ្លងមេរោគ
អេដស៍

ផ្ទាំងបញ្ចាំងលេខ២ សំរាប់សកម្មភាពទី១១

**កត្តាដែលជួយ ក្នុងការផ្ដល់ប្រឹក្សាបន្ទារ**

១
ទំនាក់ទំនងស្និតស្នាលនៅពេល ផ្ដល់ការប្រឹក្សាទាំងមូល

២
សួរសំណួរចំគោលដៅ

៣
ដឹងពីអារម្មណ៍ផ្ទាល់ខ្លួន (របស់អ្នកផ្ដល់ប្រឹក្សា) ចំពោះអតិថិជន

៤
ចំណេះដឹងស្ដីពីមេរោគអេដស៍/ជម្ងឺអេដស៍ ការរួមភេទ ការប្រឈមមុខនឹង ការចំលងមេរោគអេដស៍ និង ការរួមភេទ ដែលមានសុវត្ថិភាព

៥
កន្លែងដែលផ្ដល់ប្រឹក្សា ជាកន្លែងស្ងាត់កំបាំង

៦
ប្រើភាសារសាមញ្ញៗ

៧
បង្ហាញអោយឃើញនូវ ការយល់ពីអារម្មណ៍របស់ អតិថិជន

**ផ្ទាំងបញ្ចាំងលេខ៣ សំរាប់សកម្មភាព ទី១១**

**ការវាយតំលៃលើការប្រឈមមុខ និង ផែនការកាត់បន្ថយការប្រឈមមុខនឹងការឆ្លងមេរោគអេដស៍**

១. អ្នកផ្តល់ប្រឹក្សា និងអតិថិជន ធ្វើការវាយតំលៃរួមគ្នាលើការប្រឈមមុខ។

អ្នកផ្តល់ប្រឹក្សាអាចផ្តល់ ពតិមាន ក៏ប៉ុន្តែគួរចៀសវាងការបង្គាប់បញ្ជា ដោយសួរសំណួរៈ

- តើអ្វីទៅ ដែលអ្នកគិតថាជាការប្រព្រឹត្តប្រឈមមុខសំរាប់រូបអ្នក?
- តើអ្នកអាចធ្វើអ្វីបានខ្លះដើម្បីកាត់បន្ថយការប្រឈមមុខទាំងនេះ?

២. ពិនិត្យរកមើលពីជំរើសនានា សំរាប់កាត់បន្ថយការប្រឈមមុខ

- ពតិមានស្តីពីប្តី/ប្រពន្ធ ឬដៃគូរួមភេទ
- មធ្យោបាយ ឬបទពិសោធន៍សំរាប់កាត់បន្ថយនូវការប្រឈមមុខដែលអតិថិជន ធ្លាប់បាន ប្រព្រឹត្ត កន្លងមក។
- ជំនាញខាងផ្នែកចរចារ
- ការប្រាស្រ័យទាក់ទងជាមួយនឹងដៃគូ

៣. អ្នកផ្តល់ប្រឹក្សានិយាយតិច តែស្តាប់អោយបានច្រើន

៤. ជួយអតិថិជនអោយជ្រើសរើសនូវវិធីដែលសមស្របសំរាប់គាត់។ បើការប្រើស្រោមអនាម័យ គឺជាផ្នែកមួយ នៃផែនការកាត់បន្ថយការប្រឈមមុខ សូមសួរអតិថិជនថា តើគាត់ដឹងអ្វីខ្លះអំពីស្រោមអនាម័យ ហើយសុំ អោយអតិថិជនពាក់ស្រោមអនាម័យលើលឹង្គសិប្បនិមិត្ត មុននឹងអ្នកផ្តល់ប្រឹក្សាបង្ហាញពីរបៀបពាក់ ស្រោម អនាម័យ។

៥. អ្នកផ្តល់ប្រឹក្សាពិនិត្យរកមើលគុណប្រយោជន៍ផ្សេងៗមកលើកទឹកចិត្តអោយអតិថិជនផ្លាស់ប្តូរ ការប្រព្រឹត្ត

ផ្ទាំងបញ្ចាំងលេខ ៤ សំរាប់សកម្មភាពទី ១១

**ការផ្លាស់ប្តូរការប្រព្រឹត្ត គឺ មិនមែនជាការងាយស្រួលទេ**

ការប្រព្រឹត្តរបស់បុគ្គលម្នាក់ៗ ប្រែប្រួល ទៅតាមអាយុ បទដ្ឋានសង្គម និង ការអោយតំលៃរបស់សង្គម និង របស់បុគ្គល ។

**ការផ្លាស់ប្តូរទស្សនៈ និង ការប្រព្រឹត្ត គឺជាមូលដ្ឋានគ្រឹះ សំរាប់ការបង្ការមេរោគ និងថែទាំអ្នកជម្ងឺអេដស៍**

**ការផ្លាស់ប្តូរការប្រព្រឹត្ត ជាដំណើរការដែលទាមទារនូវពេលវេលា និងការព្យាយាមជាប់ជាបន្ត**

ដើម្បីអនុវត្តការប្រព្រឹត្តថ្មី បុគ្គលម្នាក់ត្រូវដឹងពីគុណប្រយោជន៍ ត្រូវមានចំណេះដឹង ជំនាញ និង សំភារៈ ឬ លទ្ធភាពអាចទទួលប្រើប្រាស់សេវានានា ហើយមានបរិយាកាសគាំទ្រ ។

## រូបភាព

យើងបានពិភាក្សាគ្នាឃើញថា
ការប្រឈមមុខរបស់អ្នក គឺអ្នក
មានទំនាក់ទំនងផ្លូវភេទជាមួយដៃគូ
រួមភេទជាច្រើន

**អ្នកផ្តល់ប្រឹក្សា អង្គុយ**

**អតិថិជន អង្គុយ**

ដូចដែលយើងបានពិភាក្សាគ្នា មាន
មធ្យោបាយមួយចំនួន សំរាប់កាត់ បន្ថយ ការ
ប្រឈមមុខរបស់អ្នក។ ឥឡូវនេះ អ្នកជ្រើស
រើសយកការប្រើស្រោមអនាម័យ។

**អ្នកផ្តល់ប្រឹក្សា អោយស្រោមអនាម័យទៅ អតិថិជន**

**អតិថិជន អង្គុយទទួល ស្រោមអនាម័យពី អ្នកផ្តល់ប្រឹក្សា**

**អ្នកផ្តល់ប្រឹក្សា អង្គុយញញឹម**

**អតិថិជន ដើរចេញទៅ ជាមួយនឹងស្រោមអនាម័យ**

# សកម្មភាព ទី១២

# អារម្មណ៍របស់បុគ្គលដែលមកធ្វើតេស្តឈាមរក

# មេរោគអេដស៍

# សកម្មភាព ទី១២

# អារម្មណ៍របស់បុគ្គលដែលមកធ្វើតេស្តឈាមរកមេរោគអេដស៍

អ្នកផ្តល់ប្រឹក្សាមិនត្រូវសន្មត់ថា អោយតែអតិថិជន មកសេវា VCCT នោះគេមុខជាមានបំណង និងបានត្រៀមលក្ខណៈជាស្រេចដើម្បីធ្វើតេស្តឈាមរកមេរោគអេដស៏ហើយ។ អតិថិជនខ្លះ អាចមកសេវាផ្តល់ប្រឹក្សា ដោយមានគំនិតចង់សាកមើល ប៉ុន្តែបាន ផ្លាស់ប្តូរចិត្ត ឬបែរទៅជាស្ទាក់ស្ទើរចិត្ត បន្ទាប់ពីបានជួបជាមួយនឹងអ្នកផ្តល់ប្រឹក្សា និងបានដឹងច្រើនពីមេរោគអេដស៏ជាងមុន។ អ្នកផ្តល់ប្រឹក្សា ត្រូវតែធ្វើអោយប្រាកដថា អតិថិជន បានយល់ពីអត្ថន័យ និងផលជាប់ពាក់ព័ន្ធនានានៃការធ្វើតេស្តឈាម រកមេរោគអេដស៏។ លទ្ធផលតេស្តរកមេរោគអេដស៏ អាចទំនងជាមានប្រយោជន៏ចំពោះអតិថិជន តែល្លឹកណា អតិថិជន នោះ បានត្រៀមលក្ខណៈបានសមស្រប ហើយមានអារម្មណ៏ថាបានត្រៀមលក្ខណៈរួចស្រេចដើម្បីប្រឈមទប់ទល់ជាមួយនឹងលទ្ធផល តេស្ត និងផលវិបាកជាប់ពាក់ពន្ធ័ផ្សេងទៀត។ អ្នកផ្តល់ប្រឹក្សា គួរតែចងចាំថា ការធ្វើតេស្តឈាមរកមេរោគអេដស៏ មិនមែនជារឿង បន្ទាន់ ចាំបាច់ត្រូវតែធ្វើជាដាច់ខាតនោះឡើយ។ បើអតិថិជនមិនទាន់ប្រាកដថាខ្លួនបាន ត្រៀម លក្ខណៈរួចរាល់សំរាប់លទ្ធផល តេស្តឈាមទេនោះ អ្នកផ្តល់ប្រឹក្សា ត្រូវទុកពេលអោយអតិថិជនត្រលប់ទៅវិញ ហើយគិតពិចារណាពីវាឡើងវិញ ឬក៏ រៀបចំការផ្តល់ ប្រឹក្សាមុនធ្វើតេស្ត បន្ថែមទៀត។

ការធ្វើតេស្តឈាមរកមេរោគអេដស៏ ជាការសំរេចចិត្តដ៏សំខាន់ និងលំបាកមួយនៅក្នុងជីវិតបុគ្គលម្នាក់ៗ។ ទោះបីជាអ្នកផ្តល់ប្រឹក្សាអាចប្រាប់អតិថិជនពីគុណប្រយោជន៏នៃការដឹងពីស្ថានភាពឈាម (serostatus) របស់មនុស្សម្នាក់ៗក៏ដោយ ក៏អ្នកផ្តល់ប្រឹក្សាគួរតែមានលក្ខណៈអព្យាក្រឹតដែរ ហើយ ទុកអោយអតិថិជនធ្វើការសំរេចចិត្តដោយខ្លួនឯង ថាតើត្រូវធ្វើតេស្ត ឬក៏អត់ដោយគ្មានការកៀបសង្កត់អ្វីទាំងអស់។

**<u>គោលបំនង:</u>**

១. ដើម្បីអោយសិក្ខាកាមយល់ពីការគិត អារម្មណ៍ និង ហេតុផលនៃការសំរេចចិត្តរបស់អតិថិជន ថាធ្វើ ឬ មិនធ្វើតេស្តរកមេរោគអេដស៏។

២. ដើម្បីអោយសិក្ខាកាមយល់ពីអារម្មណ៍ និងការរំជួលចិត្តរបស់អតិថិជន នៅពេលមកធ្វើតេស្តឈាម។

**<u>វិធីសាស្ត្រ:</u>**

ការដើរតួ

**<u>សំភារៈ</u>**

ករណីសិក្សាសំរាប់អានអោយសិក្ខាកាមស្តាប់

**ដំណើរការៈ**

១- រៀបចំការអង្គុយ និង កៅអីអោយដូចជាការរង់ចាំនៅឯសេវា VCCT មួយ ។ អោយម្នាក់ៗ គិតស្រមៃថា ខ្លួនគេជាបុគ្គលនៅក្នុងសាច់រឿង ដែលអ្នកសំរបសំរួល នឹងអាន អោយស្តាប់ ។

២-អ្នកសំរបសំរួលអានករណីសិក្សា រួចទុកពេលអោយសិក្ខាកាមគិតពី ៣-៥ នាទី

៣- អោយសិក្ខាកាមសំរេចចិត្តថាតើត្រូវធ្វើតេស្ត ឬក៏អត់ ។ ចែកសិក្ខាកាមជាពីរក្រុម ទៅតាមការសំរេចចិត្ត ។

៤- អោយសមាជិកក្នុងក្រុមនិមួយៗ ផ្លាស់ប្តូរគំនិត និង ហេតុផលគ្នា តើហេតុអ្វីបានជាគេសំរេចចិត្តយ៉ាងដូច្នេះ?

៥- ត្រលប់ទៅក្រុមធំវិញ ហើយផ្លាស់ប្តូរគំនិតជាមួយក្រុមធំទាំងមូល ។

៦- អ្នកសំរបសំរួល ចង្អុលប្រាប់ថា អ្នកដែលមានការប្រព្រឹត្តប្រឈមមុខអាចមានហេតុផលខុសៗគ្នាសំរាប់ការសំរេចចិត្តរបស់គេ ។ ដូច្នេះ អ្នកផ្តល់ប្រឹក្សាគួរតែនៅជាអព្យាក្រឹត ហើយមិនគួរធ្វើការសំរេចចិត្តជំនួសអោយអតិថិជន ថា តើត្រូវធ្វើតេស្តឈាមរកមេរោគអេដស៍ ឬក៏អត់ នោះឡើយ ។

៧- អ្នកសំរបសំរួល អាចប្រើផ្ទាំងបញ្ចាំងទី១ ជា ជំនួយ ។ ក្រុមនិមួយៗ ចែករំលែក ពិភាក្សា និងផ្លាស់ប្តូរគំនិតគ្នាស្តីពីអ្វីដែលគេបានរៀន និង ហេតុផលនានា សំរាប់ការ ធ្វើ និងការមិនធ្វើតេស្តឈាម ។

**មនុស្សផ្សេងគ្នាមានហេតុផល ការគិត អារម្មណ៍ និងមធ្យោបាយទប់ទល់នឹងបញ្ហារបស់ខ្លួនខុសៗ គ្នា។ ការសំរេចចិត្តរបស់បុគ្គលម្នាក់ៗ ថាតើគេត្រូវធ្វើតេស្តឬក៏អត់នោះ គឺថិតលើហេតុផល និងការត្រៀមលក្ខណៈជាស្រេចនៃបុគ្គលម្នាក់ៗ។ អ្នកផ្តល់ប្រឹក្សា មិនគួរជំរុញ ឬ បញ្ចុះបញ្ចូលអតិថិជនអោយធ្វើបែបណាមួយនោះឡើយ ។ ទុកអោយអតិថិជនសំរេចចិត្ត និងធ្វើតេស្តឈាមនៅពេលណាដែលគាត់ចង់ធ្វើ ។**



**ការសំរេចចិត្ត ថាតើត្រូវធ្វើតេស្តឈាមរកមេរោគអេដស៍ ឬក៏អត់?**

អ្នកខ្វល់ខ្វាយពីស្ថានភាពក្នុងជីវិតរបស់អ្នក។ អ្នកមានអាយុ ៣៨ឆ្នាំ ជាទាហាន និងបានរៀបការ ១០ឆ្នាំ ហើយ។ ធ្វើជាទាហាន អ្នកបានចូលក្នុងការប្រយុទ្ធក្នុងសង្គ្រាមជាច្រើន ហើយបានធ្វើដំណើរជាច្រើន។ ធម្មតាទាហានត្រូវបានអោយបោះទីតាំងនៅឆ្ងាយពីផ្ទះ។ នៅពេលរកបានចំណូលបន្ថែមក្រៅខ្លះៗ ពីកិច្ចការពិសេសៗ ឬ នៅចុងខែ តាមធម្មតា ទាហាន បានទៅដើរលេងសប្បាយនៅតាមអាហារដ្ឋាន ហើយ បន្ទាប់មក ជាមួយមិត្តភ័ក្រ ក៏បន្តទៅ បនស្រីជាមួយគ្នាជាក្រុម។ ទាហាន តាមធម្មតាស្រវឹងខ្លាំង។ ទោះបីធ្លាប់បានលឺពីជំងឺអេដស៍ ទាហាន ជាច្រើន មិនជឿវាទេ។ ទាហានខ្លះនិយាយថា គេស្មើរតែស្លាប់រៀងរាល់ថ្ងៃ ហេតុអីគេគួរបារម្ភពីអេដស៍ ហើយ ភាគច្រើន មិនប្រើស្រោមអនាម័យឡើយ។ អ្នកដែលបាននិយាយបែបនេះជាច្រើននាក់បានស្លាប់ដោយសារអេដស៍ ហើយ បន្សល់ទុកនូវប្រពន្ធ និងកូនរបស់គេ។ ដោយឃើញមិត្តជាច្រើនបានធ្លាក់ខ្លួនឈឺ ហើយស្លាប់ដោយសារអេដស៍, អ្នកព្រួយបារម្ភពីរូបអ្នក និងគ្រួសារអ្នក។ ស្ថានភាពរបស់អ្នកមិនខុសគ្នាប៉ុន្មានពីស្ថានភាពរបស់មិត្តភ័ក្រ្តជាទាហានរបស់អ្នកជាច្រើនទៀតឡើយ។ អ្នកខ្វល់ខ្វាយពីប្រពន្ធ និងកូនរបស់អ្នក។ អ្នកមកសេវា VCCT ប៉ុន្តែនៅតែមិនទាន់ប្រាកដក្នុងចិត្តថាតើត្រូវធ្វើតេស្តឈាមរកមេរោគអេដស៍ ឬក៏អត់?

**ឯកសារចែកលេខ១ សំរាប់សកម្មភាព ទី១២**

## ឧទាហរណ៍នៃលទ្ធផលសកម្មភាពសំរាប់ជំហ៊ាននិមួយៗ

<table>
<tr><td>១</td><td colspan="2">នៅពេលគេស្នើសុំអោយសំដែងតួជាអ្នកដែលអាចឆ្លងមេរោគអេដស៍ និងតាមរយៈការពិភាក្សា និង ផ្លាស់ប្តូរយោបល់គ្នាពីការសំរេចចិត្តធ្វើតេស្តឈាម ផលប្រយោជន៍ និង ផលវិបាកនៃការសំរេចចិត្តនិមួយៗ គេឃើញ ថាមានមនុស្សជាច្រើន សំរេចចិត្តធ្វើតេស្តឈាម ។</td></tr>
<tr><td>២</td><td colspan="2">ហេតុផលខ្លះៗសំរាប់ការសំរេចចិត្តធ្វើតេស្ត ឈាមនិង មិនធ្វើតេស្តឈាមនោះ មានដូចតទៅៈ</td></tr>
<tr><td></td><td>ចង់ធ្វើតេស្តឈាម ពីព្រោះ</td><td>មិនចង់ធ្វើតេស្តឈាមពីព្រោះ</td></tr>
<tr><td></td><td>▪ ចង់ដឹងដើម្បីរៀបចំផែនការសំរាប់បង្ការជំងឺអេដស៍នាពេលអនាគត</td><td>▪ បើវិជ្ជមានមិនអាចទទួលយកបានអាចស្លុតរន្ធត់ចិត្តឬក៏ចង់សំលាប់ខ្លួន</td></tr>
<tr><td></td><td>▪ ត្រូវតែទទួលយកការពិត</td><td>▪ បើវិជ្ជមាននឹងសោកសៅយ៉ាងខ្លាំង មិនដឹងល្អជាង</td></tr>
<tr><td></td><td>▪ អ្នកផ្តល់ប្រឹក្សា និងបុគ្គលិកនៅសេវា VCCT អាចរក្សាការសម្ងាត់បាន</td><td>▪ ខ្លាចថា ការសម្ងាត់ នឹងត្រូវបានបញ្ចេញអោយគេដឹង</td></tr>
<tr><td></td><td>▪ មិនចង់ព្រួយចិត្តតទៅទៀត</td><td>▪ ខ្ញុំមិនអាច ទទួលយកបានទេ</td></tr>
<tr><td></td><td>▪ ត្រូវដឹងល្អជាង ដើម្បីរៀបចំផែនការទៅ អនាគត ហើយអាចការពារប្រពន្ធ និងកូន បាន</td><td>▪ ខ្លាចប្រពន្ធ/ប្តី និងសាច់ញាតិ ដឹង</td></tr>
<tr><td></td><td>▪ បើលទ្ធផលតេស្តឈាមវិជ្ជមាន( មានផ្ទុកមេរោគអេដស៍) មិនចង់ចំលងទៅអ្នកផ្សេង ទៀត</td><td>▪ មិនអាចទទួលយកបានទេ។ សង្គមមិនទទួលយក</td></tr>
</table>

# សកម្មភាពទី១៣

## គោលនយោបាយយុទ្ធសាស្ត្រ និង គោលការណ៍ណែនាំ ស្តីពីការផ្តល់ប្រឹក្សា និងការធ្វើតេស្តឈាម រកមេរោគ អេដស៍

# សកម្មភាព ទី១៣
# គោលនយោបាយយុទ្ធសាស្ត្រ និង គោលការណ៍ណែនាំ ស្តីពីការផ្តល់ប្រឹក្សា និងការធ្វើតេស្តឈាមរកមេរោគអេដស៍

វាជាការសំខាន់ ដែលអ្នកផ្តល់ប្រឹក្សាផ្នែក VCCT មានការយល់ដឹងគ្រប់គ្រាន់អំពីគោលនយោបាយយុទ្ធសាស្ត្រ និងគោលការណ៍ណែនាំ ស្តីពីការផ្តល់ប្រឹក្សា និងការធ្វើតេស្តឈាមរកមេរោគអេដស៍ នៅព្រះរាជាណាចក្រកម្ពុជា ។ ជាពិសេសស្តីពី ការរក្សាការសម្ងាត់ និង ការការពារសិទ្ធិរបស់អ្នកជម្ងឺ ។

អ្នកផ្តល់ប្រឹក្សា ត្រូវដឹងខ្លះៗពីនិតិវិធីសំរាប់ការធ្វើតេស្តឈាម និង ពិធីសារ ដែលកំពុងប្រើក្នុងពេលបច្ចុប្បន្ន សំរាប់ពន្យល់ប្រាប់ដល់អតិថិជន ដើម្បីអោយគេមានទំនុកចិត្តថា មជ្ឈមណ្ឌល នឹងផ្តល់នូវលទ្ធផលតេស្តពិតត្រឹមត្រូវ ដល់ពួកគេ ។

**ខ្លឹមសារខាងក្រោមនេះដកស្រង់ពីឯកសារ គោលនយោបាយយុទ្ធសាស្ត្រ និង គោលការណ៍ណែនាំ ស្តីពីការផ្តល់ប្រឹក្សា និងការធ្វើតេស្តឈាមរកមេរោគអេដស៍ របស់ក្រសួងសុខាភិបាលនៅថ្ងៃទី ២៦ ខែធ្នូ ឆ្នាំ ២០០២ ។**

**គោលបំនង:**

១. ដើម្បីអោយសិក្ខាកាមយល់ពីគោលនយោបាយ គោលការណែនាំ ពិធីសារជាតិស្តីពីការផ្តល់ប្រឹក្សា និងធ្វើតេស្តឈាម រកមេរោគ អេដស៍ ដែលរៀបចំឡើងដោយក្រសួងសុខាភិបាល ។

២. ដើម្បីអោយសិក្ខាកាមយល់ និងអនុវត្តតាមគោលនយោបាយ គោលការណែនាំ និងពិធីសារនៃការផ្តល់ប្រឹក្សា និងធ្វើតេស្តឈាមរកមេរោគអេដស៍ នៅពេលបំពេញការងាររបស់ខ្លួន ។

**វិធីសាស្ត្រ:**

ការបង្ហាញ និងការពិភាក្សាជាក្រុមធំ

**សំភារៈ**

ឯកសារគោលនយោបាយ គោលការណ៍ណែនាំ ស្តីពីការផ្តល់ប្រឹក្សា និងធ្វើតេស្តឈាមរកមេរោគអេដស៍ និង ស្លាយបង្ហាញ

**ដំណើរការៈ**

១. បង្ហាញស្លាយ ដោយប្រើសំនួរពិភាក្សាក្នុងពេលបង្ហាញស្លាយ និមួយៗ

២. ចែកសៀវភៅគោលនយោបាយ គោលការណ៍ណែនាំស្តីពីការផ្តល់ប្រឹក្សា និងធ្វើតេស្តឈាមរកមេរោគអេដស៍ ជូនសិក្ខាកាម

**គោលនយោបាយសំរាប់ធ្វើតេស្តឈាមរកមេរោគអេដស៍**

១. ក្នុងកាលៈទេសៈណាក៏ដោយ ការធ្វើតេស្តឈាមរកមេរោគអេដស៍ដោយចាប់បង្ខំ (mandatory testing) ត្រូវហាមឃាត់ជាដាច់ខាត នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

*(ការធ្វើតេស្តឈាមរកមេរោគអេដស៍ដោយចាប់បង្ខំសំដៅដល់ការធ្វើតេស្តឈាមទាំងឡាយណាដែលអតិថិជនពុំមានជំរើសក្នុងការបដិសេធ)*

២. ក្នុងកាលៈទេសៈណាក៏ដោយ ការតំរូវឱ្យធ្វើតេស្តឈាមរកមេរោគអេដស៍ (Compulsory testing) ត្រូវហាមឃាត់ លើកលែងតែមានតំរូវការតាមផ្លូវច្បាប់។

*(ការតំរូវអោយធ្វើតេស្តឈាមសំដៅដល់ការធ្វើតេស្តឈាមទាំងឡាយណាដែលទទួលបានផលប្រយោជន៏ពីសេវាពិសេសណាមួយឧទាហរណ៍: ដើម្បី សុំទិដ្ឋិការ រកការងារ ថែទាំសុខភាព ។ល។ ប៉ុន្តែអតិថិជនមានជំរើសក្នុងការបដិសេធ ចំពោះផលប្រយោជន៏ពីសេវា ទាំងនោះដោយមិនទទួលយកការធ្វើតេស្ត ឈាម។*

៣. រាល់ការធ្វើតេស្តឈាមរកមេរោគអេដស៍ ត្រូវអនុវត្តដោយស្ម័គ្រចិត្ត និងមានការយល់ព្រមពីអតិថិជន។

៤. រាល់ការធ្វើតេស្តឈាមរកមេរោគអេដស៍អនាមិក (anonymous, unlinked testing) ក្នុងគោលបំណង ស្រាវជ្រាវ ឬ អង្កេតត្រូវសុំការអនុញ្ញាតិពីគណៈកម្មការក្រមសីលធមិនិងក្រសួងសុខាភិបាលមុនហើយត្រូវ អនុវត្តទៅតាមគោលការណ៍ណែនាំស្តីពីក្រមសីលធមិ សំរាប់ការស្រាវជ្រាវជំងឺអេដស៍និងជំងឺកាមរោគ ដែល បានអនុម័តដោយ ក្រសួង សុខាភិបាល។

៥. ស្ថាប័នរដ្ឋ និងឯកជន ដែលដំណើរការធ្វើតេស្តឈាមរកមេរោគអេដស៍ដោយស្ម័គ្រចិត្ត ត្រូវគោរពឱ្យបាន ម៉ឺងម៉ាត់ទៅតាមគោល នយោបាយ និងគោលការណ៍ណែនាំ ស្តីពីការធ្វើតេស្តឈាមរកមេរោគអេដស៍ ចែងដោយក្រសួងសុខាភិបាល។ ស្ថាប័នទាំងអស់ ត្រូវធ្វើការផ្តល់ប្រឹក្សាមុននិងក្រោយពេលធ្វើតេស្តឈាមនិង ផ្តល់លទ្ធផលដែលធានាថាត្រឹមត្រូវ។ ស្ថាប័នទាំងអស់ត្រូវមានការ អនុញ្ញាតិ និងត្រួតពិនិត្យដោយក្រសួងសុខាភិបាល និង ត្រូវតែមានបុគ្គលិកដែល បានទទួលការបណ្តុះបណ្តាល ក្នុងវគ្គសិក្សាដែល អនុម័ត ដោយក្រសួងសុខាភិបាល។

៦. រាល់សេវាធ្វើតេស្តឈាមរកមេរោគអេដស៍ និងផ្តល់ប្រឹក្សាស្តីពីជំងឺអេដស៍ទាំងសេវាសាធារណៈ និងឯកជនត្រូវផ្តល់របាយការណ៍ទៅ មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគនៃក្រសួងសុខាភិបាល ដោយ ប្រើប្រាស់ទំរង់របាយការណ៏គំរូ កំណត់ដោយមជ្ឈមណ្ឌលជាតិនេះ។

**ការធ្វើតេស្តឈាមមេរោគអេដស៍ សំរាប់ធ្វើរោគវិនិច្ឆ័យក្នុងគ្រឹះស្ថានថែទាំសុខភាពសាធារណៈ និងឯកជន**

- ការធ្វើតេស្តឈាមរកមេរោគអេដស៏ក្នុងគោលបំណងធ្វើរោគវិនិច្ឆ័យ គួរតែអនុវត្តនៅកន្លែងណាដែល ក្រោយពីបានដឹងនូវ ស្ថាន ភាពផ្ទុកមេរោគអេដស៍ អ្នកជំងឺអេដស៍ទទួលបាននូវការថែទាំព្យាបាល ឬការបញ្ជូនទៅរកការ ព្យាបាលមួយដ៏ប្រសើរ និងមានការយល់ព្រមជាមុនពីអ្នកជំងឺ។

- ចំពោះអ្នកមានអាយុក្រោម១៨ឆ្នាំ ការធ្វើតេស្តរកមេរោគអេដស៍ត្រូវសុំការអនុញ្ញាតិពីឪពុកម្តាយ ឬ អាណាព្យាបាលជាមុន ដោយមានការផ្តល់ប្រឹក្សាមុនពេលធ្វើតេស្តអោយបានត្រឹមត្រូវ។
- ត្រូវផ្តល់ការប្រឹក្សាមុនពេលធ្វើតេស្តឈាម ដើម្បីឱ្យមានការយល់ព្រមជាមុនពីអ្នកជំងឺ។ ការផ្តល់លទ្ធផលត្រូវមានការផ្តល់ប្រឹក្សាក្រោយពេលធ្វើតេស្តឈាម។ ហើយធ្វើទៅបាន លុះណាតែមានសំណូមពរពីអ្នកជំងឺប៉ុណ្ណោះ។
- លទ្ធផលតេស្តឈាម ត្រូវតែរក្សាទុកជាការសំងាត់អោយបានហ្មត់ចត់ និងអាចដឹងបានត្រឹមបុគ្គលទទួលបន្ទុកការថែទាំអ្នក ជំងឺប៉ុណ្ណោះ។
- គ្មានសមាជិកអ្នកជំងឺណាម្នាក់ ត្រូវទទួលដំណឹងអំពីការធ្វើតេស្តឈាមឬលទ្ធផលតេស្តឈាមឡើយលើកលែងតែមានការអនុញ្ញាតិ ពីអ្នកជំងឺ។

**ការធ្វើតេស្តឈាមរកមេរោគអេដស៍នៅសេវាផ្តល់ប្រឹក្សា និងធ្វើតេស្តរកមេរោគអេដស៍ដោយស្ម័គ្រចិត្តនិងរក្សាការសំងាត់**

ទោះជានៅក្នុងស្ថាប័នរដ្ឋ រឺឯកជនក៏ដោយ រាល់សេវាផ្តល់ប្រឹក្សានិងធ្វើតេស្តឈាមរកមេរោគអេដស៍ដោយស្ម័គ្រចិត្ត និងរក្សាការសំងាត់ត្រូវអនុវត្តតាមបែបបទខាងក្រោមនេះ:

- ត្រូវមានការអនុញ្ញាតិពីក្រសួងសុខាភិបាល
- ផ្តល់សេវាធ្វើតេស្តឈាមចំពោះអតិថិជនណាដែលស្នើសុំតែប៉ុណ្ណោះ
- រាល់ការធ្វើតេស្តឈាមរកមេរោគអេដស៍ត្រូវតែមានការផ្តល់ប្រឹក្សាមុនពេលធ្វើតេស្ត និងក្រោយពេលធ្វើតេស្តដូចមានចែង ក្នុងគោលការណ៍ណែនាំនេះ។
- បុគ្គលិកផ្តល់ប្រឹក្សា និងធ្វើតេស្តឈាមរកមេរោគអេដស៍ត្រូវមានសមត្ថភាពតាមខ្នាតគំរូរបស់ក្រសួងសុខា ភិបាល
- បែបបទនៃការធ្វើតេស្តឈាមរកមេរោគអេដស៍ ត្រូវអនុលោមទៅតាមពិធីសារ ដូចមានចែងក្នុង គោលការណ៍ណែនាំនេះ (មើលផ្នែក ៤.៤.៥ ខាងក្រោម) រឺអាចកែប្រែដោយក្រសួងសុខាភិបាល។
- ត្រូវរក្សាការសំងាត់អោយបានខ្ជាប់ខ្ជួន រាល់លទ្ធផលតេស្តរកមេរោគអេដស៍

**បែបបទដើម្បីធានាការរក្សាការសំងាត់**

- ត្រូវធានាភាពជាឯកជនដល់អ្នកផ្តល់ប្រឹក្សា និងអតិថិជនតាមដែលអាចធ្វើទៅបាន
- ត្រូវផ្តល់ជូនប័ណ្ណវិភាគមានចុះលេខកូដសំងាត់ ដល់អតិថិជនដោយអ្នកផ្តល់ប្រឹក្សា
- ការបូមឈាមគួរប្រព្រឹត្តទៅនៅកន្លែងមួយដោយឡែក ហើយឈាម និងប័ណ្ណវិភាគត្រូវបញ្ជូនទៅមន្ទីរពិសោធន៍។

- បន្ទាប់ពីការធ្វើតេស្ត បុគ្គលិកមន្ទីរពិសោធន៍ត្រូវកត់ត្រាលទ្ធផលតេស្តឈាមនៅក្នុងប័ណ្ណវិភាគហើយដាក់ ក្នុងស្រោមសំបុត្រ បិទជិត ចុះតែលេខសំងាត់ប៉ុណ្ណោះ ហើយបញ្ជូនទៅអ្នកផ្តល់ប្រឹក្សា ដែលត្រូវផ្តល់ ជូនអតិថិជន។
- អ្នកផ្តល់ប្រឹក្សាគ្មានសិទ្ធិក្នុងការបើកមើលលទ្ធផលទេ លុះណាតែមានការស្នើសុំពីអតិថិជន។

**ពិធីសារធ្វើតេស្តឈាមរកមេរោគអេដស៍**

នៅប្រទេសកម្ពុជា ពិធីសារធ្វើតេស្តឈាមរកមេរោគអេដស៍នៅសេវា VCCT ដូចគ្នានឹងពិធីសារធ្វើតេស្តឈាមរក មេរោគអេដស៍ដើម្បីរករោគវិនិច្ឆ័យដែរ។ ពិធីសារនៅក្នុងគោលការណ៍ណែនាំស្តី ពីការផ្តល់ប្រឹក្សា និងការធ្វើតេស្តឈាមរកមេរោគអេដស៍នេះ បានតាក់តែងរៀបចំនិងកែលំអរជាលំដាប់ដោយ ក្រសួងសុខាភិបាល។

**ការធ្វើតេស្តឈាមនៅក្នុងសេវារបស់ក្រសួងសុខាភិបាលគឺការធ្វើតេស្តរកអង្គបដិបក្ខប្រាណចំពោះមេរោគអេដស៍**

រាល់សេរ៉ូម រឺ ប្លាស្មាត្រូវធ្វើតេស្តលើកទីមួយដោយតេស្តធម្មតា រឺ តេស្តរហ័ស (Simple/ rapid assay):

- សេរ៉ូមឈាមដែលគ្មានប្រតិកម្មក្នុងពេលធ្វើតេស្តលើកទី១ ត្រូវចាត់ទុកថាពុំមានអង្គបដិបក្ខប្រាណ ប្រឆាំងនឹងមេរោគអេដស៍
- សេរ៉ូមឈាមប្រតិកម្មក្នុងពេលធ្វើតេស្តលើកទី១ ត្រូវធ្វើតេស្តឡើងវិញម្តងទៀត ដោយប្រើប្រាស់ តេស្តរហ័ស ឬ ធម្មតា (simple/rapid assay) ផ្សេងទៀត (ដែលខុសពីតេស្តទី១) រឺ ELISA
- សេរ៉ូមឈាមប្រតិកម្មក្នុងពេលធ្វើទាំងពីរលើក ត្រូវចាត់ទុកថាមានអង្គបដិបក្ខប្រាណប្រឆាំងនឹងមេ រោគអេដស៍
- សេរ៉ូឈាមប្រតិកម្មលើកទី ១ ប៉ុន្តែមិនប្រតិកម្មក្នុងពេលធ្វើតេស្តលើកទី២ ត្រូវធ្វើតេស្តទាំងពីរនេះ សារឡើងវិញដោយប្រើសេរ៉ូមឈាមដដែល។
- លទ្ធផលស្របគ្នានៃការធ្វើតេស្តឡើងវិញនេះបញ្ជាក់ពីលទ្ធផលវិជ្ជមាន រឺ អវិជ្ជមាន
- ប្រសិនបើលទ្ធផលតេស្តទាំងពីរលើកនៅតែផ្ទុយគ្នា ត្រូវចាត់ទុកថាលទ្ធផលមិនអាចកំណត់បាន ត្រូវបូមឈាមសារជាថ្មីដើម្បីធ្វើតេស្តសារឡើងវិញ។

**ការត្រួតពិនិត្យគុណភាព**

មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគនៃក្រសួងសុខាភិបាល ទទួលខុសត្រូវក្នុងការពិនិត្យគុណភាពនៃការធ្វើតេស្តឈាមរកមេរោគអេដស៍ ទាំងផ្នែកឯកជន និងសាធារណៈ។

តេស្តធម្មតា រឺតេស្តរហ័សដែលប្រើប្រាស់ ត្រូវទទួលស្គាល់ និងយល់ព្រមដោយក្រសួងសុខាភិបាលនៃព្រះរាជា ណាចក្រកម្ពុជា យោងតាមគំរូរបស់អង្គការសុខភាពពិភពលោក (WHO).

## ផ្ទាំងបញ្ចាំង លេខ១ សំរាប់សកម្មភាពទី១៣

## ពីធីសារសំរាប់ធ្វើតេស្តឈាមរកមេរោគអេដស៍



# សកម្មភាពទី ១៤
# ផលប៉ះពាល់នៃមេរោគអេដស៍ និងជម្ងឺអេដស៍លើបុគ្គល

## សកម្មភាព ទី១៤

## ផលប៉ះពាល់នៃមេរោគអេដស៍ និងជម្ងឺអេដស៍លើបុគ្គល

បុគ្គលម្នាក់ៗដែលបានធ្វើតេស្តឈាមថាមានផ្ទុកមេរោគអេដស៏នោះ តែងតែមានផលប៉ះពាល់ដ៏ធំធេងទៅលើជីវិតរបស់គាត់។ ដូច្នេះអ្នកផ្តល់ប្រឹក្សាត្រូវតែយល់ពីផលពិបាកទាំងនេះ នៅពេលដែលបានទទួលលទ្ធផលតេស្ត ឈាមថាមានផ្ទុកមេរោគអេដស៏ និងពេលក្រោយមកទៀតនោះ អតិថិជនត្រូវការពេលវេលានិងការគាំទ្រដើម្បីទទួលយកនូវស្ថានភាពផ្ទុកមេរោគអេដស៏នេះ ។អតិថិជនខ្លះអាចយំ រឺបង្ហាញពីភាពរំជួលចិត្ត ។អ្នកផ្តល់ប្រឹក្សាត្រូវរៀនអំពីរបៀប គ្រប់គ្រងស្ថានការណ៏ និងបង្ហាញអតិថិជនថា គាត់យល់អំពីការលំបាកនានា ដែលអតិថិជន ជួបប្រទះ ។មិនមែនជាការសមស្របឡើយដែលអ្នកផ្តល់ប្រឹក្សា ខំបង្វែងផលប៉ះពាល់នៃជំងឺអេដស៏ដោយនិយាយ ថា "កុំយំអី" "មានគេផ្ទុកមេរោគ អេដស៏ ច្រើនណាស់នៅស្រុកខ្មែរ" "វាមិនមែនជាបញ្ហាធ្ងន់ធ្ងរអីទេ" ។ ពាក្យទាំងអស់នេះមិនមានប្រយោជន៏ សំរាប់អតិថិជនឡើយ ហើយក៏ឆ្លុះបញ្ចាំងអោយឃើញថា អ្នកនិយាយនោះមិនយល់អំពីស្ថានភាពរបស់អតិថិជនទេ ។

**<u>គោលបំណង</u>**

១. ដើម្បីអោយសិក្ខាកាមមានឳកាសគិតនិងរំរែកញែករកផលប៉ះពាល់ ដែលអាចកើតមានឡើងលើអ្នកផ្ទុកមេរោគអេដស៏

២. អោយសិក្ខាកាមយល់ថាបុគ្គលណាក៏ដោយក៏អាចផ្ទុកមេរោគអេស៏បានដែរ

៣. ផ្តល់ឳកាសអោយសិក្ខាកាមបានជួបនិងពិភាក្សាជាមួយអ្នកផ្ទុកមេរោគអេដស៏ អំពិបទពិសោធន៏នៅពេលដែលដឹងថាគាត់មានផ្ទុកមេរោគអេដស៏ និងរបៀបដែលគាត់ដោះស្រាយបញ្ហានានា ។

**<u>វិធីសាស្ត្រ</u>**

ការចូលតួ និងអញ្ជើញអ្នកផ្ទុកមេរោគអេដស៏ដែលហ៊ាន បង្ហាញខ្លួន និងប្រាប់ពីបទពិសោធន៏របស់គាត់

**<u>សំភារៈ</u>**

សរសេរមុខរបរ និងតួនាទីនានាលើក្រដាសតូចៗ ដាក់នៅក្នុងប្រអប់សំរាប់អោយសិក្ខាកាមចាប់ ។ មុខរបរនិងតួនាទីទាំងនោះអាចមានៈ កូនទាហាន នាយទាហាន ប្រពន្ធមន្ត្រីរាជការ ប្រពន្ធអ្នកស្រែ ប្រពន្ធទាហាន តួងកកុន ស្ត្រីរកស៊ីផ្លូវភេទ ស្រីស្រស់ (ខ្ទើយ) បុរសស្រឡាញ់បុរស ប្រធានភូមិ គ្រូបង្រៀន អ្នកជំនួញ បុគ្គលិកអង្គការក្រៅរដ្ឋាភិបាល អ្នកបើកបរតាក់ស៊ី អ្នកចំការ បុរសអាយុ២១ ឆ្នាំ អ្នកច្រៀងការ៉ាអូខេ ជាងកាត់សក់បុរស ជាងអ៊ុតសក់ កុមារកំព្រា លោកសង្ឃ និសិត្សមហាវិទ្យាល័យ អ្នកបំរើលើយន្តហោះ អ្នកបើកយន្តហោះ បុរសមានគំរោងនឹងរៀបការ ។

**ដំណើរការ**

១. អោយសិក្ខាកាមចាប់យកក្រដាសតូចៗម្នាក់មួយ អោយគិតថាខ្លួនជាមនុស្សដែលសរសេរលើក្រដាសនោះ និង គិតអំពីសំនួរបីខាងក្រោម:

ក.អ្នកនឹងមានអារម្មណ៏យ៉ាងណានៅពេលដែលដឹងថាអ្នកមានផ្ទុករោគអេដស៍?

ខ.តើអ្នកនឹងធ្វើអ្វីខ្លះនៅពេលអ្នកមានផ្ទុកមេរោគអេដស៍?

គ.តើអ្វីនឹងកើតមានឡើងចំពោះអ្នកនៅពេលដែលអ្នកមានផ្ទុកមេរោគអេដស៍?

២. អ្នកសំរបសំរួលផ្តល់ពេលវេលា៣-៥នាទីដល់សិក្ខាកាមដើម្បីគិត រួចស្នើសុំអោយសិក្ខាកាមឆ្លើយនឹងសំណួរ ទាំងនោះម្នាក់ម្តងៗ ។

៣. អ្នកសំរបសំរួលសរសេរចំលើយទាំងនោះនៅលើក្តារខៀនឺក្រដាសផ្ទាំងធំ ដោយដាក់តាមផ្នែកនិមួយៗ ឧទាហរណ៏:

- **ផ្លូវចិត្តនិងអារម្មណ៏** ដូចជាការតក់ស្លុត ការភ័យខ្លាច ការអៀនខ្មាស់ ។ល។
- **ផ្លូវសេដ្ឋកិច្ច** ការព្រួយបារម្មណ៏ថាមិនអាចធ្វើការងារបន្តទៀតបាន គ្មានភ្ញៀវមកទាក់ទង បាត់បង់ការគោរព និងប្រជាប្រិយ៏ភាព ។ល។
- **ផ្លូវសុខភាព** ភ័យខ្លាចថានឹងធ្លាក់ខ្លួនឈឺ ហើយក្លាយជាបន្ទុកធ្ងន់លើអ្នកដ៏ទៃ គ្មានប្រាក់កាសនឹងព្យាបាល ជំងឺ ។ល។
- **ផ្លូវសង្គម** ដូចជាភ័យខ្លាចការរើសអើង ភ័យខ្លាចអ្នកដ៏ទៃដឹងរឿងថាគាត់មានផ្ទុកមេរោគអេដស៍និង មិនរាប់រក ។ល។
- **គ្រួសារ** ដូចជាបារម្ភអំពីគ្រួសារនិងកូន ខ្លះអាចគិតនឹងចាកចោលគ្រួសារ ។ល។

៤. ជជែកពិភាក្សាអំពីការព្រួយបារម្ភ ដែលសិក្ខាកាមបានលើកឡើងនិងសភាពការណ៏ដែលបានជួបប្រទះរឺដឹងលឺ ។

៥. ស្នើសុំអោយអ្នកផ្ទុកមេរោគអេដស៍ដែលចូលរួមក្នុងសិក្ខាសាលាចែករំលែកបទពិសោធន៏ ។

# សកម្មភាពទី ១៥

# ការផ្តល់ប្រឹក្សាមុនពេលធ្វើតេស្តឈាម

# សកម្មភាព ទី១៥
# ការផ្តល់ប្រឹក្សាមុនធ្វើតេស្តឈាម

ក្នុងអំឡុងពេលជួបមុនធ្វើតេស្ត ឈាមអ្នកផ្តល់ប្រឹក្សានឹងជួយអោយអតិថិជនធ្វើការសំរេចចិត្តដោយខ្លួនឯងថា តើត្រូវធ្វើតេស្តរកមេរោគអេដស៍ឬក៏អត់ តាមរយៈការផ្តល់ពត៌មាន និងការផ្តល់ប្រឹក្សា។ ដំណើរការនេះ ក៏ជួយរៀបចំខ្លួនអតិថិជន ដើម្បីធ្វើតេស្តឈាម និងត្រៀមខ្លួនសំរាប់ទប់ទល់នឹងលទ្ធផលតេស្តឈាមដែលអាចនឹងកើតឡើង។ នៅសេវា VCCT ខ្លះ អ្នកផ្តល់ប្រឹក្សាអាចប្រើផ្ទាំងរូបភាពធំៗ ដើម្បី ជួយពន្យល់អតិថិជនអំពីមេរោគអេដស៍ និងជម្ងឺអេដស៍។

អ្នកផ្តល់ប្រឹក្សាត្រូវតែផ្តល់ពេលវេលាដល់អតិថិជនអោយបានគ្រប់គ្រាន់ ដើម្បីសាកសួរសំណួរ និងយល់ពីពត៌មានថ្មីៗ។ អ្នកខ្លះបន្ទាប់ពីបានយល់ដឹងច្រើនស្តីពីមេរោគអេដស៍ និងបន្ទាប់ពីបានវាយតំលៃលើការប្រឈមមុខគ្រោះថ្នាក់របស់ខ្លួនរួចមក អាចសំរេចចិត្តមិនធ្វើតេស្តឈាម (ពីព្រោះអត់មានការប្រឈមមុខគ្រោះថ្នាក់)។ ប៉ុន្តែ អ្នកខ្លះទៀតដែលមានការប្រព្រឹត្តប្រឈមមុខគ្រោះថ្នាក់ខ្ពស់ ក៏អាចសំរេចចិត្តមិនធ្វើតេស្តឈាមដែរ។ អ្នកផ្សេងទៀតក៏អាចត្រលប់មកវិញនៅពេលក្រោយទៀត បន្ទាប់ពីគេសំរេចចិត្តចុងក្រោយថាគេចង់ដឹងពីស្ថានភាពមេរោគអេដស៍របស់គេយ៉ាងណានោះ។

ដំណើរការដែលអតិថិជនត្រូវបានអ្នកផ្តល់ប្រឹក្សាប្រាប់យ៉ាងល្អិតល្អន់ពីការធ្វើតេស្តឈាម ហើយគាត់សំរេចចិត្តធ្វើតេស្តឈាមហៅថា **ការយល់ដឹង និងព្រមព្រៀង**។

## <u>គោលបំណង</u>

១-ផ្តល់ឱកាសដល់សិក្ខាកាមសំរាប់អនុវត្តន៏ការផ្តល់ប្រឹក្សាមុនធ្វើតេស្តឈាមតរយៈល្បែងដើរតួ

២-ផ្តល់ឱកាសដល់សិក្ខាកាមពិនិត្យមើលអារម្មណ៏និងបទពិសោធន៏របស់គេក្រោយល្បែងដើរតួ

## <u>វិធីសាស្ត្រ</u>

ល្បែងដើរតួនិងការផ្តល់យោបល់ដោយអ្នកសង្កេតការណ៏ និងអ្នកដើរតួ

## <u>សំភារៈ</u>

ករណីសិក្សា ៣-៤សំរាប់ការសិក្សាមុនពេលធ្វើតេស្តឈាម

## <u>ដំណើរការណ៏</u>

១- ប្រាប់សិក្ខាកាមថានៅក្នុងលំហាត់នេះ គេត្រូវអនុវត្តជំនាញនិងចំណេះដឹងនានាស្តីអំពីអេដស៍និងការផ្តល់ប្រឹក្សា

២- អ្នកសំរបសំរួលសុំអោយសិក្ខាកាម បំផុសបញ្ចេញគំនិតថាតើនៅក្នុងការផ្តល់ប្រឹក្សាមុនពេលធ្វើតេស្តឈាម ត្រូវមានចំនុចអ្វីខ្លះ ។សរសេរចំនុចទាំងនោះនៅលើផ្ទាំងក្រដាស់ធំ ហើយពិគ្រោះគ្នាអំពីចំណុចនិមួយៗ តាមលំដាប់លំដោយ អាចប្រើផ្ទាំងបញ្ចាំងលេខ១ សំរាប់សង្ខេប ។

៣-ចែកសិក្ខាកាមជាក្រុមតូចពី ៥-៧ នាក់ ។ ក្នុងក្រុមនិមួយៗត្រូវមានអ្នកស្ម័គ្រចិត្តពីរនាក់ម្នាក់សំរាប់ដើរតួជាអ្នកផ្តល់ប្រឹក្សា ម្នាក់ទៀតជាអតិថិជន ហើយអ្នកដែលនៅសល់ជាអ្នកសង្កេតការណ៍ ។

៤- ចាប់ផ្តើមអនុវត្តល្បែងដើរតួនៃការផ្តល់ប្រឹក្សាមុនពេលធ្វើតេស្តឈាម ពីចាប់ផ្តើមដល់ចប់ ។

៥- ត្រឡប់មកក្រុមធំវិញ រួចចែករំលែកបទពិសោធន៍ពីល្បែងដើរតួរបស់ក្រុមនិមួយៗ ។

សុំអោយអ្នកដែលដើរតួជាអតិថិជនប្រាប់ពីរឿងរ៉ាវរបស់គាត់

តើអតិថិជនមានអារម្មណ៍យ៉ាងដូចម្តេចនៅពេលដែលទទួលការផ្តល់ប្រឹក្សា?

បើអតិថិជនសំរេចចិត្តថានឹងធ្វើតេស្តឈាមតើគាត់នឹងត្រឡប់មកទទួលលទ្ធផលវិញឬអត់?

តើអ្នកផ្តល់ប្រឹក្សាមានអារម្មណ៍យ៉ាងដូចម្តេចនៅពេលដែលផ្តល់ប្រឹក្សា?

តើអ្នកផ្តល់ប្រឹក្សាគិតថាគួរត្រូវកែលំអរចំនុចអ្វីខ្លះ?

តើអ្នកសង្កេតការគិតយ៉ាងណាអំពីដំណើរការផ្តល់ប្រឹក្សា ដែលបានសង្កេតមើល ផ្តល់យោបល់អំពីចំនុចល្អ និងចំនុចដែលត្រូវកែលំអរ

ផ្ទាំងបញ្ចាំងលេខ ១ សំរាប់សកម្មភាពទី១៥

## ការផ្តល់ប្រឹក្សាមុនធ្វើតេស្ត ឈាមរួមមាន៖

១- សួរអតិថិជនពីហេតុផលនៃការមករកសេវា VCCT

២- ប្រាប់ និងធានាដល់អតិថិជនពីការរក្សាការសម្ងាត់នៃការពិភាក្សាទាំងមូល និង លទ្ធផលតេស្តឈាម ។

៣- សួរអតិថិជនពីការយល់ដឹងរបស់គាត់ ស្តីពីការចំលងមេរោគអេដស៍ ហើយបញ្ជាក់ឡើងវិញពីការយល់ច្រឡំនានា ។

៤- ពិភាក្សាជាមួយអតិថិជនពីការប្រឈមមុខរបស់គាត់ ដើម្បីវាយតំលៃរួមគ្នាថា តើអតិថិជនបានស្ថិតនៅក្នុងស្ថានភាពប្រឈមមុខពិតប្រាកដដែរឬទេ ។

៥- ពន្យល់ពីដំណើរការធ្វើតេស្ត ឈាម រយៈពេលចំហរ និងអត្ថន័យនៃលទ្ធផលតេស្ត ឈាម *វិជ្ជ មាន* និង   លទ្ធផលតេស្តឈាម *អវិជ្ជមាន*។

៦- បានពិភាក្សាអំពីអត្ថប្រយោជន៍នៃការដឹងពីលទ្ធផលតេស្តរបស់ខ្លួន

៧- សួរអតិថិជន តើគាត់នឹងមានអារម្មណ៍ដូចម្តេចបើលទ្ធផលតេស្តឈាម *វិជ្ជមាន* រឺ *អវិជ្ជមាន* ?

៨- សួរអតិថិជន តើគាត់នឹងធ្វើអ្វី ក្នុងករណីដែលលទ្ធផលតេស្តឈាម *អវិជ្ជមាន* និង ក្នុងករណីដែលលទ្ធផលតេស្តឈាម *វិជ្ជមាន*។ ( ដើម្បីប៉ាន់ប្រម៉ានអំពីលទ្ធភាពទប់ទល់ និងដោះស្រាយបញ្ហារបស់ អតិថិជន) ។

៩- ពិភាក្សាពីការកាត់បន្ថយការប្រឈមមុខដែលអាចកើតមាននិង ពីផែនការទៅអនាគត

១០- ទុកពេលអោយអតិថិជនគិតពីរឿងរ៉ាវ/បញ្ហានានា

១១- អតិថិជនធ្វើការសំរេចចិត្តដោយខ្លួនឯង ថាតើត្រូវធ្វើតេស្តឈាមឬក៏អត់?

១២- បើអតិថិជន សំរេចចិត្តថាធ្វើតេស្ត ឈាម ណាត់ពេលមកទទួលលទ្ធផល  ហើយត្រូវយកអ្វីខ្លះមកជាមួយ និងរៀបចំបូមឈាម ។

១៣- បើអតិថិជនសំរេចចិត្តមិនធ្វើតេស្តឈាមហើយគាត់ស្ថិតនៅក្នុងស្ថានភាពប្រឈមមុខត្រូវពិគ្រោះ

អំពីផែនការកាត់បន្ថយការប្រឈមមុខ ។



## បញ្ជីផ្ទៀងផ្ទាត់ខាងក្រោម អាចប្រើដើម្បីវាយតំលៃលើការផ្តល់ប្រឹក្សាមុនធ្វើតេស្តឈាម

អ្នកសង្កេតការណ៍អាចប្រើប្រាស់បញ្ជីផ្ទៀងផ្ទាត់នេះក្នុងពេលដំណើរការល្បែងដើរតួ ហើយអ្នកអភិបាល VCCT ក៏អាចប្រើប្រាស់ជាឧបករណ៍សំរាប់អភិបាលបានដែរ

***ក្នុងអំឡុងពេលនៃការផ្តល់ប្រឹក្សាមុនធ្វើតេស្តឈាម តើចំណុចខាងក្រោមនេះ បានកើតឡើងដែរឬទេ?***

| | | |
|---|---|---|
| ការរក្សាការសម្ងាត់ត្រូវបានបញ្ជាក់ប្រាប់បានគ្រប់គ្រាន់ | បាន o | មិនបាន o |
| ពិភាក្សាអំពីហេតុផលនៃការមកជួប | បាន o | មិនបាន o |
| បានពិភាក្សាអំពីចំណេះដឹងស្តីពីមេរោគអេដស៍ និងរបៀបឆ្លង | បាន o | មិនបាន o |
| បានកែតំរូវការយល់ច្រឡំនានា | បាន o | មិនបាន o |
| បានធ្វើការវាយតំលៃប្រវត្តិប្រឈមមុខរបស់អតិថិជន | បាន o | មិនបាន o |
| បានផ្តល់ពតិមានទាក់ទងនឹងការធ្វើតេស្តរឈាមកមេរោគអេដស៍ (ដូចជា: ដំណើរការធ្វើតេស្ត ឈាមអត្ថន័យនៃលទ្ធផលតេស្ត ឈាមរយៈពេលចំហារ) | បាន o | មិនបាន o |
| បានពិភាក្សាអំពីអត្ថប្រយោជន៍នៃការដឹងពីលទ្ធផលតេស្តឈាមរបស់ខ្លួន | បាន o | មិនបាន o |
| បានបញ្ជាក់ការយល់ដឹងរបស់អតិថិជនទូវអ្វីដែលបានពិភាក្សា | បាន o | មិនបាន o |
| បានពិភាក្សាពីអត្ថន័យនៃលទ្ធផលតេស្តឈាមវិជ្ជមាន និង អវិជ្ជមាន និងពីផលប៉ះពាល់នានា | បាន o | មិនបាន o |
| បានប៉ាន់ស្មានលទ្ធភាពទប់ទល់នឹងលទ្ធផលតេស្តឈាមរបស់អតិថិជន | បាន o | មិនបាន o |
| បានពិភាក្សាពីផែនការកាត់បន្ថយការប្រឈមមុខសំរាប់បុគ្គល | បាន o | មិនបាន o |
| ផ្តល់ពេលវេលាគ្រប់គ្រាន់អោយអតិថិជនពិចារណាអំពីរឿងរ៉ាវ/បញ្ហានានា | បាន o | មិនបាន o |
| អតិថិជនសំរេចចិត្តធ្វើតេស្តរឺមិនធ្វើតេស្តដោយសេរី | បាន o | មិនបាន o |
| ផ្តល់ពេលវេលាគ្រប់គ្រាន់សំរាប់អតិថិជនសាកសួរ និងការបញ្ជាក់ឡើងវិញ | បាន o | មិនបាន o |
| តើការផ្តល់ប្រឹក្សានេះ បានបញ្ចប់ទៅ ក្នុងបរិយាកាសល្អប្រសើរដែររឺទេ? | បាន o | មិនបាន o |

## ករណីសិក្សាសំរាប់ផ្តល់ប្រឹក្សាមុនធ្វើតេស្តឈាមៈ

១.វិរៈ បានរស់នៅជាមួយសង្សារដែលជាស្ត្រីរកស៊ីផ្លូវភេទរយៈពេលពីរឆ្នាំមកហើយ ។ពេលរួមភេទជាមួយសង្សារគាត់ៗធ្លាប់បានបែកស្រោមចំនួន៣លើក វិរៈ គិតខ្វល់ខ្វាយថានឹងមកធ្វើតេស្តឈាមជាយូរមកហើយ ។គាត់មានការព្រួយបារម្ភណ៍ អំពីបញ្ហាអេដស៍ខ្លាំងណាស់ហើយបានមកកាន់សេវា VCCT ។

២.ស្រីលាភ ជាស្ត្រីរកស៊ីផ្លូវភេទនៅខេត្តសៀមរាបអស់រយៈពេល៣ឆ្នាំមកហើយ ។ថ្មីៗនេះបុគ្គលិកអង្គការមិនមែនរដ្ឋាភិបាលនិងមិត្តភ័ក្ត្ររបស់នាងដែលជាស្ត្រីរកស៊ីផ្លូវភេទដូចគ្នា បានជជែកពិភាក្សាពីបញ្ហាធ្វើតេស្តឈាមរកមេរោគអេដស៍ ។នាងចាំបានថាពេល ដែលនាងចាប់ផ្តើមធ្វើជាស្រីរកស៊ីផ្លូវភេទដំបូង នាងធ្លាប់មិនបានប្រើស្រោម អនាម័យច្រើនលើកច្រើនសារជាមួយភ្ញៀវដោយភ្ញៀវមិនចង់ប្រើ ។សព្វថ្ងៃនេះសុខភាពរបស់នាងនៅល្អនៅឡើយ ក៏ប៉ុន្តែនាងមានការបារម្ភណ៍ពីការឆ្លងមេរោគអេដស៍ ។ នាងមកកាន់សេវាធ្វើតេស្តឈាមមួយកន្លែង ។

៣.ហាក់ ជាបុគ្គលិករបស់អង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិមួយដែលមានទីតាំងនៅភ្នំពេញ ។ គាត់មានអាយុ៤១ ឆ្នាំហើយ ។ រៀងរាល់ខែគាត់ចុះទៅត្រួតពិនិត្យតាមដានការងាររបស់អង្គការនៅតាមបណ្តាខេត្ត ។សហសេវិកដែលធ្វើការនៅតាមបណ្តាខេត្តតែងនាំគាត់ទៅភោជនីយដ្ឋានពិសារបាយល្ងាច ដែលនៅទីនោះមានស្រីឡង់សេ រឺអ្នកបំរើស្អាតៗជាច្រើន ។គាត់ក៏មានទំនាក់ទំនងជាមួយស្ត្រីនៅគ្រប់ខេត្ត ។ប្រពន្ធរបស់គាត់នៅឯភ្នំពេញពុំបានដឹងរឿងនេះទេ ។ ហាក់ដឹងអំពីអេដស៍តាមរយៈទូរទស្សន៍ និងតាមការផ្សព្វផ្សាយនានា ក៏ប៉ុន្តែពេលខ្លះគាត់មិនបានប្រើស្រោមអនាម័យជាមួយនាងៗនោះទេ ។ថ្មីៗនេះប្រពន្ធគាត់ផ្តើមនិយាយអំពីបញ្ហាអេដស៍ដោយគាត់បានមើលទូរទស្សន៍ ។ដូច្នេះធ្វើអោយលោកហាក់គិតពិចារណាថែមទៀតអំពីអេដស៍ ហើយបារម្ភណ៍ថាគាត់ប្រហែលជាបានឆ្លងមេរោគអេដស៍ ។ គាត់ស្ទាក់ស្ទើរមិនចង់ធ្វើតេស្តឈាមរកមេរោគអេដស៍ ទេតែគាត់ចាប់ផ្តើមពិចារណាហើយពិចារណាទៀត ។ចិត្តមួយគាត់ចង់ដឹងថាតើផ្ទុកមេរោគអេដស៍ដែររឺអត់ ក៏ប៉ុន្តែនៅខ្លាចថាបើផ្ទុកមេរោគ អេដស៍មែន គាត់ប្រហែលជាទទួល មិនបាន ថ្ងៃនេះគាត់មកជួបអ្នកផ្តល់ប្រឹក្សានៅសេវា VCCT មួយកន្លែង ។

# សកម្មភាព ទី១៦

## ការផ្តល់ប្រឹក្សាក្រោយពេលធ្វើតេស្តឈាម

***ការផ្តល់លទ្ធផលតេស្តឈាមអវិជ្ជមាន(គ្មានផ្ទុកមេរោគអេដស៍)***

***ការផ្តល់លទ្ធផលតេស្តឈាមវិជ្ជមាន(មានផ្ទុកមេរោគអេដស៍)***

# សកម្មភាពទី ១៦
# ការផ្តល់ប្រឹក្សាក្រោយពេលធ្វើតេស្តឈាម

ការផ្តល់ប្រឹក្សាក្រោយពេលធ្វើតេស្តឈាម គឺជាការផ្តល់ប្រឹក្សានៅពេលដែលអតិថិជនមកទទួលលទ្ធផលតេស្តឈាម។ ការផ្តល់លទ្ធផល អវិជ្ជមានគឺជាការផ្តល់ដំណឹងល្អសំរាប់អតិថិជន។ សំរាប់អ្នកដែលធ្វើតេស្តឈាមទៅបង្ហាញថា អវិជ្ជមាននេះវាគឺជាឱកាសល្អបំផុត សំរាប់ជំរុញដល់ការផ្លាស់ប្តូរការប្រព្រឹត្ត និងបង្កើតឡើងនូវផែនការកាត់បន្ថយការប្រឈមមុខ ។សំរាប់អ្នកដែលធ្វើតេស្តឈាមទៅ បង្ហាញថាវិជ្ជមាន អ្នកផ្តល់ប្រឹក្សាអាចនឹងត្រូវចំណាយពេលច្រើនដើម្បីផ្តល់ការគាំទ្រផ្នែកផ្លូវចិត្ត ពិភាក្សាពីការរស់នៅដោយមានតំលៃប្រាប់អតិថិជនពីសេវាថែទាំ និងព្យាបាលនានា ស្របតាមតម្រូវការនិងស្ថានភាព របស់អតិថិជនម្នាក់ៗ។

ជាទូទៅ អ្នកផ្តល់ប្រឹក្សាត្រូវលើកទឹកចិត្តដល់អតិថិជន ដែលបានធ្វើតេស្តឈាមទៅអវិជ្ជមានអោយត្រឡប់មក ធ្វើតេស្តសារជាថ្មីក្នុងរយៈពេលពីរឺបីសប្តាហ៏ទៀត អាស្រ័យទៅលើពេលវេលាដែលគាត់បានប្រព្រឹត្តប្រឈមមុខលើកចុងក្រោយ។ អ្នកផ្តល់ប្រឹក្សាត្រូវតែបានលើកទឹកចិត្តអោយអតិថិជនប្រាប់ដៃគូរបស់គេថា ខ្លួនគេបានធ្វើតេស្តឈាមរួចហើយ ។អ្នកផ្តល់ប្រឹក្សាត្រូវជួយអតិថិជន អោយចេះចចារអំពីការកាត់បន្ថយការប្រឈមមុខជាមួយនឹងដៃគូរបស់គាត់។

ការអនុវត្តន៏បច្ចុប្បន្ននៅប្រទេសកម្ពុជា អ្នកផ្តល់ប្រឹក្សាមិនដឹងអំពីលទ្ធផលតេស្តជាមុនឡើយ លទ្ធផលតេស្តឈាមនោះត្រូវដាក់ក្នុង ស្រោមសំបុត្រសំរាប់ប្រគល់អោយអតិថិជន ។ ដោយបានការអនុញ្ញាតិពីអតិថិជនអ្នកផ្តល់ប្រឹក្សា នឹងបើកស្រោមសំបុត្រដើម្បី ពន្យល់ថាវិជ្ជមានឺរអវិជ្ជមានតាមដែលបានកត់ត្រាទុក ។ ដូច្នេះអ្នកផ្តល់ប្រឹក្សាត្រូវរៀបចំប្រុង ប្រយ៏បនិងដឹងហើយធ្វើការពិភាក្សាបន្តទោះជាលទ្ធផលវិជ្ជមាន រឺអវិជ្ជមានក្តី ។ ក៏ប៉ុន្តែដើម្បីងាយស្រួលក្នុងពេលបណ្តុះបណ្តាលត្រូវរៀបចំអោយសិក្ខាកាមរៀនរបៀបផ្តល់លទ្ធផលតេស្តអវិជ្ជមានមុននឹងឈានទៅរៀនរបៀបផ្តល់លទ្ធផលវិជ្ជមាន ។

គោលបំណងនៃការផ្តល់ប្រឹក្សាក្រោយពេលធ្វើតេស្តឈាមគឺ :

១-ជួយអតិថិជនអោយយល់អំពីលទ្ធផលតេស្តឈាមរបស់គាត់

២-ជួយគាំទ្រដល់អតិថិជនអោយទប់ទល់ជាមួយលទ្ធផលតេស្តឈាមនិងជួយរកប្រភពគាំទ្រផ្សេងៗទៀត

៣-ប្រាប់អំពីសេវាវេជ្ជសាស្ត្រ និងធ្វើការបញ្ជូនបន្តដើម្បីអោយគាត់អាចរស់នៅដោយមានតំលៃបាន

៤-សាកសួរអតិថិជនអំពីដៃគូរួមភេទនិងជួយគាំទ្រអោយប្រាប់ដៃគូអំពីលទ្ធផលតេស្តឈាម

៥-ពិគ្រោះអំពីការកាត់បន្ថយឱកាសឆ្លងមេរោគអេដស៏

**<u>គោលបំណង:</u>**

១- ដើម្បីអោយសិក្ខាកាមយល់ពីគោលការណ៍ និងចំណុចសំខាន់ៗនៃការផ្តល់ប្រឹក្សាក្រោយពេលធ្វើតេស្តឈាម ។

២-ដើម្បីផ្តល់ឱកាសដល់សិក្ខាកាមបានអនុវត្តជាក់ស្តែងនូវដំណើរការផ្តល់លទ្ធផលតេស្តឈាមអវិជ្ជមាន និង វិជ្ជមាន ។

**<u>សំភារៈ</u>**

ស្រោមសំបុត្រដែលមានលទ្ធផលតេស្ត ឈាមរបស់មន្ទីរពិសោធន៍ ។

**<u>ដំណើរការ:</u>**

ដំបូងហាត់អនុវត្តផ្តល់លទ្ធផលតេស្តអវិជ្ជមាន ហើយបន្ទាប់មកបន្តហាត់ផ្តល់លទ្ធផលតេស្តវិជ្ជមាន ដើម្បីអោយសិក្ខាកាមគ្រប់ៗគ្នាមានឱកាសអនុវត្តជាក់ស្តែង ឬសង្កេតលើដំណើរការទាំងពីរ ។

១- អោយសិក្ខាកាមបញ្ចេញ គំនិតរបស់គេ :

ថាតើការផ្តល់ប្រឹក្សាក្រោយពេលធ្វើតេស្តឈាមត្រូវមានចំណុចអ្វីខ្លះ?

អ្នកសំរបសំរួលត្រូវសរសេរចំណុចទាំងនោះទៅតាមលំដាប់អោយបានសមរម្យលើផ្ទាំងក្រដាសផ្សេងគ្នា សំរាប់លទ្ធផលវិជ្ជមាននិងអវិជ្ជមាន ។ ពិភាក្សាលើចំនុចនិមួយៗដែលសរសេរលើផ្ទាំងក្រដាស់ជាមួយសិក្ខាកាមដើម្បីបំភ្លឺអោយគេបានយល់ច្បាស់លាស់មុនពេលចាប់ផ្តើមល្បែងដើរតួ ។ អ្នកសំរបសំរួលអាចប្រើផ្ទាំងបញ្ចាំងលេខ១និងលេខ២ដើម្បីសង្ខេប ។

២-បំបែកសិក្ខាកាមជាក្រុមមានគ្នា៤-៥ នាក់ ។ ក្នុងក្រុមនិមួយៗ មានម្នាក់ជាអ្នកផ្តល់ប្រឹក្សា ម្នាក់ជាអតិថិជននិង២-៣ នាក់ជាអ្នកសង្កេតការណ៍ ។ អ្នកសង្កេតការណ៍ពិនិត្យមើលលើដំណើរការផ្តល់ប្រឹក្សា ហើយកត់សំគាល់ពីសំណួរដែលនៅខាងក្រោម ។

**ការផ្តល់លទ្ធផលតេស្តឈាមអវិជ្ជមាន**

១- ក្រុមទាំងអស់អនុវត្តល្បែងដើរតួអំពីរបៀបផ្តល់ប្រឹក្សាក្រោយពេលធ្វើតេស្ត ឈាមសំរាប់លទ្ធផលអវិជ្ជមាន

២-ត្រូវមានអ្នកសំរបសំរួលសំរាប់ក្រុមនិមួយៗសំរាប់ជួយបង្ហើបផ្លូវខ្លះៗប្រសិនបើអ្នកផ្តល់ប្រឹក្សាជួបប្រទះការលំបាក

៣- វិលត្រលប់ទៅកាន់ក្រុមធំវិញ ហើយចែករំលែកគ្នានូវអ្នកដើរតួជាអតិថិជនរៀបរាប់ពីករណីសិក្សាម្តងមួយករណីៗ

<u>សំណួរសំរាប់អ្នកផ្តល់ប្រឹក្សា:</u>

តើអ្វីខ្លះដែលអ្នកធ្វើបានល្អ?

តើអ្នកត្រូវកែលំអរយ៉ាងណាខ្លះទៀត?

អារម្មណ៍ មុន និងក្រោយពេលផ្តល់លទ្ធផលតេស្តឈាម

តើផែនការកាត់បន្ថយការប្រឈមមុខរបស់អតិថិជនអ្នកមានអ្វីខ្លះ?

តើអ្នកបានជួយអតិថិជនអំពីរបៀបចរចារជាមួយដៃគូលើផែនការនោះដូចម្តេចខ្លះ?

<u>សំណួរសំរាប់អតិថិជនៈ</u>

តើចំណុចអ្វីខ្លះដែលអ្នកផ្តល់ប្រឹក្សាធ្វើបានល្អ?

តើអ្វីខ្លះដែលគួរកែលំអរ?

អារម្មណ៍របស់អតិថិជនមុន និងក្រោយពេលលឺលទ្ធផលតេស្តឈាម។

តើអ្នកគិតយ៉ាងណាចំពោះផែនការកាត់បន្ថយការប្រឈមមុខ? តើវាពិតជាអាចអនុវត្តបានដែរទេ?

<u>សំណួរសំរាប់អ្នកសង្កេតការណ៍:</u>

តើចំណុចអ្វីខ្លះដែលអ្នកផ្តល់ប្រឹក្សាធ្វើបានល្អ?

តើអ្វីខ្លះដែលគួរកែលំអរ?

យល់ដូចម្តេចអំពីផែនការកាត់បន្ថយការប្រឈមមុខរបស់អតិថិជន

៤- អ្នកសំរបសំរួល ធ្វើការសង្ខេប ហើយសន្និដ្ឋានពីចំណុចនានា ដែលបានពិភាក្សារួច ដោយសង្កត់ធ្ងន់ថា អ្នកផ្តល់ប្រឹក្សាត្រូវជួយអតិថិជនអោយយល់ពីអត្ថន័យនៃលទ្ធផលតេស្តឈាមសំរាប់ពេលនេះ ហើយធ្វើការជាមួយអតិថិជនដើម្បីរៀបចំ ផែនការកាត់បន្ថយការប្រឈមមុខ។

| |
|---|
| អតិថិជន ដែលទទួលបានលទ្ធផលតេស្តអវិជ្ជមាន តែងតែសន្យាថានឹងប្រព្រឹត្តនូវទង្វើល្អទាំងអស់ ដើម្បីរក្សាខ្លួនគេ កុំអោយឆ្លងមេរោគអេដស៍។ អ្នកខ្លះថែមទាំងប្រាប់អ្នកផ្តល់ប្រឹក្សាថា គេលែងរួមភេទទៀតហើយ។ ដោយទទួលស្គាល់នូវចេតនាល្អរបស់ អតិថិជន អ្នកផ្តល់ប្រឹក្សាកុំភ្លេចឱកាសដើម្បីពង្រឹងដល់ទង្វើនានា ដែលបានកំនត់នៅក្នុងផែនការ កាត់បន្ថយការប្រឈមមុខរបស់អតិថិជនឡើយ។ បើអតិថិជនមានការប្រព្រឹត្តដែលប្រឈមមុខជាក់លាក់បែបណាមួយនោះ អ្នកផ្តល់ប្រឹក្សា ត្រូវលើកឡើងពីការប្រព្រឹត្តនោះ ហើយពិភាក្សាជាមួយអតិថិជនពីទង្វើជាក់ស្តែង សំរាប់ការផ្លាស់ប្តូរការប្រព្រឹត្តនោះ។ |

## ការផ្តល់លទ្ធផលតេស្តវិជ្ជមាន

១- អោយសិក្ខាកាមក្នុងក្រុមនិមួយៗផ្លាស់ប្តូរតួនាទីគ្នា ដើម្បីអោយអ្នកដែលមិនទាន់បានដើរតួជាអ្នកផ្តល់ប្រឹក្សា ឬ អតិថិជន អាចមានឱកាសដើរតួនោះ ។

២- អ្នកសំរបសំរួលពិភាក្សាឡើងវិញលើចំណុចផ្សេងៗដែលត្រូវមាននៅពេលផ្តល់ប្រឹក្សាក្រោយពេលធ្វើតេស្តឈាមអាចប្រើផ្ទាំងបញ្ចាំងលេខ២ ។

៣- អ្នកសំរបសំរួលចែកករណីសិក្សា ហើយផ្តល់ពេលអោយសិក្ខាកាមដែលដើរតួជាអ្នកផ្តល់ប្រឹក្សា និងអតិថិជនរៀបចំខ្លួន

៤- ក្រុមទាំងអស់អនុវត្តន៍ល្បែងដើរតួ អំពីការផ្តល់ប្រឹក្សាសំរាប់លទ្ធផលតេស្តឈាមវិជ្ជមាន

៥- ត្រឡប់ទៅក្រុមធំវិញ ហើយពិភាក្សាផ្លាស់ប្តូរបទពិសោធន៍គ្នា

អ្នកដើរតួជាអតិថិជនរៀបរាប់ពីករណីសិក្សាម្តងមួយករណីៗ

<u>សំណួរសំរាប់អ្នកផ្តល់ប្រឹក្សា:</u>

តើអ្វីខ្លះទៅដែលអ្នកធ្វើបានល្អ?

តើអ្នកមានអារម្មណ៍យ៉ាងណា នៅពេលផ្តល់លទ្ធផលតេស្តឈាមវិជ្ជមាន?

តើការផ្តល់លទ្ធផលតេស្តឈាមវិជ្ជមាន ខុសពីការផ្តល់លទ្ធផលតេស្តឈាមអវិជ្ជមានដូចម្តេច?

<u>សំណួរសំរាប់អតិថិជន:</u>

តើអ្នកផ្តល់ប្រឹក្សា ធ្វើអ្វីបានល្អ?

តើអ្នកមានអារម្មណ៍យ៉ាងដូចម្តេច នៅពេលដែលលឺថាអ្នកមានផ្ទុកមេរោគអេដស៍នោះ?

<u>សំណួរសំរាប់អ្នកសង្កេតការណ៍:</u>

តើអ្វីខ្លះទៅ ដែលអ្នកផ្តល់ប្រឹក្សាធ្វើបានល្អ?

តើចំណុចណាខ្លះដែលគួរកែលំអ?

តើអតិថិជននឹងទប់ទល់អំពីលទ្ធផលតេស្តឈាមដូចម្តេច? ហើយគាត់អាចមានការគាំទ្រពីប្រភពណាខ្លះ?

៦- អ្នកសំរបសំរួលសង្ខេប ហើយសន្និដ្ឋានពីចំណុចដែលបានពិភាក្សាគ្នារួច ដោយសង្កត់ធ្ងន់ថា អ្នកផ្តល់ប្រឹក្សា ត្រូវជួយអតិថិជនអោយយល់ពីអត្ថន័យនៃលទ្ធផលតេស្ត ហើយផ្តល់នូវការគាំទ្រផ្លូវចិត្តនិងអារម្មណ៍ ដល់អតិថិជននោះ ។

អតិថិជនអាចមានប្រតិកម្មច្រើនបែបខុសៗគ្នា ចំពោះលទ្ធផលតេស្តឈាមវិជ្ជមានចាប់ពីស្ងៀមស្ងាត់រហូតដល់តក់ស្លុតរឺមិន ចង់ជឿលទ្ធផលតេស្តឈាម ។

អតិថិជនខ្លះអាចគិតថាគាត់នឹងធ្លាក់ខ្លួនឈឺនៅពេលឆាប់ៗនឹងស្លាប់ ។អ្នកផ្តល់ប្រឹក្សាត្រូវបញ្ជាក់ប្រាប់អតិថិជនពីភាពខុសគ្នារវាងការផ្ទុកមេរោគអេដស៍ និងជំងឺអេដស៍ ហើយនិយាយពន្យល់អោយបានជាក់លាក់ថា គេអាចចិតនៅមានសុខភាពល្អ រយៈពេលយូរ ជាមួយនឹងការផ្ទុក មេរោគអេដស៍ ។

សាកសួរទៅអតិថិជនថាតើគាត់គ្រោងនឹងធ្វើអ្វី បន្ទាប់ពីចេញពីការផ្តល់ប្រឹក្សានេះទៅ ហើយបើចាំបាច់ត្រូវរំលឹកឡើងវិញអំពីផែនការដែលគាត់បានប្រាប់មុនពេលស្តាប់លឺលទ្ធផលតេស្តឈាមពីអ្វីៗដែលគាត់នឹងធ្វើ បើសិនជាលទ្ធផលតេស្តឈាម គាត់វិជ្ជមាន ។

ប៉ាន់ប្រមាណការគាំទ្រពីសង្គម និងផែនការរបស់អតិថិជន សំរាប់ការប្រាប់ដៃគូអោយដឹងពីលទ្ធផលតេស្តឈាម ។ បើចាំបាច់ ត្រូវរំលឹកអតិថិជនពីផែនការកាត់បន្ថយការប្រឈមមុខរបស់គេ ហើយប្រាប់គាត់ថាវាជាការចាំបាច់ដែលត្រូវការពារ ដៃគូរបស់គាត់ និងការពារខ្លួនគាត់ពីការឆ្លងមេរោគបន្ថែមទៀត ។

ដោយសារពេលវេលានិង ស្ថានភាពផ្លូវចិត្តអារម្មណ៍របស់អតិថិជន អ្នកផ្តល់ប្រឹក្សាមិនអាចពិភាក្សាបាន គ្រប់ចំណុចនោះឡើយ ។ ក្នុងកាលៈទេសៈបែបនោះ អ្នកផ្តល់ប្រឹក្សា យ៉ាងហោចណាស់ ក៏ត្រូវផ្តល់ ពតិមានចាំបាច់អោយអតិថិជន (រួមទាំងប្រភពបញ្ជូនបន្តដើម្បីទៅរកសេវានានា) ហើយលើកទឹកចិត្តអតិថិជនអោយមកជួបវិញនៅពេលណាដែលគាត់អាចត្រឡប់មកបាន ។

## ករណីសិក្សាសំរាប់លទ្ធផលតេស្ត ឈាមអវិជ្ជមាន

១- ម៉ានិត ធ្វើការក្នុងក្រុមហ៊ុនលក់ឧបករណ៍អេឡិចត្រូនិចមួយនៅភ្នំពេញ។ គាត់ចូលចិត្តដើរលេងស៊ីផឹកជាមួយ មិត្តភ័ក្ត។ មានយប់មួយ គាត់និងមិត្តភ័ក្តគាត់បានផឹកស្រាវីស្គី និងស្រាបៀរជាច្រើននៅអាហារដ្ឋានមួយ។ បន្ទាប់មកពួកគេទៅបនស្រី។ ថ្ងៃបន្ទាប់មក ម៉ានិត ព្រួយបារម្ភខ្លាំងណាស់។ គាត់មិនច្បាស់ថាគាត់បានប្រើ ស្រោមអនាម័យ ជាមួយស្ត្រីរកស៊ីផ្លូវភេទដែលគាត់បានដេកជាមួយនោះ ឬក៏អត់។ គាត់ដូចជាស្រពិចស្រពិលពីរឿងនេះ។ គាត់ក៏សំរេចចិត្តទៅធ្វើតេស្តឈាមរកមេរោគអេដស៍។ គាត់ទទួលការផ្តល់ប្រឹក្សាមុនពេលធ្វើតេស្តឈាមនៅពេលព្រឹកហើយពេលល្ងាចគាត់ត្រឡប់មកទទួលលទ្ធផលតេស្តឈាមវិញ។

២- បញ្ញា ធ្វើការអោយអង្គការក្រៅរដ្ឋាភិបាលមួយនៅតាមខេត្ត។ ពេលខ្លះ បន្ទាប់ពីហូបអាហារនៅអាហារដ្ឋានរួច គាត់បានយកស្រីឡង់សេស្រាបៀរទៅដេកជាមួយ។ ពេលខ្លះគាត់ប្រើស្រោម ពេលខ្លះទៀតមិនបានប្រើស្រោមទេ។ ឪពុកម្តាយគាត់បានរៀប ចំអោយគាត់រៀបការជាមួយនឹង កូលាប។ គាត់គិតថា កូលាប ជាស្រីស្អាត ដូច្នេះគាត់ក៏យល់ព្រម។ ឪពុកម្តាយនាងកូលាបបានសុំអោយបញ្ញា បង្ហាញលទ្ធផលតេស្តមេរោគអេដស៍អវិជ្ជមានមុននឹង អោយគាត់រៀបការជាមួយកូនស្រី។ បញ្ញា ស្ទាក់ស្ទើរពីការធ្វើតេស្តឈាម ប៉ុន្តែចុងក្រោយ គាត់ក៏សំរេចចិត្តធ្វើតេស្តឈាម។ គាត់ទទួលការផ្តល់ប្រឹក្សាមុនពេលធ្វើតេស្តឈាម នៅពេលព្រឹក ហើយពេលល្ងាចនាងត្រឡប់មក ទទួលលទ្ធផលតេស្តឈាមវិញ។

៣- សុក មកពីខេត្តព្រៃវែង។ គាត់រៀបការហើយ ប៉ុន្តែគ្មានកូននៅឡើយទេ។ ក្នុងអំឡុងពេលពីរឆ្នាំកន្លងទៅនេះ គាត់បានទៅខេត្ត រ៉ាយ៉ុង ប្រទេសថៃ ហើយធ្វើការជាអ្នកនេសាទត្រី។ នៅពេលទូកចូលផែម្តងៗ ជាធម្មតា បុរសៗចេញទៅក្រៅដើម្បីហូបអាហារ ហើយបន្ទាប់មកទៅបនស្រី។ ស្ត្រីរកស៊ីផ្លូវភេទថៃ តាមធម្មតាតឹងរឹងណាស់ ហើយបដិសេធមិនរួមភេទបើអត់ប្រើស្រោមអនាម័យ។ ក៏ប៉ុន្តែពេលខ្លះ សុក បានទៅកន្លែងស្ត្រី រកស៊ីផ្លូវភេទជាជនជាតិខ្មែរ។ ជានិច្ចកាលបុរសៗនិយាយ ថាយើងទាំងអស់គ្នាជាខ្មែរដូចគ្នា ដូច្នេះមិនចាំបាច់ប្រើស្រោមទេ។ នៅខេត្តព្រៃវែង មានអង្គការក្រៅរដ្ឋាភិបាលខ្លះបានចុះធ្វើការអប់រំដល់ប្រជាជនអំពីជំងឺអេដស៍ និងការឆ្លង ជាពិសេសតាមគ្រួសារដែលមានសមាជិកចេញទៅធ្វើការឆ្ងាយពីផ្ទះ។ នៅពេលសុក ត្រលប់មកខេត្តព្រៃវែងវិញ ប្រពន្ធគាត់បានសុំអោយគាត់ធ្វើតេស្តឈាមរកមេរោគអេដស៍ហើយយក លទ្ធផលតេស្តឈាមនោះមកជាមួយផង។ គាត់ស្ទាក់ស្ទើរហើយខឹងនឹងប្រពន្ធគាត់ដែលបាន អោយគាត់ធ្វើបែបនេះ ប៉ុន្តែក្រោយមក គាត់ក៏ទៅធ្វើ តេស្តឈាម។ គាត់ទទួលការផ្តល់ប្រឹក្សាមុនពេលធ្វើតេស្ត នៅពេលព្រឹក ហើយពេលល្ងាចត្រឡប់មកទទួលលទ្ធផល តេស្តឈាមវិញ។

## ករណីសិក្សាសំរាប់លទ្ធផលតេស្តឈាម វិជ្ជមាន

១- ឫទ្ធី ជាកូនពៅរបស់គ្រួសារអ្នកមានមួយ។ ឪពុកម្តាយគាត់ស្រលាញ់គាត់យ៉ាងខ្លាំង។ គាត់មានអាយុ ២៥ឆ្នាំ ហើយសង្ហារណាស់។ ឆ្នាំនេះគាត់នឹងបញ្ចប់ការសិក្សានៅមហាវិទ្យាល័យពាណិជ្ជសាស្ត្រ។ ដោយសារស្ថានភាពសេដ្ឋកិច្ចគ្រួសាររបស់គាត់ និងរូបរាងរបស់គាត់មាននិស្សិតជាច្រើនចង់ធ្វើមិត្តជាមួយគាត់។ ឫទ្ធី មិនសូវព្រួយពីអនាគតរបស់ខ្លួនឡើយ។ គាត់មានមោទនៈលើខ្លួនគាត់ក្នុងនាមជាបុរសម្នាក់ ហើយតែងតែទៅបារ ឬ ការ៉ាអូខេជាមួយ មិត្តភ័ក្តរបស់គាត់រួចនាំគ្នាទៅសណ្ឋាគារទាំងអស់គ្នា។ គាត់ជួនកាលប្រើ ជួនកាលមិនប្រើស្រោមអនាម័យជាមួយស្រីទាំងនោះទេ។ បើស្រីនោះមើលទៅស្អាត ហើយនៅក្មេង គាត់មិនប្រើស្រោមទេ។ ថ្ងៃមួយឪពុកម្តាយគាត់បាន ប្រាប់គាត់ថាពួកគាត់ចង់អោយ ឫទ្ធី រៀបការក្នុងពេលឆាប់ៗនេះ។ ឫទ្ធី មិនបានត្រៀមខ្លួន ហើយមានកង្វល់ពី ស្ថានភាពសុខភាពរបស់គាត់។ គាត់ដឹងថាឪពុកម្តាយខាងស្រីអាចនឹងសុំអោយគាត់ធ្វើតេស្តឈាមរកមេរោគអេដស៍។ ដើម្បី ការពារកិត្តិយសរបស់ខ្លួន និង ប្រវត្តិរបស់ គ្រួសារ គាត់បានសំរេចចិត្តទៅសេវាធ្វើតេស្តឈាមដោយខ្លួនឯង បន្ទាប់ពីការផ្តល់ប្រឹក្សា គាត់សម្រេចចិត្តថា ធ្វើតេស្តឈាម។ គាត់ទទួល ការផ្តល់ប្រឹក្សាមុនពេលធ្វើតេស្តឈាម នៅពេលព្រឹក ហើយពេលល្ងាចគាត់ត្រឡប់មក ទទួលលទ្ធផលតេស្តឈាម។

២- ចាន់ សុខ បានធ្វើជាទាហានរយៈពេល ១០ឆ្នាំហើយ។ គាត់មានកូនពីរនាក់ កូនបង អាយុ ៨ឆ្នាំ ហើយកូនប្អូន អាយុ ៥ឆ្នាំ។ គាត់បានដឹងជាច្រើនពីមេរោគអេដស៍/ជំងឺអេដស៍ ពីមិត្តភ័ក្ររបស់គាត់នៅក្នុងកងឯកភាពជាមួយ គ្នា។ គាត់ដឹងយ៉ាងច្បាស់ថាមនុស្សឆ្លងមេរោគអេដស៍តាមរយៈការរួមភេទ។ គាត់ក៏បានលឺថាមិត្តគាត់ខ្លះបានឆ្លង មេរោគអេដស៍ពីស្ត្រីរកស៊ីផ្លូវភេទ។ កាលពីមុន គាត់ធ្លាប់ទៅបនស្រីជាមួយមិត្តភ័ក្តរបស់គាត់។ ក៏ប៉ុន្តែ ថ្មីៗកន្លងទៅនេះគាត់ចូលចិត្តរកស្រីនៅក្នុងភូមិជិតៗ ឬស្រីជួបគ្នាក្នុងពេលបុណ្យទានម្តងៗ។ ថ្ងៃមួយ គាត់ត្រូវបានគេ ជ្រើសរើសអោយទៅរៀននៅបរទេស។ គាត់និងគ្រួសារគាត់ សប្បាយចិត្តខ្លាំងណាស់។ ក៏ប៉ុន្តែគណៈកម្មការ ជ្រើសរើសទាមទារអោយបេក្ខជនទាំងអស់ធ្វើតេស្តឈាមរកមេរោគឆ្លងនានា រួមទាំងមេរោគអេដស៍ផងដែរ។ ក្រោយមកទៀត គេបានប្រាប់គាត់ថាគាត់បានធ្វើតេស្តមិនជាប់ទេ។ គាត់ខកចិត្តយ៉ាងខ្លាំង។ គាត់សង្ស័យថាខ្លួន មានផ្ទុកមេរោគអេដស៍ ដូចនេះគាត់បានទៅកាន់ VCCT ទាំងចិត្តស្ទាក់ស្ទើរ ដើម្បីធ្វើតេស្ត បន្ទាប់ពីការផ្តល់ប្រឹក្សា គាត់សម្រេចចិត្តមិនធ្វើតេស្តឈាមវិញ។ គាត់ទទួលការផ្តល់ប្រឹក្សាមុនពេលធ្វើតេស្តឈាម នៅពេលព្រឹក ហើយពេលល្ងាចគាត់ត្រឡប់មក ទទួលលទ្ធផលតេស្តឈាមវិញ។

៣- រដ្ឋា មានអាយុ ២៨ឆ្នាំ និងកូនពីរនាក់។ នាងជាអ្នកលក់ដូរផ្លែឈើនៅផ្សារក្នុងក្រុងភ្នំពេញ។ ប្តីរបស់នាងជាមន្ត្រីរាជការធ្វើការនៅក្រសួងពាណិជ្ជកម្ម។ ប្តីគាត់តែងធ្វើដំណើរទៅតាមខេត្តនានាដើម្បីបំពេញការងារ។ នៅពេលទៅតាមខេត្ត មិត្តភ័ក្ត និងសហសេវិករបស់គាត់តែងតែអញ្ជើញគាត់ទៅបាយល្ងាច។ ការហូបអាហារ និងផឹកស្រាបៀរ ឬស្រាផ្សេងៗ គឺជារឿងមួយកើតឡើងញឹកញាប់។ លើសពីនេះទៅទៀត បើគាត់ត្រូវការ មិត្តភ័ក្ត របស់គាត់នឹងចេញលុយ

អោយគាត់រួមភេទជាមួយស្រីទៀតផង។ រដ្ឋា មានការសង្ស័យ និងព្រួយពីការប្រព្រឹត្តប្តី របស់នាងនៅពេលគាត់ទៅខេត្តម្តងៗ។ ក៏ប៉ុន្តែនាងមិនអាចធ្វើអ្វីកើតច្រើនឡើយ។ នៅផ្ទះពួកគេមិនប្រើស្រោមអនាម័យទេ។ រដ្ឋា ដឹងថាការប្រើស្រោមអនាម័យអាចបង្ការមេរោគអេដស៍កុំអោយឆ្លង ប៉ុន្តែនាងមិនអាច ប្រាប់ប្តីនាងអោយប្រើស្រោមបានទេ ពីព្រោះស្រោមអនាម័យគួរតែប្រើជាមួយស្ត្រីរកស៊ីផ្លូវភេទ ហើយនាងខ្លាចប្តី នាងមិនសប្បាយចិត្តព្រោះវាជាសញ្ញានៃការមិនទុកចិត្ត។ ពីរឆ្នាំក្រោយមក នាងមានរោគពងរលាកសើស្បែកនៅ លើប្រដាប់ភេទរបស់នាង។ នាងបានទៅជួបវេជ្ជបណ្ឌិតដើម្បីព្យាបាល។ ក្នុងអំឡុងពេលពិគ្រោះជំងឺ វេជ្ជបណ្ឌិត បានជូនយោបល់ថានាងគួរធ្វើ តេស្តឈាមរកមេរោគអេដស៍ ហើយបាន ប្រាប់នាងពីកន្លែងដែលអាចទទួលសេវាផ្តល់ ប្រឹក្សា និងធ្វើតេស្តឈាមបានល្អ។ នាងព្រួយចិត្តដេកមិន លក់ឡើយ។ ទីបញ្ចប់ នាងក៏សំរេចចិត្តទៅធ្វើតេស្តឈាម។ នាងទទួលការផ្តល់ប្រឹក្សាមុនពេល ធ្វើតេស្តនៅពេលព្រឹកហើយពេលល្ងាចនាងត្រឡប់មក ទទួលលទ្ធផលតេស្តឈាមនេះ។

៤- បុប្ផា ជាស្រីឡង់សេស្រាបៀរ។ នាងធ្វើការនេះបាន ៥ឆ្នាំហើយ។ ប្រាក់ខែរបស់នាង គឺ ៤០ ដុល្លាក្នុងមួយខែ តែចាយមិនគ្រប់គ្រាន់ទេ។ រៀងរាល់ថ្ងៃនាងឃើញមិត្តរបស់នាងរកបានចំណូលបន្ថែម តាមរយៈការចំណាយពេល និងចេញទៅក្រៅជាមួយអតិថិជនដែលមកស៊ីផឹក។ មិត្តនាងខ្លះបានប្រាប់នាងថា នាងគួរតែធ្វើដូចគ្នានេះដែរដើម្បី ទទួលបានប្រាក់ចំណូលបន្ថែមទៀត។ នាងគិតថា វាជាមធ្យោបាយល្អក្នុងការរកចំណូលតាមរយៈការធ្វើបែបនេះ។ នាងមិនប្រើស្រោមអនាម័យជាប់ជាប្រចាំឡើយជាមួយភ្ញៀវរបស់នាងនៅពេលរួមភេទ ពីព្រោះ ទីមួយភ្ញៀវរបស់ នាងមិនចង់ប្រើ ទីពីរនាងគិតថាពួកគេជាអ្នកមាន ដូច្នេះពួកគេមិនមានមេរោគអេដស៍ទេ ទីបីនាងមាន សិទ្ធិអំណាចតិចតួចក្នុងការចរចារជាមួយភ្ញៀវរបស់នាងនៅពេលដែលឋិតនៅក្នុងបន្ទប់។ ថ្ងៃមួយ នាងបានសំគាល់ ឃើញមានអ្វីម្យ៉ាងនៅលើប្រដាប់ភេទរបស់នាងហើយវាធ្វើអោយហូរឈាមនៅពេលរួមភេទ។ នាងភ័យខ្លាចខ្លាំង ណាស់ ហើយបានទៅជួបវេជ្ជបណ្ឌិត។ ក្នុងអំឡុងពេលនៃការពិគ្រោះយោបល់ វេជ្ជបណ្ឌិត បានផ្តល់ការព្យាបាល និងការអប់រំដល់នាង។ ក៏ប៉ុន្តែនាងមិនអាចធ្វើតាមការណែនាំរបស់វេជ្ជបណ្ឌិតទាំងអស់ឡើយដោយសារនាង ត្រូវការលុយ។ ដូច្នេះ នាងមានជម្ងឺកាមរោគជាញឹកញាប់។ មិនយូរប៉ុន្មានក្រោយមក នាងបានចាប់ផ្តើមក្អក និង ស្រកទំងន់ជាច្រើន។ នៅពេលពិគ្រោះជម្ងឺ វេជ្ជបណ្ឌិតបានអោយយោបល់ថានាងគួរធ្វើតេស្តឈាមរកមេរោគអេដស៍។ នាងភ័យខ្លាំងណាស់ជាមួយនឹងពត៌មាននេះ។ ពីរបីថ្ងៃក្រោយមក នាងបានទៅកាន់សេវា VCCT ដើម្បីធ្វើតេស្តឈាម។ នាងទទួលការផ្តល់ប្រឹក្សាមុនពេលធ្វើតេស្តឈាម នៅពេលព្រឹក ហើយពេលល្ងាចនាងត្រឡប់មក ទទួលលទ្ធផលតេស្តឈាមវិញ។

ផ្ទាំងបញ្ចាំងលេខ ១ សំរាប់សកម្មភាពទី១៦

## ការផ្តល់ប្រឹក្សាក្រោយធ្វើតេស្តឈាមសំរាប់លទ្ធផលតេស្ត ឈាមអវិជ្ជមានរួមមាន:

១- ពិនិត្យមើលថាតើអតិថិជននោះជាសាម៉ីខ្លួនដែលត្រូវមកទទួលលទ្ធផលតេស្តឈាម

២- រៀបរាប់ខ្លីៗពីអ្វីដែលបានពិភាក្សាគ្នាក្នុងអំឡុងពេលមុនធ្វើតេស្តឈាម

៣-សួរអតិថិជនអំពីអារម្មណ៍និងផែនការរបស់គេបើលទ្ធផលតេស្តឈាមវិជ្ជមាន ឬ អវិជ្ជមាន ដើម្បីស្ទាបស្ទង់ពីអារម្មណ៍និងទឹកចិត្ត របស់គេ។

៤-ប្រគល់ស្រោមសំបុត្រលទ្ធផលតេស្តឈាមទៅអតិថិជន ហើយសួរថាចង់អោយអ្នកផ្តល់ប្រឹក្សាបើក និងពន្យល់ ពីអត្ថន័យ ឬទេ?

៥-បើយល់ព្រមអ្នកត្រូវបើកស្រោមសំបុត្រនិងពន្យល់លទ្ធផលតេស្តឈាម

៦-ផ្តល់ឱកាសនិងពេលវេលាអោយអតិថិជនសំដែងអារម្មណ៍អំពីលទ្ធផលតេស្តឈាម និងការសាកសួរ

៧-ពន្យល់អត្ថន័យនៃលទ្ធផលតេស្ត ឈាម រយៈពេលចំហរ ហើយលើកទឹកចិត្តអោយគាត់មកធ្វើតេស្ត ឈាមឡើងវិញក្រោយ រយៈពេលបីខែ បើមានការប្រឈមមុខ

៨-ពិភាក្សាពីផែនការកាត់បន្ថយការប្រឈមមុខ ដើម្បីកុំអោយឆ្លងមេរោគអេដស៍

(ពិនិត្យមើលឡើងវិញលើការផ្តល់ប្រឹក្សាដើម្បីបង្ការ)

-ពង្រឹងការការពារ ដោយ ១.តមមិនរួមភេទ ២.មានដៃគូតែមួយ
៣.ប្រើស្រោមអនាម័យ (**A B C**)

-ចរចាជាមួយដៃគូ ដើម្បីអោយមករកសេវា VCCT

-ជំនាញចរចាសំរាប់ការរួមរ័ក្សមានសុវត្ថិភាព

-បង្ហាញរបៀបប្រើស្រោមអនាម័យ ហើយផ្តល់ស្រោមអនាម័យដូចគាត់បើគាត់ចង់ប្រើ

៩-ផ្តល់ពិតមានរឺបញ្ជូនទៅកាន់សេវាពាក់ព័ន្ធនានាបើចាំបាច់ដូចជាសេវាពន្យារកំណើតរឺសេវាកាមរោគ

ផ្ទាំងបញ្ចាំងលេខ២ សំរាប់សកម្មភាពទី១៦

## ការផ្តល់ប្រឹក្សាក្រោយធ្វើតេស្តឈាមសំរាប់លទ្ធផលតេស្តឈាម វិជ្ជមាន រួមមានៈ

១- ពិនិត្យមើលថាតើអតិថិជននោះជាសាម៉ីខ្លួនដែលត្រូវមកទទួលលទ្ធផលតេស្តឈាម

២- រៀបរាប់ខ្លីៗពីអ្វីដែលបានពិភាក្សាគ្នាក្នុងអំឡុងពេលមុនធ្វើតេស្តឈាម

៣-សួរអតិថិជនអំពីអារម្មណ៍និងផែនការបើលទ្ធផលវិជ្ជមាន និង អវិជ្ជមាន ដើម្បីស្ទាបស្ទង់ពី អារម្មណ៍ និងទឹកចិត្ត របស់គេ។

៤-ប្រគល់ស្រោមសំបុត្រលទ្ធផលទៅអតិថិជន ហើយសួរថាចង់អោយអ្នកផ្តល់ប្រឹក្សាបើក និងពន្យល់ពីអត្ថន័យឬទេ?

៥-បើយល់ព្រមបើកស្រោមសំបុត្រនិងពន្យល់លទ្ធផលតេស្តឈាម ដោយបង្ហាញការយកចិត្តទុកដាក់ និងកក់ក្តៅ

៦- ផ្តល់ពេលវេលាគ្រប់គ្រាន់អោយអតិថិជនយល់ពីអត្ថន័យនៃលទ្ធផលតេស្តឈាម និងបញ្ជាក់ពីការយល់ដឹង របស់គាត់

៧-សួរអតិថិជនពីអារម្មណ៍នៅពេលបានដឹងលទ្ធផលនិងអោយគាត់បញ្ចេញនូវនៅអ្វីៗដែលគាត់ចង់និយាយ

៨-ពិគ្រោះជាមួយអតិថិជនអំពីកង្វល់ចំពោះមុខរបស់គាត់ ស្ថានភាពគ្រួសារ និងសង្គមបង្ហាញពីការចង់ស្តាប់និងការយកចិត្តទុកដាក់ ជាពិសេសលើការរស់នៅដោយមានតំលៃ

៩-ពិគ្រោះអំពីការថែទាំសុខភាព ដូចជាការបង្ការ និងព្យាបាលជំងឺឱកាសនិយមការកាត់បន្ថយការចំលងមេរោគអេដស៍ពីម្តាយទៅកូន (ចំពោះស្ត្រីមានផ្ទៃពោះ) ការព្យាបាលជំងឺរបេងអេដស៍ និងផ្តល់ពតិមានអំពីការប្រើប្រាស់ឱសថប្រឆាំងនឹងមេរោគអេដស៍

១០-ពិគ្រោះអំពីការកាត់បន្ថយការប្រឈមមុខ រួមទាំងការការពារកុំអោយឆ្លងមេរោគអេដស៍ទៅដៃគូដែលមិនទាន់ផ្ទុកមេរោគអេដស៍រឺមិនទាន់បានធ្វើតេស្តឈាមនិងអំពីការរួមភេទមានសុវត្ថិភាព

១១-ផ្តល់ពតិមានអំពីសេវាដែលមាន និងធ្វើការបញ្ជូនបន្តទៅសេវានានាក្នុងមន្ទីរពេទ្យ រឺកន្លែងដែលនៅជិត (បើមានការព្រមព្រៀងពីអតិថិជន រួមទាំងសេវាដែលមាននៅក្នុងសហគមន៍ដូចជាក្រុមថែទាំតាមផ្ទះ និងកម្មវិធីជួយគ្រួសារនិងកុមារដែលទទួលផលប៉ះពាល់ពីជំងឺអេដស៍ ។

## បញ្ជីផ្ទៀងផ្ទាត់ខាងក្រោម អាចប្រើសំរាប់វាយតំលៃលើការផ្តល់ប្រឹក្សាក្រោយធ្វើតេស្ត

អ្នកដែលធ្វើជាអ្នកសង្កេតការណ៍ លើការសំដែងតួនិងអ្នកអភិបាល VCCT អាចប្រើបញ្ជីនេះជាជំនួយ

**ក្នុងអំឡុងពេលនៃការផ្តល់ប្រឹក្សាក្រោយពេលធ្វើតេស្តឈាមតើចំណុចខាងក្រោមនេះ បានកើតឡើងដែរឬទេ?**

| | | |
|---|---|---|
| អ្នកផ្តល់ប្រឹក្សាផ្តល់លទ្ធផលតេស្ត ឈាមដោយពន្យល់យ៉ាងងាយយល់ និងច្បាស់លាស់ | បាន o | មិនបាន o |
| អ្នកផ្តល់ប្រឹក្សាផ្តល់ពេលវេលាគ្រប់គ្រាន់អោយអតិថិជនយល់ | បាន o | មិនបាន o |
| បញ្ជាក់ពីការយល់ដឹង | បាន o | មិនបាន o |
| ពិភាក្សាពីអត្ថន័យនៃលទ្ធផលតេស្តឈាមសំរាប់អតិថិជន | បាន o | មិនបាន o |
| អតិថិជនមានឱកាសបញ្ចេញអារម្មណ៍និងអ្វីៗដែលគាត់ចង់និយាយ | បាន o | មិនបាន o |
| ពិភាក្សាពីផលប៉ះពាល់លើបុគ្គល/គ្រួសារ/សង្គម និងអ្នកដែលត្រូវប្រាប់បើមាន | បាន o | មិនបាន o |
| ការពិភាក្សាពីផែនការកាត់បន្ថយការប្រឈមមុខ | បាន o | មិនបាន o |
| ដោះស្រាយទប់ទល់នឹងប្រតិកម្មផ្លូវចិត្តដែលកើតឡើងភ្លាមៗ | បាន o | មិនបាន o |
| ពិគ្រោះអំពីប្រភពគាំទ្រនានា | បាន o | មិនបាន o |
| ពិភាក្សាអំពីការថែទាំ និងគាំទ្របន្តទៀត | បាន o | មិនបាន o |
| បានបញ្ជាក់ឡើងវិញពីផែនការ សកម្មភាពនិងអ្វីៗដែលចង់ធ្វើ | បាន o | មិនបាន o |
| បានពិភាក្សាអំពីការព្យាបាល និងការបញ្ជូនបន្ត ដោយសមស្រប | បាន o | មិនបាន o |

# សកម្មភាពទី ១៧

# ការថែទាំ ការគាំទ្រ ការបញ្ជូនបន្ត និងការរស់នៅដោយមានគាំទ្រ

## ការថែទាំ ការគាំទ្រ ការបញ្ជូនបន្ត និងការរស់នៅដោយមានតំលៃ

អតិថិជនជាច្រើន ឬភាគច្រើន ដែលធ្វើតេស្តទៅឃើញវិជ្ជមាន នឹងត្រូវការគាំទ្របន្ត ដើម្បីអោយគេអាចទទួលនូវស្ថានភាពផ្ទុកមេរោគអេដស៍របស់គេ ហើយស្វែងរកសេវាសុខភាពសមស្របនានា និងការគាំទ្រផ្លូវចិត្តនិងសង្គមផ្សេងៗទៀត។ សេវាផ្តល់ប្រឹក្សានៅ VCCT គួរតែបន្តផ្តល់ប្រឹក្សាសំរាប់អតិថិជនរួមទាំង ធ្វើការបញ្ជូនគាត់ទៅកាន់សេវាថែទាំ និងគាំទ្រដោយសមស្របនានា ។ អ្នកផ្តល់ប្រឹក្សានៅ VCCT ត្រូវប្រាប់អតិថិជន អំពីទីកន្លែង ដែល គេអាចទទួលសេវា ទាំងនោះដែលមាននៅជិតតំបន់ ដែលគេរស់នៅ។ អ្នកផ្តល់ប្រឹក្សាត្រូវដឹងពីសេវាគាំទ្រសមស្របនានា នៅក្នុងសហគមន៍ និងតំបន់ដែលគេរស់នៅ។

អ្នកផ្តល់ប្រឹក្សា គួរតែដឹងខ្លះៗអំពីជំងឺនានាដែលអាចកើតឡើងលើអ្នកផ្ទុកមេរោគអេដស៍ ហើយក៏ត្រូវដឹងពីទីកន្លែងនិងពេលវេលាដែលត្រូវបញ្ជូនអតិថិជនបន្ត ដើម្បីអោយគេទទួលបានការព្យាបាលនានា។

ការព្យាបាលទាន់ពេលវេលានិងមានប្រសិទ្ធិភាពចំពោះជំងឺឱកាសនិយមនានា គឺជាជំហានដ៏សំខាន់ដើម្បីលើកកំពស់សុខភាពអ្នកផ្ទុកមេរោគអេដស៍/ជម្ងឺអេដស៍ ហើយអាចបន្ថយការវិវត្តន៍របស់ជំងឺនេះ ដូច្នេះអ្នកផ្តល់ប្រឹក្សាត្រូវលើកទឹកចិត្តដល់ អ្នកផ្ទុកមេរោគអេដស៍អោយស្វែងរកការព្យាបាលជំងឺឱកាសនិយមអោយទាន់ពេលវេលា។

ការជួយអ្នកផ្ទុកមេរោគអេដស៍អោយយល់ពីការវិវត្តន៍នៃជម្ងឺ និងរបៀបមើលថែទាំសុខភាពរបស់ខ្លួនគឺជាការសំខាន់។ មានសៀវភៅ ជាច្រើនជាភាសាខ្មែរ ដូចជា “ការថែទាំសុខភាពដោយខ្លួនឯង” ដែលអាចប្រើសំរាប់ជួយអតិថិជនអោយដឹង ពីការទ្រទ្រង់សុខភាព របៀបបង្ការនិងព្យាបាលជម្ងឺមួយចំនួន ។

ការព្យាបាលផ្នែកវេជ្ជសាស្ត្រ ដោយប្រើប្រាស់ឱសថ អាចចាត់ថ្នាក់ជាបីប្រភេទ:

១-ការព្យាបាលបង្ការជំងឺឱកាសនិយម (Prophylaxis to prevent opportunistic infections)
២-ការព្យាបាលជំងឺឱកាសនិយម (Treatment of opportunistic infections)
៣-ការព្យាបាលដោយឱសថប្រឆាំងនឹងមេរោគអេដស៍ (Antiretroviral therapy)

ក្រសួងសុខាភិបាល មានគោលការណ៍ណែនាំសំរាប់ការព្យាបាលទាំងនេះ ដែលត្រូវតែអនុវត្តតាមអោយបានត្រឹមត្រូវ។

នៅឆ្នាំ ២០០៤ មានមន្ទីរពេទ្យជាច្រើនផ្តល់សេវានានា ដូចជា ការព្យាបាលបង្ការ និងការព្យាបាលជំងឺឱកាសនិយម ការកាត់បន្ថយការចំលងពីម្តាយទៅកូន និង ការបង្ការជម្ងឺ របេងក្នុងចំណោមអ្នកផ្ទុកមេរោគអេដស៍។ មានសេវាថែទាំតាមផ្ទះសំរាប់អ្នកជំងឺរ៉ាំរ៉ៃរួមទាំងអ្នកជំងឺអេដស៍តាមបណ្តាខេត្តជាច្រើន។ មន្ទីរពេទ្យខ្លះមានកម្មវិធីផ្តល់ឱសថពន្យាជីវិត សំរាប់អ្នកដែល

ប្រព័ន្ធការពារខ្លួនចុះខ្សោយខ្លាំង ហើយបានបង្ហាញ អោយឃើញនូវការប្រព្រឹត្ត តាមវេជ្ជបញ្ជាបានល្អ។ ឱសថប្រឆាំងមេរោគអេដស៍ (ឱសថពន្យារជីវិត) អាចជួយអ្នកផ្ទុកមេរោគអេដស៍អោយមានសុខភាពល្អឡើងវិញ។

អ្នកផ្តល់ប្រឹក្សាគួរប្រាប់អតិថិជន ដែលធ្វើតេស្តឈាមទៅឃើញវិជ្ជមាន អំពីក្រុមគាំទ្រអ្នកផ្ទុកមេរោគអេដស៍ ដែលមាននៅជិតនិងពី របៀបជួបទាក់ទងជាមួយពួកគេ។ មន្ទីរពេទ្យខ្លះអាចមាន "មណ្ឌលមិត្តជួយមិត្ត" ដើម្បីផ្តល់សេវាថែទាំនិងគាំទ្រ ក៏ដូចជាការគាំទ្រទៅវិញទៅមកក្នុងចំណោមអ្នកផ្ទុកមេរោគអេដស៍។

សេវាVCCT និមួយៗ គួរតែរៀបចំរបៀបបញ្ជូនជាមួយសេវាពាក់ព័ន្ធនានា នៅក្នុង មូលដ្ឋាន ស្តីពីនិតិវិធីបញ្ជូនបន្ត (ឬក៏បង្កើតប្រព័ន្ធបញ្ជូនបន្តប្រសិនបើមិនទាន់មាន) ដើម្បីជួយរក្សាការសំងាត់ ដល់អតិថិជន ពីស្ថានភាពផ្ទុកមេរោគអេដស៍របស់ខ្លួនចំពោះមនុស្សដែលមិនចាំបាច់ត្រូវដឹង ហើយគេអាចទទួលបានសេវាដោយមិនចាំបាច់សួរនាំច្រើន។ គួរមានការជួបប្រជុំជា ទៀងទាត់រវាងសេវា VCCT និងសេវាផ្សេងៗ ដើម្បីកែលំអប្រព័ន្ធបញ្ជូនបន្តអោយឆ្លើយតបតាមសេចក្តីត្រូវការរបស់អតិថិជន ។ មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជម្ងឺអេដស៍ សើស្បែកនិងកាមរោគ បានបង្កើតប័ណ្ណបញ្ជូនបន្តទៅសេវាផ្សេងៗ។

(ប្រើផ្ទាំងបញ្ចាំង លេខ៥ នៃសកម្មភាពទី២ សំរាប់សកម្មភាពនេះ)

បង្ហាញប័ណ្ណបញ្ជូនបន្ត របស់មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជម្ងឺអេដស៍ សើស្បែក និងកាមរោគនៅក្នុងមេរៀននេះ។

## ការពិភាក្សា:

ប្រជាជនខ្លះនិយាយថា បើអ្នកមានផ្ទុកមេរោគអេដស៍ ប៉ុន្តែមិនដឹងខ្លួនថាមាននោះវាមិនអីទេ។ ប៉ុន្តែបើអ្នកដឹងនោះមេរោគអេដស៍ នឹងស៊ីរូបអ្នក ហើយអ្នកនឹងស្លាប់ឆាប់ៗ។

តើអ្នកគិតយ៉ាងណាអំពីពាក្យសំដីនេះ?
ហេតុអ្វី បានជាគេនិយាយបែបនេះ?
តើអ្នកអាចធ្វើដូចម្តេច ដើម្បីផ្លាស់ប្តូរសភាពការណ៍នេះ?

បច្ចុប្បន្ននេះ ការថែទាំ និងការព្យាបាលសំរាប់អ្នកផ្ទុកមេរោគអេដស៍ នៅកម្ពុជា គឺមិនទាន់គ្រប់គ្រាន់នៅទេ ទោះបីជា ចំនួន សេវា VCCT កំពុងតែកើនឡើងក៏ដោយ។ ប្រជាជនត្រូវមើលឃើញ ពីផលប្រយោជន៍នៃការដឹង ពីស្ថានភាពឈាម (serostatus) របស់ខ្លួនមុននឹងគេសំរេចចិត្តមកធ្វើតេស្តឈាមរកមេរោគអេដស៍។ ដោយសារសេវាថែទាំសុខភាពនៅខ្វះខាត ហើយនៅមានការរើសអើង ធ្វើអោយអតិថិជនមានការស្ទាក់ស្ទើរមកធ្វើតេស្ត។ ការភ័យខ្លាចថាគេនឹងមានអារម្មណ៍អស់សង្ឃឹម នៅពេលដែលអតិថិជន ដឹងពីស្ថានភាពឈាមរបស់គាត់នោះ ក៏អាចរារាំងអតិថិជនមិនអោយមកស្វែងរកសេវា VCCT ផងដែរ ។

# ការរស់នៅដោយមានតំលៃ

គោលគំនិតជាមូលដ្ឋាននៃ “ការរស់នៅដោយមានតំលៃ”(positive living/living positively) គឺថា អ្នកដែលផ្ទុកមេរោគអេដស៏ នៅតែមានភាពថ្លៃថ្នូរ ហើយមានលទ្ធភាព ដូចអ្នកដ៏ទៃទេវៀតនៅក្នុងសង្គមដែរ។ កាលពីម្ភៃឆ្នាំមុន យុទ្ធនាការឃោសនាតាមប្រពន្ធ័ផ្សព្វផ្សាយពតិមានសាធារណៈ ដើម្បីប្រឆាំងនឹងការរីករាលដាលនៃមេរោគអេដស៏ តែងតែលើកឡើងថា មេរោគអេដស៏/ជម្ងឺអេដស៏ គឺស្មើគ្នានឹង “សេចក្តីស្លាប់” យ៉ាងដូច្នោះដែរ ដើម្បីបំភ័យមនុស្សអោយខ្លាចជម្ងឺអេដស៏។ ការនេះបានជះផលប៉ះពាល់អវិជ្ជមាន ធ្វើអោយមនុស្សជាច្រើនគិតថា ពេលដែលពួកគេឆ្លងមេរោគអេដស៏ហើយនោះ គេនឹងស្លាប់យ៉ាងឆាប់រហ័ស។ ការពិតនោះគឺ ទោះបីជាបានឆ្លងមេរោគអេដស៏ក៏ដោយ បុគ្គលម្នាក់ៗអាចនៅរស់រានមានសុខភាពល្អ បានរយៈពេលវែងតទៅទៀត គាត់អាចធ្វើការ និងរួមចំណែកដល់សង្គម ដូចអ្នកដ៏ទៃដែរ។ ដោយមានការឈានទៅមុខចំពោះការព្យាបាល និងថែទាំអ្នកជំងឺអេដស៏ ក្នុងអំឡុងទស្សវត្សរកន្លងមកនេះ ជម្ងឺអេដស៏បានក្លាយទៅជាជំងឺរ៉ាំរ៉ៃមួយ។ ការយល់ច្រឡំពីរបៀបឆ្លងមេរោគ បានបង្កើតនូវការភ័យខ្លាចនឹងការចំលងតាមរយៈ ការប៉ះពាល់ និងទំនាក់ទំនងជាមួយនឹងអ្នកផ្ទុកមេរោគអេដស៏។ ទោះបីជាមានការកែសំរួល នូវការយល់ច្រឡំនិងជំនឿមិនត្រឹមត្រូវ ក៏ដោយ ក៏ការមាក់ងាយ និងការរើសអើងទាក់ទងនឹងមេរោគអេដស៏និងអ្នកជម្ងឺអេដស៏ គឺនៅតែមាន។

ការខ្វះខាតការយល់ដឹងអំពីការថែទាំសុខភាព និងកង្វះសមត្ថភាពទៅស្វែងរកការព្យាបាល និងការថែទាំ ក៏អាចបណ្តាលអោយអ្នកផ្ទុកមេរោគអេដស៏មួយចំនួនមានអារម្មណ៍អស់សង្ឃឹមដែរ។

ចំពោះអ្នកផ្ទុកមេរោគអេដស៏ ការទទួលថាមេរោគអេដស៏នឹងរស់នៅជាមួយគាត់ និងគាត់ត្រូវរស់នៅ ជាមួយនឹងមេរោគអេដស៏ដែរដូច្នេះគាត់មិនត្រូវចុះចាញ់ មេរោគអេដស៏ឬក៏រង់ចាំថ្ងៃដែលគាត់នឹងធ្លាក់ខ្លួនឈឺ ហើយស្លាប់នោះជាជំហានដែលសំខាន់។ មានអ្នកផ្ទុកមេរោគអេដស៏ជាច្រើនបានបំលែងការដឹងថាខ្លួនមានផ្ទុកមេរោគអេដស៏ អោយក្លាយទៅជាកំលាំងថ្មីមួយ ជំរុញអោយគាត់រៀបចំផែនការអនាគតគាត់ និងគ្រួសារ បំលែងការ លំបាករបស់គាត់ អោយទៅជាសកម្មភាព ដែលមាន ប្រយោជន៏ដល់ខ្លួនអ្នកផ្ទុកមេរោគអេដស៏ដ៏ទៃទៀត និង សហគមន៏ដែលគាត់រស់នៅ។

នៅប្រទេសកម្ពុជាមានអ្នកផ្ទុកមេរោគអេដស៏ជាច្រើន កំពុងតែចូលរួមក្នុងសកម្មភាពបង្ការ និង ការថែទាំអ្នកជម្ងឺអេដស៏ទាំងនៅថ្នាក់ជាតិ ក៏ដូចជានៅ ថ្នាក់មូលដ្ឋាននានា។ មានមធ្យោបាយជាច្រើន ដែលយើងអាចលើកទឹកចិត្តនិងគាំទ្រដល់អ្នកផ្ទុកមេរោគអេដស៏អោយរស់នៅ ដោយមានតំលៃ និងធ្វើសកម្មភាពអ្វីដែលមានប្រយោជន៏។

“ការរស់នៅដោយមានតំលៃ” ទាមទារនូវការយល់ដឹង និងការទទួលយកសភាពផ្ទុកមេរោគអេដស៏របស់ខ្លួន និងពីសហគមន៏ផង។

“បើខ្ញុំទន់ខ្សោយ រឺឆាប់ស្លាប់  តើអ្នកណានឹងមើលថែទាំកូនទាំងបីរបស់ខ្ញុំ រហូតដល់វាធំឡើង ។ ដូច្នេះ ខ្ញុំត្រូវតែ ថែទាំសុខភាព ហើយធ្វើការជាធម្មតា ។ ខ្ញុំប្រាប់ខ្លួនឯងថា កុំអោយខឹង  កុំអោយធ្លាក់ទឹកចិត្ត ដើម្បីអាចរស់នៅបានយូរ” ។

(បុរសមានផ្ទុកមេរោគអេដស៏កម្ពុជាម្នាក់  អាយុ 39ឆ្នាំ)

“ប្តីរបស់ខ្ញុំបានស្លាប់ទៅហើយ  សល់តែខ្ញុំនៅមើលថែទាំកូនៗ ។ ខ្ញុំត្រូវតែរឹងមាំ ដើម្បីអាចមើលថែ ទាំកូន តូចៗ ។ ខ្ញុំចង់អោយកូនទៅសាលារៀន ដូចក្មេងដ៏ទៃទៀតដែរ ។ ស្ត្រីខ្លះទៀតនៅក្នុងសហគមន៏ខ្ញុំ ក៏ជួបការលំបាក ដូចខ្ញុំដែរ ដូច្នេះយើងត្រូវធ្វើការជាមួយគ្នា ដើម្បីតស៊ូតទៅទៀត ។ ស្ត្រីជិតខាង ក៏ជួយ ខ្ញុំដែរ នៅពេលដែលខ្ញុំឈឺ”  ។

(ស្ត្រីមានផ្ទុកមេរោគអេដស៏កម្ពុជាម្នាក់  អាយុ 47ឆ្នាំ)

# សកម្មភាពទី ១៨
# ការប្រាប់លទ្ធផលតេស្តឈាម ទៅអ្នកដ៏ទៃ
# ការធ្វើការជាមួយប្តីប្រពន្ធដែលមានលទ្ធផលតេស្តឈាមខុសគ្នា

## សកម្មភាពទី ១៨

## ការប្រាប់លទ្ធផលតេស្ត ឈាមទៅអ្នកដ៏ទៃ
## ការធ្វើការជាមួយប្តីប្រពន្ធ ដែលមានលទ្ធផលតេស្តឈាមខុសគ្នា

នៅក្នុងមេរៀននេះគួរតែអញ្ជើញអ្នកផ្តល់ប្រឹក្សាដែលមានបទពិសោធន៏ច្រើន អោយមកចូលរួម និងចែករំលែកនូវបទពិសោធន៏របស់គាត់អំពីការធ្វើជាមួយអតិថិជនដើម្បីជួយគាត់អំពីការប្រាប់លទ្ធផលតេស្តឈាមទៅអ្នកដ៏ទៃ និងការធ្វើការជាមួយប្តីប្រពន្ធដែលមានម្នាក់ផ្ទុកមេរោគអេដស៏ និងម្នាក់ទៀតគ្មានផ្ទុកមេរោគអេដស៏ (discordant couples) ។

ការប្រាប់អោយអ្នកដ៏ទៃដឹងអំពីស្ថានភាពផ្ទុកមេរោគអេដស៏របស់ខ្លួន មានន័យថា បុគ្គលម្នាក់សំរេចចិត្តអោយអ្នកដ៏ទៃទៀតដឹងពីស្ថានភាពផ្ទុកមេរោគអេដស៏របស់ខ្លួន ។

លក្ខណៈនៃការប្រាប់លទ្ធផលតេស្តឈាមអោយអ្នកដ៏ទៃដឹង អាចមានន័យថា:

- ពីម្នាក់ទៅម្នាក់ គឺមានលក្ខណៈបុគ្គល ដូចជាប្រាប់ទៅដៃគូរួមភេទ មិត្តភ័ក្រ ឬសាច់ញាតិ
- ប្រាប់លទ្ធផលតេស្តឈាមដល់មនុស្សមួយក្រុម ដូចជាគ្រួសាររបស់ខ្លួន សហសេវិកនៅកន្លែងធ្វើការ ឬ សមាជិកនៃក្រុមអ្នកផ្ទុកមេរោគ អេដស៏ ។
- ជាថ្នាក់ជាតិ ដូចជា តាមរយៈប្រពន្ធ័ផ្សព្វផ្សាយពតិមាន ឬតាមរយៈប្រពន្ធ័បោះពុម្ពផ្សាយផ្សេងៗ ។

អ្នកផ្តល់ប្រឹក្សាគួរពិគ្រោះអោយបានស៊ីជំរៅជាមួយ អ្នកផ្ទុក មេរោគអេដស៏អំពីគុណសម្បត្តិ និងគុណវិបត្តិនៃការ ប្រាប់លទ្ធផលតេស្តឈាមទៅអោយអ្នកដ៏ទៃដឹង ។ មិនត្រូវមានអ្នកណាម្នាក់ ទទួលរង ការកៀបសង្កត់ ឬ បង្ខំអោយបញ្ចេញអោយគេដឹងពីស្ថានភាពផ្ទុកមេរោគអេដស៏របស់ខ្លួននៅពេលដែលគាត់មិនចង់ប្រាប់នោះឡើយ ។ អង្គការសហប្រជាជាតិទទួលបន្ទុកជម្ងឺអេដស៏(UNAIDS) និងអង្គការសុខភាពពិភពលោក (WHO) លើកទឹកចិត្តដល់ការប្រាប់អោយគេដឹង ដោយមានប្រយោជន៏ ។ ការប្រាប់ដែលមានប្រយោជន៏ត្រូវមានលក្ខណៈស្ម័គ្រចិត្ត គោរពចំពោះសាម៉ីជន និង រក្សាភាព ថ្លៃថ្នូរ និងរក្សាការសំងាត់ របស់បុគ្គលដែលឆ្លងមេរោគអេដស៏បែបនេះ នឹងនាំអោយមានផលប្រយោជន៏ដល់បុគ្គល ដៃគូ និងក្រុមគ្រួសារ ដែលអាចនាំទៅរកការនិយាយអំពីជំងឺអេដស៏អេដស៏ក្នុងសហគមន៏ ហើយវាឆ្លើយតបនឹងភាពចាំបាច់ផ្នែកសីលធម៌វិជ្ជាជីវៈនៃស្ថានភាពណាមួយ ដែលត្រូវការបង្ការកុំអោយមានការ ចំលងបន្តនូវមេរោគអេដស៏ទៅអ្នកដ៏ទៃ ។

អ្នកផ្តល់ប្រឹក្សា គួរតែជួយអតិថិជនអោយគិតបានល្អិតល្អន់មុននឹងធ្វើការសំរេចចិត្តប្រាប់អោយគេដឹងពីស្ថានភាពផ្ទុកមេរោគអេដស៏របស់ខ្លួន ។

នៅប្រទេសខ្លះ កូនប្រសារស្រី និងកូនប្រសារប្រុស បានជួបប្រទះនូវផលប៉ះពាល់ធ្ងន់ធ្ងរជាច្រើនព្រោះតែស្ថានភាពផ្ទុក មេរោគអេដស៍ ពីគ្រួសារខាងប្តីប្រពន្ធ ។ ចំពោះកូនប្រុស និងកូនស្រី ទោះជាភ័យខ្លាចនឹងការមិនរវល់អើពើ ឬទណ្ឌកម្មរបស់ ឪពុកម្តាយគេក៏ដោយ ក៏នៅឃើញថាទោះបីជាមានផ្ទុកមេរោគអេដស៍ក៏ឪពុកម្តាយគេនៅតែស្រលាញ់ និងការគាំទ្រគេដដែល ។

ទោះបីជាការលាក់ការសំងាត់ស្តីពីស្ថានភាពផ្ទុកមេរោគអេដស៍របស់បុគ្គលម្នាក់ អាចជួយបង្ការអ្នកផ្ទុកមេរោគអេដស៍ ពីផលប៉ះពាល់ អវិជ្ជមានដែលអាចកើតឡើងក៏ដោយ ក៏មានអ្នកមានផ្ទុកមេរោគអេដស៍មួយចំនួន ទទួលថា ការលាក់ការសំងាត់ ទុកតែម្នាក់ឯងនេះគឺជាភាពតានតឹងដ៏ធ្ងន់ធ្ងរ ។ ការសិក្សាមួយចំនួនបង្ហាញអោយឃើញថាអ្នកផ្ទុកមេរោគអេដស៍ភាគច្រើន នឹងបញ្ចេញអោយអ្នកដ៏ទៃទៀតដឹងនៅពេលណាមួយ ។

## ពិភាក្សា:

- ផលប្រយោជន៏នៃការប្រាប់លទ្ធផលតេស្តឈាមអោយដៃគូ និងសមាជិកគ្រួសារដឹង ។
- ផលវិបាកជាប់ពាក់ព័ន្ធ និងគុណវិបត្តិដែលអាចកើតឡើងនៅពេលប្រាប់លទ្ធផលតេស្តឈាមទៅដៃគូ និងសមាជិកគ្រួសារ ។

ហេតុផលមួយចំនួនដែលអ្នកផ្ទុកមេរោគអេដស៍ មិនចង់ប្រាប់អោយគេដឹងពីស្ថានភាពផ្ទុកមេរោគអេដស៍របស់ខ្លួនរួមមាន:

- ការភ័យខ្លាចនូវការបោះបង់ចោល និងកំហឹងពីដៃគូ ឬ ប្តីប្រពន្ធ
- ការភ័យខ្លាចពីការបោះបង់ចោល និងកំហឹងពីឪពុកម្តាយ (ខូចខាតកេរ្តិ៍ឈ្មោះគ្រួសារ)
- ការភ័យខ្លាចបាត់បង់ការងារ

មានអ្នកផ្ទុកមេរោគអេដស៍ខ្លះ មានអារម្មណ៏ថា ចង់ប្រាប់អោយដៃគូរបស់គេដឹងពីស្ថានភាពផ្ទុក មេរោគអេដស៍ដែរ ប៉ុន្តែមិនដឹងថាត្រូវប្រាប់របៀបណា ដើម្បីអោយដៃគូរបស់ខ្លួនអាចទទួលយក បាន។ អ្នកផ្តល់ប្រឹក្សា អាចជួយអតិថិជនអោយហាត់សាកល្បងរបៀបនិយាយ ។

> “ការលាក់ការសម្ងាត់ពីការផ្ទុកមេរោគអេដស៍របស់ខ្លួនតែម្នាក់ឯង ហាក់ដូចជាអ្នក លីរបស់ដ៏ធ្ងន់ មួយនៅលើស្មាតែឯង ការចែករំលែកការសម្ងាត់នេះជាមួយអ្នកដែលយើងស្រលាញ់ គឺដូចគ្នានឹងការសែង របស់ដ៏ធ្ងន់ នោះដោយមនុស្សពីរនាក់គឺវាស្រាលជាង។ ទោះបីជា គេអាចខឹងនឹងអ្នកនៅពេលដំបូងក៏ដោយក្រោយមកគេនឹងឈប់ខឹងហើយនៅថ្ងៃណាមួយគេគង់តែដឹងដ៏ដែល” ។

# ការធ្វើការជាមួយប្តីប្រពន្ធដែលមានលទ្ធផលតេស្តឈាមខុសគ្នា

គូដែលមានលទ្ធផលតេស្តឈាមខុសគ្នាមានន័យថាប្តីរឺប្រពន្ធតែម្នាក់ឯងមានផ្ទុកមេរោគអេដស៍ (រឺម្ខាងស្ថិតនៅក្នុងរយៈ ពេលចំហ) ។

ការផ្តល់លទ្ធផលតេស្តឈាមដល់ប្តីប្រពន្ធដែលម្នាក់មានផ្ទុកមេរោគអេដស៍និងម្នាក់ទៀតគ្មានផ្ទុកមេរោគអេដស៍ អាចជាការលំបាក មួយ។ មានករណីខ្លះដែលគូស្រកនាំគ្នាមកធ្វើតេស្តរកមេរោគអេដស៍ជាមួយគ្នា ដើម្បីអោយដឹងលទ្ធផលតេស្តឈាមទាំងអស់គ្នា។ អ្នកផ្តល់ប្រឹក្សាត្រូវតែដឹងថាលទ្ធផលតេស្តឈាមអាចផ្ទុយគ្នាបាន។ ជាការ សំខាន់ដែលអ្នកផ្តល់ប្រឹក្សា ត្រូវពន្យល់ពីរឿងនេះដល់ប្តីប្រពន្ធដែលមកសេវាVCCT។ បើអាចធ្វើបានអ្នកផ្តល់ប្រឹក្សាគប្បីធ្វើ ការផ្តល់ប្រឹក្សាមុនធ្វើតេស្តឈាម ម្នាក់ម្តងដើម្បីធានាថាបុគ្គល ម្នាក់ៗស្ម័គ្រចិត្តមកធ្វើតេស្តដោយខ្លួនឯង ហើយមានឱកាសធ្វើការវាយតំលៃដោយស្មោះត្រង់លើការប្រឈមមុខរបស់គាត់។ អ្នកផ្តល់ប្រឹក្សា ត្រូវតែដឹងថា មិនអាចប្រាប់លទ្ធផលតេស្តឈាមរបស់អ្នកណាម្នាក់ ដោយគ្មានការ អនុញ្ញាតពីអតិថិជនឡើយ។ ពេល ធ្វើការផ្តល់ប្រឹក្សាដែលមានម្នាក់ផ្ទុកមេរោគអេដស៍ និងម្នាក់ទៀតគ្មានផ្ទុកមេរោគអេដស៍ អតិថិជនដែលមានលទ្ធផលតេស្តឈាម វិជ្ជមានអាច សុំអោយអ្នកផ្តល់ប្រឹក្សាជួយ ប្រាប់ដល់ ដៃគូរបស់ខ្លួន (ដែលមានលទ្ធផលឈាមអវិជ្ជមាន) នៅពេលដែលដៃគូទាំងពីរនៅជា មួយគ្នាឯសេវា VCCT ។

តួនាទីរបស់អ្នកផ្តល់ប្រឹក្សា រួមមាន ការជួយដល់ប្តីរឺប្រពន្ធអោយចេះសំរួលចិត្តរបស់គេ ចំពោះ លទ្ធផលតេស្តឈាមរបស់ខ្លួន និងចំពោះ លទ្ធផលតេស្តឈាមរបស់ដៃគូផង។ ក្នុងករណីដៃគូទាំងពីមានផ្ទុកមេរោគអេដស៍ដូចគ្នា ឬ ករណីប្តីប្រពន្ធមាន តែម្នាក់ដែលផ្ទុកមេរោគ អេដស៍និងម្នាក់ទៀតគ្មានផ្ទុកមេរោគអេដស៍គឺជារឿងមួយដែលដៃគូអាចស្តីបន្ទោសគ្នាទៅវិញទៅមក លើការប្រព្រឹត្តដែលនាំអោយមាន ការឆ្លងមេរោគអេដស៍ នេះ។ ទោះជាការសំដែងចេញពាក្យពេជន៍ពីអារម្មណ៍អាចមាន ប្រយោជន៍ អ្នកផ្តល់ប្រឹក្សាត្រូវតែដាក់ក៏រិតកំណត់មួយ ដើម្បីបង្ការកុំអោយដៃគូឈ្លោះប្រកែកគ្នារឺវាយគ្នា ហើយបំបែរការបន្ទោសគ្នាអោយមកលើការរៀបចំផែនការសំរាប់ការរស់នៅ ដោយមានតំលៃ ជាមួយគ្នាវិញ។

អ្នកផ្តល់ប្រឹក្សាត្រូវតែជួយដល់ប្តីប្រពន្ធអោយរៀបចំបង្កើតនូវផែនការដើម្បីការពារដៃគូដែលគ្មានផ្ទុក មេរោគអេដស៍ពីការឆ្លង និងជួយដល់ដៃគូ មានដែលផ្ទុកមេរោគអេដស៍ អោយរស់នៅដោយមានតំលៃ។ ការពិភាក្សា ពីការប្រើស្រោមអនាម័យ គឺជាការចាំបាច់។ អ្នកផ្តល់ប្រឹក្សាគួរពន្យល់ដល់ប្តីប្រពន្ធ ថាអ្នកដែលមានលទ្ធផលតេស្តឈាមអវិជ្ជមាន អាចថិតនៅក្នុងរយៈពេលចំហ។ ដូច្នេះគាត់ គួរតែ មកធ្វើតេស្តឡើងវិញ ក្នុងរយៈពេលពីបីទៅប្រាំមួយខែបន្ទាប់មកទៀត។

អ្នកផ្តល់ប្រឹក្សាត្រូវចងចាំគ្រប់ពេលវេលាថា មិនត្រូវចូលពាក់ព័ន្ធផ្នែកអារម្មណ៍ជាមួយនឹងរឿងរ៉ាវរបស់ប្តីប្រពន្ធ និងចូលពាក់ពន្ធ័នឹងការឈ្លោះប្រកែកគ្នា និងការសំរេចចិត្តរបស់គេទេ។ តួនាទីរបស់អ្នកផ្តល់ប្រឹក្សា គឺផ្តួចផ្តើម និងសំរបសំរួល ដល់ការពិភាក្សារវាងប្តីប្រពន្ធ ផ្តល់ពតិមានសមស្របដល់ពួកគាត់ ហើយលើកទឹកចិត្ត និងសំរបសំរួលដល់ការប្រាស្រ័យទាក់ទងរវាងគ្នា។

# សកម្មភាពទី ១៩

# វគ្គបញ្ចប់ និង ការវាយតំលៃ

## សកម្មភាព ទី១៩
## វគ្គបញ្ចប់ និង ការវាយតំលៃ

នៅថ្ងៃចុងក្រោយនៃការបណ្តុះបណ្តាល អ្នកសំរបសំរួលត្រូវធ្វើការវាយតំលៃក្រោយសិក្ខាសាលា រួចធ្វើការបូកសរុប និងរាយការអំពី លទ្ធផលនេះ ។

អ្នកសំរបសំរួលគួរតែពិនិត្យមើលឡើងវិញពីចំណុចសំខាន់ៗទាំងអស់ ហើយផ្តល់ ឯកសារ សំភារៈនានា ដែលមិនទាន់ចែកអោយសិក្ខាកាម ។

សូមអោយសិក្ខាកាម បំពេញលើតារាងវាយតំលៃវគ្គសិក្សា ។

# តារាងវាយតំលៃវគ្គសិក្សា

(មិនបាច់ដាក់ឈ្មោះទេ)

សូមឆ្លើយសំណួរទាំងអស់ដោយស្មោះត្រង់ សំរាប់ជាគុណប្រយោជន៏នៃការបណ្តុះបណ្តាលពេលអនាគត ។

1. សូមដាក់ពិន្ទុចំពោះមេរៀននិមួយៗ ។ សូមដាក់ពិន្ទុខ្ពស់បំផុតលើមេរៀនណា ដែលអ្នកគិតថាមានប្រយោជន៏បំផុត ។

| សកម្មភាព | ខ្លឹមសារ | 1 | 2 | 3 | ហេតុផល |
|---|---|---|---|---|---|
| 1 | ការរីករាលដាលនៃមេរោគអេដស៏/ជម្ងឺអេដស៏ នៅកម្ពុជា | | | | |
| 2 | ការផ្តល់ប្រឹក្សា និងធ្វើតេស្តរកមេរោគអេដស៏ ដោយស្ម័គ្រចិត្តនិងរក្សាការក្សា សំងាត់ជាផ្នែកមួយនៃយុទ្ធសាស្ត្របង្ការមេរោគអេដស៏និងព្យាបាលជម្ងឺអេដស៏ | | | | |
| 3 | ចំណេះដឹងស្តីពីមេរោគអេដស៏/ជម្ងឺអេដស៏ ចំណោទសួរ ត្រូវ ឬ ខុស ស្តីពីមេរោគអេដស៏/ជម្ងឺអេដស៏ | | | | |
| 4 | កំរិតប្រឈមមុខនឹងគ្រោះថ្នាក់ និង ការវាយតំលៃលើការប្រឈមមុខនឹងគ្រោះថ្នាក់ តើលក្ខណៈប្រឈមមុខនឹងគ្រោះថ្នាក់ មានកំរិតណា? | | | | |
| 5 | ទស្សនៈ ការអោយតំលៃ និង ការដឹងខ្លួន តើអ្នកគិតយ៉ាងណាចំពោះគាត់? | | | | |
| 6 | គោលការណ៍នៃការផ្តល់ប្រឹក្សា - ការរក្សាការសម្ងាត់ ស្រោមសំបុត្ររឿងសម្ងាត់ | | | | |
| 7 | គោលការណ៍នៃការផ្តល់ប្រឹក្សា - ការផ្តោតលើអតិថិជន សូមអ្នក ជួយប្រាប់ខ្ញុំផង? | | | | |
| 8 | គោលការណ៍នៃការផ្តល់ប្រឹក្សាមិនបង្គាប់បញ្ជា : ដើរដោយទុកចិត្ត | | | | |
| 9 | ជំនាញក្នុងការផ្តល់ប្រឹក្សា វីដេអូស្តីពីការផ្តល់ប្រឹក្សា និង ផ្តល់យោបល់ត្រឡប់ | | | | |
| 10 | គោលការណ៍ និង ជំនាញក្នុងការផ្តល់ប្រឹក្សា ប្រើប្រាស់គោលការណ៍ និង ជំនាញទាំងអស់រួមគ្នា តើខ្ញុំគួរតែធ្វើតេស្តរកមេរោគអេដស៏ឬទេ? តើខ្ញុំគួរធ្វើអ្វីខ្លះជាមួយនឹងប្តីខ្ញុំ? | | | | |

| | | | | | |
|---|---|---|---|---|---|
| **11** | ការផ្តល់ប្រឹក្សាដើម្បីបង្ការ  ការវាយតំលៃការប្រឈមមុខនឹងគ្រោះថ្នាក់<br>និងផែនការកាត់ បន្ថយការ ប្រឈមមុខនឹង គ្រោះថ្នាក | | | | |
| **12** | អារម្មណ៏របស់បុគ្គលដែលមកធ្វើតេស្តរកមេរោគអេដស៏<br>និងហេតុផលធ្វើតេស្តនិងមិនធ្វើតេស្ត | | | | |
| **13** | ផលប៉ះពាល់នៃមេរោគអេដស៏ និងជម្ងឺអេដស៏លើបុគ្គល | | | | |
| **14** | ការផ្តល់ប្រឹក្សាមុនធ្វើតេស្ត | | | | |
| **15** | ការផ្តល់ប្រឹក្សាក្រោយធ្វើតេស្ត<br>ការផ្តល់លទ្ធផលតេស្តអវិជ្ជមាន( គ្មានផ្ទុក) និងវិជ្ជមាន( មានផ្ទុក) | | | | |
| **16** | ការថែទាំ ការគាំទ្រ និង ការបញ្ជូនបន្ត ( ការថែាំជាបន្ត)<br>ការរស់នៅដោយមានតំលៃ | | | | |
| **17** | ការប្រាប់លទ្ធផលទៅអ្នកដទៃ និងការធ្វើការជាមួយប្តីប្រពន្ធដែលមាន<br>លទ្ធផលឃាមខុសគ្នា | | | | |
| **18** | គោលនយោបាយយុទ្ធសាស្រ្ត និងគោលការណ៏ណែនាំស្តីពីការផ្តល់<br>ប្រឹក្សា និងធ្វើតេស្តរកមេរោគអេដស៏ដោយស្ម័គ្រចិត្តនិងរក្សាការសំងាត់ | | | | |
| **19** | វគ្គបញ្ចប់ និងការវាយតំលៃលើវគ្គសិក្សា | | | | |

2. តើអ្នកគិតយ៉ាងណាចំពោះការបណ្តុះបណ្តាលនេះ ទាំងមេរៀន ទាំងវិធីសាស្រ្តបណ្តុះបណ្តាល?

3. សំណូមពរសំរាប់ការបណ្តុះបណ្តាលពេលអនាគត ផ្នែកដែលគួរកែលំអ និង តាមរបៀបណា?

4. យោបល់ផ្សេងទៀត?

ការបោះពុម្ពសៀវភៅនេះគឺធ្វើឡើងតាមរយៈការឧបត្ថម្ភដោយ អង្គការ FHI/IMPACT ឧបត្ថម្ភថវិកាដោយ USAID ក្រោមកិច្ចព្រមព្រៀងសហប្រតិបត្តិការ IMPACT ក្រោមកិច្ចសន្យា HRN-A00-97-00017-00 ចំពោះ អង្គការសុខភាពគ្រួសារអន្តរជាតិ